

# ព្រះ
# ត្រៃបិដកបាលី
## និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# សំយុត្តនិកាយ និទានវគ្គ
# តតិយភាគ
# ៣១

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០៦

គ.ស. ១៩៦៣

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស និទានវគ្គោ

## តតិយោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## អភិសមយសំយុត្តំ

### ពុទ្ធវគ្គោ

(១) ឯវំមេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច បដិច្ចសមុប្បាទំ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ

# សុត្តន្តបិដក

# សំយុត្តនិកាយ និទានវគ្គ

# តតិយភាគ

---

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ*

*ជាអរហន្ត សម្មាសម្ពុទ្ធ អង្គនោះ ។*

## អភិសមយសំយុត្ត

### ពុទ្ធវគ្គ

*[ ១ ] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាលព្រះមានព្រះភាគ គង់នៅក្នុងវត្តនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវបដិច្ចសមុប្បាទធម៌ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយប្រុងស្តាប់ធម៌នោះ*

សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(២) ភគវា ឯតទវោច កតមោ ច ភិក្ខវេ បដិច្ចសមុប្បាទោ អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមរូបំ នាមរូបបច្ចយា សឡាយតនំ សឡាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ បដិច្ចសមុប្បាទោ ។

ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំង-នោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ២ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះបដិច្ចសមុប្បាទធម៌ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ៦កើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះអាយតនៈ៦ជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈ សេចក្តីសោកស្តាយ សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតមានព្រម ព្រោះជាតិជាបច្ច័យ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិច្ចសមុប្បាទធម៌ ។

(៣) អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។ បឋមំ ។

អភិសមយសំយុត្ត ពុទ្ធវគ្គ បដិច្ចសមុប្បាទ

(៣) ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់ឥតសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ការរលត់នៃនាមរូប ព្រោះការរលត់នៃវិញ្ញាណ ការរលត់នៃអាយតនៈ ៦ ព្រោះការរលត់នៃនាមរូប ការរលត់នៃផស្សៈ ព្រោះការរលត់នៃអាយតនៈ ៦ ការរលត់នៃវេទនា ព្រោះការរលត់នៃផស្សៈ ការរលត់នៃតណ្ហា ព្រោះការរលត់នៃវេទនា ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ការរលត់នៃជាតិ ព្រោះការរលត់នៃភព ជរាមរណៈ សេចក្តីសោកស្តាយ សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏រមែងរលត់ទៅ ព្រោះការរលត់នៃជាតិ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះហើយ ពួកភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។ ចប់សូត្រ ទី ១ ។

(៦) សាវត្ថិយំ វិហរតិ... បដិច្ចសមុប្បាទំ វោ ភិក្ខវេ ទេសិស្សាមិ វិភជិស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(៧) ភគវា ឯតទវោច កតមោ ច ភិក្ខវេ បដិច្ចសមុប្បាទោ អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមរូបំ នាមរូបបច្ចយា សឡាយតនំ សឡាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៦) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែង នឹងញែក នូវបដិច្ចសមុប្បាទធម៌ ដល់អ្នកទាំង-ឡាយ ចូរអ្នកទាំងឡាយប្រុងស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

(៧) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ ចុះបដិច្ចសមុប្បាទធម៌ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ៦ កើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះអាយតនៈ៦ ជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈ សេចក្តីសោកស្តាយ សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតមានព្រម ព្រោះជាតិជាបច្ច័យ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(៦) កតមញ្ច ភិក្ខវេ ជរាមរណំ ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ជរា ។ កតមញ្ច ភិក្ខវេ មរណំ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ មរណំ ។ ឥតិ អយញ្ច ជរា ឥទំ ច មរណំ ឥទំ វុច្ចតិ ភិក្ខវេ ជរាមរណំ ។

(៧) កតមា ច ភិក្ខវេ ជាតិ ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ អយំ វុច្ចតិ ភិក្ខវេ ជាតិ ។

(៦) ម្នាលភិក្ខុទាំងឡាយ ចុះជរានិងមរណៈ តើដូចម្ដេច ។ សេចក្ដីគ្រាំគ្រា ភាពគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ ដំណើរថយនៃអាយុ ដំណើរចាស់ទុំនៃឥន្ទ្រិយទាំងឡាយ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ នេះ ហៅថាជរា ។ ម្នាលភិក្ខុទាំងឡាយ ចុះមរណៈ តើដូចម្ដេច ចុតិ ការឃ្លាត ការបែកធ្លាយ ការបាត់ទៅ សេចក្ដីស្លាប់ ដំណើរស្លាប់ ការធ្វើមរណកាល ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការដាច់នៃជីវិតិន្ទ្រិយ ណា របស់សត្វទាំងឡាយនោះ ៗ ចាកសត្តនិកាយនោះ ៗ នេះ ហៅថាមរណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ជរានេះផង មរណៈនេះផង នេះ ហៅថាជរានិងមរណៈ ។

(៧) ម្នាលភិក្ខុទាំងឡាយ ចុះជាតិ តើដូចម្ដេច ។ កិរិយាកើតជាដំបូង កិរិយាកើតព្រម កិរិយាចុះចាប់ផ្ទៃ កិរិយាកើត កិរិយាវិលត្រឡប់មកកើត កិរិយាកើតប្រាកដនៃខន្ធទាំងឡាយ កិរិយាបាននូវអាយតនៈ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា ជាតិ ។

[៨] កតមោ ច ភិក្ខវេ ភវោ ។ តយោមេ ភិក្ខវេ ភវា កាមភវោ រូបភវោ អរូបភវោ អយំ វុច្ចតិ ភិក្ខវេ ភវោ ។

[៩] កតមញ្ច ភិក្ខវេ ឧបាទានំ ។ ចត្តារិមានិ ភិក្ខវេ ឧបាទានានិ កាមុបាទានំ ទិដ្ឋុបាទានំ សីលព្វតុបាទានំ អត្តវាទុបាទានំ ឥទំ វុច្ចតិ ភិក្ខវេ ឧបាទានំ ។

[១០] កតមា ច ភិក្ខវេ តណ្ហា ។ ឆយិមេ ភិក្ខវេ តណ្ហាកាយា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា អយំ វុច្ចតិ ភិក្ខវេ តណ្ហា ។

[១១] កតមា ច ភិក្ខវេ វេទនា ។ ឆយិមេ ភិក្ខវេ វេទនាកាយា ចក្ខុសម្ផស្សជា វេទនា សោតសម្ផស្សជា វេទនា ឃានសម្ផស្សជា វេទនា ជិវ្ហាសម្ផស្សជា វេទនា កាយសម្ផស្សជា វេទនា មនោសម្ផស្សជា វេទនា អយំ វុច្ចតិ ភិក្ខវេ វេទនា ។

(៨) ម្នាលភិក្ខុទាំងឡាយ ចុះភព តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភព[១]នេះ មាន ៣ គឺ កាមភព ១ រូបភព ១ អរូបភព ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភព ។

(៩) ម្នាលភិក្ខុទាំងឡាយ ចុះឧបាទាន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ឧបាទាននេះ មាន ៤ គឺ កាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧបាទាន ។

(១០) ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកតណ្ហានេះមាន ៦ គឺ រូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា តណ្ហា ។

(១១) ម្នាលភិក្ខុទាំងឡាយ ចុះវេទនា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកវេទនានេះមាន ៦ គឺ វេទនាកើតអំពីចក្ខុសម្ផ័ស្ស ១ វេទនាកើតអំពីសោតសម្ផ័ស្ស ១ វេទនាកើតអំពីឃានសម្ផ័ស្ស ១ វេទនាកើតអំពីជិវ្ហាសម្ផ័ស្ស ១ វេទនាកើតអំពីកាយសម្ផ័ស្ស ១ វេទនាកើតអំពីមនោសម្ផ័ស្ស ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វេទនា ។

---

១ លំនៅនៃកំណើតសត្វ ។

(១២) កតមោ ច ភិក្ខវេ ផស្សោ ។ ឆយិមេ ភិក្ខវេ ផស្សកាយា ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ ជិវ្ហាសម្ផស្សោ កាយសម្ផស្សោ មនោសម្ផស្សោ អយំ វុច្ចតិ ភិក្ខវេ ផស្សោ ។

(១៣) កតមញ្ច ភិក្ខវេ សឡាយតនំ ។ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ ឥទំ វុច្ចតិ ភិក្ខវេ សឡាយតនំ ។

(១៤) កតមញ្ច ភិក្ខវេ នាមរូបំ ។ វេទនា សញ្ញា ចេតនា ផស្សោ មនសិការោ ឥទំ វុច្ចតិ នាមំ ។ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ ភិក្ខវេ នាមរូបំ ។

(១៥) កតមញ្ច ភិក្ខវេ វិញ្ញាណំ ។ ឆយិមេ ភិក្ខវេ វិញ្ញាណកាយា ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោវិញ្ញាណំ ឥទំ វុច្ចតិ ភិក្ខវេ វិញ្ញាណំ ។

អភិសមយសំយុត្ត ពុទ្ធវគ្គ វិញ្ញាណ

(១២) ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកផស្សៈនេះមាន ៦ គឺ ចក្ខុសម្ផស្ស ១ សោតសម្ផស្ស ១ ឃានសម្ផស្ស ១ ជិវ្ហាសម្ផស្ស ១ កាយសម្ផស្ស ១ មនោសម្ផស្ស ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ផស្សៈ ។

(១៣) ម្នាលភិក្ខុទាំងឡាយ ចុះអាយតនៈ ៦ តើដូចម្តេច ។ ចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ មនាយតនៈ ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអាយតនៈ ៦ ។

(១៤) ម្នាលភិក្ខុទាំងឡាយ ចុះនាមរូប តើដូចម្តេច ។ វេទនា ១ សញ្ញា ១ ចេតនា ១ ផស្សៈ ១ មនសិការៈ ១ នេះហៅថា នាម ។ មហាភូតរូប ៤ និងឧបាទាយរូប របស់មហាភូតរូប ៤ នេះ ហៅថា រូប ។ ម្នាលភិក្ខុទាំងឡាយ នាមនេះផង រូបនេះផង នេះហៅថា នាមរូប ដោយប្រការដូច្នេះ ។

(១៥) ម្នាលភិក្ខុទាំងឡាយ ចុះវិញ្ញាណ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកវិញ្ញាណនេះ មាន ៦ គឺ ចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោវិញ្ញាណ ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិញ្ញាណ ។

(១៦) កតមេ ច ភិក្ខវេ សង្ខារា ។ តយោមេ ភិក្ខវេ សង្ខារា កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោ ឥមេ វុច្ចន្តិ ភិក្ខវេ សង្ខារា ។

(១៧) កតមា ច ភិក្ខវេ អវិជ្ជា ។ យំ ខោ ភិក្ខវេ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ អយំ វុច្ចតិ ភិក្ខវេ អវិជ្ជា ។ ឥតិ ខោ ភិក្ខវេ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(១៨) អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ទុតិយំ ។

(១៦) ម្នាលភិក្ខុទាំងឡាយ ចុះសង្ខារ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សង្ខារនេះ មាន ៣ គឺ កាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សង្ខារ ។

(១៧) ម្នាលភិក្ខុទាំងឡាយ ចុះអវិជ្ជា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនដឹងក្នុងទុក្ខ ១ សេចក្តីមិនដឹងក្នុងហេតុជាទីកើតទុក្ខ ១ សេចក្តីមិនដឹងក្នុងទីរលត់ទុក្ខ ១ សេចក្តីមិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអវិជ្ជា ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ដោយប្រការដូច្នេះឯង ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(១៨) ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់ឥតមានសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

ចប់សូត្រ ទី ២ ។

(១៩) សាវត្ថិយំ វិហរតិ ... មិច្ឆាបដិបទញ្ច វោ ភិក្ខវេ ទេសិស្សាមិ សម្មាបដិបទញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(២០) ភគវា ឯតទវោច កតមា ច ភិក្ខវេ មិច្ឆាបដិបទា អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ មិច្ឆាបដិបទា ។

(២១) កតមា ច ភិក្ខវេ សម្មាបដិបទា អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាបដិបទាតិ ។ តតិយំ ។

(១៩) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវមិច្ឆាបដិបទានិងសម្មាបដិបទា ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ប្រុងស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

(២០) ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះមិច្ឆាបដិបទា តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មិច្ឆាបដិបទា ។

(២១) ម្នាលភិក្ខុទាំងឡាយ ចុះសម្មាបដិបទា តើដូចម្តេច ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់ឥតមានសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សម្មាបដិបទា ។ ចប់សូត្រ ទី ៣ ។

(២២) សាវត្ថិយំ វិហរតិ... វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ កិច្ឆំ វតាយំ លោកោ អាបន្នោ ជាយតិ ច ជិយ្យតិ ច មិយ្យតិ ច ចវតិ ច ឧបបជ្ជតិ ច អថ ច បនិមស្ស ទុក្ខស្ស និស្សរណំ នប្បជានាតិ ជរាមរណស្ស កុទស្សុ នាម ឥមស្ស ទុក្ខស្ស និស្សរណំ បញ្ញាយិស្សតិ ជរាមរណស្សាតិ ។

(២៣) អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ ជរាមរណំ ហោតិ កឹបច្ចយា ជរាមរណន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ជាតិយា ខោ សតិ ជរាមរណំ ហោតិ ជាតិបច្ចយា ជរាមរណន្តិ ។ អថខោ ភិក្ខវេ

[៦២] ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធ កាលនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ ក្នុងកាលមុនអំពីការត្រាស់ដឹង ទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ សត្វលោកនេះ ដល់នូវសេចក្តីលំបាកណាស់ តែងកើត ចាស់ ស្លាប់ ច្យុត និងចាប់បដិសន្ធិ តែមទាំងមិនដឹងច្បាស់ នូវការរលាស់ចោលសេចក្តីទុក្ខ គឺជរានិងមរណៈនេះទៀតផង កាលណាហ្ន៎ ទើបការរលាស់ចោលសេចក្តីទុក្ខ គឺជរានិងមរណៈនេះ នឹងប្រាកដឡើងបាន ។

[៦៣] ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបជរានិងមរណៈកើតមាន ជរានិងមរណៈកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោ-មនសិការៈថា កាលបើជាតិកើតមាន ជរានិងមរណៈក៏កើតមាន ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ

វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ ជាតិ ហោតិ កឹបច្ចយា ជាតីតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ភវេ ខោ សតិ ជាតិ ហោ-តិ ភវប្បច្ចយា ជាតីតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ ភវោ ហោតិ កឹបច្ចយា ភវោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ឧបាទានេ ខោ សតិ ភវោ ហោតិ ឧបាទានប្បច្ចយា ភវោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ ឧបាទានំ ហោតិ កឹបច្ចយា ឧបាទានន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ តណ្ហាយ ខោ សតិ ឧបាទានំ ហោតិ តណ្ហាបច្ចយា ឧបាទានន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ តណ្ហា ហោតិ កឹបច្ចយា តណ្ហាតិ ។

ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបជាតិកើតមាន ជាតិកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើភពកើតមាន ជាតិក៏កើតមាន ជាតិកើតមាន ព្រោះភពជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបភពកើតមាន ភពកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើឧបាទានកើតមាន ភពក៏កើតមាន ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបឧបាទានកើតមាន ឧបាទានកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញាព្រោះយោនិសោមនសិការៈថា កាលបើតណ្ហាកើតមាន ឧបាទានក៏កើតមាន ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបតណ្ហាកើតមាន តណ្ហាកើតមាន ព្រោះអ្វីជាបច្ច័យ ។

អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ វេទនាយ ខោ សតិ តណ្ហា ហោតិ វេទនាបច្ចយា តណ្ហាតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ វេទនា ហោតិ កិំបច្ចយា វេទនាតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ផស្សេ ខោ សតិ វេទនា ហោតិ ផស្សបច្ចយា វេទនាតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ ផស្សោ ហោតិ កិំបច្ចយា ផស្សោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ សឡាយតនេ ខោ សតិ ផស្សោ ហោតិ សឡាយតនបច្ចយា ផស្សោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើវេទនាកើតមាន តណ្ហាក៏កើតមាន តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបវេទនាកើតមាន វេទនាកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើផស្សៈកើតមាន វេទនាក៏កើតមាន វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបផស្សៈកើតមាន ផស្សៈកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើសឡាយតនៈកើតមាន ផស្សៈក៏កើតមាន ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន

សឡាយតនំ ហោតិ កឹបច្ចយា សឡាយតនន្តិ ។
អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោម-
នសិការា អហុ បញ្ញាយ អភិសមយោ នាមរូបេ
ខោ សតិ សឡាយតនំ ហោតិ នាមរូបប្បច្ចយា
សឡាយតនន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស
ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ
នាមរូបំ ហោតិ កឹបច្ចយា នាមរូបន្តិ ។ អថខោ
ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោម-
នសិការា អហុ បញ្ញាយ អភិសមយោ វិញ្ញាណេ
ខោ សតិ នាមរូបំ ហោតិ វិញ្ញាណប្បច្ចយា នាម-
រូបន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស
ឯតទហោសិ កិម្ហិ នុ ខោ សតិ វិញ្ញាណំ ហោតិ
កឹបច្ចយា វិញ្ញាណន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស
ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ
អភិសមយោ សង្ខារេសុ(១) ខោ សតិ វិញ្ញាណំ ហោតិ
សង្ខារប្បច្ចយា វិញ្ញាណន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស
ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ

---

១ កត្ថចិ បោត្ថកេ សង្ខារេតិ បត្តិ ។

ទើបសឡាយតនៈកើតមាន សឡាយតនៈកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើនាមរូបកើតមាន សឡាយតនៈ ក៏កើតមាន សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបនាមរូបកើតមាន នាមរូបកើតមានព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញាព្រោះយោនិសោមនសិការៈថា កាលបើវិញ្ញាណកើតមាន នាមរូបក៏កើតមាន នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបវិញ្ញាណកើតមាន វិញ្ញាណកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញាព្រោះយោនិសោមនសិការៈថា កាលបើសង្ខារទាំងឡាយកើតមាន វិញ្ញាណក៏កើតមាន វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន

សង្ខារា ហោន្តិ កឹបច្ចយា សង្ខារាតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោ មនសិការា អហុ បញ្ញាយ អភិសមយោ អវិជ្ជាយ ខោ សតិ សង្ខារា ហោន្តិ អវិជ្ជាបច្ចយា សង្ខារាតិ ។ ឥតិ ហិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ សមុទយោ សមុទយោតិ ខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

(២៤) អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ អសតិ ជរាមរណំ ន ហោតិ

ទើបសង្ខារទាំងឡាយកើតមាន សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បាន ត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើអវិជ្ជាកើតមាន សង្ខារទាំងឡាយក៏កើតមាន សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ ព្រោះហេតុដូច្នេះ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីពោធិសត្វ មានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលព្រះអង្គមិនធ្លាប់ស្ដាប់ ក្នុងកាលមុនថា ការកើតឡើងព្រម ការកើតឡើងព្រម ដូច្នេះ ។

[២៤] ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្ដីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបជរានិងមរណៈមិនមាន

តស្ស និរោធា ជរាមរណនិរោធោតិ ។ អថខោ ភិក្ខវេ
វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ
បញ្ញាយ អភិសមយោ ជាតិយា ខោ អសតិ ជរ-
មរណំ ន ហោតិ ជាតិនិរោធា ជរាមរណនិរោ-
ធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស
ឯតទហោសិ កិម្ហិ នុ ខោ អសតិ ជាតិ ន ហោតិ
កិស្ស និរោធា ជាតិនិរោធោតិ ។ អថខោ ភិក្ខវេ
វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ
បញ្ញាយ អភិសមយោ ភវេ ខោ អសតិ ជាតិ ន
ហោតិ ភវនិរោធា ជាតិនិរោធោតិ ។ អថខោ ភិក្ខវេ
វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ
ខោ អសតិ ភវោ ន ហោតិ កិស្ស និរោធា ភវ-
និរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស
យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ
ឧបាទានេ ខោ អសតិ ភវោ ន ហោតិ ឧបាទាននិ-
រោធា ភវនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស
ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ អសតិ

ការរលត់នៃជរានិងមរណៈ ព្រោះការរលត់នៃអ្វី ៗ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើជាតិមិនមាន ជរានិងមរណៈក៏មិនមាន ការរលត់នៃជរានិងមរណៈ ព្រោះការរលត់នៃជាតិ ៗ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបជាតិមិនមាន ការរលត់នៃជាតិ ព្រោះការរលត់នៃអ្វី ៗ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើភពមិនមាន ជាតិក៏មិនមាន ការរលត់នៃជាតិ ព្រោះការរលត់នៃភព ៗ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះ-រិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបភពមិនមាន ការរលត់នៃភព ព្រោះការរលត់នៃអ្វី ៗ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សី-ពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិ-ការៈថា កាលបើឧបាទានមិនមាន ភពក៏មិនមាន ការរលត់នៃភព ព្រោះការរលត់ នៃឧបាទាន ៗ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន

ឧបាទានំ ន ហោតិ កិស្ស និរោធា ឧបាទាននិរោ-
ធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស
យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ
តណ្ហាយ ខោ អសតិ ឧបាទានំ ន ហោតិ តណ្ហានិ-
រោធា ឧបាទាននិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស
ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ អសតិ
តណ្ហា ន ហោតិ កិស្ស និរោធា តណ្ហានិរោធោតិ ។
អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោ-
មនសិការា អហុ បញ្ញាយ អភិសមយោ វេទនាយ
ខោ អសតិ តណ្ហា ន ហោតិ វេទនានិរោធា តណ្ហា-
និរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស
ឯតទហោសិ កិម្ហិ នុ ខោ អសតិ វេទនា ន ហោតិ
កិស្ស និរោធា វេទនានិរោធោតិ ។ អថខោ ភិក្ខវេ

ទើបឧបាទានមិនមាន ការរលត់នៃឧបាទាន ព្រោះការរលត់នៃអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើតណ្ហាមិនមាន ឧបាទានក៏មិនមាន ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបតណ្ហាមិនមាន ការរលត់នៃតណ្ហា ព្រោះការរលត់នៃអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើវេទនាមិនមាន តណ្ហាក៏មិនមាន ការរលត់នៃតណ្ហា ព្រោះការរលត់នៃវេទនា ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបវេទនាមិនមាន ការរលត់នៃវេទនា ព្រោះការរលត់នៃអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ

វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ
បញ្ញាយ អភិសមយោ ផស្សេ ខោ អសតិ វេទនា ន
ហោតិ ផស្សនិរោធា វេទនានិរោធោតិ ។ អថខោ ភិក្ខវេ
វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ
អសតិ ផស្សោ ន ហោតិ កិស្ស និរោធា ផស្សនិរោ-
ធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស
យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ
សឡាយតនេ ខោ អសតិ ផស្សោ ន ហោតិ សឡា-
យតននិរោធា ផស្សនិរោធោតិ ។ អថខោ ភិក្ខវេ
វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ
ខោ អសតិ សឡាយតនំ ន ហោតិ កិស្ស និរោធា
សឡាយតននិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស
ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ
អភិសមយោ នាមរូបេ ខោ អសតិ សឡាយតនំ
ន ហោតិ នាមរូបនិរោធា សឡាយតននិរោធោតិ ។
អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទ-
ហោសិ កិម្ហិ នុ ខោ អសតិ នាមរូបំ ន ហោតិ

ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើផស្សៈមិនមាន វេទនាក៏មិនមាន ការរលត់នៃវេទនា ព្រោះការរលត់នៃផស្សៈ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបផស្សៈមិនមាន ការរលត់នៃផស្សៈ ព្រោះការរលត់នៃអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើសឡាយតនៈមិនមាន ផស្សៈក៏មិនមាន ការរលត់នៃផស្សៈ ព្រោះការរលត់នៃសឡាយតនៈ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបសឡាយតនៈមិនមាន ការរលត់នៃសឡាយតនៈ ព្រោះការរលត់នៃអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើនាមរូបមិនមាន សឡាយតនៈក៏មិនមាន ការរលត់នៃសឡាយតនៈ ព្រោះការរលត់នៃនាមរូប ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបនាមរូបមិនមាន

កិស្ស និរោធា នាមរូបនិរោធោតិ ។ អថខោ ភិក្ខវេ
វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ
បញ្ញាយ អភិសមយោ វិញ្ញាណេ ខោ អសតិ នាមរូបំ
ន ហោតិ វិញ្ញាណនិរោធា នាមរូបនិរោធោតិ ។ អថ-
ខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ
កិម្ហិ នុ ខោ អសតិ វិញ្ញាណំ ន ហោតិ កិស្ស
និរោធា វិញ្ញាណនិរោធោតិ ។ អថខោ ភិក្ខវេ វិប-
ស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ
បញ្ញាយ អភិសមយោ សង្ខារេ ខោ អសតិ វិញ្ញាណំ
ន ហោតិ សង្ខារនិរោធា វិញ្ញាណនិរោធោតិ ។ អ-
ថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ
កិម្ហិ នុ ខោ អសតិ សង្ខារា ន ហោន្តិ កិស្ស
និរោធា សង្ខារនិរោធោតិ ។ អថខោ ភិក្ខវេ វិប-
ស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ
បញ្ញាយ អភិសមយោ អវិជ្ជាយ ខោ អសតិ សង្ខា-
រា ន ហោន្តិ អវិជ្ជានិរោធា សង្ខារនិរោធោតិ ។

ការរលត់នៃនាមរូប ព្រោះការរលត់នៃអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញាព្រោះយោនិសោមនសិការៈថា កាលបើវិញ្ញាណមិនមាន នាមរូបក៏មិនមាន ការរលត់នៃនាមរូប ព្រោះការរលត់នៃវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបវិញ្ញាណមិនមាន ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញាព្រោះយោនិសោមនសិការៈថា កាលបើសង្ខារមិនមាន វិញ្ញាណក៏មិនមាន ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបសង្ខារទាំងឡាយមិនមាន ការរលត់នៃសង្ខារ ព្រោះការរលត់នៃអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ បានត្រាស់ដឹងដោយប្រាជ្ញាព្រោះយោនិសោមនសិការៈថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ការរលត់នៃសង្ខារ ព្រោះការរលត់នៃអវិជ្ជា ។

ឥតិ ហិទំ អវិជ្ជានិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ និរោធោ និរោធោតិ ខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទីតិ ។ ចតុត្ថំ ។

(២៥) សត្តន្នំ ពុទ្ធានំ ឯវំ វិត្ថារេតព្វោ ។ សិខិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស... វេស្សភុស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស...កកុសន្ធស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស កោណាគមនស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស... កស្សបស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស... ។

ព្រោះហេតុដូច្នេះ ការរលត់នៃសង្ខារ ព្រោះការរលត់នៃអវិជ្ជា ការរលត់នៃវិញ្ញាណនេះ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីពោធិសត្វ មានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលព្រះអង្គមិនធ្លាប់ស្តាប់ ក្នុងកាលមុនថា ការរលត់ ការរលត់ ដូច្នេះ ។ ចប់សូត្រ ទី ៤ ។

[៤៩] សូម្បីការត្រាស់ដឹងរបស់ព្រះពុទ្ធទាំង ៧ ព្រះអង្គ ក៏បណ្ឌិតគប្បីសំដែងឲ្យពិស្តារតាមចំនួនយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធ ... ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធ ... ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធ ... ម្នាលភិក្ខុទាំង-ឡាយ ព្រះកោនាគមនៈមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធ ... ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបៈមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធ ... ។

(២៦) បុព្វេវ មេ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ កិច្ឆំ វតាយំ លោកោ អាបន្នោ ជាយតិ ច ជិយ្យតិ ច មិយ្យតិ ច ចវតិ ច ឧបបជ្ជតិ ច អថ ច បនិមស្ស ទុក្ខស្ស និស្សរណំ នប្បជានាតិ ជរាមរណស្ស កុទាស្សុ នាម ឥមស្ស ទុក្ខស្ស និស្សរណំ បញ្ញាយិស្សតិ ជរាមរណស្សាតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិម្ហិ នុ ខោ សតិ ជរាមរណំ ហោតិ កឹបច្ចយា ជរាមរណន្តិ ។ តស្ស មយ្ហំ ភិក្ខវេ យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ជាតិយា ខោ សតិ ជរាមរណំ ហោតិ ជាតិបច្ចយា ជរាមរណន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិម្ហិ នុ ខោ សតិ ជាតិ ហោតិ ។បេ។ ភវោ ... ឧបាទានំ ... តណ្ហា ... វេទនា ... ផស្សោ ... សឡាយតនំ ... នាមរូបំ ... វិញ្ញាណំ ... សង្ខារា ហោន្តិ កឹបច្ចយា សង្ខារាតិ ។

[ ២៦ ] ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ កន្លងកាលមុន អំពីការត្រាស់ដឹង មានសេចក្តីត្រិះរិះដូច្នេះថា ទុក្ខ សត្វលោកនេះ ដល់នូវសេចក្តីលំបាកណាស់ តែងកើត ចាស់ ស្លាប់ ច្យុត និងចាប់បដិសន្ធិ ប៉ុន្តែទាំងមិនដឹងច្បាស់នូវការរលាស់ចោលសេចក្តីទុក្ខ គឺជរានិងមរណៈនេះទៀតផង កាលណាទៅហ្ន៎ ទើបការរលាស់ចោលសេចក្តីទុក្ខ គឺជរានិងមរណៈនេះ នឹងប្រាកដឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបជរានិងមរណៈកើតមាន ជរានិងមរណៈកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើជាតិកើតមាន ជរានិងមរណៈក៏កើតមាន ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបជាតិកើតមាន ។ បេ ។ ភព ... ឧបាទាន ... តណ្ហា ... វេទនា ... ផស្សៈ ... សឡាយតនៈ ... នាមរូប ... វិញ្ញាណ ... ទើបសង្ខារទាំងឡាយកើតមាន សង្ខារទាំងឡាយកើតមាន ព្រោះអ្វីជាបច្ច័យ ។

តស្ស មយ្ហំ ភិក្ខវេ យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ អវិជ្ជាយ ខោ សតិ សង្ខារា ហោន្តិ អវិជ្ជាបច្ចយា សង្ខារាតិ ។ ឥតិ ហិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ សមុទយោ សមុទយោតិ ខោ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

(២៧) តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិម្ហិ នុ ខោ អសតិ ជរាមរណំ ន ហោតិ កិស្ស និរោធា ជរាមរណនិរោធោតិ ។ តស្ស មយ្ហំ ភិក្ខវេ យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ជាតិយា ខោ អសតិ ជរាមរណំ ន ហោតិ ជាតិនិរោធា ជរាមរណនិរោធោតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិម្ហិ នុ ខោ អសតិ ជាតិ ន ហោតិ ។ បេ ។ ភវោ... ឧបាទានំ... តណ្ហា... វេទនា...ផស្សោ...សឡាយតនំ...នាមរូបំ...វិញ្ញាណំ...

ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើអវិជ្ជាកើតមាន សង្ខារទាំងឡាយក៏កើតមាន សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ ព្រោះហេតុដូច្នេះ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណនេះកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានស្ដាប់ក្នុងកាលមុនថា ការកើតឡើងព្រម ការកើតឡើងព្រម ដូច្នេះ ។

(២៧) ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្ដីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបជរានិងមរណៈមិនមាន ការរលត់នៃជរានិងមរណៈ ព្រោះការរលត់នៃអ្វី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើជាតិមិនមាន ជរានិងមរណៈក៏មិនមាន ការរលត់នៃជរានិងមរណៈ ព្រោះការរលត់នៃជាតិ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្ដីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបជាតិមិនមាន ។ បេ ។ ភព... ឧបាទាន... តណ្ហា ... វេទនា... ផស្សៈ ... សឡាយតនៈ... នាមរូប... វិញ្ញាណ...

សង្ខារា ន ហោន្តិ កិស្ស និរោធា សង្ខារនិរោធោតិ ។ តស្ស មយ្ហំ ភិក្ខវេ យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ អវិជ្ជាយ ខោ អសតិ សង្ខារា ន ហោន្តិ អវិជ្ជានិរោធា សង្ខារនិរោធោតិ ។ ឥតិ ហិទំ អវិជ្ជានិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ និរោធោ និរោធោតិ ខោ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទីតិ ។ ទសមំ ។

ពុទ្ធវគ្គោ បឋមោ ។

## តស្ស ឧទ្ទានំ ភវតិ

ទេសនាវិភង្គំ បដិបទញ្ច
វិបស្សី សិខី ច វេស្សភូ
កកុសន្ធោ កោនាគមនោ ច កស្សបោ
មហាសក្យមុនី ច គោតមោតិ ។

ទើបសង្ខារទាំងឡាយមិនមាន ការរលត់នៃសង្ខារ ព្រោះការរលត់នៃអ្វី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ការរលត់នៃសង្ខារ ព្រោះការរលត់នៃអវិជ្ជា ។ ព្រោះហេតុដូច្នេះ ការរលត់នៃសង្ខារ ព្រោះការរលត់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានស្តាប់ក្នុងកាលមុនថា ការរលត់ ការរលត់ ដូច្នេះ ។ ចប់សូត្រ ទី ១០ ។

ចប់ ពុទ្ធវគ្គ ១ ។

## បញ្ជីនៃពុទ្ធវគ្គនោះគឺ

ទេសនាវិភង្គ ១ បដិបទា ១ ព្រះវិបស្សី ១ ព្រះសិខី ១ ព្រះវេស្សភូ ១ ព្រះកកុសន្ធៈ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១ ព្រះមហាសក្យមុនីគោតម ១ ។

# អាហារវគ្គោ

(២៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ ចត្តារោមេ ភិក្ខវេ អាហារា ភូតានំ វា សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ ។ កតមេ ចត្តារោ ។ កពឡីការោ អាហារោ ឱឡារិកោ វា សុខុមោ វា ផស្សោ ទុតិយោ មនោសញ្ចេតនា តតិយា វិញ្ញាណំ ចតុត្ថំ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អាហារា ភូតានំ វា សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ ។

# អាហារវគ្គ

(២៨) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាហារនេះមាន ៤ តែងប្រព្រឹត្តទៅ ដើម្បីការតាំងនៅបាននៃពួកភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង(១) ។ អាហារទាំង ៤ តើដូចម្តេច ។ កវឡីការាហារ ដ៏គ្រោតគ្រាតក្តី ល្អិតក្តី (ជាទី១) ផស្សាហារ ជាទី ២ មនោសញ្ចេតនាហារ ជាទី ៣ វិញ្ញាណាហារ ជាទី ៤ ។ ម្នាលភិក្ខុទាំងឡាយ អាហារទាំង ៤ នេះឯង តែងប្រព្រឹត្តទៅ ដើម្បីការតាំងនៅបាននៃពួកភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង ។

---

១ សត្វកំពុងស្វែងរកនូវសម្ភពគឺកំណើត ហៅថាសម្ភវេសី ក្នុងកំណើតទាំង ៤ នោះ ពួកសត្វដែលជាអណ្ឌជៈកំណើត និងជលាម្ពុជៈកំណើត ដែលមិនទាន់ញាស់ចេញមកនិងមិនទាន់កើតចេញមកនៅឡើយ ហៅថា សម្ភវេសី លុះញាស់ចេញ កើតចេញហើយ ហៅថា ភូត ។ ចំណែកសំសេទជៈកំណើត និងឱបបាតិកៈកំណើត ដែលកើតក្នុងខណៈចិត្តជាបឋម ហៅថាសម្ភវេសី តាំងអំពីខណៈជាគម្រប់ពីរទៅ ហៅថាភូត ឬថាកើតដោយឥរិយាបថណា បើមិនទាន់ផ្លាស់ឥរិយាបថនោះទេ ហៅថាសម្ភវេសីដែរ លុះផ្លាស់ឥរិយាបថនោះទៅហើយ ហៅថាភូតដែរ ។ មួយវិញទៀត សត្វដែលកើតហើយ មិនកើតទៅទៀត ហៅថាភូត បានដល់ព្រះខីណាស្រព សត្វដែលមិនទាន់លះបង់ភវសំយោជនៈបាន នៅស្វែងរកសម្ភពទៅទៀត ហៅថាសម្ភវេសីដែរ បានដល់សេក្ខបុគ្គល និងបុថុជ្ជន (អដ្ឋកថា) ។

(២៩) ឥមេ ច ភិក្ខវេ ចត្តារោ អាហារា កិំនិទានា កិំសមុទយា កិំជាតិកា កិំបភវា ។ ឥមេ ចត្តារោ អាហារា តណ្ហានិទានា តណ្ហាសមុទយា តណ្ហាជាតិកា តណ្ហាបភវា ។ តណ្ហា ចាយំ ភិក្ខវេ កិំនិទានា កិំសមុទយា កិំជាតិកា កិំបភវា ។ តណ្ហា វេទនានិទានា វេទនាសមុទយា វេទនាជាតិកា វេទនាបភវា ។ វេទនា ចាយំ ភិក្ខវេ កិំនិទានា កិំសមុទយា កិំជាតិកា កិំបភវា ។ វេទនា ផស្សនិទានា ផស្សសមុទយា ផស្សជាតិកា ផស្សប្បភវា ។ ផស្សោ ចាយំ ភិក្ខវេ កិំនិទានោ កិំសមុទយោ កិំជាតិកោ កិំបភវោ ។ ផស្សោ សឡាយតននិទានោ សឡាយតនសមុទយោ សឡាយតនជាតិកោ សឡាយតនប្បភវោ ។ សឡាយតនញ្ចិទំ ភិក្ខវេ កិំនិទានំ កិំសមុទយំ កិំជាតិកំ កិំបភវំ ។ សឡាយតនំ នាមរូបនិទានំ នាមរូបសមុទយំ នាមរូបជាតិកំ នាមរូបប្បភវំ ។ នាមរូបញ្ចិទំ ភិក្ខវេ កិំនិទានំ

[២៩] ម្នាលភិក្ខុទាំងឡាយ ចុះអាហារទាំង ៤ នេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ អាហារទាំង ៤ នេះ មានតណ្ហាជាហេតុ មានតណ្ហានាំឲ្យកើត មានតណ្ហាជាកំណើត មានតណ្ហាជាប្រភព ។ ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ តណ្ហា មានវេទនាជាហេតុ មានវេទនានាំឲ្យកើត មានវេទនាជាកំណើត មានវេទនាជាប្រភព ។ ម្នាលភិក្ខុទាំងឡាយ ចុះវេទនានេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ វេទនា មានផស្សៈជាហេតុ មានផស្សៈនាំឲ្យកើត មានផស្សៈជាកំណើត មានផស្សៈជាប្រភព ។ ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈនេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ ផស្សៈ មានសឡាយតនៈជាហេតុ មានសឡាយតនៈនាំឲ្យកើត មានសឡាយតនៈជាកំណើត មានសឡាយតនៈជាប្រភព ។ ម្នាលភិក្ខុទាំងឡាយ ចុះសឡាយតនៈនេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ សឡាយតនៈនេះ មាននាមរូបជាហេតុ មាននាមរូបនាំឲ្យកើត មាននាមរូបជាកំណើត មាននាមរូបជាប្រភព ។ ម្នាលភិក្ខុទាំងឡាយ ចុះនាមរូបនេះ មានអ្វីជាហេតុ

កឹំសមុទយំ កឹំជាតិកំ កឹំបភវំ ។ នាមរូបំ វិញ្ញាណនិទានំ វិញ្ញាណសមុទយំ វិញ្ញាណជាតិកំ វិញ្ញាណប្បភវំ ។ វិញ្ញាណញ្ចិទំ ភិក្ខវេ កឹំនិទានំ កឹំសមុទយំ កឹំជាតិកំ កឹំបភវំ ។ វិញ្ញាណំ សង្ខារនិទានំ សង្ខារសមុទយំ សង្ខារជាតិកំ សង្ខារប្បភវំ ។ សង្ខារា ចិមេ ភិក្ខវេ កឹំនិទានា កឹំសមុទយា កឹំជាតិកា កឹំបភវា ។ សង្ខារា អវិជ្ជានិទានា អវិជ្ជាសមុទយា អវិជ្ជាជាតិកា អវិជ្ជាបភវា ។ ឥតិ ខោ ភិក្ខវេ អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៣០) អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ បឋមំ ។

មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ នាមរូប មានវិញ្ញាណជាហេតុ មានវិញ្ញាណនាំឲ្យកើត មានវិញ្ញាណជាកំណើត មានវិញ្ញាណជាប្រភព ។ ម្នាលភិក្ខុទាំងឡាយ ចុះវិញ្ញាណនេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ វិញ្ញាណ មានសង្ខារជាហេតុ មានសង្ខារនាំឲ្យកើត មានសង្ខារជាកំណើត មានសង្ខារជាប្រភព ។ ម្នាលភិក្ខុទាំងឡាយ ចុះសង្ខារទាំងឡាយនេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ សង្ខារទាំងឡាយ មានអវិជ្ជាជាហេតុ មានអវិជ្ជានាំឲ្យកើត មានអវិជ្ជាជាកំណើត មានអវិជ្ជាជាប្រភព ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នេះ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(៣០) ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់ឥតមានសេសសល់ នៃអវិជ្ជា ការរលត់ នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់ នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

ចប់សូត្រ ទី ១ ។

(៣១) សាវត្ថិយំ វិហរតិ... ចត្តារោមេ ភិក្ខវេ អាហារា ភូតានំ វា សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ ។ កតមេ ចត្តារោ ។ កពឡីការោ អាហារោ ឱឡារិកោ វា សុខុមោ វា ផស្សោ ទុតិយោ មនោសញ្ចេតនា តតិយា វិញ្ញាណំ ចតុត្ថំ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អាហារា ភូតានំ វា សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយាតិ ។

(៣២) ឯវំ វុត្តេ អាយស្មា មោលិយផគ្គុនោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ វិញ្ញាណាហារំ អាហារេតីតិ ។ នោ កល្លោ បញ្ហោតិ ភគវា អវោច អាហារេតីតិ អហំ ន វទាមិ អាហារេតីតិ ចាហំ វទេយ្យំ តត្រស្ស កល្លោ បញ្ហោ កោ នុ ខោ ភន្តេ អាហារេតីតិ ឯវញ្ចាហំ ន វទាមិ ឯវំ មំ អវទន្តំ យោ ឯវំ បុច្ឆេយ្យ

(៣១) ព្រះមានព្រះភាគ ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ អាហារនេះមាន ៤ តែងប្រព្រឹត្តទៅ ដើម្បីការតាំងនៅបាននៃភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង ។ អាហារទាំង ៤ តើដូចម្តេច ។ កវឡីការាហារ ធំគ្រោតគ្រាតក្តី ល្អិតក្តី (ជាទី ១) ផស្សាហារ ជាទី ២ មនោសញ្ចេតនាហារ ជាទី ៣ វិញ្ញាណាហារ ជាទី ៤ ។ ម្នាលភិក្ខុទាំងឡាយ អាហារទាំង ៤ នេះឯង តែងប្រព្រឹត្តទៅ ដើម្បីការតាំងនៅបាននៃពួកភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង ។

(៣២) កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះមោលិយផគ្គុនមានអាយុ បានក្រាបបង្គំទូលសួរ នូវព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ តែងទំពាស៊ីនូវវិញ្ញាណាហារ ។ ព្រះមានព្រះភាគត្រាស់តបថា ប្រស្នានេះ មិនត្រូវទេ ដូច្នេះ ហើយទើបត្រាស់ថា តថាគតមិនពោលថា នរណាហ្ន៎ តែងទំពាស៊ីដូច្នេះឡើយ ប្រសិនបើតថាគតពោលថា នរណាហ្ន៎ តែងទំពាស៊ី ដូច្នេះ ប្រស្នាថា បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ តែងទំពាស៊ី ដូច្នេះ នោះត្រូវគ្នានឹងពាក្យតថាគតហើយ តែថា តថាគតមិនពោលយ៉ាងនេះទេ កាលបើយ៉ាងនេះ បុគ្គលណាសួរ ចំពោះតថាគតដែលមិនពោលសោះ យ៉ាងនេះថា

កិស្ស នុ ខោ ភន្តេ វិញ្ញាណាហារោតិ ឯស កល្លោ បញ្ហោ តត្រ កល្លំ វេយ្យាករណំ វិញ្ញាណាហារោ អាយតឹ បុនព្ភវាភិនិព្វត្តិយា(១) តស្មឹ ភូតេ សតិ ស-ឡាយតនំ សឡាយតនបច្ចយា ផស្សោតិ ។

(៣៣) កោ នុ ខោ ភន្តេ ផុសតីតិ ។ នោ កល្លោ បញ្ហោតិ ភគវា អវោច ផុសតីតិ អហំ ន វទា-មិ ផុសតីតិ ចាហំ វទេយ្យំ តត្រស្ស កល្លោ បញ្ហោ កោ នុ ខោ ភន្តេ ផុសតីតិ ឯវញ្ចាហំ ន វទាមិ ឯវំ មំ អវទន្តំ យោ ឯវំ បុច្ឆេយ្យ កិំបច្ចយា នុ ខោ ភន្តេ ផស្សោតិ ឯស កល្លោ បញ្ហោ តត្រ កល្លំ វេយ្យាករណំ សឡាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនាតិ ។

---

១ ឱ, ម. ឯត្តកេ បច្ចយោតិ បាឋោ ទិស្សតិ ។

បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណាហារ ( ជាបច្ច័យ ) នៃធម៌ដូចម្តេចហ្ន៎ ដូច្នេះ ប្រស្នានុ៎ះរបស់បុគ្គលនោះទើបត្រូវ ទាំងត្រូវព្យាករណ៍ចំពោះប្រស្នានោះថា វិញ្ញាណាហារ គឺបដិសន្ធិចិត្ត ( ជាបច្ច័យ ) នៃកិរិយាកើត ក្នុងភពថ្មីទៀត គឺនាមរូបតទៅ, កាលបើការកើតក្នុងភពថ្មីទៀត គឺនាមរូបនោះ កើតមានហើយ, សឡាយតនៈក៏កើតមាន ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ។

( ៣៣ ) បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ តែងពាល់ត្រូវ ។ ព្រះមានព្រះភាគត្រាស់តបថា ប្រស្នានេះមិនត្រូវទេ ដូច្នេះហើយ ទើបត្រាស់ថា តថាគតមិនពោលថា នរណាហ្ន៎តែងពាល់ត្រូវដូច្នេះទេ ប្រសិនបើតថាគតពោលថា នរណាហ្ន៎តែងពាល់ត្រូវដូច្នេះ ប្រស្នាថា បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ តែងពាល់ត្រូវដូច្នេះ នោះត្រូវគ្នានឹងពាក្យតថាគតហើយ តែថា តថាគតមិនពោលយ៉ាងនេះទេ កាលបើយ៉ាងនេះ បុគ្គលណាសួរ ចំពោះតថាគតដែលមិនពោលសោះ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ផស្សៈកើតមាន ព្រោះអ្វីជាបច្ច័យហ្ន៎ ដូច្នេះ ប្រស្នានុ៎ះ របស់បុគ្គលនោះទើបត្រូវ ទាំងត្រូវព្យាករណ៍ចំពោះប្រស្នានោះថា ផស្សៈ កើតមានព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។

[៣៦] កោ នុ ខោ ភន្តេ វេទយតីតិ ។ នោ កល្លោ បញ្ហោតិ ភគវា អវោច វេទយតីតិ អហំ ន វទាមិ វេទយតីតិ ចាហំ វទេយ្យំ តត្រស្ស កល្លោ បញ្ហោ កោ នុ ខោ ភន្តេ វេទយតីតិ ឯវញ្ចាហំ ន វទាមិ ឯវំ មំ អវទន្តំ យោ ឯវំ បុច្ឆេយ្យ កឹបច្ចយា នុ ខោ ភន្តេ វេទនាតិ ឯស កល្លោ បញ្ហោ តត្រ កល្លំ វេយ្យាករណំ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហាតិ ។

[៣៧] កោ នុ ខោ ភន្តេ តណ្ហីយតីតិ(១) ។ នោ កល្លោ បញ្ហោតិ ភគវា អវោច តណ្ហីយតីតិ អហំ ន វទាមិ តណ្ហីយតីតិ ចាហំ វទេយ្យំ តត្រស្ស កល្លោ បញ្ហោ កោ នុ ខោ ភន្តេ តណ្ហីយតីតិ ឯវញ្ចាហំ ន វទាមិ ឯវំ មំ អវទន្តំ យោ ឯវំ បុច្ឆេយ្យ

---

១ ឱ.ម. តសតីតិ ។

( ៣៧ ) បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎តែងទទួលយក ។ ព្រះមានព្រះភាគត្រាស់តបថា ប្រស្នានេះមិនត្រូវទេ ដូច្នេះហើយ ទើបត្រាស់ថា តថាគតមិនពោលថា នរណាហ្ន៎តែងទទួលយក ដូច្នេះទេ ប្រសិនបើតថាគតពោលថា នរណាហ្ន៎តែងទទួលយកដូច្នេះ ប្រស្នាថា បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ តែងទទួលយកដូច្នេះ នោះត្រូវគ្នានឹងពាក្យតថាគតហើយ តែថា តថាគតមិនពោលយ៉ាងនេះទេ កាលបើយ៉ាងនេះ បុគ្គលណាសួរចំពោះតថាគតដែលមិនពោលសោះ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន វេទនាកើតមាន ព្រោះអ្វីជាបច្ច័យហ្ន៎ ដូច្នេះ ប្រស្នានុ៎ះរបស់បុគ្គលនោះទើបត្រូវ ចាំងត្រូវព្យាករណ៍ចំពោះប្រស្នានោះថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ។

( ៣៨ ) បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ តែងតក់ស្លុត ។ ព្រះមានព្រះភាគត្រាស់ថា ប្រស្នានេះមិនត្រូវទេ ដូច្នេះហើយ ទើបត្រាស់ថា តថាគតមិនពោលថា នរណាហ្ន៎តែងតក់ស្លុតដូច្នេះទេ ប្រសិនបើតថាគតពោលថា នរណាហ្ន៎តែងតក់ស្លុតដូច្នេះ ប្រស្នាថា បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎តែងតក់ស្លុតដូច្នេះ នោះត្រូវគ្នានឹងពាក្យតថាគតហើយ តែថាតថាគតមិនពោលយ៉ាងនេះទេ កាលបើយ៉ាងនេះ បុគ្គលណាសួរចំពោះតថាគតដែលមិនពោលសោះ យ៉ាងនេះថា បពិត្រព្រះអង្គ

កឹបច្ចយា នុ ខោ ភន្តេ តណ្ហាតិ ឯស កល្លោ

បញ្ហោ តត្រ កល្លំ វេយ្យាករណំ វេទនាបច្ចយា

តណ្ហា តណ្ហាបច្ចយា ឧបាទានន្តិ ។

[៣៦] កោ នុ ខោ ភន្តេ ឧបាទិយតីតិ ។

នោ កល្លោ បញ្ហោតិ ភគវា អវោច ឧបាទិយតីតិ

អហំ ន វទាមិ ឧបាទិយតីតិ ចាហំ វទេយ្យំ តត្រស្ស

កល្លោ បញ្ហោ កោ នុ ខោ ភន្តេ ឧបាទិយតីតិ

ឯវញ្ចាហំ ន វទាមិ ឯវំ មំ អវទន្តំ យោ ឯវំ បុច្ឆេយ្យ

ដ៏ចម្រើន តណ្ហាកើតមាន ព្រោះអ្វីជាបច្ច័យហ្ន៎ ដូច្នេះ ប្រស្នានុ៎ះរបស់ បុគ្គលនោះទើបត្រូវ ទាំងត្រូវព្យាករណ៍ ចំពោះប្រស្នានោះថា តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ៗ

(៣៦) បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ តែងប្រកាន់មាំ ៗ ព្រះមានព្រះភាគត្រាស់ថា ប្រស្នានេះមិនត្រូវទេ ដូច្នេះហើយ ទើបត្រាស់ថា តថាគតមិនពោលថា នរណាហ្ន៎តែងប្រកាន់មាំដូច្នេះទេ ប្រស្នាថា បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ តែងប្រកាន់មាំដូច្នេះ នោះត្រូវគ្នានឹងពាក្យតថាគតហើយ តែថា តថាគតមិនពោលយ៉ាងនេះទេ កាលបើយ៉ាងនេះ បុគ្គលណា សួរចំពោះតថាគតដែលមិនពោលសោះ យ៉ាងនេះថា

កឹបច្ចយា នុ ខោ ភន្តេ ឧបាទានន្តិ ឯស កល្លោ បញ្ហោ តត្រ កល្លំ វេយ្យាករណំ តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោតិ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៣៧] ឆន្នំ ត្វេវ ផគ្គុន ផស្សាយតនានំ អសេសវិរាគនិរោធា ផស្សនិរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

ទុតិយំ ។

បពិត្រព្រះអង្គដ៏ចម្រើន ឧបាទានកើតមាន ព្រោះអ្វីជាបច្ច័យហ្ន៎ ដូច្នេះ ប្រស្នានុ៎ះរបស់បុគ្គលនោះទើបត្រូវ ទាំងត្រូវព្យាករណ៍ចំពោះប្រស្នានោះថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(៣៧) ម្នាលផគ្គុន ឯការរលត់នៃផស្សៈ ព្រោះការរលត់អត់មានសេសសល់នៃផស្សាយតនៈទាំង ៦ ការរលត់នៃវេទនា ព្រោះការរលត់នៃផស្សៈ ការរលត់នៃតណ្ហា ព្រោះការរលត់នៃវេទនា ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ការរលត់នៃជាតិ ព្រោះការរលត់នៃភព ជរាមរណៈ សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏រមែងរលត់ទៅ ព្រោះការរលត់នៃជាតិ ។ ការរលត់ទៅនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ២ ។

(៣៨) សាវត្ថិយំ វិហរតិ... យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ជរាមរណំ នប្បជានន្តិ ជរាមរណសមុទយំ នប្បជានន្តិ ជរាមរណនិរោធំ នប្ប-ជានន្តិ ជរាមរណនិរោធគាមិនីបដិបទំ នប្បជានន្តិ ។ ជាតឹ ។បេ។ ភវំ... ឧបាទានំ... តណ្ហំ... វេទនំ... ផស្សំ... សឡាយតនំ...នាមរូបំ...វិញ្ញាណំ...សង្ខារេ នប្បជានន្តិ សង្ខារសមុទយំ នប្បជានន្តិ សង្ខារនិរោធំ នប្បជានន្តិ សង្ខារនិរោធគាមិនីបដិបទំ នប្បជានន្តិ ។ ន មេ តេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បន តេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

[ ៣៨ ] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ ណាមួយ មិនដឹងច្បាស់នូវជរាមរណៈ មិនដឹងច្បាស់ នូវហេតុជាទីកើតនៃជរាមរណៈ មិនដឹងច្បាស់ នូវទីរលត់នៃជរាមរណៈ មិនដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃជរាមរណៈ ។ នូវជាតិ ។ បេ ។ នូវភព ... នូវឧបាទាន ... នូវតណ្ហា ... នូវវេទនា ... នូវផស្សៈ ... នូវសឡាយតនៈ ... នូវនាមរូប ... នូវវិញ្ញាណ ... មិនដឹងច្បាស់នូវសង្ខារទាំងឡាយ មិនដឹងច្បាស់នូវហេតុជាទីកើតនៃសង្ខារ មិនដឹងច្បាស់នូវទីរលត់នៃសង្ខារ មិនដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ តថាគតមិនរាប់ថាសមណៈក្នុងពួកសមណៈផង មិនរាប់ថាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង ព្រោះសមណព្រាហ្មណ៍មានអាយុទាំងនោះ មិនធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផល ឬព្រហ្មញ្ញផល ដោយបញ្ញាដ៏ឧត្តមរបស់ខ្លួនឯង ក្នុងបច្ចុប្បន្នឡើយ ។

(៣៩) យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ជរាមរណំ បជានន្តិ ជរាមរណសមុទយំ បជានន្តិ ជរាមរណនិរោធំ បជានន្តិ ជរាមរណនិរោធគាមិនីបដិបទំ បជានន្តិ ។ ជាតឹ ។ បេ ។ ភវំ... ឧបាទានំ... តណ្ហំ... វេទនំ... ផស្សំ... សឡាយតនំ... នាមរូបំ... វិញ្ញាណំ... សង្ខារេ បជានន្តិ សង្ខារសមុទយំ បជានន្តិ សង្ខារនិរោធំ បជានន្តិ សង្ខារនិរោធគាមិនីបដិបទំ បជានន្តិ ។ តេ ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ នវមំ ។

(៣៩) ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកសមណព្រាហ្មណ៍ណាមួយ ដឹងច្បាស់នូវជរាមរណៈ ដឹងច្បាស់ នូវហេតុជាទីកើតនៃជរាមរណៈ ដឹងច្បាស់នូវទីរលត់នៃជរាមរណៈ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរាមរណៈ ។ នូវជាតិ ។ បេ ។ នូវភព ... នូវឧបាទាន ... នូវតណ្ហា ... នូវវេទនា ... នូវផស្សៈ ... នូវសឡាយតនៈ ... នូវនាមរូប ... នូវវិញ្ញាណ ... ដឹងច្បាស់នូវសង្ខារទាំងឡាយ ដឹងច្បាស់នូវហេតុជាទីកើតនៃសង្ខារ ដឹងច្បាស់នូវទីរលត់នៃសង្ខារ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ ទើបតថាគត រាប់ថាសមណៈក្នុងពួកសមណៈផង រាប់ថាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង ព្រោះថាសមណព្រាហ្មណ៍មានអាយុទាំងនោះ រមែងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផលផង នូវព្រហ្មញ្ញផលផង ដោយបញ្ញាដ៏ឧត្តមរបស់ខ្លួនឯងក្នុងបច្ចុប្បន្ន ។ ចប់សូត្រ ទី ៣ ។

(៤០) សាវត្ថិយំ វិហរតិ... យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេ ធម្មេ នប្បជានន្តិ ឥមេសំ ធម្មានំ សមុទយំ នប្បជានន្តិ ឥមេសំ ធម្មានំ និរោធំ នប្បជានន្តិ ឥមេសំ ធម្មានំ និរោធគាមិនិំ បដិបទំ នប្បជានន្តិ ។ កតមេ ធម្មេ នប្បជានន្តិ កតមេសំ ធម្មានំ សមុទយំ នប្បជានន្តិ កតមេសំ ធម្មានំ និរោធំ នប្បជានន្តិ កតមេសំ ធម្មានំ និរោធគាមិនិំ បដិបទំ នប្បជានន្តិ ។ ជរាមរណំ នប្បជានន្តិ ជរាមរណសមុទយំ នប្បជានន្តិ ជរាមរណនិរោធំ នប្បជានន្តិ ជរាមរណនិរោធគាមិនិំ បដិបទំ នប្បជានន្តិ ។ ជាតិំ ។ បេ ។ ភវំ... ឧបាទានំ... តណ្ហំ... វេទនំ... ផស្សំ... សឡាយតនំ... នាមរូបំ... វិញ្ញាណំ... សង្ខារេ នប្បជានន្តិ សង្ខារសមុទយំ នប្បជានន្តិ សង្ខារនិរោធំ នប្បជានន្តិ សង្ខារនិរោធគាមិនិំ បដិបទំ នប្បជានន្តិ ។ ឥមេ ធម្មេ នប្បជានន្តិ ឥមេសំ ធម្មានំ សមុទយំ នប្បជានន្តិ ឥមេសំ ធម្មានំ និរោធំ នប្បជានន្តិ

[ ៦០ ] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់នូវធម៌ទាំងនេះ មិនដឹងច្បាស់នូវហេតុជាទីកើតនៃធម៌ទាំងនេះ មិនដឹងច្បាស់នូវទីរលត់នៃធម៌ទាំងនេះ មិនដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃធម៌នេះ ។ សមណព្រាហ្មណ៍ទាំងនោះ មិនដឹងច្បាស់នូវធម៌អ្វី មិនដឹងច្បាស់នូវហេតុជាទីកើតនៃធម៌អ្វី មិនដឹងច្បាស់នូវទីរលត់នៃធម៌អ្វី មិនដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃធម៌អ្វី ។ គឺ មិនដឹងច្បាស់នូវជរាមរណៈ មិនដឹងច្បាស់នូវហេតុជាទីកើតនៃជរាមរណៈ មិនដឹងច្បាស់នូវទីរលត់នៃជរាមរណៈ មិនដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃជរាមរណៈ ។ នូវជាតិ ។ បេ ។ នូវភព ... នូវឧបាទាន ... នូវតណ្ហា ... នូវវេទនា ... នូវផស្សៈ ... នូវសឡាយតនៈ ... នូវនាមរូប ... នូវវិញ្ញាណ ... មិនដឹងច្បាស់នូវសង្ខារទាំងឡាយ មិនដឹងច្បាស់ នូវហេតុជាទីកើតនៃសង្ខារ មិនដឹងច្បាស់នូវទីរលត់នៃសង្ខារ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ។ សមណព្រាហ្មណ៍ទាំងនោះ មិនដឹងច្បាស់នូវធម៌ទាំងនេះ មិនដឹងច្បាស់នូវហេតុជាទីកើតនៃធម៌ទាំងនេះ មិនដឹងច្បាស់ នូវទីរលត់នៃធម៌ទាំងនេះ

ឥមេសំ ធម្មានំ និរោធគាមិនឹបដិបទំ នប្បជានន្តិ ។ ន មេ តេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បន តេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

[៤១] យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេ ធម្មេ បជានន្តិ ឥមេសំ ធម្មានំ សមុទយំ បជានន្តិ ឥមេសំ ធម្មានំ និរោធំ បជានន្តិ ឥមេសំ ធម្មានំ និរោធគាមិនឹបដិបទំ បជានន្តិ ។ កតមេ ធម្មេ បជានន្តិ កតមេសំ ធម្មានំ សមុទយំ បជានន្តិ កតមេសំ ធម្មានំ និរោធំ បជានន្តិ កតមេសំ ធម្មានំ និរោធគាមិនឹបដិបទំ បជានន្តិ ។ ជរាមរណំ បជានន្តិ ជរាមរណសមុទយំ បជានន្តិ ជរាមរណនិរោធំ បជានន្តិ ជរាមរណនិរោធគាមិនឹបដិបទំ បជានន្តិ ។ ជាតឹ ។បេ។ ភវំ... ឧបាទានំ ... តណ្ហំ ... វេទនំ ... ផស្សំ ... សឡាយតនំ ... នាមរូបំ ... វិញ្ញាណំ ... សង្ខារេ បជានន្តិ

មិនដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃធម៌ទាំងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍នោះ តថាគត មិនរាប់ថាសមណៈក្នុងពួកសមណៈផង មិនរាប់ថាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍ផង ព្រោះថា សមណព្រាហ្មណ៍មានអាយុទាំងនោះ រមែងមិនធ្វើឲ្យជាក់ច្បាស់ មិនសម្រេចនូវសាមញ្ញផល ឬព្រហ្មញ្ញផល ដោយបញ្ញាដ៏ឧត្តមរបស់ខ្លួនឯង ក្នុងបច្ចុប្បន្នឡើយ ។

[ ៤១ ] ម្នាលភិក្ខុទាំងឡាយ ចំណែកខាងពួកសមណព្រាហ្មណ៍ណាមួយ ដឹងច្បាស់នូវធម៌ទាំងនេះ ដឹងច្បាស់នូវហេតុជាទីកើតនៃធម៌ទាំងនេះ ដឹងច្បាស់នូវទីរលត់នៃធម៌ទាំងនេះ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃធម៌ទាំងនេះ ។ សមណព្រាហ្មណ៍ទាំងនោះ ដឹងច្បាស់នូវធម៌អ្វី ដឹងច្បាស់នូវហេតុជាទីកើតនៃធម៌អ្វី ដឹងច្បាស់នូវទីរលត់នៃធម៌អ្វី ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃធម៌អ្វី ។ គឺ ដឹងច្បាស់នូវជរាមរណៈ ដឹងច្បាស់នូវហេតុជាទីកើតនៃជរាមរណៈ ដឹងច្បាស់នូវទីរលត់នៃជរាមរណៈ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃជរាមរណៈ ។ នូវជាតិ ។ បេ ។ នូវភព ... នូវឧបាទាន ... នូវតណ្ហា ... នូវវេទនា ... នូវផស្សៈ ... នូវសឡាយតនៈ ... នូវនាមរូប ... នូវវិញ្ញាណ ... ដឹងច្បាស់នូវសង្ខារទាំងឡាយ

សង្ខារសមុទយំ បជានន្តិ សង្ខារនិរោធំ បជានន្តិ សង្ខារនិរោធគាមិនឹបដិបទំ បជានន្តិ ។ ឥមេ ធម្មេ បជានន្តិ ឥមេសំ ធម្មានំ សមុទយំ បជានន្តិ ឥមេសំ ធម្មានំ និរោធំ បជានន្តិ ឥមេសំ ធម្មានំ និរោធគាមិនឹ-បដិបទំ បជានន្តិ ។ តេ ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ ចតុត្ថំ ។

(៤២) សាវត្ថិយំ វិហរតិ អថខោ អាយស្មា កច្ចានគោត្តោ[១] យេន ភគវា តេនុបសង្កមិ ឧប-សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា កច្ចានគោត្តោ ភគវន្តំ ឯតទវោច សម្មាទិដ្ឋិ សម្មាទិដ្ឋីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សម្មាទិដ្ឋិ ហោតីតិ ។

---

១ ឱ. កច្ចាយនគោត្តោ ។

ដឹងច្បាស់នូវហេតុជាទីកើតនៃសង្ខារ ដឹងច្បាស់នូវទីរលត់នៃសង្ខារ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ។ សមណព្រាហ្មណ៍ទាំងនោះ ដឹងច្បាស់នូវធម៌ទាំងនេះ ដឹងច្បាស់នូវហេតុជាទីកើតនៃធម៌ទាំងនេះ ដឹងច្បាស់នូវទីរលត់នៃធម៌ទាំងនេះ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃធម៌ទាំងនេះ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ ទើបតថាគត រាប់ថាជាសមណៈក្នុងពួកសមណៈផង រាប់ថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង ព្រោះថាសមណព្រាហ្មណ៍មានអាយុទាំងនោះ រមែងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផលផង នូវព្រហ្មញ្ញផលផង ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ចប់សូត្រ ទី ៤ ។

( ៤២ ) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... គ្រានោះ ព្រះកច្ចានគោត្រមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះកច្ចានគោត្រមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែងត្រាស់ថា សម្មាទិដ្ឋិ សម្មាទិដ្ឋិ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ចុះសម្មាទិដ្ឋិ តើកើតមាន ដោយហេតុប៉ុន្មានយ៉ាង ។

(៤៣) ទ្វយនិស្សិតោ ខ្វាយំ កច្ចាន លោកោ យេភុយ្យេន អត្ថិតញ្ចេវ នត្ថិតញ្ច ។ លោកសមុទយំ ខោ កច្ចាន យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា លោកេ នត្ថិតា សា ន ហោតិ ។ លោកនិរោធំ ខោ កច្ចាន យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា លោកេ អត្ថិតា សា ន ហោតិ ។ ឧបាយុបាទានាភិនិវេសវិនិពន្ធោ ខ្វាយំ កច្ចាន លោកោ យេភុយ្យេន តញ្ចាយំ ឧបាយុបាទានំ ចេតសោ អធិដ្ឋានំ អភិនិវេសានុសយំ ន ឧបេតិ ន ឧបាទិយតិ នាធិដ្ឋាតិ អត្តា មេតិ ។ ទុក្ខមេវ ឧប្បជ្ជមានំ ឧប្បជ្ជតិ ទុក្ខំ និរុជ្ឈមានំ និរុជ្ឈតីតិ ន កង្ខតិ ន វិចិកិច្ឆតិ ។ អបរប្បច្ចយា ញាណមេវស្ស ឯត្ថ ហោតិ ។ ឯត្តាវតា ខោ កច្ចាន សម្មាទិដ្ឋិ ហោតិ ។

[៤៣] ម្នាលកច្ចានៈ សត្វលោកនេះ ច្រើនតែអាស្រ័យនូវចំណែកពីរយ៉ាងគឺ អត្ថិភាព (សស្សតទិដ្ឋិ)១ នត្ថិភាព (ឧច្ឆេទទិដ្ឋិ)១ ។ ម្នាលកច្ចានៈ នត្ថិភាពក្នុងលោក រមែងមិនមាន ដល់បុគ្គលដែលឃើញនូវហេតុជាទីកើតនៃលោក ដោយប្រាជ្ញាដ៏ប្រពៃតាមពិតឡើយ ។ ម្នាលកច្ចានៈ អត្ថិភាពក្នុងលោក រមែងមិនមានដល់បុគ្គលដែលឃើញនូវទីរលត់នៃលោក ដោយប្រាជ្ញាដ៏ប្រពៃតាមពិតឡើយ ។ ម្នាលកច្ចានៈ សត្វលោកនេះ ច្រើនតែជាប់ចំពាក់ដោយឧបាយ ឧបាទាន និងសេចក្តីប្រកាន់មាំ ចំណែកខាងអរិយសាវ័កនេះ រមែងមិនចូលទៅដល់ មិនប្រកៀកប្រកាន់ មិនអធិដ្ឋាន នូវឧបាយនិងឧបាទាន នូវការតាំងទុកនៃចិត្ត នូវសេចក្តីប្រកាន់មាំនិងអនុសយក្កិលេសនោះៗ ថា ខ្លួនរបស់អាត្មាអញដូច្នេះឡើយ ។ ឧបាទានក្ខន្ធទុក្ខ កាលកើត ក៏កើតឡើង ឧបាទានក្ខន្ធទុក្ខ កាលរលត់ ក៏រលត់ទៅ ព្រោះហេតុនោះ ទើបអរិយសាវ័កមិនសង្ស័យ មិនងឿងឆ្ងល់ឡើយ ។ ញាណរបស់អរិយសាវ័កនោះ រមែងមានក្នុងឧបាទានក្ខន្ធទុក្ខនុ៎ះ ដោយមិនបាច់ជឿពាក្យបុគ្គលដទៃឡើយ ។ ម្នាលកច្ចានៈ សម្មាទិដ្ឋិ កើតមានដោយហេតុប៉ុណ្ណេះឯង ។

[៤៤] សព្វមត្ថីតិ ខោ កច្ចាន អយមេកោ អន្តោ សព្វំ នត្ថីតិ អយំ ទុតិយោ អន្តោ ។ ឯតេ តេ កច្ចាន ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ បញ្ចមំ ។

[៤៥] សាវត្ថិយំ វិហរតិ... អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ធម្មកថិកោ ធម្មកថិកោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ធម្មកថិកោ ហោតីតិ ។

(៤៤) ម្នាលកច្ចានៈ ទីបំផុតទី ១ នេះ ថា វត្ថុទាំងពួងមាន ទីបំផុត ទី ២ នេះ ថា វត្ថុទាំងពួងមិនមាន ។ ម្នាលកច្ចានៈ តថាគតមិនអាស្រ័យនូវទីបំផុតទាំងពីរនុ៎ះទេ តែងសំដែងនូវធម៌ដោយបទកណ្តាលថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ឯការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់ឥតមានសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

ចប់សូត្រ ទី ៥ ។

(៤៥) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... គ្រានោះ ភិក្ខុ ១ រូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែងត្រាស់ថា ធម្មកថិក ធម្មកថិក (អ្នកសំដែងធម៌ អ្នកសំដែងធម៌) បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុជាធម្មកថិក មានដោយហេតុប៉ុន្មានយ៉ាង ។

[៤៦] ជរាមរណស្ស ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ ជរាមរណស្ស ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ធម្មានុធម្មប្បដិបន្នោ ភិក្ខូតិ អលំ វចនាយ ។ ជរាមរណស្ស ចេ ភិក្ខុ និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ទិដ្ឋធម្មនិព្វានប្បត្តោ ភិក្ខូតិ អលំ វចនាយ ។ ជាតិយា ចេ ភិក្ខុ ។ បេ ។ ភវស្ស ចេ ភិក្ខុ ឧបាទានស្ស ចេ ភិក្ខុ តណ្ហាយ ចេ ភិក្ខុ វេទនាយ ចេ ភិក្ខុ ... ផស្សស្ស ចេ ភិក្ខុ ... សឡាយតនស្ស ចេ ភិក្ខុ ... នាមរូបស្ស ចេ ភិក្ខុ ... វិញ្ញាណស្ស ចេ ភិក្ខុ ... សង្ខារានញ្ចេ

(៦៦) ព្រះអង្គត្រាស់ថា បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់ នៃជរាមរណៈ ទើបគួរហៅថា ភិក្ខុជាធម្មកថិកបាន ។ បើភិក្ខុប្រតិបត្តិដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់ នៃជរាមរណៈ ទើបគួរហៅថា ភិក្ខុអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ។ បើភិក្ខុមានចិត្តរួចស្រឡះហើយ ព្រោះការនឿយណាយ ព្រោះការវិនាស ព្រោះការរលត់ នៃជរាមរណៈ ព្រោះការមិនប្រកាន់មាំ ទើបគួរហៅថា ភិក្ខុអ្នកដល់ នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។ បើភិក្ខុសំដែងធម៌ ដើម្បីការរលត់នៃជាតិ ។ បេ ។ បើភិក្ខុសំដែងធម៌ ដើម្បីការរលត់នៃភព ... បើភិក្ខុសំដែងធម៌ ដើម្បីការរលត់នៃឧបាទាន ... បើភិក្ខុសំដែងធម៌ ដើម្បីការរលត់នៃតណ្ហា ... បើភិក្ខុសំដែងធម៌ ដើម្បីការរលត់នៃវេទនា ... បើភិក្ខុសំដែងធម៌ ដើម្បីការរលត់នៃផស្សៈ ... បើភិក្ខុសំដែងធម៌ ដើម្បីការរលត់នៃសឡាយតនៈ ... បើភិក្ខុសំដែងធម៌ ដើម្បីការរលត់នៃនាមរូប ... បើភិក្ខុសំដែងធម៌ ដើម្បីការរលត់នៃវិញ្ញាណ ... បើភិក្ខុសំដែងធម៌ ដើម្បីការរលត់នៃសង្ខារ ...

ភិក្ខុ ... អវិជ្ជាយ ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ អវិជ្ជាយ ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ធម្មានុធម្មប្បដិបន្នោ ភិក្ខូតិ អលំ វចនាយ ។ អវិជ្ជាយ ចេ ភិក្ខុ និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ទិដ្ឋធម្មនិព្វាន-ប្បត្តោ ភិក្ខូតិ អលំ វចនាយាតិ ។ ឆដ្ឋំ ។

(៤៧) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថ ខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហេ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ អចេលោ កស្សបោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។

បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់ នៃអវិជ្ជា ទើបគួរហៅថា ភិក្ខុធម្មកថិក ។ បើភិក្ខុប្រតិបត្តិ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់ នៃអវិជ្ជា ទើបគួរហៅថា ភិក្ខុអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ។ បើភិក្ខុមានចិត្តរួចស្រឡះហើយ ព្រោះការនឿយណាយ ព្រោះការវិនាស ព្រោះការរលត់ នៃអវិជ្ជា ព្រោះការមិនប្រកាន់មាំ ទើបគួរហៅថា ភិក្ខុអ្នកដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។ ចប់សូត្រ ទី ៦ ។

(៤៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ហើយស្តេចចូលទៅក្នុងក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ អចេលកស្សប បានឃើញព្រះមានព្រះភាគ យាងមកអំពីចម្ងាយលើម ៗ លុះឃើញហើយ ក៏ដើរចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏ឋិតនៅក្នុងទីសមគួរ ។

(៤៨) ឯកមន្តំ ឋិតោ ខោ អចេលោ កស្សបោ ភគវន្តំ ឯតទវោច បុច្ឆេយ្យាម មយំ ភគវន្តំ កញ្ចិទេវ ទេសំ សចេ នោ ភគវា ឱកាសំ ករោតិ បញ្ហស្ស វេយ្យាករណាយាតិ ។ អកាលោ ខោ តាវ កស្សប បញ្ហស្ស អន្តរឃរំ បវិដ្ឋម្ហាតិ ។ ទុតិយម្បិ ខោ អចេលោ កស្សបោ ភគវន្តំ ឯតទវោច បុច្ឆេយ្យាម មយំ ភគវន្តំ កញ្ចិទេវ ទេសំ សចេ នោ ភគវា ឱកាសំ ករោតិ បញ្ហស្ស វេយ្យាករណាយាតិ ។ អកាលោ ខោ តាវ កស្សប បញ្ហស្ស អន្តរឃរំ បវិដ្ឋម្ហាតិ ។ តតិយម្បិ ខោ ។បេ។ បវិដ្ឋម្ហាតិ ។

(៤៩) ឯវំ វុត្តេ អចេលោ កស្សបោ ភគវន្តំ ឯតទវោច ន ខោ បន មយំ ភគវន្តំ ពហុទេវ បុច្ឆិតុកាមាតិ ។ បុច្ឆ កស្សប យទាកង្ខសីតិ ។ កឹ នុ ខោ ភោ គោតម សយំកតំ ទុក្ខន្តិ ។ មា ហេវំ កស្សបាតិ ភគវា អវោច ។ កឹ បន ភោ គោតម

(៦៨) លុះអចេលកស្សប ឋិតនៅក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា យើងខ្ញុំនឹងសួរនូវហេតុនីមួយចំពោះព្រះគោតមដ៏ចម្រើន បើព្រះគោតមដ៏ចម្រើន បើកឱកាសដើម្បីការដោះស្រាយប្រស្នារបស់យើងខ្ញុំ ។ ព្រះមានព្រះភាគត្រាស់តបថា កុំអាលសិន កស្សប កាលនេះជាកាលមិនគួរដល់ប្រស្នាទេ ព្រោះយើងកំពុងចូលមកកាន់ចន្លោះផ្ទះ ។ អចេលកស្សប ក្រាបបង្គំសួរព្រះមានព្រះភាគជាគម្រប់ពីរដងថា យើងខ្ញុំនឹងសួរនូវហេតុនីមួយចំពោះព្រះគោតមដ៏ចម្រើន បើព្រះគោតមដ៏ចម្រើន បើកឱកាសដើម្បីការដោះស្រាយនូវប្រស្នារបស់យើងខ្ញុំ ។ កុំអាលសិន កស្សប កាលនេះជាកាលមិនគួរដល់ប្រស្នាទេ ព្រោះយើងកំពុងចូលមកកាន់ចន្លោះផ្ទះ ។ អចេលកស្សប ក្រាបបង្គំសួរជាគម្រប់បីដង ។ បេ ។ ព្រោះយើងកំពុងចូលមកកាន់ចន្លោះផ្ទះ ។

(៦៩) លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អចេលកស្សប ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា យើងខ្ញុំមិនមានបំណងដើម្បីសួរព្រះគោតមដ៏ចម្រើន ច្រើនរឿងទេ ។ ម្នាលកស្សប អ្នកប្រាថ្នានឹងសួរនូវហេតុណា ចូរសួរចុះ ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងឬអ្វី ។ ព្រះមានព្រះភាគត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សប ។ បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ

បរកតំ ទុក្ខន្តិ ។ មា ហេវំ កស្សបាតិ ភគវា
អវោច ។ កិំ នុ ខោ ភោ គោតម សយំកតញ្ច
បរកតញ្ច ទុក្ខន្តិ ។ មា ហេវំ កស្សបាតិ ភគវា
អវោច ។ កិំ បន ភោ គោតម អសយំការំ អបរការំ
អធិច្ចសមុប្បន្នំ ទុក្ខន្តិ ។ មា ហេវំ កស្សបាតិ
ភគវា អវោច ។ កិំ នុ ខោ ភោ គោតម នត្ថិ
ទុក្ខន្តិ ។ ន ខោ កស្សប នត្ថិ ទុក្ខំ អត្ថិ ខោ
កស្សប ទុក្ខន្តិ ។ តេនហិ ភវំ គោតមោ ទុក្ខំ
ន ជានាតិ ន បស្សតីតិ ។ ន ខ្វាហំ កស្សប ទុក្ខំ
ន ជានាមិ ន បស្សាមិ ជានាមិ ខ្វាហំ កស្សប
ទុក្ខំ បស្សាមិ ខ្វាហំ កស្សប ទុក្ខន្តិ ។ កិំ
នុ ខោ ភោ គោតម សយំកតំ ទុក្ខន្តិ ឥតិ
បុដ្ឋោ សមានោ មា ហេវំ កស្សបាតិ វទេសិ

សេចក្តីទុក្ខ គឺបុគ្គលដទៃធ្វើឲ្យឬ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សប ។ បពិត្រព្រះគោតម ដ៏ចម្រើន សេចក្តីទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង ឬអ្វី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សប ។ បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្តីទុក្ខ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់អ្នកដទៃទេ គឺកើតឡើងដោយឥតហេតុ ឬអ្វី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សប ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខ មិនមានទេឬ ។ ម្នាលកស្សប សេចក្តីទុក្ខមិនមែនជាមិនមានទេ ម្នាលកស្សប សេចក្តីទុក្ខមានដោយពិត ។ បើដូច្នោះ មានតែព្រះគោតមដ៏ចម្រើន មិនស្គាល់ មិនឃើញសេចក្តីទុក្ខទេឬ ។ ម្នាលកស្សប តថាគត មិនមែនជាមិនស្គាល់មិនឃើញសេចក្តីទុក្ខទេ ម្នាលកស្សប តថាគតស្គាល់សេចក្តីទុក្ខដោយពិត ម្នាលកស្សប តថាគតឃើញសេចក្តីទុក្ខដោយពិត ។ ចុះកាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងឬអ្វី ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សប

កឹ បន ភោ គោតម បរកតំ ទុក្ខន្តិ ឥតិ បុដ្ឋោ
សមានោ មា ហេវំ កស្សបាតិ វទេសិ កឹ នុ
ខោ ភោ គោតម សយង្កតញ្ច បរកតញ្ច ទុក្ខន្តិ
ឥតិ បុដ្ឋោ សមានោ មា ហេវំ កស្សបាតិ វទេសិ
កឹ បន ភោ គោតម អសយង្ការំ អបរង្ការំ
អធិច្ចសមុប្បន្នំ ទុក្ខន្តិ ឥតិ បុដ្ឋោ សមានោ មា ហេវំ
កស្សបាតិ វទេសិ កឹ នុ ខោ ភោ គោតម នត្ថិ
ទុក្ខន្តិ ឥតិ បុដ្ឋោ សមានោ ន ខោ កស្សប នត្ថិ
ទុក្ខំ អត្ថិ ខោ កស្សប ទុក្ខន្តិ វទេសិ តេនហិ ភវំ
គោតមោ ទុក្ខំ ន ជានាតិ ន បស្សតីតិ ឥតិ បុដ្ឋោ
សមានោ ន ខ្វាហំ កស្សប ទុក្ខំ ន ជានាមិ ន
បស្សាមិ ជានាមិ ខ្វាហំ កស្សប ទុក្ខំ បស្សាមិ
ខ្វាហំ កស្សប ទុក្ខន្តិ វទេសិ អាចិក្ខតុ ច មេ ភន្តេ
ភគវា ទុក្ខំ ទេសេតុ ច មេ ភន្តេ ភគវា ទុក្ខន្តិ ។

កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្តីទុក្ខ គឺបុគ្គលដទៃធ្វើឲ្យឬ ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សប កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផងឬ ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សប កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្តីទុក្ខ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយឥតហេតុឬ ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សប កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខ មិនមានទេឬ ព្រះអង្គត្រាស់ថា ម្នាលកស្សប សេចក្តីទុក្ខ មិនមែនជាមិនមានទេ ម្នាលកស្សប សេចក្តីទុក្ខមានដោយពិត កាលដែលខ្ញុំសួរថា បើដូច្នោះ មានតែព្រះគោតមដ៏ចម្រើន មិនស្គាល់មិនឃើញសេចក្តីទុក្ខឬ ព្រះអង្គត្រាស់ថា ម្នាលកស្សប តថាគតមិនមែនជាមិនស្គាល់ មិនឃើញសេចក្តីទុក្ខទេ ម្នាលកស្សប តថាគតស្គាល់សេចក្តីទុក្ខដោយពិត ម្នាលកស្សប តថាគតឃើញសេចក្តីទុក្ខដោយពិត បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ប្រាប់សេចក្តីទុក្ខដល់ខ្ញុំផង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសំដែងសេចក្តីទុក្ខដល់ខ្ញុំផង ។

(៥០) សោ ករោតិ សោ បដិសំវេទយតីតិ ខោ កស្សប អាទិតោ សតោ សយំកតំ ទុក្ខន្តិ ឥតិ វទំ សស្សតំ ឯតំ បរេតិ ។ អញ្ញោ ករោតិ អញ្ញោ បដិសំវេទយតីតិ ខោ កស្សប វេទនាភិតុន្នស្ស សតោ បរកតំ ទុក្ខន្តិ ឥតិ វទំ ឧច្ឆេទំ ឯតំ បរេតិ ។ ឯតេ តេ កស្សប ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

(៤០) ម្នាលកស្សប កាលបើមានសេចក្តីយល់ឃើញខាងដើមថា គេធ្វើ គេក៏ទទួលផល ដូច្នេះ លទ្ធិថា សេចក្តីទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង ក៏នឹងមាន បុគ្គលកាលពោលយ៉ាងនេះ ឈ្មោះថាប្រកាន់នូវសស្សតទិដ្ឋិនុ៎ះ ។ ម្នាលកស្សប កាលបើមានសេចក្តីយល់ឃើញខាងដើមថា អ្នកដទៃធ្វើ អ្នកឯទៀតទទួលផល ដូច្នេះ បុគ្គលដែលត្រូវវេទនាគ្របសង្កត់ ក៏នឹងមានលទ្ធិថា សេចក្តីទុក្ខ គឺបុគ្គលដទៃធ្វើ បុគ្គលកាលពោលយ៉ាងនេះ ឈ្មោះថាប្រកាន់នូវឧច្ឆេទទិដ្ឋិនុ៎ះ ។ ម្នាលកស្សប តថាគត មិនប្រកាន់នូវទីបំផុតទាំងពីរនុ៎ះឡើយ តែងសំដែងធម៌ដោយបទកណ្តាលថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់ឥតសេសសល់ នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(៥១) ឯវំ វុត្តេ អចេលោ កស្សបោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ ។ បេ ។ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ យោ ខោ កស្សប អញ្ញតិត្ថិយបុព្វោ ឥមស្មឹ ធម្មវិនយេ អាកង្ខតិ បព្វជ្ជំ អាកង្ខតិ ឧបសម្បទំ សោ ចត្តារោ មាសេ បរិវសតិ ចតុន្នំ មាសានំ អច្ចយេន បរិវុត្ថបរិវាសំ អារទ្ធចិត្តា ភិក្ខូ អាកង្ខមានា បព្វាជេន្តិ ឧបសម្បាទេន្តិ ភិក្ខុភាវាយ

( ៩១ ) លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អចេលកស្សប ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភ្លឺច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចំរើន ភ្លឺច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលផ្ងារឡើង នូវវត្ថុដែលផ្កាប់ ។បេ។ ដោយគិតថា ពួកបុគ្គលមានភ្នែកភ្លឺ នឹងឃើញរូបបាន យ៉ាងណាមិញ ធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយអនេកបរិយាយ ក៏យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមបាននូវបព្វជ្ជា សូមបាននូវឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលកស្សប បុគ្គលណាធ្លាប់ជាអន្យតិរ្ថិយ ប្រាថ្នានូវបព្វជ្ជា ប្រាថ្នានូវឧបសម្បទាក្នុងធម្មវិន័យនេះ បុគ្គលនោះតែងនៅបរិវាស អស់ ៤ ខែសិន លុះបុគ្គលនោះបាននៅបរិវាសគ្រប់ ៤ ខែហើយ ពួកភិក្ខុដែលមានចិត្តប្រោសប្រាណ កាលបើប្រាថ្នា ទើបបំបួស ទើបឲ្យឧបសម្បទា ដើម្បីភិក្ខុភាពបាន

អបិច មយា បុគ្គលវេមត្តតា វិទិតាតិ ។ សចេ ភន្តេ អញ្ញតិត្ថិយបុព្វា ឥមស្មឹ ធម្មវិនយេ អាកង្ខន្តិ បព្វជ្ជំ អាកង្ខន្តិ ឧបសម្បទំ ចត្តារោ មាសេ បរិវសន្តិ ចតុន្នំ មាសានំ អច្ចយេន បរិវុត្ថបរិវាសេ អារទ្ធចិត្តា ភិក្ខូ អាកង្ខមានា បព្វាជេន្តិ ឧបសម្បាទេន្តិ ភិក្ខុភាវាយ អហំ ចត្តារិ វស្សានិ បរិវសិស្សាមិ ចតុន្នំ វស្សានំ អច្ចយេន បរិវុត្ថបរិវាសំ អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តុ ឧបសម្បាទេន្តុ ភិក្ខុភាវាយាតិ ។

(៥២) អលត្ថ ខោ អចេលោ កស្សបោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ច បនាយស្មា កស្សបោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោ-

ម្យ៉ាងទៀត តថាគតបានដឹងច្បាស់នូវការផ្សេង នៃបុគ្គលដែលគួរនៅបរិវាសនិងមិនគួរនៅបរិវាស ។ អចេលកស្សបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើបុគ្គលទាំងឡាយធ្លាប់ជាអន្យតិរ្ថិយ ប្រាថ្នានូវបព្វជ្ជា ប្រាថ្នានូវឧបសម្បទា ក្នុងធម្មវិន័យនេះ តែងនៅបរិវាសអស់ ៤ ខែសិន លុះបុគ្គលនោះបាននៅបរិវាសគ្រប់ ៤ ខែហើយ ពួកភិក្ខុដែលមានចិត្តប្រោសប្រាណ កាលបើប្រាថ្នា ទើបបំបួស ទើបឲ្យឧបសម្បទា ដើម្បីភិក្ខុភាពបាន ឯខ្ញុំព្រះអង្គនឹងហ៊ាននៅបរិវាសអស់ ៤ ឆ្នាំ លុះខ្ញុំព្រះអង្គបាននៅបរិវាសគ្រប់ ៤ ឆ្នាំហើយ សូមពួកភិក្ខុដែលមានចិត្តប្រោសប្រាណបំបួស ឲ្យឧបសម្បទា ដើម្បីភិក្ខុភាពឲ្យទាន ។

(៥២) អចេលកស្សប ក៏បានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ លុះកស្សបមានអាយុ បានឧបសម្បទាហើយ មិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទមានព្យាយាមជាគ្រឿងកំដៅនូវកិលេស មានចិត្តស្ទុង (ទៅកាន់ព្រះនិព្វាន) កុលបុត្តទាំងឡាយចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌នោះ

សានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា កឡារោ អរហតំ អ-ហោសីតិ ។ សត្តមំ ។

(៨៣) សាវត្ថិយំ វិហរតិ ... អថ ខោ តិម្ពរុកោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណី-យំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយក៏បានដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ ព្រះកស្សបមានអាយុ ក៏រាប់ថាជាព្រះអរហន្តមួយអង្គដែរ ។ ចប់សូត្រ ទី ៧ ។

( ៨៣ ) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... គ្រានោះ បរិព្វាជកឈ្មោះតិម្ពរុក្ខ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។

(៨៤) ឯកមន្តំ និសិន្នោ ខោ តិម្ពរុកោ បរិព្វាជកោ ភគវន្តំ ឯតទវោច កិំ នុ ខោ ភោ គោតម សយំកតំ សុខទុក្ខន្តិ ។ មា ហេវំ តិម្ពរុកាតិ ភគវា អវោច ។ កិំ បន ភោ គោតម បរកតំ សុខទុក្ខន្តិ ។ មា ហេវំ តិម្ពរុកាតិ ភគវា អវោច ។ កិំ នុ ខោ ភោ គោតម សយំកតញ្ច បរកតញ្ច សុខទុក្ខន្តិ ។ មា ហេវំ តិម្ពរុកាតិ ភគវា អវោច ។ កិំ បន ភោ គោតម អសយំការំ អបរំការំ អធិច្ចសមុប្បន្នំ សុខទុក្ខន្តិ ។ មា ហេវំ តិម្ពរុកាតិ ភគវា អវោច ។ កិំ នុ ខោ ភោ គោតម នត្ថិ សុខទុក្ខន្តិ ។ ន ខោ តិម្ពរុក នត្ថិ សុខទុក្ខំ អត្ថិ ខោ តិម្ពរុក សុខទុក្ខន្តិ ។

អភិសមយសំយុត្ត អាហារវគ្គ ការសាកសួររកសេចក្ដីទុក្ខ

[៤៨] លុះតិម្ពរុក្ខ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្ដីសុខនិងទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង ឬអ្វី ។ ព្រះមានព្រះភាគទ្រង់ត្រាស់តបថា កុំពោលយ៉ាងនេះឡើយ តិម្ពរុក្ខ ។ បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្ដីសុខនិងទុក្ខ គឺបុគ្គលដទៃធ្វើឲ្យឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា កុំពោលយ៉ាងនេះឡើយ តិម្ពរុក្ខ ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្ដីសុខនិងទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង ឬអ្វី ។ ព្រះមានព្រះភាគត្រាស់ថា កុំពោលយ៉ាងនេះឡើយ តិម្ពរុក្ខ ។ បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្ដីសុខនិងទុក្ខ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយឥតហេតុទេ ឬអ្វី ។ ព្រះមានព្រះភាគត្រាស់ថា កុំពោលយ៉ាងនេះឡើយ តិម្ពរុក្ខ ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្ដីសុខនិងទុក្ខ មិនមានទេឬ ។ ម្នាលតិម្ពរុក្ខ សេចក្ដីសុខនិងទុក្ខ មិនមែនជាមិនមានទេ ម្នាលតិម្ពរុក្ខ សេចក្ដីសុខនិងទុក្ខ មានដោយពិត ។

តេនហិ ភវំ គោតមោ សុខទុក្ខំ ន ជានាតិ ន បស្សតីតិ ។ ន ខ្វាហំ តិម្ពរុក្ខ សុខទុក្ខំ ន ជានាមិ ន បស្សាមិ ជានាមិ ខ្វាហំ តិម្ពរុក្ខ សុខទុក្ខំ បស្សាមិ ខ្វាហំ តិម្ពរុក្ខ សុខទុក្ខន្តិ ។ កឹ នុ ខោ ភោ គោតម សយំកតំ សុខទុក្ខន្តិ ឥតិ បុដ្ឋោ សមានោ មា ហេវំ តិម្ពរុក្ខាតិ វទេសិ កឹ បន ភោ គោតម បរំកតំ សុខទុក្ខន្តិ ឥតិ បុដ្ឋោ សមានោ មា ហេវំ តិម្ពរុក្ខាតិ វទេសិ កឹ នុ ខោ ភោ គោតម សយំកតញ្ច បរំកតញ្ច សុខទុក្ខន្តិ ឥតិ បុដ្ឋោ សមានោ មា ហេវំ តិម្ពរុក្ខាតិ វទេសិ កឹ បន ភោ គោតម អសយំការំ អបរំការំ អធិច្ចសមុប្បន្នំ សុខទុក្ខន្តិ ឥតិ បុដ្ឋោ សមានោ មា ហេវំ តិម្ពរុក្ខាតិ វទេសិ កឹ នុ ខោ ភោ គោតម នត្ថិ សុខទុក្ខន្តិ ឥតិ បុដ្ឋោ សមានោ ន ខោ តិម្ពរុក្ខ នត្ថិ សុខទុក្ខំ អត្ថិ ខោ តិម្ពរុក្ខ សុខទុក្ខន្តិ វទេសិ

បើដូច្នោះ មានតែព្រះគោតមដ៏ចម្រើន មិនស្គាល់ មិនឃើញសេចក្តីសុខនិងទុក្ខទេ ។ ម្នាលតិម្ពរុក តថាគតមិនមែនមិនស្គាល់មិនឃើញសេចក្តីសុខនិងទុក្ខទេ ម្នាលតិម្ពរុក តថាគតស្គាល់សេចក្តីសុខនិងទុក្ខដោយពិត ម្នាលតិម្ពរុក តថាគតឃើញសេចក្តីសុខនិងទុក្ខដោយពិត ។ ចុះកាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីសុខនិងទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងឬអ្វី ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ តិម្ពរុក កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្តីសុខនិងទុក្ខ គឺបុគ្គលដទៃធ្វើឲ្យឬ ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ តិម្ពរុក កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីសុខនិងទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង ឬអ្វី ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ តិម្ពរុក កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្តីសុខនិងទុក្ខ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយឥតហេតុទេឬអ្វី ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ តិម្ពរុក កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីសុខនិងទុក្ខ មិនមានទេឬ ព្រះអង្គត្រាស់ថា ម្នាលតិម្ពរុក សេចក្តីសុខនិងទុក្ខ មិនមែនជាមិនមានទេ ម្នាលតិម្ពរុក សេចក្តីសុខនិងទុក្ខ មានដោយពិត

តេនហិ ភវំ គោតមោ សុខទុក្ខំ ន ជានាតិ ន បស្សតីតិ ឥតិ បុដ្ឋោ សមានោ ន ខ្វាហំ តិម្ពរុក្ខ សុខទុក្ខំ ន ជានាមិ ន បស្សាមិ ជានាមិ ខ្វាហំ តិម្ពរុក្ខ សុខទុក្ខំ បស្សាមិ ខ្វាហំ តិម្ពរុក្ខ សុខ-ទុក្ខន្តិ វទេសិ អាចិក្ខតុ ច មេ ភវំ គោតមោ សុខទុក្ខំ ទេសេតុ ច មេ ភវំ គោតមោ សុខទុក្ខន្តិ ។

(៤៤) សា វេទនា សោ វេទយតីតិ ខោ តិម្ពរុក្ខ អាទិតោ សតោ សយំកតំ សុខទុក្ខន្តិ ឯវម្បាហំ ន វទាមិ ។ អញ្ញា វេទនា អញ្ញោ វេទយតីតិ ខោ តិម្ពរុក្ខ វេទនាភិតុន្នស្ស សតោ បរកតំ សុខទុក្ខន្តិ ឯវម្បាហំ ន វទាមិ ។ ឯតេ តេ តិម្ពរុក្ខ ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ

កាលដែលខ្ញុំសួរថា បើដូច្នោះ មានតែព្រះគោតមដ៏ចម្រើន មិនស្គាល់ មិនឃើញសេចក្ដីសុខនិងទុក្ខទេ ព្រះអង្គត្រាស់ថា ម្នាលតិម្ពរុក តថាគតមិនមែនជាមិនស្គាល់មិនឃើញសេចក្ដីសុខនិងទុក្ខទេ ម្នាលតិម្ពរុក តថាគតស្គាល់សេចក្ដីសុខនិងទុក្ខដោយពិត ម្នាលតិម្ពរុក តថាគតឃើញសេចក្ដីសុខនិងទុក្ខដោយពិត សូមព្រះគោតមដ៏ចម្រើន ប្រាប់សេចក្ដីសុខនិងទុក្ខដល់ខ្ញុំព្រះអង្គផង សូមព្រះគោតមដ៏ចម្រើន សំដែងសេចក្ដីសុខនិងទុក្ខដល់ខ្ញុំព្រះអង្គផង ។

[៤៩] ម្នាលតិម្ពរុក កាលបើមានសេចក្ដីយល់ឃើញខាងដើមថា វេទនានោះ ក៏គឺអ្នកនោះទទួល ដូច្នេះ លទ្ធិថា សេចក្ដីសុខនិងទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង ក៏និងមាន ឯតថាគតមិនពោលយ៉ាងនេះទេ ។ ម្នាលតិម្ពរុក កាលបើមានសេចក្ដីយល់ឃើញខាងដើមថា វេទនាដទៃ អ្នកដទៃទទួល ដូច្នេះ បុគ្គលដែលត្រូវវេទនាគ្របសង្កត់ ក៏និងមានលទ្ធិថា សេចក្ដីសុខនិងទុក្ខ គឺអ្នកដទៃធ្វើឲ្យ ឯតថាគតមិនពោលយ៉ាងនេះទេ ។ ម្នាលតិម្ពរុក តថាគតមិនប្រកាន់នូវទីបំផុតទាំងពីរនុ៎ះឡើយ តែងសំដែងធម៌ដោយបទកណ្ដាលថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ការរលត់នៃសង្ខារ ព្រោះការវិនាស

សង្ខារនិរោធា វិញ្ញាណនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

(៩៦) ឯវំ វុត្តេ តិម្ពរុក្ខោ បរិព្វាជកោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឯសាហំ ភគវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

អដ្ឋមំ ។

(៩៧) សាវត្ថិយំ វិហរតិ... អវិជ្ជានីវរណស្ស ភិក្ខវេ ពាលស្ស តណ្ហាយ សំយុត្តស្ស ឯវមយំ កាយោ សមុទាគតោ ឥតិ អយញ្ចេវ កាយោ ពហិទ្ធា ច នាមរូបំ ឥត្ថេតំ ទ្វយំ ទ្វយំ បដិច្ច ផស្សោ សឡេវាយតនានិ យេហិ ផុដ្ឋោ ពាលោ សុខទុក្ខំ

និងការរលត់ផុតសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(៩៦) លុះព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ តិម្ពរុកបរិព្វាជក ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវសរណគមន៍ស្មើដោយជីវិត តាំងអំពីថ្ងៃនេះទៅ ។ ចប់សូត្រ ទី ៨ ។

(៩៧) ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ដែលមានអវិជ្ជាជាគ្រឿងកំបាំង ដែលប្រកបដោយតណ្ហា រមែងមានកាយគឺបដិសន្ធិនេះ កើតឡើងយ៉ាងនេះឯង(១) ដ្បិត ផស្សៈ រមែងកើតឡើងព្រោះអាស្រ័យនូវធម៌ជាគូ ១ នឹងគ្នានុ៎ះ យ៉ាងនេះ គឺកាយនេះផង(២) នាមរូបខាងក្រៅផង(៣) បុគ្គលពាលដែលផស្សាយតនៈ(៤) ទាំង ៦

---

១ អដ្ឋកថាចារ្យ លោកពន្យល់ថា កាយកើតឡើងដោយសារអវិជ្ជានិងតណ្ហា ។ ២ បានខាងកាយមានវិញ្ញាណរបស់ខ្លួនឯង ។ ៣ បានខាងកាយមានវិញ្ញាណរបស់អ្នកដទៃ ។ ៤ សំដៅយកអាយតនៈ ៦ ទាំងខាងក្នុងទាំងខាងក្រៅ ។

បដិសំវេទយតិ ឯតេសំ វា អញ្ញតរេន ។ អវិជ្ជានីវរណស្ស ភិក្ខវេ បណ្ឌិតស្ស តណ្ហាយ សំយុត្តស្ស ឯវមយំ កាយោ សមុទាគតោ ឥតិ អយញ្ចេវ កាយោ ពហិទ្ធា ច នាមរូបំ ឥត្ថេតំ ទ្វយំ ទ្វយំ បដិច្ច ផស្សោ សឡេវាយតនានិ យេហិ ផុដ្ឋោ បណ្ឌិតោ សុខទុក្ខំ បដិសំវេទយតិ ឯតេសំ វា អញ្ញតរេន ។

(៥៨) តត្រ ភិក្ខវេ កោ វិសេសោ កោ អធិប្បាយសោ កិន្នានាករណំ បណ្ឌិតស្ស ពាលេនាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។

ឬក៏ បណ្តាផស្សាយតនៈទាំងនោះ ណាមួយ ពាល់ត្រូវហើយ រមែងទទួលនូវសុខនិងទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិត ដែលមានអវិជ្ជាជាគ្រឿងពាំង ដែលប្រកបដោយតណ្ហា រមែងមានកាយនេះកើតឡើងយ៉ាងនេះឯង ដ្បិត ផស្សៈរមែងកើតឡើង ព្រោះអាស្រ័យនូវធម៌ជាគូ ៗ នឹងគ្នានុ៎ះ យ៉ាងនេះ គឺកាយនេះផង នាមរូបខាងក្រៅផង បុគ្គលជាបណ្ឌិត ដែលផស្សាយតនៈទាំង ៦ ឬក៏ បណ្តាផស្សាយតនៈទាំងនុ៎ះ ណាមួយ ពាល់ត្រូវហើយ រមែងទទួលនូវសុខនិងទុក្ខ ។

(៥៨) ម្នាលភិក្ខុទាំងឡាយ កងដំណើរនោះ បណ្ឌិតនិងពាល តើមានសេចក្តីវិសេសដូចម្តេច មានសេចក្តីអធិប្បាយដូចម្តេច មានសេចក្តីផ្សេងគ្នាដូចម្តេច ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ (នេះ) មានព្រះមានព្រះភាគជាឫសគល់ មានព្រះមានព្រះភាគ ជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹង របស់យើងខ្ញុំ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំសូមអង្វរសូមព្រះមានព្រះភាគ បំភ្លឺនូវសេចក្តីនៃភាសិតនុ៎ះ ដល់ខ្ញុំព្រះអង្គឲ្យបាន ភិក្ខុទាំងឡាយ បានស្តាប់ព្រះមានព្រះភាគហើយ នឹងចងចាំទុក ។

តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(៥៩) ភគវា ឯតទវោច យាយ ច ភិក្ខវេ អវិជ្ជាយ និវុតស្ស ពាលស្ស យាយ ច តណ្ហាយ សំយុត្តស្ស អយំ កាយោ សមុទាគតោ សា ចេវ អវិជ្ជា ពាលស្ស អប្បហីនា សា ច តណ្ហា អបរិក្ខីណា តំ កិស្ស ហេតុ ន ហិ ភិក្ខវេ ពាលោ អចរិ ព្រហ្មចរិយំ សម្មា ទុក្ខក្ខយាយ តស្មា ពាលោ កាយស្ស ភេទា កាយូបគោ ហោតិ សោ កាយូបគោ សមានោ ន បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។ យាយ ច ភិក្ខវេ អវិជ្ជាយ និវុតស្ស បណ្ឌិតស្ស យាយ ច តណ្ហាយ សំយុត្តស្ស អយំ កាយោ សមុទាគតោ សា ចេវ អវិជ្ជា បណ្ឌិតស្ស បហីនា

ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយប្រុងចាំស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

(៤៩) ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ដែលអវិជ្ជាណាបិទបាំងទុកផង ដែលតណ្ហាណាប្រកបទុកផង ទើបកាយនេះកើតឡើង បុគ្គលពាលមិនបានលះបង់អវិជ្ជានោះផង មិនទាន់អស់តណ្ហានោះផង ដំណើរនោះ តើព្រោះហេតុដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលពាល មិនបានប្រព្រឹត្តមគ្គព្រហ្មចរិយៈ ដើម្បីការអស់នៃទុក្ខដោយប្រពៃទេ ព្រោះហេតុនោះ បុគ្គលពាល លុះបែកធ្លាយពងកាយទៅហើយ ក៏ចូលទៅកាន់បដិសន្ធិកាយ (ផ្សេងទៀត) កាលបុគ្គលពាលនោះ ចូលទៅកាន់បដិសន្ធិកាយ (ផ្សេងទៀត) រមែងមិនរួចស្រឡះ ចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយលំបាកចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត តថាគតពោលថាបុគ្គលពាលនោះ មិនរួចស្រឡះចាកវដ្តទុក្ខឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិត ដែលអវិជ្ជាណាបិទបាំងទុកផង ដែលតណ្ហាណាប្រកបទុកផង ទើបកាយនេះកើតឡើង តែបុគ្គលជាបណ្ឌិត បានលះបង់អវិជ្ជានោះ

សា ច តណ្ហា បរិក្ខីណា តំ កិស្ស ហេតុ អចរិ ភិក្ខវេ បណ្ឌិតោ ព្រហ្មចរិយំ សម្មា ទុក្ខក្ខយាយ តស្មា បណ្ឌិតោ កាយស្ស ភេទា ន កាយូបគោ ហោតិ សោ អកាយូបគោ សមានោ បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ(១) ឥទំ នានាករណំ បណ្ឌិតស្ស ពាលេន យទិទំ ព្រហ្មចរិយវាសោតិ ។ នវមំ ។

(២០) សាវត្ថិយំ វិហរតិ... បដិច្ចសមុប្បាទញ្ច វោ ភិក្ខវេ ទេសេស្សាមិ បដិច្ចសមុប្បន្នេ ច ធម្មេ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

---

១ ម.ម. អធិប្បាយោ ។

ចេញផង ធ្វើឲ្យអស់តណ្ហានោះផង ដំណើរនោះ ព្រោះហេតុដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះ បណ្ឌិតបានប្រព្រឹត្តមគ្គព្រហ្មចរិយៈ ដើម្បីការអស់នៃទុក្ខដោយប្រពៃ ព្រោះហេតុនោះ បណ្ឌិត លុះបែកធ្លាយរាងកាយទៅហើយ មិនចូលទៅកាន់បដិសន្ធិកាយទៀតឡើយ កាលបណ្ឌិតនោះ មិនបានចូលទៅកាន់បដិសន្ធិកាយទៀត រមែងរួចស្រឡះចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត តថាគតពោលថា បណ្ឌិតនោះ រមែងរួចស្រឡះចាកទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ ការប្រព្រឹត្តមគ្គព្រហ្មចរិយៈណា នេះឯង ជាសេចក្តីវិសេស នេះឯង ជាសេចក្តីអធិប្បាយ នេះឯងជាសេចក្តីផ្សេងគ្នា នៃបណ្ឌិតនិងពាល ។ ចប់សូត្រ ទី ៩ ។

[ ៦០ ] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវបដិច្ចសមុប្បាទធម៌ផង(១) នូវបដិច្ចសមុប្បន្នធម៌(២) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយប្រុងស្តាប់នូវសេចក្តីនោះ ចូរយកចិត្តទុកដាក់ដោយប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

១ ការកើតឡើងនៃហេតុព្រោះអាស្រ័យគ្នា ក្នុងទីនេះសំដៅយកបច្ច័យមានអវិជ្ជាជាដើម ។

២ សភាវធម៌ដែលកើតឡើងហើយ ព្រោះអាស្រ័យបច្ច័យ ។

(៦១) ភគវា ឯតទវោច កតមោ ច ភិក្ខវេ បដិច្ចសមុប្បាទោ ជាតិប្បច្ចយា ភិក្ខវេ ជរាមរណំ ឧប្បា-ទា វា តថាគតានំ អនុប្បាទា វា តថាគតានំ ឋិតា វ សា ធាតុ ធម្មដ្ឋិតតា ធម្មនិយាមតា ឥទប្បច្ចយតា តំ តថាគតោ អភិសម្ពុជ្ឈតិ អភិសមេតិ អភិសម្ពុជ្ឈិត្វា អភិសមេត្វា អាចិក្ខតិ ទេសេតិ បញ្ញាបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានីករោតិ បស្សថាតិ ចាហ ។ ជាតិប្បច្ចយា ភិក្ខវេ ជរាមរណំ ។ បេ ។ ភវប្បច្ចយា ភិក្ខវេ ជាតិ ... ឧបាទានប្បច្ចយា ភិក្ខវេ ភវោ ... តណ្ហាបច្ចយា ភិក្ខវេ ឧបាទានំ ... វេទនាបច្ចយា ភិក្ខវេ តណ្ហា ... ផស្សប្បច្ចយា ភិក្ខវេ វេទនា ...

(៦១) ព្រះមានព្រះភាគទ្រង់ត្រាស់ ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះបដិច្ចសមុប្បាទធម៌ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ព្រះតថាគតកើតឡើងក្ដី ព្រះតថាគតមិនទាន់កើតឡើងក្ដី ធាតុ[១]នោះ ធម្មដ្ឋិតិ[២]នោះ ធម្មនិយាម[៣]នោះ ឥទប្បច្ច័យ[៤]នោះ តែងឋិតនៅជាធម្មតា តថាគត ត្រាស់ដឹង យល់ច្បាស់នូវបច្ច័យនោះ លុះត្រាស់ដឹង យល់ច្បាស់ហើយ ទើបប្រាប់ សំដែង ពន្យល់ តែងតាំង បើកបង្ហាញ ចែករំលែក ធ្វើឲ្យរាក់ ហើយប្រាប់ថែមថា អ្នកទាំងឡាយ ចូរមើលចុះ ។ ម្នាលភិក្ខុទាំងឡាយ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ជាតិកើតមាន ព្រោះភពជាបច្ច័យ ... ម្នាលភិក្ខុទាំងឡាយ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ... ម្នាលភិក្ខុទាំងឡាយ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ... ម្នាលភិក្ខុទាំងឡាយ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ... ម្នាលភិក្ខុទាំងឡាយ វេទនាកើតមាន ព្រោះផស្សៈ

---

១ សភាពនៃធម៌ដែលជាគូបច្ច័យ ហៅថា ធាតុ ។ ២ ធម៌កើតឡើងអំពីបច្ច័យ អាស្រ័យគ្នាហើយឋិតនៅ ហៅថា ធម្មដ្ឋិតិ ។ ៣ បច្ច័យដែលកំណត់នូវធម៌ ហៅថា ធម្មនិយាម ។ ៤ បច្ច័យនៃធម៌មានជរាមរណៈ ជាដើមនេះ ហៅថា ឥទប្បច្ច័យ ។

សឡាយតនប្បច្ចយា ភិក្ខវេ ផស្សោ ... នាមរូបប្បច្ច-យា ភិក្ខវេ សឡាយតនំ ... វិញ្ញាណប្បច្ចយា ភិក្ខវេ នាមរូបំ ... សង្ខារប្បច្ចយា ភិក្ខវេ វិញ្ញាណំ ... អវិជ្ជា-បច្ចយា ភិក្ខវេ សង្ខារា ឧប្បាទា វា តថាគតានំ អនុប្បាទា វា តថាគតានំ ឋិតា វ សា ធាតុ ធម្មដ្ឋិតតា ធម្មនិយាមតា ឥទប្បច្ចយតា តំ តថាគតោ អភិសម្ពុជ្ឈតិ អភិសមេតិ អភិសម្ពុជ្ឈិត្វា អភិសមេត្វា អាចិក្ខតិ ទេសេតិ បញ្ញាបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានីករោតិ បស្សថាតិ ចាហ ។ អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា ។ ឥតិ ខោ ភិក្ខវេ យា តត្រ តថតា អវិតថតា អនញ្ញថតា ឥទប្បច្ចយតា អយំ វុច្ចតិ ភិក្ខវេ បដិច្ចសមុប្បាទោ ។

ជាបច្ច័យ ... ម្នាលភិក្ខុទាំងឡាយ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ... ម្នាលភិក្ខុទាំងឡាយ សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ... ម្នាលភិក្ខុទាំងឡាយ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ... ម្នាលភិក្ខុទាំងឡាយ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ... ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ព្រះតថាគតកើតឡើងក្តី ព្រះតថាគតមិនទាន់កើតឡើងក្តី ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ ឥទប្បច្ច័យនោះ តែងឋិតនៅជាធម្មតា តថាគត ត្រាស់ដឹង យល់ច្បាស់ នូវបច្ច័យនោះ លុះត្រាស់ដឹង យល់ច្បាស់ហើយ ទើបប្រាប់ សំដែង ពន្យល់ តែងតាំង បើកបង្ហាញ ចែករំលែក ធ្វើឲ្យរាក់ ហើយប្រាប់ថែមថា អ្នកទាំងឡាយចូរមើលចុះ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណា ជារបស់ពិតទៀងទាត់ មិនប្រែប្រួល មានសភាវៈនេះជាបច្ច័យ ក្នុងធម៌នោះ ម្នាលភិក្ខុទាំងឡាយ នេះហៅថាបដិច្ចសមុប្បាទធម៌ ដោយប្រការដូច្នេះឯង ។

[៦២] កតមេ ច ភិក្ខវេ បដិច្ចសមុប្បន្នា ធម្មា ជរាមរណំ ភិក្ខវេ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ ។ ជាតិ ភិក្ខវេ អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មា ។ ភវោ ភិក្ខវេ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ ខយធម្មោ វយធម្មោ វិរាគធម្មោ និរោធធម្មោ ។ ឧបាទានំ ភិក្ខវេ ។បេ។ តណ្ហា ភិក្ខវេ... វេទនា ភិក្ខវេ... ផស្សោ ភិក្ខវេ... សឡាយតនំ ភិក្ខវេ... នាមរូបំ ភិក្ខវេ... វិញ្ញាណំ ភិក្ខវេ... សង្ខារា ភិក្ខវេ... អវិជ្ជា ភិក្ខវេ អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មា ។ ឥមេ វុច្ចន្តិ ភិក្ខវេ បដិច្ចសមុប្បន្នា ធម្មា ។

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ ចុះបដិច្ចសមុប្បន្នធម៌ទាំងឡាយ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ជរាមរណៈ មិនទៀង ជាធម្មជាតដែលបច្ច័យប្រជុំតាក់តែង កើតព្រោះអាស្រ័យបច្ច័យ ជាធម្មជាតតែងអស់ជាធម្មតា សូន្យជាធម្មតា វិនាសជាធម្មតា រលត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ជាតិ មិនទៀង ជាធម្មជាតិដែលបច្ច័យប្រជុំតាក់តែង កើតព្រោះអាស្រ័យបច្ច័យ ជាធម្មជាតិតែងអស់ជាធម្មតា សូន្យជាធម្មតា វិនាសជាធម្មតា រលត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភព មិនទៀង ជាសភាវៈដែលបច្ច័យប្រជុំតាក់តែង កើតព្រោះអាស្រ័យបច្ច័យ ជាសភាវៈតែងអស់ជាធម្មតា សូន្យជាធម្មតា វិនាសជាធម្មតា រលត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ឧបាទាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តណ្ហា ... ម្នាលភិក្ខុទាំងឡាយ វេទនា ... ម្នាលភិក្ខុទាំងឡាយ ផស្សៈ ... ម្នាលភិក្ខុទាំងឡាយ សឡាយតនៈ ... ម្នាលភិក្ខុទាំងឡាយ នាមរូប ... ម្នាលភិក្ខុទាំងឡាយ វិញ្ញាណ ... ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ ... ម្នាលភិក្ខុទាំងឡាយ អវិជ្ជា មិនទៀង ជាធម្មជាតិដែលបច្ច័យប្រជុំតាក់តែង កើតព្រោះអាស្រ័យបច្ច័យ ជាធម្មជាតិតែងអស់ជាធម្មតា សូន្យជាធម្មតា វិនាសជាធម្មតា រលត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងនេះហៅថា បដិច្ចសមុប្បន្នធម៌ ។

(៦៣) យតោ ខោ ភិក្ខវេ អរិយសាវកស្ស អយញ្ច បដិច្ចសមុប្បាទោ ឥមេ ច បដិច្ចសមុប្បន្នា ធម្មា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ សោ វត បុព្វន្តំ វា ឧបធាវិស្សតិ[១] អហោសឹ នុ ខោ អហំ អតីតមទ្ធានំ ននុ ខោ អហោសឹ អតីតមទ្ធានំ កឹ នុ ខោ អហោសឹ អតីតមទ្ធានំ កថំ នុ ខោ អហោសឹ អតីតមទ្ធានំ កឹ ហុត្វា កឹ អហោសឹ នុ ខោ អហំ អតីតមទ្ធានន្តិ អបរន្តំ វា ឧបធាវិស្សតិ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ ននុ ខោ ភវិស្សាមិ អនាគតមទ្ធានំ កឹ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ កថំ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ កឹ ហុត្វា កឹ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានន្តិ ឯតរហិ វា បច្ចុប្បន្នំ អទ្ធានំ អជ្ឈត្តំ កថំកថី ភវិស្សតិ អហំ នុ ខោស្មិ នោ នុ ខោស្មិ កឹ នុ ខោស្មិ កថំ នុ ខោស្មិ អយំ នុ ខោ សត្តោ កុតោ អាគតោ សោ កុហឹ គាមី ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ តំ កិស្ស ហេតុ

១ ឱ. ម. បដិធាវិស្សតិ ។

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ កាលណា អរិយសាវ័កបានឃើញនូវបដិច្ចសមុប្បាទធម៌នេះផង នូវបដិច្ចសមុប្បន្នធម៌នេះផង ដោយប្រពៃ ដោយប្រាជ្ញាដ៏ឧត្តមតាមពិត អរិយសាវ័កនោះ នឹងពិចារណារកទីបំផុតខាងដើម គឺខន្ធក្នុងអតីតកាលថា អាត្មាអញបានកើតហើយក្នុងអតីតកាលដែរឬហ្ន៎ អាត្មាអញមិនបានកើតក្នុងអតីតកាលទេឬហ្ន៎ អាត្មាអញបានកើតហើយក្នុងអតីតកាល ដូចម្តេចហ្ន៎ អាត្មាអញបានកើតហើយក្នុងអតីតកាល ដោយប្រការដូចម្តេចហ្ន៎ អាត្មាអញកើតជាអ្វី ហើយបានកើតជាអ្វី ក្នុងអតីតកាលហ្ន៎ ដូច្នេះក្តី ពិចារណារកនូវទីបំផុតខាងចុង គឺខន្ធក្នុងអនាគតកាលថា អាត្មាអញនឹងកើតក្នុងអនាគតកាលដែរឬហ្ន៎ អាត្មាអញនឹងមិនកើតក្នុងអនាគតកាលទេឬហ្ន៎ អាត្មាអញនឹងកើតក្នុងអនាគត-កាលដូចម្តេចហ្ន៎ អាត្មាអញនឹងកើតក្នុងអនាគតកាល ដោយប្រការដូចម្តេចហ្ន៎ អាត្មាអញនឹងកើតជាអ្វី ហើយកើតជាអ្វី ទៅក្នុងអនាគតកាលហ្ន៎ ដូច្នេះក្តី នឹងមានសេចក្តីងឿងឆ្ងល់ ចំពោះខន្ធខាងក្នុង ( ខន្ធរបស់ខ្លួន ) ក្នុងបច្ចុប្បន្នកាលឥឡូវនេះថា អាត្មាអញមានដែរឬហ្ន៎ អាត្មាអញមិនមានទេឬហ្ន៎ អាត្មាអញមានដូចម្តេចហ្ន៎ អាត្មាអញមានដោយប្រការដូចម្តេចទៅហ្ន៎ សត្វនេះមកពីណាហ្ន៎ សត្វនោះនឹងទៅកើតក្នុងទីណាហ្ន៎ ដូច្នេះក្តី ហេតុនេះរមែងមិនមានឡើយ ដំណើរនោះ តើព្រោះហេតុ

តថា ហិ ភិក្ខវេ អរិយសាវកស្ស អយញ្ច បដិច្ច-សមុប្បាទោ ឥមេ ច បដិច្ចសមុប្បន្នា ធម្មា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋាតិ ។ ទសមំ ។

អាហារវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

អាហារផគ្គុនញ្ចេវ
ទ្វេ ច សមណព្រាហ្មណា
កច្ចានគោត្តំ ធម្មកថិកំ
អចេលំ តិម្ពរុកេន ច
ពាលបណ្ឌិតញ្ចេវ(១)
ទសមោ បច្ចយេន ចាតិ ។

១ ឱ.ម. ពាលេន បណ្ឌិតោ ចេវ ។

ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថា ព្រះអរិយសាវកបានឃើញនូវបដិច្ចសមុប្បាទធម៌នេះផង នូវបដិច្ចសមុប្បន្នធម៌នេះផង ដោយប្រពៃដោយប្រាជ្ញាដ៏ឧត្តមតាមពិត ។ ចប់សូត្រ ទី ១០ ។

ចប់ អាហារវគ្គ ទី ២ ។

## បញ្ជីនៃអាហារវគ្គនោះ គឺ

និយាយអំពីអាហារ ១ អំពីមោលិយផគ្គុន ១ អំពីសមណៈនិងព្រាហ្មណ៍ ២ លើក អំពីកច្ចានគោត្រ ១ អំពីធម្មកថិក ១ អំពីអចេលកស្សប ១ អំពីតិម្ពរុកបរិព្វាជក ១ អំពីពាលនិងបណ្ឌិត ១ អំពីបច្ច័យ ១ ត្រូវជា ១០ ។

# ទសពលវគ្គោ

(២១) សាវត្ថិយំ វិហរតិ... ទសពលសមន្នាគតោ ភិក្ខវេ តថាគតោ ចតូហិ ច វេសារជ្ជេហិ សមន្នាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ឥតិ វេទនាយ សមុទយោ ឥតិ វេទនាយ អត្ថង្គមោ ឥតិ សញ្ញា ឥតិ សញ្ញាយ សមុទយោ ឥតិ សញ្ញាយ អត្ថង្គមោ ឥតិ សង្ខារា ឥតិ សង្ខារានំ សមុទយោ ឥតិ សង្ខារានំ អត្ថង្គមោ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា

## ទសពលវគ្គ

(៦៤) ព្រះមានព្រះភាគ ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតប្រកបដោយកម្លាំង ១០ ផង ប្រកបដោយវេសារជ្ជធម៌[១] ៤ ផង រមែងប្តេជ្ញានូវឋានៈដ៏ប្រសើរ បន្លឺនូវសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅថា រូបដូច្នេះ ហេតុជាទីកើតឡើងនៃរូបដូច្នេះ សេចក្តីរលត់នៃរូបដូច្នេះ វេទនាដូច្នេះ ហេតុជាទីកើតឡើងនៃវេទនាដូច្នេះ សេចក្តីរលត់នៃវេទនាដូច្នេះ សញ្ញាដូច្នេះ ហេតុជាទីកើតឡើងនៃសញ្ញាដូច្នេះ សេចក្តីរលត់នៃសញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ ហេតុជាទីកើតឡើង នៃសង្ខារទាំងឡាយដូច្នេះ សេចក្តីរលត់នៃសង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ហេតុជាទីកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្តីរលត់នៃវិញ្ញាណដូច្នេះ កាលបើធម្មជាតនេះមាន ធម្មជាតនេះក៏មានដែរ ព្រោះការកើតឡើងនៃធម្មជាតនេះ ទើបធម្មជាតនេះកើតឡើងដែរ កាលបើធម្មជាតនេះមិនមាន ធម្មជាតនេះក៏មិនមានដែរ ព្រោះការរលត់ទៅនៃធម្មជាតនេះ ទើបធម្មជាតនេះរលត់ទៅដែរ គឺថាសង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ

---

១ សេចក្តីក្លៀវក្លា ។

សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ បឋមំ ។

[៦៥] សាវត្ថិយំ វិហរតិ... ទសពលសមន្នាគតោ ភិក្ខវេ តថាគតោ ចតូហិ ច វេសារជ្ជេហិ សមន្នាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ឥតិ វេទនាយ សមុទយោ ឥតិ វេទនាយ អត្ថង្គមោ ឥតិ សញ្ញា ឥតិ សញ្ញាយ សមុទយោ ឥតិ សញ្ញាយ អត្ថង្គមោ ឥតិ សង្ខារា ឥតិ សង្ខារានំ សមុទយោ ឥតិ សង្ខារានំ អត្ថង្គមោ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ

វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ការរលត់នៃសង្ខារព្រោះការវិនាសនិងការរលត់មិនសេសសល់ នៃអវិជ្ជា ការរលត់នៃវិញ្ញាណព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ១ ។

(៦៥) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតប្រកបដោយកម្លាំង ១០ ផង ប្រកបដោយវេសារជ្ជធម៌ ៤ ផង រមែងប្តេជ្ញានូវឋានៈប្រសើរ បន្លឺនូវសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅថា រូបដូច្នេះ ហេតុជាទីកើតឡើងនៃរូបដូច្នេះ សេចក្តីរលត់នៃរូបដូច្នេះ វេទនាដូច្នេះ ហេតុជាទីកើតឡើងនៃវេទនាដូច្នេះ សេចក្តីរលត់នៃវេទនាដូច្នេះ សញ្ញាដូច្នេះ ហេតុជាទីកើតឡើងនៃសញ្ញាដូច្នេះ សេចក្តីរលត់នៃសញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ ហេតុជាទីកើតឡើងនៃសង្ខារទាំងឡាយដូច្នេះ សេចក្តីរលត់នៃសង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ហេតុជាទីកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្តីរលត់នៃវិញ្ញាណដូច្នេះ កាលបើធម្មជាតនេះមាន ធម្មជាតនេះក៏មានដែរ ព្រោះការកើតឡើងនៃធម្មជាតនេះ ទើបធម្មជាតនេះកើតឡើងដែរ

ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ។

(២២) ឯវំ ស្វាក្ខាតោ ភិក្ខវេ មយា ធម្មោ ឧត្តានោ វិវដោ បកាសិតោ ឆិន្នបិលោតិកោ ។ ឯវំ ស្វាក្ខាតេ ខោ ភិក្ខវេ មយា ធម្មេ ឧត្តានេ វិវដេ បកាសិតេ ឆិន្នបិលោតិកេ អលមេវ សទ្ធាបព្វជិតេន កុលបុត្តេន វីរិយំ អារភិតុំ កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ សរីរេ ឧបសុស្សតុ មំសលោហិតំ យន្តំ បុរិសត្ថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបាបុណិត្វា

កាលបើធម្មជាតនេះមិនមាន ធម្មជាតនេះក៏មិនមានដែរ ព្រោះការរលត់នៃធម្មជាតនេះ ទើបធម្មជាតនេះរលត់ដែរ គឺថាសង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រម នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

[៦៦] ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតសំដែងហើយដោយប្រពៃ តថាគត បានបើក បានប្រកាស ឲ្យផ្សាយ ដូចជាកំណាត់សំពត់ដែលគេកាត់ហើយ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែលតថាគតសំដែងហើយដោយប្រពៃ តថាគត បានបើក បានប្រកាស ឲ្យផ្សាយ ដូចជាកំណាត់សំពត់ដែលគេកាត់ហើយ យ៉ាងនេះ កុលបុត្តដែលបួសហើយព្រោះសទ្ធា គួរតែប្រារព្ធ នូវសេចក្ដីព្យាយាម (ប្រកបដោយអង្គ ៤) ថា ស្បែក ១ សរសៃ ១ ឆ្អឹង ១ ចូរសល់នៅចុះ ឯសាច់ឈាមក្នុងសរីរៈ ចូររីងស្ងួតទៅចុះ គុណជាតណា ដែលបុគ្គលគប្បីដល់ដោយកម្លាំងរបស់បុរស ដោយសេចក្ដីព្យាយាម របស់បុរស ដោយសេចក្ដីប្រឹងប្រែងរបស់បុរស បើមិនទាន់ដល់នូវគុណជាតនោះទេ

បុរិសស្ស វីរិយស្ស សណ្ឋានំ ភវិស្សតីតិ ។ ទុក្ខំ ភិក្ខវេ កុសីតោ វិហរតិ វោកិណ្ណោ បាបកេហិ អកុសលេហិ ធម្មេហិ មហន្តញ្ច សទត្ថំ បរិហាបេតិ ។ អារទ្ធវីរិយោ ច ខោ ភិក្ខវេ សុខំ វិហរតិ បវិវិត្តោ បាបកេហិ អកុសលេហិ ធម្មេហិ មហន្តញ្ច សទត្ថំ បរិបូរេតិ ។ ន ភិក្ខវេ ហីនេន អគ្គស្ស បត្តិ ហោតិ អគ្គេន ច ខោ(១) អគ្គស្ស បត្តិ ហោតិ ។ មណ្ឌបេយ្យមិទំ ភិក្ខវេ ព្រហ្មចរិយំ សត្ថា សម្មុខីភូតោ ។

១ ឱ. ម. អគ្គេន ច ខោ ភិក្ខវេ ។

នឹងមិនបញ្ជប់នូវសេចក្ដីព្យាយាមរបស់បុរសឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្ជិលច្រអូស រមែងច្រឡូកច្រឡំដោយអកុសលធម៌ដ៏លាមក នៅជាទុក្ខ ថែមទាំងញ៉ាំងប្រយោជន៍នៃខ្លួនដ៏ធំឲ្យសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលដែលមានព្យាយាមតឹងរឹង រមែងស្ងប់ស្ងាត់ចាកអកុសលធម៌ដ៏លាមក នៅជាសុខ ថែមទាំងញ៉ាំងប្រយោជន៍នៃខ្លួនដ៏ធំឲ្យបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ ការដល់នូវគុណវិសេសដ៏ខ្ពង់ខ្ពស់[១] ដោយឥន្ទ្រិយដ៏ថោកទាប[២] រមែងមិនមានទេ ការដល់នូវគុណវិសេសដ៏ខ្ពង់ខ្ពស់ ដោយឥន្ទ្រិយដ៏ខ្ពង់ខ្ពស់ទើបមាន ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះ ជាធម្មជាតជ្រះថ្លាគួរក្រេបផឹក ព្រោះព្រះសាស្ដាមាននៅចំពោះមុខ ។

---

១ សំដៅយកព្រះអរហត្តផល ។ ២ សំដៅយកឥន្ទ្រិយទាំង ៥ មានសទ្ធាជាដើម ។

(៦៧) តស្មាតិហ ភិក្ខវេ វីរិយំ អារភថ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឯវំ នោ អយំ អម្ហាកំ បព្វជ្ជា អវំកតា អវញ្ឈា ភវិស្សតិ សផលា សឧទ្រយា យេសំ(១) មយំ បរិភុញ្ជាម ចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារំ តេសំ តេ ការា អម្ហេសុ មហប្ផលា ភវិស្សន្តិ មហានិសំសាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ អត្តត្ថំ វា ហិ ភិក្ខវេ សម្បស្សមានេន អលមេវ អប្បមាទេន សម្បាទេតុំ ។ បរត្ថំ វា ហិ ភិក្ខវេ សម្បស្សមានេន អលមេវ អប្បមាទេន សម្បាទេតុំ ។ ឧភយត្ថំ វា ហិ ភិក្ខវេ សម្បស្សមានេន អលមេវ អប្បមាទេន សម្បាទេតុន្តិ ។ ទុតិយំ ។

---

១ ម. យេសញ្ហិ ។

( ៦៧ ) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីការដល់នូវគុណធម៌ដែលមិនទាន់បានដល់ ដើម្បីការត្រាស់ដឹងនូវគុណធម៌ដែលមិនទាន់បានត្រាស់ដឹង ដើម្បីការធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ក្នុងសាសនានេះ ដោយគិតយ៉ាងនេះថា បព្វជ្ជារបស់យើងទាំងឡាយនេះ មិនមែនទទេ មិនមែនឥតផលទេ រមែងប្រកបដោយផល ប្រកបដោយសេចក្តីចម្រើន ព្រោះថា យើងទាំងឡាយ បរិភោគ នូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ របស់ជនទាំងឡាយណា ការបូជាទាំងនោះ ចំពោះយើងទាំងឡាយ របស់ជនទាំងនោះ នឹងមានផលច្រើន មានអានិសង្សច្រើន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សា យ៉ាងនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន គួរតែញុំាងកិច្ចទាំងពួងឲ្យបរិបូណ៌ដោយសេចក្តីមិនប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលឃើញច្បាស់ នូវប្រយោជន៍របស់បុគ្គលដទៃ គួរតែញុំាងកិច្ចទាំងពួងឲ្យបរិបូណ៌ ដោយសេចក្តីមិនប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលឃើញច្បាស់នូវប្រយោជន៍ទាំងពីរ គួរតែញុំាងកិច្ចទាំងពួងឲ្យបរិបូណ៌ ដោយសេចក្តីមិនប្រមាទ ។ ចប់សូត្រ ទី ២ ។

(២៨) សាវត្ថិយំ វិហរតិ ... ជានតោហំ ភិក្ខវេ បស្សតោ អាសវានំ ខយំ វទាមិ នោ អជានតោ នោ អបស្សតោ ។ កិញ្ច ភិក្ខវេ ជានតោ កឹ បស្សតោ អាសវានំ ខយោ ហោតិ ។ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ។ បេ ។ ឥតិ វេទនា ។ បេ ។ ឥតិ សញ្ញា ។ បេ ។ ឥតិ សង្ខារា ។ បេ ។ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ ឯវំ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អាសវានំ ខយោ ហោតិ ។

(២៩) យម្បិ តំ ភិក្ខវេ ខយស្មឹ ខយេ ញាណំ តម្បិ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ ខយេ ញាណស្ស ឧបនិសា ។

( ៦៨ ) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា កិរិយាអស់ទៅនៃអាសវៈ ចំពោះតែបុគ្គល ដែលដឹងច្បាស់ ឃើញច្បាស់ មិនពោល ចំពោះបុគ្គល ដែលមិនដឹងច្បាស់ មិនឃើញច្បាស់ទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលកាលដឹងអ្វី កាលឃើញអ្វី ទើបមានការអស់ទៅនៃអាសវៈ ។ បុគ្គលដឹងឃើញថា រូបដូច្នេះ ហេតុជាទីកើតឡើងនៃរូបដូច្នេះ សេចក្តីរលត់នៃរូបដូច្នេះ ។បេ។ វេទនាដូច្នេះ ។បេ។ សញ្ញាដូច្នេះ ។បេ។ សង្ខារទាំងឡាយដូច្នេះ ។បេ។ វិញ្ញាណដូច្នេះ ហេតុជាទីកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្តីរលត់នៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ទើបមានការអស់ទៅនៃអាសវៈ ។

( ៦៩ ) ម្នាលភិក្ខុទាំងឡាយ កាលធម៌(១)ជាគ្រឿងអស់ទៅនៃអាសវៈកើតឡើងហើយ ខយញ្ញាណ(២)ណា កើតឡើងដែរ តថាគតពោលថា ខយញ្ញាណនោះ ប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃខយញ្ញាណ តើដូចម្តេច ។

---

១ បានដល់អរហត្តផល ។ ២ សេចក្តីដឹងក្នុងធម៌ជាគ្រឿងអស់ទៅនៃអាសវៈ បានដល់បច្ចវេក្ខណញ្ញាណ ។

វិមុត្តីតិស្ស វចនីយំ ។ វិមុត្តិម្បហំ[១] ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ វិមុត្តិយា ឧបនិសា ។ វិរាគោតិស្ស វចនីយំ ។ វិរាគម្បហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ វិរាគស្ស ឧបនិសា ។ និព្វិទាតិស្ស វចនីយំ ។ និព្វិទម្បហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ និព្វិទាយ ឧបនិសា ។ យថាភូតញាណទស្សនន្តិស្ស វចនីយំ ។ យថាភូតញាណទស្សនម្បហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ យថាភូតញាណទស្សនស្ស ឧបនិសា ។ សមាធីតិស្ស វចនីយំ ។ សមាធិម្បហំ ភិក្ខវេ សឧបនិសំ វទាមិ

---

១ ឱ. ម. វិមុត្តិម្បហំ ។

គប្បីឆ្លើយថា វិមុត្តិគឺអរហត្តផល ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា វិមុត្តិប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃវិមុត្តិ តើដូចម្តេច ។ គប្បីឆ្លើយថា វិរាគៈគឺមគ្គ ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា វិរាគៈប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃវិរាគៈ តើដូចម្តេច ។ គប្បីឆ្លើយថា និព្វិទាញាណគឺពលវិបស្សនា[1]ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា និព្វិទាញាណប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃនិព្វិទាញាណ តើដូចម្តេច ។ គប្បីឆ្លើយថា យថាភូតញ្ញាណទស្សនៈគឺតរុណវិបស្សនា[2] ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា យថាភូតញ្ញាណទស្សនៈ ប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃយថាភូតញ្ញាណទស្សនៈ តើដូចម្តេច ។ គប្បីឆ្លើយថា សមាធិ ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សមាធិប្រកបដោយហេតុ

---

១ បានដល់ញាណទាំង ៤ គឺ ភយតូបដ្ឋានញ្ញាណ ១ អាទីនវានុបស្សនាញាណ ១ មុញ្ចិតុកម្យតាញាណ ១ សង្ខារុបេក្ខាញាណ ១ ។ ២ បានដល់ញាណទាំង ៤ គឺ សង្ខារបរិច្ឆេទញ្ញាណ ១ កង្ខាវិតរណញ្ញាណ ១ សម្មសនញ្ញាណ ១ មគ្គាមគ្គញ្ញាណ ១ ( អដ្ឋកថា ) ។

នោ អនុបនិសំ ។ កា ច ភិក្ខវេ សមាធិស្ស ឧបនិសា ។ សុខន្តិស្ស វចនីយំ ។ សុខម្បាហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ សុខស្ស ឧបនិសា ។ បស្សទ្ធីតិស្ស វចនីយំ ។ បស្សទ្ធិម្បាហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ បស្សទ្ធិយា ឧបនិសា ។ បីតីតិស្ស វចនីយំ ។ បីតិម្បាហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ បីតិយា ឧបនិសា ។ បាមុជ្ជន្តិស្ស វចនីយំ ។ បាមុជ្ជម្បាហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ បាមុជ្ជស្ស ឧបនិសា ។ សទ្ធាតិស្ស វចនីយំ ។ សទ្ធម្បាហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ សទ្ធាយ ឧបនិសា ។

មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃសមាធិ តើដូចម្តេច ។ គប្បីឆ្លើយថា សុខៈ ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សុខៈប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃសុខៈ តើដូចម្តេច ។ គប្បីឆ្លើយថា បស្សទ្ធិ ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បស្សទ្ធិប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃបស្សទ្ធិ តើដូចម្តេច ។ គប្បីឆ្លើយថា បីតិ ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បីតិប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃបីតិ តើដូចម្តេច ។ គប្បីឆ្លើយថា បាមុជ្ជៈ ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បាមុជ្ជៈប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃបាមុជ្ជៈ តើដូចម្តេច ។ គប្បីឆ្លើយថា សទ្ធា ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សទ្ធាប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃសទ្ធា តើដូចម្តេច ។

ទុក្ខន្តិស្ស វចនីយំ ។ ទុក្ខម្បាហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ ទុក្ខស្ស ឧបនិសា ។ ជាតីតិស្ស វចនីយំ ។ ជាតិម្បាហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ ជាតិយា ឧបនិសា ។ ភវោតិស្ស វចនីយំ ។ ភវម្បាហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ ភវស្ស ឧបនិសា ។ ឧបាទានន្តិស្ស វចនីយំ ។ ឧបាទានម្បាហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ ឧបាទានស្ស ឧបនិសា ។ តណ្ហាតិស្ស វចនីយំ ។ តណ្ហាម្បាហំ ភិក្ខវេ សឧបនិសំ វទាមិ នោ អនុបនិសំ ។ កា ច ភិក្ខវេ តណ្ហាយ ឧបនិសា ។ វេទនាតិស្ស វចនីយំ ។បេ។ ផស្សោតិស្ស វចនីយំ... សឡាយតនន្តិស្ស វចនីយំ... នាមរូបន្តិស្ស វចនីយំ... វិញ្ញាណន្តិស្ស វចនីយំ...

គប្បីឆ្លើយថា ទុក្ខ ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទុក្ខប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃទុក្ខ តើដូចម្តេច ។ គប្បីឆ្លើយថា ជាតិ ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ជាតិប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃជាតិ តើដូចម្តេច ។ គប្បីឆ្លើយថា ភព ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភពប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃភព តើដូចម្តេច ។ គប្បីឆ្លើយថា ឧបាទាន ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ឧបាទានប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃឧបាទាន តើដូចម្តេច ។ គប្បីឆ្លើយថា តណ្ហា ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា តណ្ហាប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃតណ្ហា តើដូចម្តេច ។ គប្បីឆ្លើយថា វេទនា ជាហេតុ ។ បេ ។ គប្បីឆ្លើយថា ផស្សៈ ជាហេតុ ... គប្បីឆ្លើយថា សឡាយតនៈ ជាហេតុ ... គប្បីឆ្លើយថា នាមរូប ជាហេតុ ... គប្បីឆ្លើយថា វិញ្ញាណ ជាហេតុ ...

សង្ខារាតិស្ស វចនីយំ ។ សង្ខារេបហំ ភិក្ខវេ សឧបនិសេ វទាមិ នោ អនុបនិសេ ។ កា ច ភិក្ខវេ សង្ខារានំ ឧបនិសា ។ អវិជ្ជាតិស្ស វចនីយំ ។ ឥតិ ខោ ភិក្ខវេ អវិជ្ជូបនិសា សង្ខារា សង្ខារូបនិសំ វិញ្ញាណំ វិញ្ញាណូបនិសំ នាមរូបំ នាមរូបូបនិសំ សឡាយតនំ សឡាយតនូបនិសោ ផស្សោ ផស្សូបនិសា វេទនា វេទនូបនិសា តណ្ហា តណ្ហូបនិសំ ឧបាទានំ ឧបាទានូបនិសោ ភវោ ភវូបនិសា ជាតិ ជាតូបនិសំ ទុក្ខំ ទុក្ខូបនិសា សទ្ធា សទ្ធូបនិសំ បាមុជ្ជំ បាមុជ្ជូបនិសា បីតិ បីតូបនិសា បស្សទ្ធិ បស្សទ្ធូបនិសំ សុខំ សុខូបនិសោ សមាធិ សមាធូបនិសំ យថាភូតញាណទស្សនំ យថាភូតញាណទស្សនូបនិសា និព្វិទា និព្វិទូបនិសោ វិរាគោ វិរាគូបនិសា វិមុត្តិ វិមុត្តូបនិសំ ខយេ ញាណំ ។

តប្បីឆ្លើយថា សង្ខារទាំងឡាយ ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សង្ខារទាំងឡាយប្រកបដោយហេតុ មិនពោលថា មិនមានហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនៃសង្ខារទាំងឡាយ តើដូចម្តេច ។ គប្បីឆ្លើយថា អវិជ្ជា ជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រែដូចនេះ សង្ខារទាំងឡាយមានអវិជ្ជាជាហេតុ វិញ្ញាណមាន សង្ខារជាហេតុ នាមរូបមានវិញ្ញាណជាហេតុ សឡាយតនៈមាននាមរូប ជាហេតុ ផស្សៈមានសឡាយតនៈជាហេតុ វេទនាមានផស្សៈជាហេតុ តណ្ហាមានវេទនាជាហេតុ ឧបាទានមានតណ្ហាជាហេតុ ភពមានឧបា-ទានជាហេតុ ជាតិមានភពជាហេតុ ទុក្ខមានជាតិជាហេតុ សទ្ធាមាន ទុក្ខជាហេតុ បាមុជ្ជៈមានសទ្ធាជាហេតុ បីតិមានបាមុជ្ជៈជាហេតុ បស្សទ្ធិ មានបីតិជាហេតុ សុខៈមានបស្សទ្ធិជាហេតុ សមាធិមានសុខៈជាហេតុ យថាភូតញាណទស្សនៈមានសមាធិជាហេតុ និព្វិទាញាណមានយថាភូត-ញាណទស្សនៈជាហេតុ វិរាគៈមាននិព្វិទាញាណជាហេតុ វិមុត្តិមាន វិរាគៈជាហេតុ ខយញាណ មានវិមុត្តិជាហេតុ ។

[៧០] សេយ្យថាបិ ភិក្ខវេ ឧបរិ បព្វតេ ថុល្លផុសិតកេ ទេវេ វស្សន្តេ តំ ឧទកំ យថានិន្នំ បវត្តមានំ បព្វតកន្ទរបទរសាខា បរិបូរេតិ បព្វតកន្ទរបទរសាខា បរិបូរា កុសុព្ភេ បរិបូរេន្តិ កុសុព្ភា បរិបូរា មហាសោព្ភេ បរិបូរេន្តិ មហាសោព្ភា បរិបូរា កុន្នទិយោ បរិបូរេន្តិ កុន្នទិយោ បរិបូរា មហានទិយោ បរិបូរេន្តិ មហានទិយោ បរិបូរា មហាសមុទ្ទំ(១) បរិបូរេន្តិ ឯវមេវ ខោ ភិក្ខវេ អវិជ្ជូបនិសា សង្ខារា សង្ខារូបនិសំ វិញ្ញាណំ វិញ្ញាណូបនិសំ នាមរូបំ នាមរូបូបនិសំ សឡាយតនំ សឡាយតនូបនិសោ ផស្សោ ផស្សូបនិសា វេទនា វេទនូបនិសា តណ្ហា តណ្ហូបនិសំ ឧបាទានំ ឧបាទានូបនិសោ ភវោ ភវូបនិសា ជាតិ ជាតូបនិសំ ទុក្ខំ ទុក្ខូបនិសា សទ្ធា សទ្ធូបនិសំ បាមុជ្ជំ បាមុជ្ជូបនិសា បីតិ បីតូបនិសា បស្សទ្ធិ បស្សទ្ធូបនិសំ សុខំ សុខូបនិសោ សមាធិ សមាធូបនិសំ យថាភូតញ្ញាណទស្សនំ យថាភូតញ្ញាណទស្សនូបនិសា និព្វិទា

---

១ ម.យ. សាគរំ ។

អភិសមយសំយុត្ត ទសពលវគ្គ ឧបមាដោយទឹកប្រព្រឹត្តទៅក្នុងទីទាប

( ៧០ ) ម្នាលភិក្ខុទាំងឡាយ ដូចទឹកភ្លៀងមានគ្រាប់ដ៏ថ្លោស បង្អុរចុះលើភ្នំ កាលទឹកនោះហូរទៅកាន់ទីទាប រមែងញុំាងជ្រោះភ្នំ ក្រហែងនិងប្រឡាយទឹកឲ្យពេញ កាលបើជ្រោះភ្នំ ក្រហែង និងប្រឡាយទឹកពេញហើយ រមែងញុំាងត្រពាំងតូចឲ្យពេញ កាលបើត្រពាំងតូចពេញហើយ រមែងញុំាងបឹងឲ្យពេញ កាលបើបឹងពេញហើយ រមែងញុំាងស្ទឹងឲ្យពេញ កាលបើស្ទឹងពេញហើយ រមែងញុំាងទន្លេឲ្យពេញ កាលបើទន្លេពេញហើយ រមែងញុំាងមហាសមុទ្រឲ្យពេញ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមានអវិជ្ជាជាហេតុ វិញ្ញាណមានសង្ខារជាហេតុ នាមរូបមានវិញ្ញាណជាហេតុ សឡាយតនៈមាននាមរូបជាហេតុ ផស្សៈមានសឡាយតនៈជាហេតុ វេទនាមានផស្សៈជាហេតុ តណ្ហាមានវេទនាជាហេតុ ឧបាទានមានតណ្ហាជាហេតុ ភពមានឧបាទានជាហេតុ ជាតិមានភពជាហេតុ ទុក្ខមានជាតិជាហេតុ សទ្ធាមានទុក្ខជាហេតុ បាមុជ្ជៈមានសទ្ធាជាហេតុ បីតិមានបាមុជ្ជៈជាហេតុ បស្សទ្ធិមានបីតិជាហេតុ សុខៈមានបស្សទ្ធិជាហេតុ សមាធិមានសុខៈជាហេតុ យថាភូតញាណទស្សនៈមានសមាធិជាហេតុ និព្វិទាញាណមានយថា-

និព្វិទូបនិសោ វិរាគោ វិរាគូបនិសា វិមុត្តិ វិមុត្តូបនិសំ ខយេ ញាណន្តិ ។ នតិយំ ។

(៧១) រាជគហេ វិហរតិ វេឡុវនេ ... អថខោ អាយស្មា សារីបុត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ ។ អថខោ អាយស្មតោ សារីបុត្តស្ស ឯតទហោសិ អតិប្បគោ ខោ តាវ រាជគហេ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្ក-មេយ្យន្តិ ។ អថខោ អាយស្មា សារីបុត្តោ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមិ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

ភូតញ្ញាណទស្សនៈជាហេតុ វិរាគៈមាននិព្វិទាញាណជាហេតុ វិមុត្តិមានវិរាគៈជាហេតុ ខយញ្ញាណមានវិមុត្តិជាហេតុ ។ ចប់សូត្រ ទី ៣ ។

( ៧១ ) ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ ... គ្រានោះ ព្រះសារីបុត្តមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហ-សម័យ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ការត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ នៅព្រឹកពេកណាស់ បើដូច្នោះ គួរតែអាត្មាអញចូលទៅកាន់អារាមនៃពួកអន្យតិរ្ថិយបរិព្វាជក(១) សិន ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ ចូលទៅកាន់អារាមនៃពួកអន្យតិរ្ថិយបរិព្វាជក លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងអន្យតិរ្ថិយបរិព្វាជកទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭក ហើយ ក៏គង់ក្នុងទីសមគួរ ។

---

១ អ្នកបួសមានលទ្ធិដទៃ ។

អភិសមយសំយុត្តស្ស ទសពលវគ្គេ បរិព្វាជកវត្ថុ

(៧២) ឯកមន្តំ និសិន្នា ខោ អាយស្មន្តំ សារិបុត្តំ តេ អញ្ញតិត្ថិយា បរិព្វាជកា ឯតទវោចុំ សន្តាវុសោ សារិបុត្ត ឯកេ សមណព្រាហ្មណា កម្មវាទា សយំកតំ ទុក្ខំ បញ្ញបេន្តិ ។ សន្តិ បនាវុសោ សារិបុត្ត ឯកេ សមណព្រាហ្មណា កម្មវាទា បរំកតំ ទុក្ខំ បញ្ញបេន្តិ ។ សន្តាវុសោ សារិបុត្ត ឯកេ សមណព្រាហ្មណា កម្មវាទា សយំកតញ្ច បរំកតញ្ច ទុក្ខំ បញ្ញបេន្តិ ។ សន្តិ បនាវុសោ សារិបុត្ត ឯកេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរំការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញបេន្តិ ។ ឥធ បនាវុសោ សារិបុត្ត សមណោ គោតមោ កឹវាទី កិមក្ខាយី កថំ ព្យាករមានា ច មយំ វុត្តវាទិនោ ចេវ សមណស្ស គោតមស្ស អស្សាម ន ច សមណំ គោតមំ អភូតេន អព្ភាចិក្ខេយ្យាម ធម្មស្ស ចានុធម្មំ ព្យាករេយ្យាម ន ច កោចិ សហធម្មិកោ វាទានុបាតោ(១) គារយ្ហំ ឋានំ អាគច្ឆេយ្យាតិ ។

---

១ ម. វាទានុវាទោ ។

(៧៦) លុះព្រះសារីបុត្តមានអាយុ គង់ក្នុងទីសមគួរហើយ អន្យតិរ្ថិយបរិព្វាជកទាំងនោះ ក៏ពោលពាក្យដូច្នេះថា ម្នាលសារីបុត្តមានអាយុ មានសមណព្រាហ្មណ៍ពួកមួយ ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង ។ ម្នាលសារីបុត្តមានអាយុ មានសមណព្រាហ្មណ៍ពួកមួយ ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលដទៃធ្វើឲ្យ ។ ម្នាលសារីបុត្តមានអាយុ មានសមណព្រាហ្មណ៍ពួកមួយ ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង ។ ម្នាលសារីបុត្តមានអាយុ មានសមណព្រាហ្មណ៍ពួកមួយ ជាកម្មវាទ បញ្ញត្តថា ទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ ។ ម្នាលសារីបុត្តមានអាយុ បណ្តាហេតុទាំង ៤ នេះ ព្រះសមណគោតមបានពោលដូចម្តេច បានប្រាប់ដូចម្តេច ចុះកាលយើងទាំងឡាយ ព្យាករដូចម្តេច ទើបឈ្មោះថាជាអ្នកពោលតាមពាក្យដែលព្រះសមណគោតមពោលហើយផង ឈ្មោះថាមិនពោលបង្កាច់ព្រះសមណគោតមដោយពាក្យមិនពិតផង ឈ្មោះថាព្យាករនូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងលំអានពាក្យបន្តបន្ទាប់ដែលប្រកបដោយធម៌ហើយ ក៏មិនមកកាន់ឋានៈដែលបណ្ឌិតគួរតិះដៀលផង ។

(៧៣) បដិច្ចសមុប្បន្នំ ខោ អាវុសោ ទុក្ខំ វុត្តំ ភគវតា កឹ បដិច្ច ផស្សំ បដិច្ច ឥតិ វទំ វុត្តវាទី ចេវ ភគវតោ អស្ស ន ច ភគវន្តំ អភូតេន អព្ភាចិក្ខេយ្យ ធម្មស្ស ចានុធម្មំ ព្យាករេយ្យ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យ ។ តត្រាវុសោ យេ តេ សមណព្រាហ្មណា កម្មវាទា សយំកតំ ទុក្ខំ បញ្ញបេន្តិ តទបិ ផស្សប្បច្ចយា ។ យេបិ តេ ។ បេ ។ យេបិ តេ ។ បេ ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរំការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញបេន្តិ តទបិ ផស្សប្បច្ចយា ។ តត្រាវុសោ យេ តេ សមណព្រាហ្មណា កម្មវាទា សយំកតំ ទុក្ខំ បញ្ញបេន្តិ

[ ៧៣ ] ព្រះសារីបុត្រពោលថា ម្នាលអាវុសោ សេចក្តីទុក្ខ ព្រះមានព្រះភាគបានពោលហើយថា កើតឡើងព្រោះអាស្រ័យហេតុ តើអាស្រ័យហេតុដូចម្តេច គឺអាស្រ័យផស្សៈ កាលបើបុគ្គលពោលដូច្នេះ ឈ្មោះថា ពោលតាមពាក្យដែលព្រះមានព្រះភាគបានពោលហើយផង មិនពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង ព្យាករនូវធម៌សមគួរដល់ធម៌ផង ទាំងលំអានពាក្យបន្តបន្ទាប់ដែលប្រកបដោយធម៌ហើយ ក៏មិនមកកាន់ឋានៈដែលបណ្ឌិតគួរតិះដៀលផង ។ ម្នាលអាវុសោ បណ្តាវាទៈទាំង ៤ នោះ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង តែសេចក្តីទុក្ខនោះកើតឡើង ព្រោះផស្សៈជាបច្ច័យ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណ-ព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ មិនមែនជាកំពើរបស់ខ្លួន មិនមែនជាកំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ តែសេចក្តីទុក្ខនោះកើតឡើង ព្រោះផស្សៈជាបច្ច័យ ។ ម្នាលអាវុសោ បណ្តាវាទៈទាំង ៤ នោះ ពួកសម-ណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង

តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតិ ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា បរំកតំ ទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតិ ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា សយំកតញ្ច បរំកតញ្ច ទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតិ ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរំការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតីតិ ។

(៧៤) អស្សោសិ ខោ អាយស្មា អានន្ទោ អាយស្មតោ សារីបុត្តស្ស តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ ឥមំ កថាសល្លាបំ ។ អថ ខោ អាយស្មា អានន្ទោ រាជគហេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តោ យេន ភគវា តេនុបសង្កមិ

សមណព្រាហ្មណ៍ទាំងនោះឯង ទទួលទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលដទៃធ្វើឲ្យ សមណព្រាហ្មណ៍ទាំងនោះឯង ទទួលទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ពួកសមណៈព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង សមណព្រាហ្មណ៍ទាំងនោះឯង ទទួលទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ពួកសមណៈព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ សមណព្រាហ្មណ៍ទាំងនោះឯង ទទួលទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។

[ ៧៤ ] ព្រះអានន្ទមានអាយុ បានឮនូវការចរចា ដោយពាក្យនេះ របស់ព្រះសារីបុត្តមានអាយុ ជាមួយនឹងអន្យតិរ្ថិយបរិព្វាជកទាំងនោះហើយ ។ ទើបព្រះអានន្ទមានអាយុ ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ លុះត្រឡប់មកអំពីបិណ្ឌបាត ក្នុងបច្ឆាភត្តកាល ចូលទៅគាល់ព្រះ

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ យាវតកោ អាយស្មតោ សារីបុត្តស្ស តេហិ អញ្ញតិត្ថិយេហិ បរិព្វា-ជកេហិ សទ្ធឹ អហោសិ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។

(៧៩) សាធុ សាធុ អានន្ទ យថាតំ សារីបុត្តោ វ សម្មា ព្យាករមានោ ព្យាករេយ្យ ។ បដិច្ចស-មុប្បន្នំ ខោ អានន្ទ ទុក្ខំ វុត្តំ មយា កឹ បដិច្ច ផស្សំ បដិច្ច ឥតិ វទំ វុត្តវាទី ចេវ មេ អស្ស ន ច មំ អភូតេន អព្ភាចិក្ខេយ្យ ធម្មស្ស ចានុធម្មំ ព្យាករេយ្យ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យ ។ តត្រានន្ទ យេ តេ ស-មណព្រាហ្មណា កម្មវាទា សយំកតំ ទុក្ខំ បញ្ញបេន្តិ តទបិ ផស្សបច្ចយា ។ យេបិ តេ ។បេ។ យេបិ តេ ។បេ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា

មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលនូវការចរចាដោយពាក្យទាំងអស់នោះ របស់ព្រះសារីបុត្តមានអាយុ ជាមួយនឹងអន្យតិរ្ថិយបរិព្វាជកទាំងនោះ ចំពោះព្រះមានព្រះភាគ ។

(៧៥) ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ប្រពៃហើយ ប្រពៃហើយ តាមដែលសារីបុត្តព្យាករហើយនោះ ឈ្មោះថាព្យាករដោយប្រពៃ ។ ម្នាលអានន្ទ សេចក្តីទុក្ខ ដែលតថាគតបានពោលហើយថា កើតឡើងព្រោះអាស្រ័យហេតុ តើអាស្រ័យហេតុដូចម្តេច គឺអាស្រ័យផស្សៈ កាលបើបុគ្គលពោលដូច្នេះ ឈ្មោះថា ពោលតាមពាក្យដែលតថាគតពោលហើយផង មិនពោលបង្កាច់តថាគតដោយពាក្យមិនពិតផង ព្យាករនូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងលំអានពាក្យបន្តបន្ទាប់ដែលប្រ-កបដោយធម៌ហើយ ក៏មិនមកកាន់ឋានៈដែលបណ្ឌិតគួរតិះដៀលផង ។ ម្នាលអានន្ទ បណ្តាវាទៈទាំង ៤ នោះ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង តែទុក្ខនោះកើតឡើងព្រោះផស្សៈជាបច្ច័យ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ

អសយំការំ អបរការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញបេន្តិ តទបិ ផស្សប្បច្ចយា ។ តត្រានន្ទ យេបិ តេ សមណព្រាហ្មណា កម្មវាទា សយំកតំ ទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតិ ។ យេបិ តេ ។ បេ ។ យេបិ តេ ។ បេ ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៧៦) ឯកមិទាហំ អានន្ទ សមយំ រាជគហេ វិហរាមិ វេឡុវនេ កលន្ទកនិវាបេ ។ អថខ្វាហំ អានន្ទ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសឹ ។ តស្ស មយ្ហំ អានន្ទ

បញ្ញត្តថា ទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គល ដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ តែទុក្ខនោះកើតឡើង ព្រោះផស្សៈជាបច្ច័យ ។ ម្នាលអានន្ទ បណ្ដាវាទៈទាំង ៤ នោះ ពួកសមណ-ព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង សមណព្រាហ្មណ៍ទាំងនោះឯង ទទួលទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ សមណព្រាហ្មណ៍ទាំងនោះឯង ទទួលទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។

[៧៦] ម្នាលអានន្ទ សម័យមួយ តថាគតនៅក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះនោះឯង ។ ម្នាលអានន្ទ គ្រានោះ តថាគតស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ម្នាលអានន្ទ តថាគតនោះ

ឯតទហោសិ អតិប្បគោ ខោ តាវ រាជគហេ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យន្តិ ។ អថខ្វាហំ អានន្ទ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមឹ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទឹ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹ ។ ឯកមន្តំ និសិន្នំ ខោ មំ អានន្ទ តេ អញ្ញតិត្ថិយា បរិព្វាជកា ឯតទវោចុំ សន្តាវុសោ គោតម ឯកេ សមណព្រាហ្មណា កម្មវាទា សយំកតំ ទុក្ខំ បញ្ញបេន្តិ សន្តិ បនាវុសោ គោតម ឯកេ សមណព្រាហ្មណា កម្មវាទា បរំកតំ ទុក្ខំ បញ្ញបេន្តិ សន្តាវុសោ គោតម ឯកេ សមណព្រាហ្មណា កម្មវាទា សយំកតញ្ច បរំកតញ្ច ទុក្ខំ បញ្ញបេន្តិ សន្តិ បនាវុសោ គោតម ឯកេ សមណព្រាហ្មណា កម្មវាទា

មានសេចក្ដីត្រិះរិះដូច្នេះថា ការត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ នៅព្រឹកពេកណាស់ បើដូច្នោះ គួរតែអាត្មាអញចូលទៅកាន់អារាមនៃពួកអន្យតិរ្ថិយបរិញ្វាជកសិន ។ ម្នាលអានន្ទ លំដាប់នោះ តថាគតចូលទៅកាន់អារាមនៃពួកអន្យតិរ្ថិយបរិញ្វាជក លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយ ជាមួយនឹងអន្យតិរ្ថិយបរិញ្វាជកទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ ម្នាលអានន្ទ លុះតថាគតអង្គុយក្នុងទីសមគួរហើយ អន្យតិរ្ថិយបរិញ្វាជកទាំងនោះ ក៏ពោលពាក្យដូច្នេះថា បពិត្រព្រះគោតមមានអាយុ មានសមណព្រាហ្មណ៍ពួកមួយ ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង បពិត្រព្រះគោតមមានអាយុ មានសមណព្រាហ្មណ៍ពួកមួយ ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលដទៃធ្វើឲ្យ បពិត្រព្រះគោតមមានអាយុ មានសមណព្រាហ្មណ៍ពួកមួយ ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង បពិត្រព្រះគោតមមានអាយុ មានសមណព្រាហ្មណ៍ពួកមួយ ជាកម្មវាទ

អសយំការំ អបរការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញ-
បេន្តិ ។ ឥធ នោ អាយស្មា គោតមោ កឹវាទី
កិមក្ខាយី កថំ ព្យាករមានា ច មយំ វុត្តវាទិនោ
ចេវ អាយស្មតោ គោតមស្ស អស្សាម ន ច អាយស្មន្តំ
គោតមំ អភូតេន អព្ភាចិក្ខេយ្យាម ធម្មស្ស ចានុធម្មំ
ព្យាករេយ្យាម ន ច កោចិ សហធម្មិកោ វាទានុ-
វាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យាតិ ។ ឯវំ វុត្តាហំ
អានន្ទ តេ អញ្ញតិត្ថិយេ បរិព្វាជកេ ឯតទវោចំ
បដិច្ចសមុប្បន្នំ ខោ អាវុសោ ទុក្ខំ វុត្តំ មយា កឹ
បដិច្ច ផស្សំ បដិច្ច ឥតិ វទំ វុត្តវាទី ចេវ មេ
អស្ស ន ច មំ អភូតេន អព្ភាចិក្ខេយ្យ ធម្មស្ស
ចានុធម្មំ ព្យាករេយ្យ ន ច កោចិ សហធម្មិ-
កោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យ ។

បញ្ញត្តថា ទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ ។ ចុះព្រះគោតមមានអាយុពោលដូចម្តេច ប្រាប់ដូចម្តេច ដល់យើងទាំងឡាយ ក្នុងហេតុទាំង ៤ នេះ យើងទាំងឡាយកាលព្យាករដូចម្តេច ទើបឈ្មោះថាពោលតាមពាក្យដែលព្រះគោតមមានអាយុពោលហើយផង ឈ្មោះថាមិនពោលបង្កាច់ព្រះគោតមមានអាយុដោយពាក្យមិនពិតផង ឈ្មោះថាព្យាករនូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងលំអានពាក្យបន្តិចបន្តួចដែលប្រកបដោយធម៌ហើយ ក៏មិនមកកាន់ឋានៈដែលបណ្ឌិតគួរតិះដៀលផង ។ ម្នាលអានន្ទ កាលបើអន្យតិរ្ថិយបរិព្វាជកទាំងនោះ ពោលយ៉ាងនេះហើយ តថាគត ក៏ពោលតបទៅនឹងអន្យតិរ្ថិយបរិព្វាជកទាំងនោះដូច្នេះថា ម្នាលអាវុសោទាំងឡាយ សេចក្តីទុក្ខដែលតថាគតបានពោលហើយថា កើតឡើងព្រោះអាស្រ័យហេតុ តើអាស្រ័យហេតុដូចម្តេច គឺអាស្រ័យផស្សៈ កាលបើបុគ្គលពោលដូច្នេះ ទើបឈ្មោះថា ពោលតាមពាក្យដែលតថា-គតបានពោលហើយផង មិនពោលបង្កាច់តថាគតដោយពាក្យមិនពិតផង ព្យាករនូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងលំអានពាក្យបន្តិចបន្តួចដែលប្រកបដោយធម៌ហើយ ក៏មិនមកកាន់ឋានៈដែលបណ្ឌិតគួរតិះដៀលផង ។

តត្រាវុសោ យេ តេ សមណព្រាហ្មណា កម្មវាទា សយំកតំ ទុក្ខំ បញ្ញបេន្តិ តទបិ ផស្សប្បច្ចយា ។ យេបិ តេ ។បេ។ យេបិ តេ ។បេ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរំការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញបេន្តិ តទបិ ផស្សប្បច្ចយា ។ តត្រាវុសោ យេ តេ សមណព្រាហ្មណា កម្មវាទា សយំកតំ ទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតិ ។ យេបិ តេ ។បេ។ យេបិ តេ ។បេ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរំការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតីតិ ។

ម្នាលអាវុសោទាំងឡាយ បណ្ដាវាទៈទាំង ៤ នោះ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង តែទុក្ខនោះកើតឡើង ព្រោះផស្សៈជាបច្ច័យ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ តែទុក្ខនោះកើតឡើង ព្រោះផស្សៈជាបច្ច័យ ។ ម្នាលអាវុសោទាំងឡាយ បណ្ដាវាទៈទាំង ៤ នោះ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង ពួកសមណព្រាហ្មណ៍ទាំងនោះឯង ទទួលទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា ទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ សមណព្រាហ្មណ៍ទាំងនោះឯង ទទួលទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។

(៧៧) អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យត្រ ហិ នាម ឯកេន បទេន សព្ពោ អត្ថោ វុត្តោ ភវិស្សតិ សិយា នុ ខោ ភន្តេ ឯសេវត្ថោ វិត្ថារេន វុច្ចមានោ គម្ភីរោ ចេវ អស្ស គម្ភីរាវភាសោ ចាតិ ។ តេនហានន្ទ តញ្ញេវេត្ថ បដិភាតុ ។

(៧៨) សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ ជរាមរណំ អាវុសោ អានន្ទ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវន្តិ ។ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យំ ជរាមរណំ ខោ អាវុសោ ជាតិនិទានំ ជាតិសមុទយំ ជាតិជាតិកំ ជាតិប្បភវន្តិ ។ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យំ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ ជាតិ បនាវុសោ អានន្ទ កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ ។ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យំ

(៧៧) ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកពេកណាស់ ព្រោះថា សេចក្តីទាំងពួង ព្រះមានព្រះភាគទ្រង់ពោលតែដោយបទមួយ បពិត្រព្រះអង្គដ៏ចម្រើន ឯសេចក្តីនុ៎ះ ប្រសិនបើព្រះអង្គពោលដោយពិស្តារវិញ ប្រហែលជាជ្រាលជ្រៅ ទាំងមានឱភាសជ្រាលជ្រៅណាស់ ។ ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកបំភ្លឺនូវសេចក្តីនោះ ក្នុងបទៈទាំង ៤ នេះមកមើល ។

(៧៨) បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអានន្ទមានអាយុ ជរាមរណៈ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ជរាមរណៈ មានជាតិជាហេតុ មានជាតិនាំឲ្យកើត មានជាតិជាកំណើត មានជាតិជាប្រភព ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអានន្ទមានអាយុ ចុះជាតិ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គ គប្បីដោះស្រាយយ៉ាងនេះថា

ជាតិ ខោ អាវុសោ កិំនិទានា កិំសមុទយា កិំជាតិកា កិំប្បភវាតិ ។ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ ភវោ បនាវុសោ ននុ កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោតិ ។ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យំ ភវោ ខោ អាវុសោ ឧបាទាននិទានោ ឧបាទានសមុទយោ ឧបាទានជាតិកោ ឧបាទានប្បភវោតិ ។ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ ឧបាទានំ បនាវុសោ ។ បេ ។ តណ្ហា បនាវុសោ ។ បេ ។ វេទនា បនាវុសោ ។ បេ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ ផស្សោ បនាវុសោ ភនុ កឹនិទានោ កឹសមុទយោ

ម្នាលអាវុសោទាំងឡាយ ជាតិ មានភពជាហេតុ មានភពនាំឲ្យកើត មានភពជាកំណើត មានភពជាប្រភព ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអានន្ទមានអាយុ ចុះភព មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភព មានឧបាទានជាហេតុ មានឧបាទាននាំឲ្យកើត មានឧបាទានជាកំណើត មានឧបាទានជាប្រភព ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអានន្ទមានអាយុ ចុះឧបាទាន ។ បេ ។ ម្នាលអានន្ទមានអាយុ ចុះតណ្ហា ។ បេ ។ ម្នាលអានន្ទមានអាយុ ចុះវេទនា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអានន្ទមានអាយុ ចុះផស្សៈ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត

កឹជាតិកោ កឹបភវោតិ ។ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យំ ផស្សោ ខោ អាវុសោ សឡាយតននិទា-នោ សឡាយតនសមុទយោ សឡាយតនជាតិកោ សឡាយតនប្បភវោ ឆន្នំ ត្វេវ អាវុសោ ផស្សាយត-នានំ អសេសវិរាគនិរោធា ផស្សនិរោធោ ផស្សនិ-រោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និ-រុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។ ចតុត្ថំ ។

មានអ្វីជាកំណើត មានអ្វីជាប្រភព ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ផស្សៈ មានសឡាយតនៈជាហេតុ មានសឡាយតនៈនាំឲ្យកើត មានសឡាយតនៈជាកំណើត មានសឡាយតនៈជាប្រភព ម្នាលអាវុសោទាំងឡាយ ការរលត់នៃផស្សៈ ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃសឡាយតនៈទាំង ៦ ការរលត់នៃវេទនាព្រោះការរលត់នៃផស្សៈ ការរលត់នៃតណ្ហា ព្រោះការរលត់នៃវេទនាការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ការរលត់នៃជាតិ ព្រោះការរលត់នៃភព ជរានិងមរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ សេចក្ដីលំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏តែងរលត់ទៅព្រោះការរលត់នៃជាតិ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះឯង ។ ចប់សូត្រ ទី ៤ ។

(៧៩) សាវត្ថិយំ វិហរតិ... អថខោ អាយស្មា ភូមិជោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ភូមិជោ អាយស្មន្តំ សារីបុត្តំ ឯតទវោច សន្តាវុសោ សារីបុត្ត ឯកេ សមណព្រាហ្មណា កម្មវាទា សយំកតំ សុខទុក្ខំ បញ្ញបេន្តិ សន្តិ បនាវុសោ សារីបុត្ត ឯកេ សមណព្រាហ្មណា កម្មវាទា បរកតំ សុខទុក្ខំ បញ្ញបេន្តិ សន្តាវុសោ សារីបុត្ត ឯកេ សមណព្រាហ្មណា កម្មវាទា សយំកតញ្ច បរកតញ្ច សុខទុក្ខំ បញ្ញបេន្តិ សន្តិ បនាវុសោ សារីបុត្ត ឯកេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរការំ អធិច្ចសមុប្បន្នំ សុខទុក្ខំ បញ្ញបេន្តិ ។

( ៧៩ ) ទ្រង់គង់ជិតក្រុងសាវត្ថី ... គ្រានោះ ព្រះភូមិជៈមានអាយុ ចេញអំពីទីស្ងាត់ ក្នុងសាយណ្ហសម័យ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយ ជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះភូមិជៈមានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ពោលនឹងព្រះសារីបុត្តមានអាយុ ដូច្នេះថា ម្នាលសារីបុត្តមានអាយុ មានសមណព្រាហ្មណ៍ពួកមួយ ជាកម្មវាទ បញ្ញត្តថា សុខនិងទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង ម្នាលសារីបុត្តមានអាយុ មានសមណព្រាហ្មណ៍ពួកមួយទៀត ជាកម្មវាទ បញ្ញត្តថា សុខនិងទុក្ខ គឺបុគ្គលដទៃធ្វើឲ្យ ម្នាលសារីបុត្តមានអាយុ មានសមណព្រាហ្មណ៍ពួកមួយ ជាកម្មវាទ បញ្ញត្តថា សុខនិងទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង ម្នាលសារីបុត្តមានអាយុ មានសមណព្រាហ្មណ៍ពួកមួយទៀត ជាកម្មវាទ បញ្ញត្តថា សុខនិងទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ ។

ឥធ នោ អាវុសោ សារិបុត្ត ភគវា កឹវាទី កិមក្ខាយី កថំ ព្យាករមានា ច មយំ វុត្តវាទិនោ ចេវ ភគវតោ អស្សាម ន ច ភគវន្តំ អភូតេន អព្ភាចិក្ខេយ្យាម ធម្មស្ស ចានុធម្មំ ព្យាករេយ្យាម ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យាតិ ។

(៨០) បដិច្ចសមុប្បន្នំ ខោ អាវុសោ សុខទុក្ខំ វុត្តំ ភគវតា កឹ បដិច្ច ផស្សំ បដិច្ច ឥតិ វទំ វុត្តវាទី ចេវ ភគវតោ អស្ស ន ច ភគវន្តំ អភូតេន អព្ភាចិក្ខេយ្យ ធម្មស្ស ចានុធម្មំ ព្យាករេយ្យ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យ ។ តត្រាវុសោ យេ តេ សមណព្រាហ្មណា កម្មវាទា សយំកតំ សុខទុក្ខំ បញ្ញបេន្តិ តទបិ

ម្នាលសារីបុត្តមានអាយុ ព្រះមានព្រះភាគ ទ្រង់ពោលដូចម្តេច ទ្រង់ប្រាប់ដូចម្តេច ដល់យើងទាំងឡាយ កុងហេតុទាំង ៤ នេះ ចុះកាលយើងទាំងឡាយព្យាករដូចម្តេច ទើបឈ្មោះថាពោលតាមពាក្យដែលព្រះមានព្រះភាគពោលហើយផង ឈ្មោះថាមិនពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង ឈ្មោះថាព្យាករទូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងលំអានពាក្យបន្តិចបន្តួចដែលប្រកបដោយធម៌ហើយ ក៏មិនមកកាន់ឋានៈដែលបណ្ឌិតគប្បីតិះដៀលផង ។

(៨០) ព្រះសារីបុត្តតបថា ម្នាលអាវុសោ សុខទុក្ខ ព្រះមានព្រះភាគបានពោលហើយថា កើតឡើងព្រោះអាស្រ័យហេតុ តើអាស្រ័យហេតុដូចម្តេច គឺអាស្រ័យផស្សៈ កាលបើបុគ្គលពោលដូច្នេះ ឈ្មោះថា ពោលតាមពាក្យដែលព្រះមានព្រះភាគពោលហើយផង មិនពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង ព្យាករទូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងលំអានពាក្យបន្តិចបន្តួចដែលប្រកបដោយធម៌ហើយ ក៏មិនមកកាន់ឋានៈ ដែលបណ្ឌិតគប្បីតិះដៀលផង ។ ម្នាលអាវុសោ បណ្តាវាទៈទាំង ៤ នោះ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា សុខទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង តែសុខទុក្ខនោះឯង កើតឡើង

ផស្សប្បច្ចយា ។ យេបិ តេ ។បេ។ យេបិ តេ ។បេ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរការំ អធិច្ចសមុប្បន្នំ សុខទុក្ខំ បញ្ញបេន្តិ តទបិ ផស្សប្បច្ចយា ។ តត្រាវុសោ យេ តេ សមណព្រាហ្មណា កម្មវាទា សយំកតំ សុខទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតិ ។ យេបិ តេ ។បេ។ យេបិ តេ ។បេ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរការំ អធិច្ចសមុប្បន្នំ សុខទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតីតិ ។

ព្រោះផស្សៈជាបច្ច័យ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា សុខនិងទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ តែសុខនិងទុក្ខនោះឯងកើតឡើង ព្រោះផស្សៈជាបច្ច័យ ។ ម្នាលអាវុសោ បណ្ដាវាទៈទាំង ៤ នោះ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា សុខនិងទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង សមណព្រាហ្មណ៍ទាំងនោះឯង ទទួលសុខនិងទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា សុខនិងទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ សមណព្រាហ្មណ៍ទាំងនោះឯង ទទួលសុខនិងទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។

(៨១) អស្សោសិ ខោ អាយស្មា អានន្ទោ អាយស្មតោ សារីបុត្តស្ស អាយស្មតា ភូមិជេន សទ្ធឹ ឥមំ កថាសល្លាបំ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ យាវតកោ អាយស្មតោ សារីបុត្តស្ស អាយស្មតា ភូមិជេន សទ្ធឹ អហោសិ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។

(៨២) សាធុ សាធុ អានន្ទ យថាតំ សារីបុត្តោ ន សម្មា ព្យាករមានោ ព្យាករេយ្យ ។ បដិច្ចសមុប្បន្នំ ខោ អានន្ទ សុខទុក្ខំ វុត្តំ មយា កឹ បដិច្ច ផស្សំ បដិច្ច ឥតិ វទំ វុត្តវាទី ចេវ មេ អស្ស ន ច មំ អភូតេន អព្ភាចិក្ខេយ្យ ធម្មស្ស ចានុធម្មំ ព្យាករេយ្យ ន ច កោចិ សហធម្មិកោ វាទានុបាតោ

(៨១) ព្រះអានន្ទមានអាយុ បានស្តាប់ការចរចានេះ របស់ព្រះសារីបុត្តមានអាយុ ជាមួយនឹងព្រះភូមិជៈមានអាយុហើយ ។ ទើបព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលការចរចាទាំងអស់នោះ របស់ព្រះសារីបុត្តមានអាយុ ជាមួយនឹងព្រះភូមិជៈមានអាយុ ចំពោះព្រះមានព្រះភាគ ។

(៨២) ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ប្រពៃហើយ ប្រពៃហើយ គួរនឹងពាក្យដែលសារីបុត្តព្យាករ ឈ្មោះថាព្យាករដោយប្រពៃ ។ ម្នាលអានន្ទ សុខនិងទុក្ខ តថាគតបានពោលហើយថា កើតឡើងព្រោះអាស្រ័យហេតុ តើអាស្រ័យហេតុដូចម្តេច គឺអាស្រ័យផស្សៈ កាលបើបុគ្គលពោលដូច្នេះ ឈ្មោះថាពោលតាមពាក្យដែលតថាគតពោលហើយផង មិនពោលបង្កាច់តថាគតដោយពាក្យមិនពិតផង ព្យាករនូវធម៌សមគួរដល់ធម៌ផង ទាំងលំអានពាក្យបន្តិចបន្តួចដែលប្រកបដោយធម៌ហើយ

គារយ្ហំ ឋានំ អាគច្ឆេយ្យ ។ តត្រាវុសោ យេ តេ សមណព្រាហ្មណា កម្មវាទា សយំកតំ សុខទុក្ខំ បញ្ញបេន្តិ តទបិ ផស្សប្បច្ចយា ។ យេបិ តេ ។ បេ ។ យេបិ តេ ។ បេ ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរំការំ អធិច្ចសមុប្បន្នំ សុខទុក្ខំ បញ្ញបេន្តិ តទបិ ផស្សប្បច្ចយា ។ តត្រាវុសោ យេ តេ សមណព្រាហ្មណា កម្មវាទា សយំកតំ សុខទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតិ ។ យេបិ តេ ។ បេ ។ យេបិ តេ ។ បេ ។ យេបិ តេ សមណព្រាហ្មណា កម្មវាទា អសយំការំ អបរំការំ អធច្ចសមុប្បន្នំ សុខទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតិ ។

ក៏មិនមកកាន់ឋានៈដែលបណ្ឌិតគប្បីតិះដៀលផង ។ ម្នាលអានន្ទ បណ្ដាវាទៈទាំង ៤ នោះ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា សុខទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង តែសុខទុក្ខនោះឯង កើតឡើង ព្រោះផស្សៈជាបច្ច័យ ។ ពួកសមណព្រាហ្មណ៍ណា ។បេ។ ពួកសមណព្រាហ្មណ៍ណា ។បេ។ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា សុខទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ តែសុខទុក្ខនោះឯង កើតឡើងព្រោះផស្សៈជាបច្ច័យ ។ ម្នាលអានន្ទ បណ្ដាវាទៈទាំង ៤ នោះ ពួកសមណព្រាហ្មណ៍ណាជាកម្មវាទ បញ្ញត្តថា សុខទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង សមណព្រាហ្មណ៍ទាំងនោះ ទទួលសុខទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ពួកសមណព្រាហ្មណ៍ណា ។បេ។ ពួកសមណព្រាហ្មណ៍ណា ។បេ។ ពួកសមណព្រាហ្មណ៍ណា ជាកម្មវាទ បញ្ញត្តថា សុខទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ សមណព្រាហ្មណ៍ទាំងនោះឯង ទទួលសុខទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។

(៨៣) កាយេ វា ហានន្ទ សតិ កាយសញ្ចេ-
តនាហេតុ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ វាចាយ វា
ហានន្ទ សតិ វចីសញ្ចេតនាហេតុ ឧប្បជ្ជតិ អជ្ឈត្តំ
សុខទុក្ខំ មនេ វា ហានន្ទ សតិ មនោសញ្ចេតនា-
ហេតុ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ អវិជ្ជាបច្ចយា
វ សាមំ វា តំ អានន្ទ កាយសង្ខារំ អភិសង្ខរោតិ
យំបច្ចយាយតំ(១) ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។
បរេ វាយតំ(២) អានន្ទ កាយសង្ខារំ អភិសង្ខរោ-
ន្តិ យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។
សម្បជានោ វា តំ អានន្ទ កាយសង្ខារំ អភិសង្ខរោតិ
យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ អ-
សម្បជានោ វា តំ អានន្ទ កាយសង្ខារំ អភិសង្ខរោតិ
យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ សាមំ
វា តំ អានន្ទ វចីសង្ខារំ អភិសង្ខរោតិ យំបច្ចយាយតំ
ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ បរេ វាយតំ អានន្ទ

---

១ ឱ. យំ បច្ចយស្ស តន្តិ ទិស្សតិ ។ ម. បច្ចយោយំ តន្តិ ទិស្សតិ ។ ២ ឱ. បរេវាស្ស តន្តិ ទិស្ស ។ ម. វាយន្តិ ទិស្សតិ ។

អភិសមយសំយុត្ត ទសពលវគ្គ កិរិយាធ្វើនូវកាយ-វចី-មនោសង្ខារ

(៨៣) ម្នាលអានន្ទ កាលបើកាយមាន សុខនិងទុក្ខខាងក្នុង រមែងកើតឡើង ព្រោះកាយសញ្ចេតនា(១)ជាហេតុ ម្នាលអានន្ទ កាលបើវាចាមាន សុខនិងទុក្ខខាងក្នុង រមែងកើតឡើង ព្រោះវចីសញ្ចេតនាជាហេតុ ម្នាលអានន្ទ កាលបើមនោមាន សុខនិងទុក្ខខាងក្នុង រមែងកើតឡើង ព្រោះមនោសញ្ចេតនាជាហេតុ ក៏មាន ។ ម្នាលអានន្ទ សុខនិងទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺកាយសង្ខារ(២)ណា បុគ្គលតែងធ្វើកាយសង្ខារនោះដោយខ្លួនឯង ព្រោះអវិជ្ជាជាបច្ច័យ ក៏មាន ។ ម្នាលអានន្ទ សុខនិងទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យ គឺកាយសង្ខារណា បុគ្គលទាំងឡាយដទៃ តែងធ្វើកាយសង្ខារនោះ ក៏មាន ។ ម្នាលអានន្ទ សុខនិងទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺកាយ-សង្ខារណា បុគ្គលកាលដឹងច្បាស់ តែងធ្វើកាយសង្ខារនោះ ក៏មាន ។ ម្នាលអានន្ទ សុខនិងទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺកាយ-សង្ខារណា បុគ្គលមិនដឹងច្បាស់ តែងធ្វើកាយសង្ខារនោះ ក៏មាន ។ ម្នាលអានន្ទ សុខនិងទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺវចីសង្ខារណា បុគ្គលតែងធ្វើវចីសង្ខារនោះដោយខ្លួនឯង ក៏មាន ។ ម្នាលអានន្ទ

---

១ ចេតនាដែលកើតឡើងក្នុងកាយទ្វារ ។ ២ កាយកម្ម ។

វចីសង្ខារំ អភិសង្ខរោន្តិ យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ សម្បជានោ វា តំ អានន្ទ ។ បេ ។ អសម្បជានោ វា តំ អានន្ទ វចីសង្ខារំ អភិសង្ខរោតិ យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ សាមំ វា តំ អានន្ទ មនោសង្ខារំ អភិសង្ខរោតិ យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ បរេ វាយតំ អានន្ទ មនោសង្ខារំ អភិសង្ខរោន្តិ យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ សម្បជានោ វា តំ អានន្ទ ។ បេ ។ អសម្បជានោ វា តំ អានន្ទ មនោសង្ខារំ អភិសង្ខរោតិ យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ ឥមេសុ អានន្ទ ធម្មេសុ[១] អវិជ្ជា អនុបតិតា ។

---

១ ឱ. ម. ឆសុ ធម្មេសូតិ ទិស្សតិ ។

សុខនិងទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺវចីសញ្ចេតនាណា បុគ្គលទាំងឡាយដទៃ តែងធ្វើវចីសញ្ចេតនានោះ ក៏មាន ។ ម្នាលអានន្ទ បុគ្គលដឹងច្បាស់ ។ បេ ។ ម្នាលអានន្ទ សុខនិងទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺវចីសញ្ចេតនាណា បុគ្គលមិនដឹងច្បាស់ តែងធ្វើវចីសញ្ចេតនានោះ ក៏មាន ។ ម្នាលអានន្ទ សុខនិងទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺមនោសញ្ចេតនាណា បុគ្គលតែងធ្វើមនោសញ្ចេតនានោះដោយខ្លួនឯង ក៏មាន ។ ម្នាលអានន្ទ សុខនិងទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺមនោសញ្ចេតនាណា បុគ្គលទាំងឡាយដទៃ តែងធ្វើមនោសញ្ចេតនានោះ ក៏មាន ។ ម្នាលអានន្ទ បុគ្គលដឹងច្បាស់ ។ បេ ។ ម្នាលអានន្ទ សុខនិងទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺមនោសញ្ចេតនាណា បុគ្គលមិនដឹងច្បាស់ តែងធ្វើមនោសញ្ចេតនានោះ ក៏មាន ។ ម្នាលអានន្ទ អវិជ្ជាធ្លាក់ចុះហើយ ៗ ក្នុងធម៌ទាំងនេះឯង ។

(៨៤) អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សោ កាយោ ន ហោតិ យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ សា វាចា ន ហោតិ យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ សោ មនោ ន ហោតិ យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ខេត្តំ វា(១) ន ហោតិ ។ វត្ថុំ វា ន ហោតិ ។ អាយតនំ វា ន ហោតិ ។ អធិករណំ តំ វា ន ហោតិ យំបច្ចយាយតំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខន្តិ ។ បញ្ចមំ ។

(៨៥) សាវត្ថិយំ វិហរតិ ... អថខោ អាយស្មា ឧបវាណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

(៨៦) ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបវាណោ ភគវន្តំ ឯតទវោច សន្តិ បន(២) ភន្តេ ឯកេ សមណព្រាហ្មណា សយំកតំ ទុក្ខំ បញ្ញបេន្តិ

១ ឱ. ម. បត្តូសុ ហាំនេតសុ វាសទ្ទោ ន ទិស្សតិ តត្ថ បន ទិស្សតិ ។ ២ សព្វវារេសុ សន្តិ ហីតិ បទទ្វយេន ភវិតព្វំ ។

( ៨៤ ) ម្នាលអានន្ទ សុខទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺកាយណា កាយនោះ មិនមាន ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃអវិជ្ជា ។ សុខទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺវាចាណា វាចានោះ មិនមាន ។ សុខទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺចិត្តណា ចិត្តនោះ មិនមាន ខេត្តក្តី មិនមាន ។ វត្ថុក្តី មិនមាន ។ អាយតនៈក្តី មិនមាន ។ សុខទុក្ខខាងក្នុង កើតឡើងជាប់ដោយបច្ច័យគឺអធិករណៈ(១)ណា អធិករណ៍នោះក្តី មិនមាន ។ ចប់សូត្រ ទី ៨ ។

( ៨៥ ) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... គ្រានោះ ព្រះឧបវាណៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។

( ៨៦ ) លុះព្រះឧបវាណៈមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ពួកមួយ បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង

១ ហេតុ ។

សន្តិ បន ភន្តេ ឯកេ សមណព្រាហ្មណា បរកតំ ទុក្ខំ បញ្ញបេន្តិ សន្តិ បន ភន្តេ ឯកេ សមណព្រាហ្មណា សយំកតញ្ច បរកតញ្ច ទុក្ខំ បញ្ញបេន្តិ សន្តិ បន ភន្តេ ឯកេ សមណព្រាហ្មណា អសយំការំ អបរការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញបេន្តិ ។ ឥធ នោ ភន្តេ ភគវា កឹវាទី កិមក្ខាយី កថំ ព្យាករមានា ច មយំ វុត្តវាទិនោ ចេវ ភគវតោ អស្សាម ន ច ភគវន្តំ អភូតេន អព្ភាចិក្ខេយ្យាម ធម្មស្ស ចានុធម្មំ ព្យាករេយ្យាម ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យាតិ ។

(៨៧) បដិច្ចសមុប្បន្នំ ខោ ឧបវាណ ទុក្ខំ វុត្តំ មយា កឹ បដិច្ច ផស្សំ បដិច្ច ឥតិ វទំ វុត្តវាទី ចេវ មេ អស្ស ន ច មំ អភូតេន អព្ភាចិក្ខេយ្យ

បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ពួកមួយទៀត បញ្ញត្តថា ទុក្ខ គឺបុគ្គលដទៃធ្វើឲ្យ បពិត្រព្រះអង្គដ៏ចម្រើន មានសមណ-ព្រាហ្មណ៍ពួកមួយទៀត បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ពួកមួយទៀត បញ្ញត្តថា ទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ពោលដូចម្តេច ទ្រង់ប្រាប់ដូចម្តេច ដល់យើងទាំងឡាយ ក្នុងហេតុទាំង ៤ នេះ កាលយើងទាំង-ឡាយព្យាករដូចម្តេច ទើបឈ្មោះថាពោលតាមពាក្យដែលព្រះមានព្រះភាគទ្រង់ពោលហើយផង ឈ្មោះថាមិនពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង ឈ្មោះថាព្យាករនូវធម៌សមគួរដល់ធម៌ផង ទាំងលំអានពាក្យបន្តបន្ទាប់ដែលប្រកបដោយធម៌ហើយ ក៏មិនមកកាន់ឋានៈដែលបណ្ឌិតគប្បីតិះដៀលផង ។

(៨៧) ម្នាលឧបវាណៈ សេចក្តីទុក្ខ តថាគតបានពោលហើយថា កើតឡើងព្រោះអាស្រ័យហេតុ កើតអាស្រ័យហេតុដូចម្តេច គឺអាស្រ័យផស្សៈ កាលបើបុគ្គលពោលដូច្នេះ ឈ្មោះថា ពោលតាមពាក្យដែលតថាគតពោលហើយផង មិនពោលបង្កាច់តថាគតដោយពាក្យមិនពិតផង

ធម្មស្ស ចានុធម្មំ ព្យាករេយ្យ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យ ។ តត្រុបវាណ យេ តេ សមណព្រាហ្មណា សយំកតំ ទុក្ខំ បញ្ញបេន្តិ តទបិ ផស្សបច្ចយា ។ យេបិ តេ ។ បេ ។ យេបិ តេ ។ បេ ។ យេបិ តេ សមណព្រាហ្មណា អសយំការំ អបរការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញបេន្តិ តទបិ ផស្សបច្ចយា ។ តត្រុបវាណ យេ តេ សមណព្រាហ្មណា សយំកតំ ទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតិ ។ យេបិ តេ ។ បេ ។ យេបិ តេ ។ បេ ។ យេបិ តេ សមណព្រាហ្មណា អសយំការំ អបរការំ អធិច្ចសមុប្បន្នំ ទុក្ខំ បញ្ញបេន្តិ តេ វត អញ្ញត្រ ផស្សា បដិសំវេទយន្តីតិ នេតំ ឋានំ វិជ្ជតីតិ ។ ឆដ្ឋំ ។

ព្យាករនូវធម៌ដ៏សមគួរដល់ធម៌ផង ទាំងលំអានពាក្យបន្តិចបន្តួចដែលប្រ-កបដោយធម៌ហើយ ក៏មិនមកកាន់ឋានៈដែលបណ្ឌិតគប្បីតិះដៀលផង ។ ម្នាលឧបវាណៈ បណ្តាសមណព្រាហ្មណ៍ទាំង ៤ ពួកនោះ ពួកសមណ-ព្រាហ្មណ៍ណា បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង តែទុក្ខនោះឯង កើតឡើងព្រោះផស្សៈជាបច្ច័យ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា បញ្ញត្តថា ទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ តែទុក្ខនោះឯង កើតឡើងព្រោះផស្សៈជាបច្ច័យ ។ ម្នាលឧបវាណៈ បណ្តាសមណព្រាហ្មណ៍ទាំង ៤ ពួកនោះ ពួកសមណព្រាហ្មណ៍ណា បញ្ញត្តថា ទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង សមណព្រាហ្មណ៍ទាំងនោះឯង ទទួលទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណព្រាហ្មណ៍ណា ។ បេ ។ ពួកសមណ-ព្រាហ្មណ៍ណា បញ្ញត្តថា ទុក្ខ មិនមែនជាអំពើរបស់ខ្លួន មិនមែនជាអំពើរបស់បុគ្គលដទៃ គឺកើតឡើងដោយមិនអាស្រ័យហេតុ សមណ-ព្រាហ្មណ៍ទាំងនោះឯង ទទួលទុក្ខក្រៅអំពីផស្សៈ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ចប់សូត្រ ទី ៦ ។

(៨៨) សាវត្ថិយំ វិហរតិ ... អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៨៩) កតមញ្ច ភិក្ខវេ ជរាមរណំ ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ជរា ។ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ មរណំ ។ ឥតិ អយញ្ច ជរា ឥទញ្ច មរណំ ឥទំ វុច្ចតិ ភិក្ខវេ ជរាមរណំ ។ ជាតិសមុទយា ជរាមរណសមុទយោ ជាតិនិរោធា ជរាមរណនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ជរាមរណនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ កតមា ច ភិក្ខវេ ជាតិ ។ បេ ។

( ៨៨ ) ទ្រង់គង់ជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

( ៨៩ ) ម្នាលភិក្ខុទាំងឡាយ ជរានិងមរណៈ តើដូចម្តេច ។ សេចក្តីគ្រាំគ្រា ភាពគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ ដំណើរថយអាយុ ដំណើរចាស់ទុំនៃឥន្ទ្រិយទាំងឡាយ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ នេះហៅថា ជរា ។ ចុតិ ការឃ្លាត ការបែកធ្លាយ ការបាត់បង់ សេចក្តីស្លាប់ ដំណើរស្លាប់ ការធ្វើនូវមរណកាល ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការដាច់នៃជីវិតិន្ទ្រិយ ណា របស់សត្វទាំងឡាយនោះ ៗ ចាកសត្តនិកាយនោះ ៗ នេះហៅថា មរណៈ ។ ម្នាលភិក្ខុទាំងឡាយ ជរានេះផង មរណៈនេះផង នេះហៅថា ជរានិងមរណៈ ដូច្នេះឯង ។ ការកើតឡើងនៃជរានិងមរណៈ ព្រោះការកើតឡើងនៃជាតិ ការរលត់នៃជរានិងមរណៈ ព្រោះការរលត់នៃជាតិ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាបដិបទា ដែលជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ គឺ ប្រាជ្ញាយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ ការនិយាយត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ សេចក្តីរឭកត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះជាតិ តើដូចម្តេច ។ បេ ។

កតមោ ច ភិក្ខវេ ភវោ ... កតមញ្ច ភិក្ខវេ ឧបាទានំ ... កតមា ច ភិក្ខវេ តណ្ហា ... កតមា ច ភិក្ខវេ វេទនា ... កតមោ ច ភិក្ខវេ ផស្សោ ... កតមញ្ច ភិក្ខវេ សឡាយតនំ ... កតមញ្ច ភិក្ខវេ នាមរូបំ ... កតមញ្ច ភិក្ខវេ វិញ្ញាណំ ... កតមេ ច ភិក្ខវេ សង្ខារា តយោមេ ភិក្ខវេ សង្ខារា កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោ ឥមេ វុច្ចន្តិ ភិក្ខវេ សង្ខារា ។ អវិជ្ជាសមុទយា សង្ខារសមុទយោ អវិជ្ជានិរោធា សង្ខារនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សង្ខារនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។

(៩០) យតោ ខោ ភិក្ខវេ អរិយសាវកោ ឯវំ បច្ចយំ បជានាតិ ឯវំ បច្ចយសមុទយំ បជានាតិ ឯវំ បច្ចយនិរោធំ បជានាតិ ឯវំ បច្ចយនិរោធគាមិនឹ បដិបទំ បជានាតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ

ម្នាលភិក្ខុទាំងឡាយ ភព តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ ឧបាទាន តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ តណ្ហា តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ វេទនា តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ ផស្សៈ តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ សឡាយតនៈ តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ នាមរូប តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ វិញ្ញាណ តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយនេះ មាន ៣ គឺ កាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សង្ខារ ។ ការកើតឡើងនៃសង្ខារ ព្រោះការកើតឡើងនៃអវិជ្ជា ការរលត់នៃសង្ខារ ព្រោះការរលត់នៃអវិជ្ជា មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាបដិបទា ដែលជាដំណើរទៅកាន់ទីរលត់នៃសង្ខារ គឺ ប្រាជ្ញាយល់ឃើញត្រូវ ១ ។បេ។ ការតម្កល់ចិត្តត្រូវ ១ ។

[៩០] ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវ័កដឹងច្បាស់នូវបច្ច័យយ៉ាងនេះ ដឹងច្បាស់នូវការកើតឡើងនៃបច្ច័យយ៉ាងនេះ ដឹងច្បាស់នូវទីរលត់នៃបច្ច័យយ៉ាងនេះ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃបច្ច័យយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះ

ទិដ្ឋិសម្បន្នោ ឥតិបិ ទស្សនសម្បន្នោ ឥតិបិ អាគតោ ឥមំ សទ្ធម្មំ ឥតិបិ បស្សតិ ឥមំ សទ្ធម្មំ ឥតិបិ សេក្ខេន ញាណេន សមន្នាគតោ ឥតិបិ សេក្ខាយ វិជ្ជាយ សមន្នាគតោ ឥតិបិ ធម្មសោតំ សមាបន្នោ ឥតិបិ អរិយោ និព្វេធិកបញ្ញោ ឥតិបិ អមតទ្វារំ អាហច្ច តិដ្ឋតិ ឥតិបីតិ ។ សត្តមំ ។

(៩៧) សាវត្ថិយំ វិហរតិ ... តត្រ ខោ ។បេ។ ឥធ ភិក្ខវេ ភិក្ខុ ជរាមរណំ បជានាតិ ជរាមរណសមុទយំ បជានាតិ ជរាមរណនិរោធំ បជានាតិ ជរាមរណនិរោធគាមិនឹ បដិបទំ បជានាតិ ។ ជាតឹ បជានាតិ ។បេ។ ភវំ បជានាតិ ... ឧបាទានំ បជានាតិ ... តណ្ហំ បជានាតិ ... វេទនំ បជានាតិ ... ផស្សំ បជានាតិ ... សឡាយតនំ បជានាតិ ... នាមរូបំ បជានាតិ ... វិញ្ញាណំ បជានាតិ ... សង្ខារេ បជានាតិ សង្ខារសមុទយំ បជានាតិ សង្ខារនិរោធំ បជានាតិ សង្ខារនិរោធគាមិនឹ បដិបទំ បជានាតិ ។

ហៅថា បរិបូណ៌ដោយទិដ្ឋិក៏បាន ថាបរិបូណ៌ដោយទស្សនៈក៏បាន ថាមកកាន់ព្រះសទ្ធម្មនេះក៏បាន ថាឃើញនូវព្រះសទ្ធម្មនេះក៏បាន ថាប្រកបដោយសេក្ខញាណក៏បាន ថាប្រកបដោយសេក្ខវិជ្ជាក៏បាន ថាដល់ព្រមនូវធម្មស្រោតក៏បាន ថាជាអរិយៈអ្នកមាននិព្វេធិកប្បញ្ញាក៏បាន ថាឋិតនៅជិតនូវទ្វារនៃអមតៈគឺព្រះនិព្វានក៏បាន ។ ចប់សូត្រ ទី ៧ ។

[៩១] ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ក្នុងទីនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវជរានិងមរណៈ ដឹងច្បាស់នូវការកើតឡើងនៃជរានិងមរណៈ ដឹងច្បាស់នូវទីរលត់នៃជរានិងមរណៈ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ ដឹងច្បាស់នូវជាតិ ។ បេ ។ ដឹងច្បាស់នូវភព ... ដឹងច្បាស់នូវឧបាទាន ... ដឹងច្បាស់នូវតណ្ហា ... ដឹងច្បាស់នូវវេទនា ... ដឹងច្បាស់នូវផស្សៈ ... ដឹងច្បាស់នូវសឡាយតនៈ ... ដឹងច្បាស់នូវនាមរូប ... ដឹងច្បាស់នូវវិញ្ញាណ ... ដឹងច្បាស់នូវសង្ខារទាំងឡាយ ដឹងច្បាស់នូវការកើតឡើងនៃសង្ខារ ដឹងច្បាស់នូវទីរលត់នៃសង្ខារ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ។

(៩២) កតមញ្ច ភិក្ខវេ ជរាមរណំ ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ជរា ។ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ មរណំ ។ ឥតិ អយញ្ច ជរា ឥទញ្ច មរណំ ឥទំ វុច្ចតិ ភិក្ខវេ ជរាមរណំ ។ ជាតិសមុទយា ជរាមរណសមុទយោ ជាតិនិរោធា ជរាមរណនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ជរាមរណនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ កតមា ច ភិក្ខវេ ជាតិ ។ បេ ។ កតមោ ច ភិក្ខវេ ភវោ ... កតមញ្ច ភិក្ខវេ ឧបាទានំ ... កតមា ច ភិក្ខវេ តណ្ហា ... វេទនា ... ផស្សោ ... សឡាយតនំ ... នាមរូបំ ... វិញ្ញាណំ ...

(៩២) ម្នាលភិក្ខុទាំងឡាយ ជរានិងមរណៈ តើដូចម្តេច ។ សេចក្តីគ្រាំគ្រា ភាពគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ ដំណើរថយអាយុ ដំណើរចាស់ទុំនៃឥន្ទ្រិយទាំងឡាយ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ នេះហៅថា ជរា ។ ចុតិ ការឃ្លាត ការបែកធ្លាយ ការបាត់បង់ សេចក្តីស្លាប់ ដំណើរស្លាប់ ការធ្វើនូវមរណកាល ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការដាច់នៃជីវិតិន្ទ្រិយ ណា របស់សត្វទាំងឡាយនោះ ៗ ចាកសត្តនិកាយនោះ ៗ នេះហៅថា មរណៈ ។ ម្នាលភិក្ខុទាំងឡាយ ជរានេះផង មរណៈនេះផង នេះហៅថាជរានិងមរណៈ ដូច្នេះឯង ។ ការកើតឡើងនៃជរានិងមរណៈ ព្រោះការកើតឡើងនៃជាតិ ការរលត់នៃជរានិងមរណៈ ព្រោះការរលត់នៃជាតិ មគ្គដ៏ប្រសើរប្រកបដោយអង្គទាំង ៨ នេះឯង ជាបដិបទា ដែលជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ គឺប្រាជ្ញាយល់ឃើញត្រូវ ១ ។ បេ ។ ការតម្កល់ចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ជាតិ តើដូចម្តេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភព តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ ឧបាទាន តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ តណ្ហា តើដូចម្តេច ... វេទនា ... ផស្សៈ ... សឡាយតនៈ ... នាមរូប ... វិញ្ញាណ ...

កតមេ ច ភិក្ខវេ សង្ខារា តយោមេ ភិក្ខវេ សង្ខារា កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោ ឥមេ វុច្ចន្តិ ភិក្ខវេ សង្ខារា ។ អវិជ្ជាសមុទយា សង្ខារសមុទយោ អវិជ្ជានិរោធា សង្ខារនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សង្ខារនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។

(៩៣) យតោ ខោ ភិក្ខវេ ភិក្ខុ ឯវំ ជរាមរណំ បជានាតិ ឯវំ ជរាមរណសមុទយំ បជានាតិ ឯវំ ជរាមរណនិរោធំ បជានាតិ ឯវំ ជរាមរណនិរោធគាមិនឹ បដិបទំ បជានាតិ ។ ឯវំ ជាតឹ បជានាតិ ។ បេ ។ ភវំ...ឧបាទានំ...តណ្ហំ...វេទនំ...ផស្សំ...សឡាយតនំ...នាមរូបំ...វិញ្ញាណំ...ឯវំ សង្ខារេ បជានាតិ ឯវំ សង្ខារសមុទយំ បជានាតិ ឯវំ សង្ខារនិរោធំ បជានាតិ ឯវំ សង្ខារនិរោធគាមិនឹ បដិបទំ បជានាតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ទិដ្ឋិសម្បន្នោ ឥតិបិ ទស្សនសម្បន្នោ ឥតិបិ អាគតោ ឥមំ សទ្ធម្មំ ឥតិបិ

ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយនេះ មាន ៣ គឺ កាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សង្ខារ ។ ការកើតឡើងនៃសង្ខារ ព្រោះការកើតឡើងនៃអវិជ្ជា ការរលត់នៃសង្ខារ ព្រោះការរលត់នៃអវិជ្ជា មគ្គដ៏ប្រសើរប្រកបដោយអង្គទាំង ៨ នេះឯង ជាបដិបទាដែលជាដំណើរទៅកាន់ទីរលត់នៃសង្ខារ គឺ ប្រាជ្ញាយល់ឃើញត្រូវ ១ ។ បេ ។ ការតម្កល់ចិត្តត្រូវ ១ ។

(៩៣) ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុ ដឹងច្បាស់នូវជរាមរណៈយ៉ាងនេះ ដឹងច្បាស់នូវការកើតឡើងនៃជរាមរណៈយ៉ាងនេះ ដឹងច្បាស់នូវទីរលត់នៃជរាមរណៈយ៉ាងនេះ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរាមរណៈយ៉ាងនេះ ។ ដឹងច្បាស់នូវជាតិយ៉ាងនេះ ។ បេ ។ ដឹងច្បាស់នូវភព ... ឧបាទាន ... តណ្ហា ... វេទនា ... ផស្សៈ ... សឡាយតនៈ ... នាមរូប ... វិញ្ញាណ ... នូវសង្ខារទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវការកើតឡើងនៃសង្ខារយ៉ាងនេះ ដឹងច្បាស់នូវទីរលត់នៃសង្ខារយ៉ាងនេះ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថាបរិបូណ៌ដោយទិដ្ឋិក៏បាន ជាបរិបូណ៌ដោយទស្សនៈក៏បាន ជាមកកាន់

បស្សតិ ឥមំ សទ្ធម្មំ ឥតិបិ សេក្ខេន ញាណេន សមន្នាគតោ ឥតិបិ សេក្ខាយ វិជ្ជាយ សមន្នាគតោ ឥតិបិ ធម្មសោតំ សមាបន្នោ ឥតិបិ អរិយោ និព្វេធិកបញ្ញោ ឥតិបិ អមតទ្វារំ អាហច្ច តិដ្ឋតិ ឥតិបីតិ ។ អដ្ឋមំ ។

(៩៨) សាវត្ថិយំ វិហរតិ ... តត្រ ខោ ។ បេ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ជរាមរណំ ន បរិជានន្តិ ជរាមរណសមុទយំ ន បរិជានន្តិ ជរាមរណនិរោធំ ន បរិជានន្តិ ជរាមរណនិរោធគាមិនឹ បដិបទំ ន បរិជានន្តិ ។ ជាតឹ ន បរិជានន្តិ ។ បេ ។ ភវំ ... ឧបាទានំ ... តណ្ហំ ... វេទនំ ... ផស្សំ ... សឡាយតនំ ... នាមរូបំ ... វិញ្ញាណំ ... សង្ខារេ ន បរិជានន្តិ សង្ខារសមុទយំ ន បរិជានន្តិ សង្ខារនិរោធំ ន បរិជានន្តិ សង្ខារនិរោធគាមិនឹ បដិបទំ ន បរិជានន្តិ ។ ន មេតេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា

ព្រះសទ្ធម្មនេះក៏បាន ថាឃើញនូវព្រះសទ្ធម្មនេះក៏បាន ថាប្រកបដោយសេក្ខញាណក៏បាន ថាប្រកបដោយសេក្ខវិជ្ជាក៏បាន ថាដល់ព្រមនូវធម្មសោតក៏បាន ថាជាអរិយៈអ្នកមាននិព្វេធិកប្បញ្ញាក៏បាន ថាឋិតអែបនែបនូវទ្វារនៃអមតៈគឺព្រះនិព្វានក៏បាន ។ ចប់សូត្រទី ៨ ។

( ៩៤ ) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ក្នុងទីនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ មិនកំណត់ដឹងនូវជរាមរណៈ មិនកំណត់ដឹងនូវការកើតឡើងនៃជរាមរណៈ មិនកំណត់ដឹងនូវទីរលត់នៃជរាមរណៈ មិនកំណត់ដឹងនូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរាមរណៈ ។ មិនកំណត់ដឹងនូវជាតិ ។ បេ ។ មិនកំណត់ដឹងនូវភព ... ឧបាទាន ... តណ្ហា ... វេទនា ... ផស្សៈ ... សឡាយតនៈ ... នាមរូប ... វិញ្ញាណ ... នូវសង្ខារទាំងឡាយ មិនកំណត់ដឹងនូវការកើតឡើងនៃសង្ខារ មិនកំណត់ដឹងនូវទីរលត់នៃសង្ខារ មិនកំណត់ដឹងនូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនុ៎ះ តថាគត មិនបានសន្មតថាជាសមណៈក្នុងពួកសមណៈផង មិនបានសន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង

ន ច បនេតេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

(១៩) យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ជរាមរណំ បរិជានន្តិ ជរាមរណសមុទយំ បរិជានន្តិ ជរាមរណនិរោធំ បរិជានន្តិ ជរាមរណនិរោធគាមិនឹ បដិបទំ បរិជានន្តិ ។ ជាតឹ បរិជានន្តិ ។បេ។ ភវំ ... ឧបាទានំ ... តណ្ហំ ... វេទនំ ... ផស្សំ ... សឡាយតនំ ... នាមរូបំ ... វិញ្ញាណំ ... សង្ខារេ បរិជានន្តិ សង្ខារសមុទយំ បរិជានន្តិ សង្ខារនិរោធំ បរិជានន្តិ សង្ខារនិរោធគាមិនឹ បដិបទំ បរិជានន្តិ ។ តេ ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ នវមំ ។

មិនតែប៉ុណ្ណោះ សមណព្រាហ្មណ៍មានអាយុទាំងនុ៎ះឯង រមែងមិនបាន ធ្វើឲ្យជាក់ច្បាស់ មិនសម្រេច នូវសាមញ្ញផល ឬព្រហ្មញ្ញផល ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នទេ ។

(៩៥) ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ ណាមួយ កំណត់ដឹងនូវជរានិងមរណៈ កំណត់ដឹងនូវការកើតឡើងនៃជរានិងមរណៈ កំណត់ដឹងនូវទីរលត់នៃជរានិងមរណៈ កំណត់ដឹងនូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ ។ កំណត់ដឹងនូវជាតិ ។ បេ ។ កំណត់ដឹងនូវភព ... ឧបាទាន ... តណ្ហា ... វេទនា ... ផស្សៈ ... សឡាយតនៈ ... នាមរូប ... វិញ្ញាណ ... នូវសង្ខារទាំងឡាយ កំណត់ដឹងនូវការកើតឡើងនៃសង្ខារ កំណត់ដឹងនូវទីរលត់នៃសង្ខារ កំណត់ដឹងនូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងនោះ តថាគត បានសន្មតថាជាសមណៈក្នុងពួកសមណៈផង សន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង មិនតែប៉ុណ្ណោះ សមណព្រាហ្មណ៍មានអាយុទាំងនោះឯង រមែងបាន ធ្វើឲ្យជាក់ច្បាស់ សម្រេច នូវសាមញ្ញផលផង នូវព្រហ្មញ្ញផលផង ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ចប់សូត្រ ទី ៩ ។

(៩៦) សាវត្ថិយំ វិហរតិ ... តត្រ ខោ ។ បេ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ជរាមរណំ នប្បជានន្តិ ជរាមរណសមុទយំ នប្បជានន្តិ ជរាមរណនិរោធំ នប្បជានន្តិ ជរាមរណនិរោធគាមិនឹ បដិបទំ នប្បជានន្តិ តេ វត ជរាមរណំ សមតិក្កម្ម ឋស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។ ជាតឹ នប្បជានន្តិ ។ បេ ។ ភវំ ... ឧបាទានំ ... តណ្ហំ ... វេទនំ ... ផស្សំ ... សឡាយតនំ ... នាមរូបំ ... វិញ្ញាណំ ... សង្ខារេ នប្បជានន្តិ សង្ខារសមុទយំ នប្បជានន្តិ សង្ខារនិរោធំ នប្បជានន្តិ សង្ខារនិរោធគាមិនឹ បដិបទំ នប្បជានន្តិ តេ វត សង្ខារេ សមតិក្កម្ម ឋស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៩៧) យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ជរាមរណំ បជានន្តិ ជរាមរណសមុទយំ បជានន្តិ ជរាមរណនិរោធំ បជានន្តិ ជរាមរណនិរោធគាមិនឹ បដិបទំ បជានន្តិ តេ វត ជរាមរណំ សមតិក្កម្ម ឋស្សន្តីតិ ឋានមេតំ វិជ្ជតិ ។

អភិសមយសំយុត្ត ទសពលវគ្គ ការមិនដឹងច្បាស់នូវជរានិងមរណៈជាដើម

( ៩៦ ) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ក្នុងទីនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់នូវជរានិងមរណៈ មិនដឹងច្បាស់នូវការកើតឡើងនៃជរានិងមរណៈ មិនដឹងច្បាស់នូវទីរលត់នៃជរានិងមរណៈ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ សមណព្រាហ្មណ៍ទាំងនោះឯង នឹងប្រព្រឹត្តកន្លងនូវជរានិងមរណៈបាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ មិនដឹងច្បាស់នូវជាតិ ។ បេ ។ មិនដឹងច្បាស់នូវភព ... ឧបាទាន ... តណ្ហា ... វេទនា ... ផស្សៈ ... សឡាយតនៈ ... នាមរូប ... វិញ្ញាណ ... នូវសង្ខារទាំងឡាយ មិនដឹងច្បាស់នូវការកើតឡើងនៃសង្ខារ មិនដឹងច្បាស់នូវទីរលត់នៃសង្ខារ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារ សមណព្រាហ្មណ៍ទាំងនោះឯង នឹងប្រព្រឹត្តកន្លងនូវសង្ខារទាំងឡាយបាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។

( ៩៧ ) ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ ណាមួយ ដឹងច្បាស់នូវជរានិងមរណៈ ដឹងច្បាស់នូវការកើតឡើងនៃជរានិងមរណៈ ដឹងច្បាស់នូវទីរលត់នៃជរានិងមរណៈ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ សមណព្រាហ្មណ៍ទាំងនោះឯង នឹងប្រព្រឹត្តកន្លងនូវជរានិងមរណៈបាន ពាក្យដូច្នេះនេះ ទើបសមហេតុ ។

ជាតឹ បជានន្តិ ។ បេ ។ ភវំ ... ឧបាទានំ ... តណ្ហំ ... វេទនំ ... ផស្សំ ... សឡាយតនំ ... នាមរូបំ ... វិញ្ញាណំ ... សង្ខារេ បជានន្តិ សង្ខារសមុទយំ បជានន្តិ សង្ខារនិរោធំ បជានន្តិ សង្ខារនិរោធគាមិនឹ បដិបទំ បជានន្តិ តេ វត សង្ខារេ សមតិក្កម្ម ឋស្សន្តីតិ ឋានមេតំ វិជ្ជតីតិ ។ ទសមំ ។

ទសពលវគ្គោ តតិយោ ។

## តស្សុទ្ទានំ

ទ្វេ ទសពលា ឧបនិសា ច
អញ្ញតិត្ថិយភូមិជោ
ឧបវាណោ បច្ចយោ ភិក្ខុ
ទ្វេ ច សមណព្រាហ្មណាតិ ។

ដឹងច្បាស់នូវជាតិ ។បេ។ ដឹងច្បាស់នូវភព ... ឧបាទាន ... តណ្ហា ... វេទនា ... ផស្សៈ ... សឡាយតនៈ ... នាមរូប ... វិញ្ញាណ ... នូវសង្ខារទាំងឡាយ ដឹងច្បាស់នូវការកើតឡើងនៃសង្ខារ ដឹងច្បាស់នូវការរលត់នៃសង្ខារ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារ សមណព្រាហ្មណ៍ទាំងនោះឯង នឹងប្រព្រឹត្តកន្លងនូវសង្ខារទាំងឡាយបាន ពាក្យដូច្នេះនេះ ទើបសមហេតុ ។ ចប់សូត្រ ទី ១០ ។

ចប់ ទសពលវគ្គ ទី ៣ ។

# ឧទ្ទាននៃទសពលវគ្គនោះគឺ

និយាយអំពីព្រះតថាគតជាទសពល ២ លើក និយាយអំពីហេតុនៃឧបញ្ញាណជាដើម ១ និយាយអំពីពួកអន្យតិរ្ថិយបរិព្វាជកសួរប្រស្នានឹងព្រះសារីបុត្ត ១ និយាយអំពីព្រះភូមិជៈភិក្ខុសួរប្រស្នានឹងព្រះសារីបុត្ត ១ និយាយអំពីព្រះឧបវាណៈមានអាយុសួរប្រស្នានឹងព្រះមានព្រះភាគ ១ និយាយអំពីបច្ច័យគឺអវិជ្ជាជាដើម ១ និយាយអំពីភិក្ខុដឹងច្បាស់នូវជរាមរណៈជាដើម ១ និយាយអំពីសមណព្រាហ្មណ៍ ២ លើក ។

# កឡារខត្តិយវគ្គោ

(៩៨) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ វុត្តមិទំ សារីបុត្ត (បារាយនេ អជិតបញ្ហេ)

យេ ច សង្ខាតធម្មាសេ
យេ ច សេក្ខា បុថូ ឥធ
តេសំ មេ និបកោ ឥរិយំ
បុដ្ឋោ(១) ច ព្រូហិ មារិសាតិ

ឥមស្ស នុ ខោ សារីបុត្ត សង្ខិត្តេន ភាសិតស្ស កថំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

(៩៩) ឯវំ វុត្តេ អាយស្មា សារីបុត្តោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ភគវា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ ។ បេ ។ ទុតិយម្បិ ខោ អាយស្មា សារីបុត្តោ តុណ្ហី អហោសិ ។ តតិយម្បិ ខោ ភគវា

---

១ ម. បុដ្ឋោ មេ ។

# កទ្វារខត្តិយវគ្គ

(៩៨) សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ជិតក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះសារីបុត្តមានអាយុថា ម្នាលសារីបុត្ត អជិតមាណពបានពោលហើយ (ក្នុងអជិតបញ្ហា បារា-យនវគ្គ) នូវពាក្យនេះថា

ពួកបុគ្គលណា មានធម៌ពិចារណា(១)ហើយក្តី ពួកបុគ្គល
ណា ជាសេក្ខៈដ៏ច្រើនក្តី ក្នុងសាសនានេះ បពិត្រព្រះអង្គ
អ្នកនិទ្ទុក្ខ ព្រះអង្គជាអ្នកមានបញ្ញា ខ្ញុំព្រះអង្គ សួរនូវការ
ប្រព្រឹត្តិរបស់បុគ្គលទាំងនោះ សូមទ្រង់សំដែងឲ្យបាន

ម្នាលសារីបុត្ត ភាសិតសង្ខេបនេះ អ្នកគប្បីយល់ឃើញសេចក្តី ដោយពិស្តារ ដោយប្រការដូចម្តេចហ្ន៎ ។

(៩៩) កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តមានអាយុ ក៏នៅស្ងៀម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះសារីបុត្តមានអាយុ ជាគម្រប់ ២ ដង ។ បេ ។ ព្រះសា-រីបុត្តមានអាយុ ក៏នៅស្ងៀម ជាគម្រប់ ២ ដង ។ ព្រះមានព្រះភាគ

---

១ អសេក្ខបុគ្គល ។

អាយស្មន្តំ សារិបុត្តំ អាមន្តេសិ វុត្តមិទំ សារិបុត្ត

(បារាយនេ អជិតបញ្ហេ)

យេ ច សង្ខាតធម្មាសេ

យេ ច សេក្ខា បុថូ ឥធ

តេសំ មេ និបកោ ឥរិយំ

បុដ្ឋោ ច ព្រូហិ មារិសាតិ

ឥមស្ស នុ ខោ សារិបុត្ត សង្ខិត្តេន ភាសិតស្ស

កថំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ ឯវំ វុត្តេ[១] តតិយម្បិ

ខោ អាយស្មា សារិបុត្តោ តុណ្ហី អហោសិ ។

---

១ ឱ.ម. ឯវំ វុត្តេតិ បាឋោ ន ទិស្សតិ ។

ទ្រង់ត្រាស់នឹងព្រះសារីបុត្តមានអាយុ ជាគម្រប់ ៣ ដងថា ម្នាលសារីបុត្ត អជិតមាណពបុច្ឆាពោលហើយ (ក្នុងអជិតបញ្ហា ប៉ារាយនវគ្គ) នូវពាក្យនេះថា

ពួកបុគ្គលណា មានធម៌ពិចារណាហើយក្តី ពួកបុគ្គលណា
ជាសេក្ខៈដ៏ច្រើនក្តី ក្នុងសាសនានេះ បពិត្រព្រះអង្គអ្នក
និទិក្ខ ព្រះអង្គជាអ្នកមានបញ្ញា ខ្ញុំព្រះអង្គ សួរនូវការ
ប្រព្រឹត្តិរបស់បុគ្គលទាំងនោះ សូមទ្រង់សំដែងឲ្យពាន

ម្នាលសារីបុត្ត ភាសិតសង្ខេបនេះ អ្នកគប្បីយល់ឃើញសេចក្តីដោយពិស្តារ ដោយប្រការដូចម្តេចហ្ន៎ ។ កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តមានអាយុ ក៏នៅស្ងៀម ជាគម្រប់ ៣ ដង ។

(១០០) ភូតមិទន្តិ សារីបុត្ត បស្សសីតិ ។ ភូតមិទន្តិ ភន្តេ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ភូតមិទន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា ភូតស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ តទាហារសម្ភវន្តិ(១) យថាភូតំ សម្មប្បញ្ញាយ បស្សតិ តទាហារសម្ភវន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អាហារសម្ភវស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ យថាភូតំ សម្មប្បញ្ញាយ បស្សតិ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា និរោធធម្មស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ ឯវំ ខោ ភន្តេ សេក្ខោ ហោតិ ។

---

១ សម្ភវន្តីតិ ឥតិ ញាហៅ មញ្ញោ ភវើយ្យ ។

(១០០) ម្នាលសារីបុត្ត អ្នកឃើញថា នេះជាភូត (ខន្ធបញ្ចកៈ) ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាភូត លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាភូត ដូច្នេះហើយ ក៏ប្រតិបត្តិ ដើម្បីការនឿយណាយ ដើម្បីការធុញទ្រាន់ ដើម្បីការរលត់ នៃភូត ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា អាហារនៃភូតនោះ រមែងកើតមានព្រម លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា អាហារនៃភូតនោះ កើតមានព្រម ដូច្នេះហើយ ក៏ប្រតិបត្តិ ដើម្បីការនឿយណាយ ដើម្បីការធុញទ្រាន់ ដើម្បីការរលត់ នៃកំណើតអាហារ ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា ធម្មជាតណា ជាភូត ធម្មជាតនោះ មានកិរិយារលត់ទៅជាធម្មតា ព្រោះការរលត់នៃអាហារនោះ លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា ធម្មជាតណា ជាភូត ធម្មជាតនោះ មានកិរិយារលត់ទៅជាធម្មតា ព្រោះការរលត់នៃអាហារនោះហើយ ក៏ប្រតិបត្តិ ដើម្បីការនឿយណាយ ដើម្បីការធុញទ្រាន់ ដើម្បីការរលត់ នៃភូតដែលមានកិរិយារលត់ទៅជាធម្មតា ។ បពិត្រព្រះអង្គដ៏ចម្រើន សេក្ខបុគ្គល យ៉ាងនេះឯង ។

[១០១] កថញ្ច ភន្តេ សង្ខាតធម្មោ ហោតិ ។ ភូតមិទន្តិ ភន្តេ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ភូតមិទន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា ភូតស្ស និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ តទាហារ សម្ភវន្តិ យថាភូតំ សម្មប្បញ្ញាយ បស្សតិ តទាហារ សម្ភវន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អាហារសម្ភវស្ស និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ យថាភូតំ សម្មប្បញ្ញាយ បស្សតិ

( ១០១ ) បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលឈ្មោះថា មានធម៌ពិចារណាហើយ តើដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាភូត លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាភូត ដូច្នេះហើយ ក៏មានចិត្តរួចស្រឡះ ព្រោះការនឿយណាយ ព្រោះការធុញទ្រាន់ ព្រោះការរលត់ ព្រោះការមិនប្រកាន់មាំ នូវភូត ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា អាហារនៃភូតនោះ រមែងកើតមានព្រម លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា អាហារនៃភូតនោះ រមែងកើតមានព្រម ដូច្នេះហើយ ក៏មានចិត្តរួចស្រឡះ ព្រោះការនឿយណាយ ព្រោះការធុញទ្រាន់ ព្រោះការរលត់ ព្រោះការមិនប្រកាន់មាំ នូវកំណើតនៃអាហារ ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា ធម្មជាតណាជាភូត ធម្មជាតនោះ មានកិរិយារលត់ទៅជាធម្មតា ព្រោះការរលត់

តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា និរោធធម្មស្ស និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ។ ឯវំ ខោ ភន្តេ សង្ខាតធម្មោ ហោតិ ។ ឥតិ ខោ ភន្តេ យំ តំ វុត្តំ (បារាយនេ អជិតបញ្ហេ)

យេ ច សង្ខាតធម្មាសេ
យេ ច សេក្ខា បុថូ ឥធ
តេសម្មេ និបកោ ឥរិយំ
បុដ្ឋោ ច ព្រូហិ មារិសាតិ

ឥមស្ស ខោហំ ភន្តេ សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។

នៃអាហារនោះ លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា ធម្មជាតណា ជាភូត ធម្មជាតនោះ មានកិរិយារលត់ទៅជាធម្មតា ព្រោះការរលត់នៃអាហារនោះ ដូច្នេះហើយ ក៏មានចិត្តរួចស្រឡះ ព្រោះការនឿយណាយ ព្រោះការធុញទ្រាន់ ព្រោះការរលត់ ព្រោះការមិនប្រកាន់មាំ នូវភូត ដែលមានកិរិយារលត់ទៅជាធម្មតា ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលមានធម៌ពិចារណាហើយ យ៉ាងនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលអជិតមាណពបានពោលហើយ ( ក្នុងអជិតបញ្ហា បារាយនវគ្គ ) ថា

ពួកបុគ្គលណា មានធម៌ពិចារណាហើយក្តី ពួកបុគ្គលណា
ជាសេក្ខៈដ៏ច្រើនក្តី ក្នុងសាសនានេះ បពិត្រព្រះអង្គអ្នក
និទ្ទុក្ខ ព្រះអង្គជាអ្នកមានបញ្ញា ខ្ញុំព្រះអង្គសួរនូវការប្រព្រឹត្តិ
របស់បុគ្គលទាំងនោះ សូមទ្រង់សំដែងឲ្យទាន
សិនមានការបកស្រាយ ដោយប្រការដូច្នេះឯង

បពិត្រព្រះអង្គដ៏ចម្រើន ភាសិតសង្ខេបនេះ ខ្ញុំព្រះអង្គយល់សេចក្តី ដោយពិស្តារ យ៉ាងនេះ ។

[១០២] សាធុ សាធុ សារីបុត្ត ភូតមិទន្តិ សារីបុត្ត យថាភូតំ សម្មប្បញ្ញាយ បស្សតិ ភូតមិទន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា ភូតស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ តទាហារសម្ភវន្តិ យថាភូតំ សម្មប្បញ្ញាយ បស្សតិ តទាហារសម្ភវន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អាហារសម្ភវស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ យថាភូតំ សម្មប្បញ្ញាយ បស្សតិ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា និរោធធម្មស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ ឯវំ ខោ សារីបុត្ត សេក្ខោ ហោតិ ។

(១០៤) ម្នាលសារីបុត្ត ត្រូវហើយ ត្រូវហើយ ម្នាលសារីបុត្ត បុគ្គល ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាភូត លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាភូត ដូច្នេះហើយ ក៏ប្រតិបត្តិ ដើម្បីការនឿយណាយ ដើម្បីការធុញទ្រាន់ ដើម្បីការរលត់ នៃភូត ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា អាហារនៃភូតនោះ រមែងកើតមានព្រម លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា អាហារនៃភូតនោះ រមែងកើតមានព្រម ដូច្នេះហើយ ក៏ប្រតិបត្តិ ដើម្បីការនឿយណាយ ដើម្បីការធុញទ្រាន់ ដើម្បីការរលត់ នៃកំណើតអាហារ ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា ធម្មជាតណា ជាភូត ធម្មជាតនោះ មានកិរិយារលត់ទៅជាធម្មតា ព្រោះការរលត់នៃអាហារនោះ លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា ធម្មជាតណា ជាភូត ធម្មជាតនោះ មានកិរិយារលត់ទៅជាធម្មតា ព្រោះការរលត់នៃអាហារនោះ ដូច្នេះហើយ ក៏ប្រតិបត្តិ ដើម្បីការនឿយណាយ ដើម្បីការធុញទ្រាន់ ដើម្បីការរលត់ នៃភូត ដែលមានកិរិយារលត់ទៅជាធម្មតា ។ ម្នាលសារីបុត្ត សេក្ខបុគ្គល យ៉ាងនេះឯង ។

(១០៣) កថញ្ច សារីបុត្ត សង្ខាតធម្មោ ហោតិ ។ ភូតមិទន្តិ សារីបុត្ត យថាភូតំ សម្មប្បញ្ញាយ បស្សតិ ភូតមិទន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា ភូតស្ស និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ តទាហារសម្ភវន្តិ យថាភូតំ សម្មប្បញ្ញាយ បស្សតិ តទាហារសម្ភវន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អាហារសម្ភវស្ស និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ យថាភូតំ សម្មប្បញ្ញាយ បស្សតិ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ យថាភូតំ សម្មប្បញ្ញាយ ទិស្វា

( ១០៣ ) ម្នាលសារីបុត្ត បុគ្គលដែលឈ្មោះថាមានធម៌ពិចារណាហើយ តើដូចម្តេច ។ ម្នាលសារីបុត្ត បុគ្គល ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាភូត លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាភូត ដូច្នេះហើយ ក៏មានចិត្តប្រស្រឡះ ព្រោះការនឿយណាយ ព្រោះការធុញទ្រាន់ ព្រោះការរលត់ ព្រោះការមិនប្រកាន់មាំ នូវភូត ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា អាហារនៃភូតនោះ រមែងកើតមានព្រម លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា អាហារនៃភូតនោះ រមែងកើតមានព្រម ដូច្នេះហើយ ក៏មានចិត្តប្រស្រឡះ ព្រោះការនឿយណាយ ព្រោះការធុញទ្រាន់ ព្រោះការរលត់ ព្រោះការមិនប្រកាន់មាំ នូវកំណើតនៃអាហារ ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា ធម្មជាតណា ជាភូត ធម្មជាតនោះ មានកិរិយារលត់ទៅជាធម្មតា ព្រោះការរលត់នៃអាហារនោះ លុះឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា ធម្មជាតណា ជាភូត ធម្មជាតនោះ មានកិរិយារលត់ទៅជាធម្មតា ព្រោះការរលត់នៃអាហារនោះហើយ

និរោធធម្មស្ស និព្ពិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ។ ឯវំ ខោ សារីបុត្ត សង្ខាតធម្មោ ហោតិ ។ ឥតិ ខោ សារីបុត្ត យំ តំ វុត្តំ (បារាយនេ អជិតបញ្ហេ)

យេ ច សង្ខាតធម្មាសេ
យេ ច សេក្ខា បុថូ ឥធ
តេសំ មេ និបកោ ឥរិយំ
បុដ្ឋោ ច ព្រូហិ មារិសាតិ

ឥមស្ស ខោ សារីបុត្ត សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ បឋមំ ។

[១០៦] សាវត្ថិយំ វិហរតិ ... អថខោ កឡារខត្តិយោ ភិក្ខុ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិ-ត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនី-យំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

ក៏មានចិត្តរួចស្រឡះ ព្រោះការនឿយណាយ ព្រោះការធុញទ្រាន់ ព្រោះការរលត់ ព្រោះការមិនប្រកាន់មាំ នូវភូតដែលមានកិរិយារលត់ទៅជាធម្មតា ។ ម្នាលសារីបុត្ត បុគ្គលដែលឈ្មោះថា មានធម៌ពិចារណាហើយ យ៉ាងនេះឯង ។ ម្នាលសារីបុត្ត ពាក្យដែលអជិតមាណពបានពោលហើយ ( ក្នុងអជិតបញ្ហា បារាយនវគ្គ ) ថា

ពួកបុគ្គលណា មានធម៌ពិចារណាហើយក្តី ពួកបុគ្គលណា
ជាសេក្ខៈដ៏ច្រើនក្តី ក្នុងសាសនានេះ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ
ព្រះអង្គជាអ្នកមានបញ្ញា ខ្ញុំព្រះអង្គ សួរនូវការប្រព្រឹត្តិរបស់
បុគ្គលទាំងនោះ សូមទ្រង់សំដែងឲ្យបាន

សិងមានការបកស្រាយ ដោយប្រការដូច្នេះឯង

ម្នាលសារីបុត្ត ភាសិតសង្ខេបនេះ អ្នកគប្បីយល់ឃើញសេចក្តីដោយពិស្តារ យ៉ាងនេះ ។ ចប់សូត្រ ទី ១ ។

( ១០៤ ) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... គ្រានោះ ភិក្ខុឈ្មោះកឡារខត្តិយៈ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។

ឯកមន្តំ និសិន្នោ ខោ កឡារខត្តិយោ ភិក្ខុ អាយស្មន្តំ សារីបុត្តំ ឯតទវោច មោឡិយផគ្គុនោ អាវុសោ សារីបុត្ត ភិក្ខុ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោតិ នហិ នូន សោ អាយស្មា ឥមស្មឹ ធម្មវិនយេ អស្សាសមលត្ថាតិ តេនហាយស្មា សារីបុត្តោ ឥមស្មឹ ធម្មវិនយេ អស្សាសម្បត្តោតិ ។ ន ខ្វាហំ អាវុសោ កង្ខាមីតិ ។ អាយតឹ បនាវុសោតិ ។ ន ខ្វាហំ អាវុសោ វិចិកិច្ឆាមីតិ ។

(១០៨) អថខោ កឡារខត្តិយោ ភិក្ខុ ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ កឡារខត្តិយោ ភិក្ខុ ភគវន្តំ ឯតទវោច អាយស្មតា ភន្តេ សារីបុត្តេន អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ

លុះកឡារខត្តិយភិក្ខុ អង្គុយក្នុងទីសមគួរហើយ ក៏ពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលសារីបុត្តមានអាយុ ភិក្ខុឈ្មោះមោលិយផគ្គុនបានលាសិក្ខា ត្រឡប់ទៅកាន់ហីនភេទហើយ ព្រះមោលិយផគ្គុនមានអាយុនោះ មិនបាននូវទីពឹងក្នុងធម្មវិន័យដោយពិតទេ បើដូច្នោះ មានតែព្រះសារីបុត្តមានអាយុ បានដល់នូវទីពឹងក្នុងធម្មវិន័យនេះហើយ ។ ព្រះសារីបុត្តពោលថា ម្នាលអាវុសោ ខ្ញុំមិនសង្ស័យទេ ។ ព្រះកឡារខត្តិយៈពោលថា ម្នាលអាវុសោ ចុះបដិសន្ធិក្នុងខាងមុខទៀត ។ ម្នាលអាវុសោ ខ្ញុំមិនងឿងឆ្ងល់ទេ ។

(១០៥) គ្រានោះ កឡារខត្តិយភិក្ខុ ក្រោកអំពីអាសនៈចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះកឡារខត្តិយភិក្ខុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុ ពោលអួតព្រះអរហត្តផលថា ខ្ញុំដឹងច្បាស់ថា ជាតិ(របស់អាត្មាអញ)អស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ

ឥត្ថត្តាយាតិ បជានាមីតិ ។ អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន សារីបុត្តំ អាមន្តេហិ សត្ថា តំ អាវុសោ សារីបុត្ត អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោច សត្ថា តំ អាវុសោ សារីបុត្ត អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ អាយស្មា សារីបុត្តោ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

(១០៦) ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សារីបុត្តំ ភគវា ឯតទវោច សច្ចំ កិរ តយា សារីបុត្ត អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ ន ខោ ភន្តេ ឯតេហិ បទេហិ ឯតេហិ ព្យញ្ជនេហិ អត្ថោ ច វុត្តោតិ ។ យេន កេនចិបិ សារីបុត្ត

ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុមួយរូបមកថា ម្នាលភិក្ខុ អ្នកចូរមក ចូរហៅសារីបុត្តតាមពាក្យតថាគតមកថា បពិត្រព្រះសារីបុត្តមានអាយុ ព្រះសាស្តាត្រាស់ហៅលោកម្ចាស់ ។ ភិក្ខុនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណា ព្រះអង្គ ហើយក៏ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា បពិត្រព្រះសារីបុត្តមានអាយុ ព្រះសាស្តាត្រាស់ហៅលោកម្ចាស់ ។ ព្រះសារីបុត្តមានអាយុ ទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។

[ ១០៦ ] លុះព្រះសារីបុត្តមានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគត្រាស់សួរដូច្នេះថា ម្នាលសារីបុត្ត ឮថា អ្នកពោលអួតអរហត្តផលថា ខ្ញុំដឹងច្បាស់ថា ជាតិ(របស់អាត្មាអញ)អស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ដូច្នេះពិតឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានពោលសេចក្តី ដោយបទទាំងនេះ ដោយព្យញ្ជនៈទាំងនេះទេ ។ ម្នាលសារីបុត្ត

បរិយាយេន កុលបុត្តោ អញ្ញំ ព្យាករោតិ អថខោ ព្យាកតំ ព្យាកតតោ ទដ្ឋព្វន្តិ ។ ននុ អហម្បិ ភន្តេ ឯវំ វទាមិ ន ខោ ភន្តេ ឯតេហិ បទេហិ ឯតេហិ ព្យញ្ជនេហិ អត្ថោ ច វុត្តោតិ ។ សចេ តំ សារីបុត្ត ឯវំ បុច្ឆេយ្យុំ កថំ ជានតា បន តយា អាវុសោ សារីបុត្ត កថំ បស្សតា អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ឯវំ បុដ្ឋោ តំ សារីបុត្ត កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ កថំ ជានតា បន តយា អាវុសោ សារីបុត្ត កថំ បស្សតា អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ

កុលបុត្តពោលអរហត្តផល សូម្បីដោយបរិយាយណាមួយ ត្រូវតែឃើញនូវពាក្យពោលអួត ថាជាពាក្យពោលអួត ដោយពិត ៗ បពិត្រព្រះអង្គដ៏ចម្រើន ក្រែងខ្ញុំព្រះអង្គទើបនឹងក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មិនបានពោលសេចក្តី ដោយបទទាំងនុ៎ះ ដោយព្យញ្ជនៈទាំងនុ៎ះទេ ដូច្នេះឬ ៗ ម្នាលសារីបុត្ត ប្រសិនបើជនទាំងឡាយ សួរអ្នកយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះលោកបានដឹងដូចម្តេច បានឃើញដូចម្តេច បានជាពោលអរហត្តផលថា ខ្ញុំដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ម្នាលសារីបុត្ត កាលបើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយដូចម្តេច ៗ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះលោកដឹងដូចម្តេច ឃើញដូចម្តេច បានជាពោលអរហត្តផលថា ខ្ញុំដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ

កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ឯវំ បុដ្ឋោហំ ភន្តេ ឯវំ ព្យាករេយ្យំ យំនិទានាវុសោ ជាតិ តស្ស និទានស្ស សង្ខយា ខីណស្មឹ ខីណាមីតិ វិទិត្វា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ឯវំ បុដ្ឋោហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។

(១០៧) សចេ បន តំ សារីបុត្ត ឯវំ បុច្ឆេយ្យុំ ជាតិ បនាវុសោ សារីបុត្ត កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ ឯវំ បុដ្ឋោ ត្វំ សារីបុត្ត កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ ជាតិ បនាវុសោ សារីបុត្ត កឹនិទានា កឹសមុទយា កឹជាតិកា

សោឡសកិច្ចអាត្មាអញ បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គ គប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ជាតិមានធម៌ណាជាហេតុ កាលបើបច្ច័យនៃជាតិអស់ហើយ ព្រោះការអស់ទៅនៃហេតុនោះ យើងក៏ដឹងច្បាស់ថា ផលគឺជាតិអស់ហើយ ទើបប្តេជ្ញាថា ជាតិ ( របស់អាត្មាអញ ) អស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញ បាននៅរួចហើយ សោឡសកិច្ចអាត្មាអញ បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡស-កិច្ចនេះទៀត មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គ គប្បីដោះស្រាយ យ៉ាងនេះឯង ។

( ១០៧ ) ម្នាលសារីបុត្ត ប្រសិនបើជនទាំងឡាយ សួរអ្នកយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះជាតិ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ម្នាលសារីបុត្ត កាលបើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះជាតិ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត

កឹបភវាតិ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យំ ជាតិ ខោ អាវុសោ ភវនិទានា ភវសមុទយា ភវជាតិកា ភវប្បភវាតិ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។

(១០៨) សចេ បន តំ សារីបុត្ត ឯវំ បុច្ឆេយ្យុំ ភវោ បនាវុសោ សារីបុត្ត កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោតិ ឯវំ បុដ្ឋោ ត្វំ សារីបុត្ត កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ ភវោ បនាវុសោ សារីបុត្ត កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោតិ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យំ ភវោ ខោ អាវុសោ ឧបាទាននិទានោ ឧបាទានសមុទយោ ឧបាទានជាតិកោ ឧបាទានប្បភវោតិ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។

មានអ្វីជាប្រភព បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ជាតិ មានភពជាហេតុ មានភពនាំឲ្យកើត មានភពជាកំណើត មានភពជាប្រភព បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គ គប្បីដោះស្រាយ យ៉ាងនេះឯង ។

(១០៨) ម្នាលសារីបុត្ត ប្រសិនបើជនទាំងឡាយ សួរអ្នកយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះភព មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ម្នាលសារីបុត្ត កាលបើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះភព មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភព មានឧបាទានជាហេតុ មានឧបាទាននាំឲ្យកើត មានឧបាទានជាកំណើត មានឧបាទានជាប្រភព បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គ គប្បីដោះស្រាយ យ៉ាងនេះឯង ។

(១០៩) សចេ បន តំ សារីបុត្ត ឯវំ បុច្ឆេយ្យុំ ឧបាទានំ បនាវុសោ សារីបុត្ត កឹនិទានំ ។ បេ ។ កឹបភវន្តិ ឯវំ បុដ្ឋោ ត្វំ សារីបុត្ត កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ ឧបាទានំ បនាវុសោ សារីបុត្ត កឹនិទានំ ។ បេ ។ កឹបភវន្តិ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យំ ឧបាទានំ ខោ អាវុសោ តណ្ហានិទានំ ។ បេ ។ តណ្ហាបភវន្តិ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។

(១១០) សចេ បន តំ សារីបុត្ត ឯវំ បុច្ឆេយ្យុំ តណ្ហា បនាវុសោ សារីបុត្ត កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ ឯវំ បុដ្ឋោ ត្វំ សារីបុត្ត កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ តណ្ហា បនាវុសោ សារីបុត្ត កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ ឯវំ បុដ្ឋាហំ ភន្តេ

[១០៩] ម្នាលសារីបុត្ត ប្រសិនបើជនទាំងឡាយ សួរអ្នកយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះឧបាទាន មានអ្វីជាហេតុ ។ បេ ។ មានអ្វីជាប្រភព ម្នាលសារីបុត្ត កាលបើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះឧបាទាន មានអ្វីជាហេតុ ។ បេ ។ មានអ្វីជាប្រភព បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ឧបាទាន មានតណ្ហាជាហេតុ ។ បេ ។ មានតណ្ហាជាប្រភព បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយ យ៉ាងនេះឯង ។

[១១០] ម្នាលសារីបុត្ត ប្រសិនបើជនទាំងឡាយ សួរអ្នកយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះតណ្ហា មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព ម្នាលសារីបុត្ត កាលបើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះតណ្ហា មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំ

ឯវំ ព្យាករេយ្យំ តណ្ហា ខោ អាវុសោ វេទនានិទានា វេទនាសមុទយា វេទនាជាតិកា វេទនាបភវាតិ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។

[១១១] សចេ បន តំ សារីបុត្ត ឯវំ បុច្ឆេយ្យុំ វេទនា បនាវុសោ សារីបុត្ត កឹនិទានា ។ បេ ។ កឹបភវាតិ ឯវំ បុដ្ឋោ ត្វំ សារីបុត្ត កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ វេទនា បនាវុសោ សារីបុត្ត កឹនិទានា ។ បេ ។ កឹបភវាតិ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យំ វេទនា ខោ អាវុសោ ផស្សនិទានា ។ បេ ។ ផស្សប្បភវាតិ ឯវំ បុដ្ឋាហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។

ព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ តណ្ហា មានវេទនាជាហេតុ មានវេទនានាំឲ្យកើត មានវេទនាជាកំណើត មានវេទនាជាប្រភព បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គ គប្បីដោះស្រាយ យ៉ាងនេះឯង ។

( ២១១ ) ម្នាលសារីបុត្ត ប្រសិនបើជនទាំងឡាយ សួរអ្នកយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះវេទនា មានអ្វីជាហេតុ ។ បេ ។ មានអ្វីជាប្រភព ម្នាលសារីបុត្ត កាលបើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា នែសារីបុត្តមានអាយុ ចុះវេទនា មានអ្វីជាហេតុ ។ បេ ។ មានអ្វីជាប្រភព បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ វេទនា មានផស្សៈជាហេតុ ។ បេ ។ មានផស្សៈជាប្រ-ភព បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គ គប្បីដោះស្រាយ យ៉ាងនេះឯង ។

(១១២) សចេ បន តំ សារិបុត្ត ឯវំ បុច្ឆេយ្យុំ កថំ ជានតោ បន តេ អាវុសោ សារិបុត្ត កថំ បស្សតោ យា វេទនាសុ នន្ទី សា ន ឧបដ្ឋាសីតិ ឯវំ បុដ្ឋោ ត្វំ សារិបុត្ត កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ កថំ ជានតោ បន តេ អាវុសោ សារិបុត្ត កថំ បស្សតោ យា វេទនាសុ នន្ទី សា ន ឧបដ្ឋាសីតិ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យំ តិស្សោ ខោ ឥមា អាវុសោ វេទនា កតមា តិស្សោ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ឥមា ខោ អាវុសោ តិស្សោ វេទនា អនិច្ចា យទនិច្ចំ តំ ទុក្ខន្តិ វិទិតំ យា វេទនាសុ នន្ទី សា ន ឧបដ្ឋាសីតិ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។

(១១២) ម្នាលសារីបុត្ត ប្រសិនបើជនទាំងឡាយ សួរអ្នកយ៉ាងនេះថា នែសារីបុត្តមានអាយុ លោកបានដឹងដូចម្តេច ឃើញដូចម្តេច បានជាសេចក្តីត្រេកអរក្នុងវេទនាទាំងឡាយ មិនតាំងឡើងបាន ម្នាលសារីបុត្ត កាលបើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយ សួរខ្ញុំព្រះអង្គយ៉ាងនេះថា នែសារីបុត្តមានអាយុ លោកបានដឹងដូចម្តេច ឃើញដូចម្តេច បានជាសេចក្តីត្រេកអរក្នុងវេទនាទាំងឡាយ មិនតាំងឡើងបាន បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ វេទនានេះ មាន ៣ វេទនាទាំង ៣ តើដូចម្តេច គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ម្នាលអាវុសោទាំងឡាយ វេទនាទាំង ៣ នេះឯង មិនទៀង ធម្មជាតណាមិនទៀង ធម្មជាតនោះ យើងដឹងច្បាស់ថាជាទុក្ខ បានជាសេចក្តីត្រេកអរក្នុងវេទនាទាំងឡាយមិនតាំងឡើងបាន បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយ យ៉ាងនេះឯង ។

(១១៣) សាធុ សាធុ សារីបុត្ត អយម្បិ ខោ សារីបុត្ត បរិយាយោ ឯតស្សេវ អត្ថស្ស សង្ខិត្តេន វេយ្យាករណាយ យំកិញ្ចិ វេទយិតំ តំ ទុក្ខស្មិន្តិ សចេ បន តំ សារីបុត្ត ឯវំ បុច្ឆេយ្យុំ កថំ វិមោក្ខា បន តយា អាវុសោ សារីបុត្ត អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ឯវំ បុដ្ឋោ ត្វំ សារីបុត្ត កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ កថំ វិមោក្ខា បន តយា អាវុសោ សារីបុត្ត អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ

(១១៣) ម្នាលសារីបុត្ត ត្រូវហើយ ត្រូវហើយ ម្នាលសារីបុត្ត នេះឯង ជាបរិយាយប្រព្រឹត្តទៅដើម្បីការដោះស្រាយនូវសេចក្តីនេះ ដោយសង្ខេបថា ការទទួលអារម្មណ៍ណាមួយ ការទទួលអារម្មណ៍នោះ ជាទុក្ខ ម្នាលសារីបុត្ត ចុះប្រសិនបើជនទាំងឡាយសួរយ៉ាងនេះថា នែសារីបុត្តមានអាយុ ព្រោះវិមោក្ខដូចម្តេច លោកទើបពោលអ្នកអរហត្តផលថា យើងដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ម្នាលសារីបុត្ត កាលបើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើជនទាំងឡាយសួរខ្ញុំព្រះអង្គយ៉ាងនេះថា នែសារីបុត្តមានអាយុ ព្រោះវិមោក្ខដូចម្តេច លោកទើបពោលអ្នកអរហត្តផលថា ខ្ញុំដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ

នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ឯវំ បុដ្ឋោ អហំ កឡារ ឯវំ ព្យាករេយ្យំ អជ្ឈត្តំវិមោក្ខា ខ្វាហំ អាវុសោ សព្វុបាទានក្ខយា តថាសតោ វិហរាមិ យថាសតំ វិហរន្តំ អាសវា នានុស្សវន្តិ អត្តានញ្ច នាវជានាមីតិ ឯវំ បុដ្ឋោ អហំ កឡារ ឯវំ ព្យាករេយ្យន្តិ ។

(១១៦) សាធុ សាធុ សារីបុត្ត អយម្បិ ខោ សារីបុត្ត បរិយាយោ ឯតស្សេវ អត្ថស្ស សង្ខិត្តេន វេយ្យាករណាយ យេ អាសវា សមណេន វុត្តា តេស្វាហំ ន កង្ខាមិ តេ មេ បហីនាតិ ន វិចិកិច្ឆាមីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។

មគ្គការនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គ គប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រោះតែអជ្ឈត្តវិមោក្ខ(១) ទើបអាសវៈទាំងឡាយ មិនជាប់តាមយើងដែលមានសតិយ៉ាងណា យើងក៏មានសតិយ៉ាងនោះ ព្រោះការអស់ទៅនៃឧបាទានទាំងពួង មួយទៀត យើងមិនបានមើលងាយនូវខ្លួនឡើយ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គគប្បីដោះស្រាយ យ៉ាងនេះឯង ។

[ ១១៤ ] ម្នាលសារីបុត្ត ត្រូវហើយ ត្រូវហើយ ម្នាលសារីបុត្ត នេះឯង ជាបរិយាយប្រព្រឹត្តទៅដើម្បីការដោះស្រាយសេចក្ដីនេះ ដោយសង្ខេបថា អាសវៈទាំងឡាយណា ដែលព្រះពុទ្ធជាសមណៈបានពោលហើយ យើងមិនសង្ស័យក្នុងអាសវៈទាំងនោះទេ អាសវៈទាំងនោះ យើងបានលះហើយ ព្រោះហេតុនោះ យើងមិនងឿងឆ្ងល់ឡើយ ។ ព្រះមានព្រះភាគ បានត្រាស់នូវពាក្យនេះហើយ លុះព្រះសុគតត្រាស់នូវពាក្យនេះរួចហើយ ក៏ទ្រង់ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ ។

---

១ សំដៅយកព្រះអរហត្តដែលបុគ្គលបានសម្រេចដោយការកំណត់នូវសង្ខារខាងក្នុង ។

អភិសមយសំយុត្តស្ស កឡារខត្តិយវគ្គេ ភិក្ខាមន្តនំ

(១១៨) តត្រ ខោ អាយស្មា សារិបុត្តោ អចិរបក្កន្តស្ស ភគវតោ ភិក្ខូ អាមន្តេសិ បុព្វេ អប្បដិសំវិទិតំ មំ អាវុសោ ភគវា បឋមំ បញ្ហំ អបុច្ឆិ តស្ស មេ អហោសិ ទន្ធាយិតត្តំ យតោ ច ខោ មេ អាវុសោ ភគវា បឋមំ បញ្ហំ អនុមោទិ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ទិវសញ្ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ ទិវសំបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ រត្តឹ ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ រត្តឹបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ រត្តិន្ទិវញ្ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ រត្តិន្ទិវំបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ

(១១៩) កាលដែលព្រះមានព្រះភាគ ស្តេចចេញទៅមិនយូរប៉ុន្មាន ព្រះសារីបុត្តមានអាយុ ក៏ហៅភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ បានសួរប្រស្នាទី ១ នឹងខ្ញុំ ជាប្រស្នាដែលខ្ញុំមិនធ្លាប់ដឹងពីមុនមកទេ សេចក្តីយឺតយូរក្នុងការដោះស្រាយ ក៏កើតមានដល់ខ្ញុំ ម្នាលអាវុសោទាំងឡាយ កាលដែលព្រះមានព្រះភាគ បានអនុមោទនាប្រស្នាជាដំបូងរបស់ខ្ញុំហើយ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ប្រសិនបើព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ចំពោះអាត្មាអញ អស់មួយថ្ងៃ អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ថ្វាយព្រះមានព្រះភាគ អស់មួយថ្ងៃ ប្រសិនបើព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ចំពោះអាត្មាអញ អស់មួយយប់ អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ថ្វាយព្រះមានព្រះភាគ អស់មួយយប់ ប្រសិនបើព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ចំពោះអាត្មាអញ អស់មួយយប់មួយថ្ងៃ អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ

អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ ទ្វេ
រត្តិន្ទិវានិ ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ ។ បេ ។ ទ្វេ
រត្តិន្ទិវានិបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ ។ បេ ។
តីណិ រត្តិន្ទិវានិ ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ ...
តីណិ រត្តិន្ទិវានិបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ ...
ចត្តារិ រត្តិន្ទិវានិ ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ ...
ចត្តារិ រត្តិន្ទិវានិបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ ...
បញ្ច រត្តិន្ទិវានិ ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ ...
បញ្ច រត្តិន្ទិវានិបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ ...
ឆ រត្តិន្ទិវានិ ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ ...
ឆ រត្តិន្ទិវានិបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ ...
សត្ត រត្តិន្ទិវានិ ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ
អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ
សត្ត រត្តិន្ទិវានិបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ
អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហីតិ ។

ថ្វាយព្រះមានព្រះភាគ អស់មួយយប់មួយថ្ងៃ ប្រសិនបើព្រះមានព្រះភាគ សួរសេចក្តីនុ៎ះ ចំពោះអាត្មាអញ អស់ ២ យប់ ២ ថ្ងៃ ។បេ។ អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ថ្វាយព្រះមានព្រះភាគ អស់ ២ យប់ ២ ថ្ងៃ ។បេ។ ប្រសិនបើព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ចំពោះអាត្មាអញ អស់ ៣ យប់ ៣ ថ្ងៃ ... អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ថ្វាយព្រះមានព្រះភាគ អស់ ៣ យប់ ៣ ថ្ងៃ ... ប្រសិនបើព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ចំពោះអាត្មាអញ អស់ ៤ យប់ ៤ ថ្ងៃ ... អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ថ្វាយព្រះមានព្រះភាគ អស់ ៤ យប់ ៤ ថ្ងៃ ... ប្រសិនបើ ព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ចំពោះអាត្មាអញ អស់ ៥ យប់ ៥ ថ្ងៃ ... អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ថ្វាយព្រះមានព្រះភាគ អស់ ៥ យប់ ៥ ថ្ងៃ ... ប្រសិនបើព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ចំពោះអាត្មាអញ អស់ ៦ យប់ ៦ ថ្ងៃ ... អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ថ្វាយព្រះមានព្រះភាគ អស់ ៦ យប់ ៦ ថ្ងៃ ... ប្រសិនបើព្រះមានព្រះភាគ សួរសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ចំពោះអាត្មាអញ អស់ ៧ យប់ ៧ ថ្ងៃ អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ថ្វាយព្រះមានព្រះភាគ អស់ ៧ យប់ ៧ ថ្ងៃ ។

(១១៦) អថខោ កឡារខត្តិយោ ភិក្ខុ ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ កឡារខត្តិយោ ភិក្ខុ ភគវន្តំ ឯតទវោច អាយស្មតា ភន្តេ សារីបុត្តេន សីហនាទោ នទិតោ បុព្វេ អប្បដិសំវិទិតំ មំ អាវុសោ ភគវា បឋមំ បញ្ហំ អបុច្ឆិ តស្ស មេ អហោសិ ទន្ធាយិតត្តំ យតោ ច ខោ មេ អាវុសោ ភគវា បឋមំ បញ្ហំ អនុមោទិ តស្ស មយ្ហំ អាវុសោ ឯតទហោសិ ទិវសញ្ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ ទិវសម្បាហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ រត្តិញ្ចេបិ ។ បេ ។ រត្តិន្ទិវំ ចេបិ មំ ភគវា ... ទ្វេ រត្តិន្ទិវានិ ចេបិ មំ ភគវា ... តីណិ ... ចត្តារិ ... បញ្ច ... ឆ ... សត្ត រត្តិន្ទិវានិ ចេបិ មំ ភគវា ឯតមត្ថំ បុច្ឆេយ្យ

(១១៦) គ្រានោះ កឡារខត្តិយភិក្ខុក្រោកអំពីអាសនៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះកឡារខត្តិយភិក្ខុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តមានអាយុបន្លឺសីហនាទថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគបានសួរប្រស្នាទី ១ នឹងខ្ញុំ ជាប្រស្នាដែលខ្ញុំមិនធ្លាប់ដឹងមកពីកាលមុនទេ សេចក្តីយឺតយូរក្នុងការដោះស្រាយក៏កើតមានដល់ខ្ញុំ ម្នាលអាវុសោទាំងឡាយ កាលណាបើព្រះមានព្រះភាគ បានអនុមោទនាប្រស្នាជាដំបូងរបស់ខ្ញុំហើយ ម្នាលអាវុសោទាំងឡាយ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ប្រសិនបើព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ចំពោះអាត្មាអញ អស់១ថ្ងៃ អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ថ្វាយព្រះមានព្រះភាគ អស់១ថ្ងៃ ប្រសិនបើអស់១យប់ ។ បេ ។ ប្រសិនបើព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ចំពោះអាត្មាអញ អស់១ យប់ ១ ថ្ងៃ ... ប្រសិនបើព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ចំពោះអាត្មាអញ អស់ ២ យប់ ២ ថ្ងៃ ... ៣ យប់ ៣ ថ្ងៃ... ៤ យប់ ៤ ថ្ងៃ... ៥ យប់៥ថ្ងៃ... ៦ យប់ ៦ ថ្ងៃ... ប្រសិនបើព្រះមានព្រះភាគសួរសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ

អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ សត្ត រត្តិន្ទិវានិបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហីតិ ។

(១១៧) សា ហិ ភិក្ខុ សារីបុត្តស្ស ធម្មធាតុ សុប្បដិវិទ្ធា យស្សា ធម្មធាតុយា សុប្បដិវិទ្ធត្តា ទិវសញ្ចេបហំ សារីបុត្តំ ឯតមត្ថំ បុច្ឆេយ្យំ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ ទិវសម្បិ មេ សារីបុត្តោ ឯតមត្ថំ ព្យាករេយ្យ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ រត្តឹ ចេបហំ សារីបុត្តំ ឯតមត្ថំ បុច្ឆេយ្យំ អញ្ញមញ្ញេហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ រត្តឹបិ មេ សារីបុត្តោ ឯតមត្ថំ ព្យាករេយ្យ ។ បេ ។ រត្តិន្ទិវញ្ចេបហំ សារីបុត្តំ ឯតមត្ថំ បុច្ឆេយ្យំ ... រត្តិន្ទិវម្បិ មេ សារីបុត្តោ ឯតមត្ថំ ព្យាករេយ្យ ... ទ្វេ រត្តិន្ទិវានិ ចេបហំ សារីបុត្តំ ឯតមត្ថំ បុច្ឆេយ្យំ ... ទ្វេ រត្តិន្ទិវានិបិ មេ សារីបុត្តោ ឯតមត្ថំ ព្យាករេយ្យ ... តីណិ រត្តិន្ទិវានិ ចេបហំ សារីបុត្តំ ឯតមត្ថំ បុច្ឆេយ្យំ ... តីណិ រត្តិន្ទិវានិបិ មេ សារីបុត្តោ ឯតមត្ថំ ព្យាករេយ្យ ...

ចំពោះអាត្មាអញ អស់ ៧ យប់ ៧ ថ្ងៃ អាត្មាអញអាចនឹងដោះស្រាយសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ថ្វាយព្រះមានព្រះភាគ អស់ ៧ យប់ ៧ ថ្ងៃ ។

[១១៧] ម្នាលភិក្ខុ ធម្មធាតុ[១] គឺសារីបុត្តត្រាស់ដឹងហើយដោយប្រពៃពិត ព្រោះតែត្រាស់ដឹងធម្មធាតុដោយប្រពៃ បានជាបើតថាគតសួរសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ចំពោះសារីបុត្ត អស់ ១ ថ្ងៃ សារីបុត្តគប្បីដោះស្រាយសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ប្រាប់តថាគត អស់ ១ ថ្ងៃបាន ប្រសិនបើតថាគតសួរសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ចំពោះសារីបុត្ត អស់ ១ យប់ សារីបុត្តក៏គប្បីដោះស្រាយសេចក្តីនុ៎ះ ប្រាប់តថាគត អស់ ១ យប់បាន ។ បេ ។ ប្រសិនបើតថាគតសួរសេចក្តីនុ៎ះ ចំពោះសារីបុត្ត អស់ ១ យប់ ១ ថ្ងៃ ... សារីបុត្តក៏គប្បីដោះស្រាយសេចក្តីនុ៎ះ ប្រាប់តថាគត អស់ ១ យប់ ១ ថ្ងៃ ... ប្រសិនបើតថាគតសួរសេចក្តីនុ៎ះ ចំពោះសារីបុត្ត អស់ ២ យប់ ២ ថ្ងៃ ... សារីបុត្ត ក៏គប្បីដោះស្រាយសេចក្តីនុ៎ះ ប្រាប់តថាគត អស់ ២ យប់ ២ ថ្ងៃ ... ប្រសិនបើតថាគតសួរសេចក្តីនុ៎ះ ចំពោះសារីបុត្ត អស់ ៣ យប់ ៣ ថ្ងៃ ... សារីបុត្តក៏គប្បីដោះស្រាយសេចក្តីនុ៎ះ ប្រាប់តថាគត អស់ ៣ យប់ ៣ ថ្ងៃ ...

---

១ សំដៅយកសាវកបារមីញាណ ។

ចត្តារិ រត្តិន្ទិវានិ ចេបហំ សារីបុត្តំ ឯតមត្ថំ បុច្ឆេយ្យំ...
ចត្តារិ រត្តិន្ទិវានិបិ មេ សារីបុត្តោ ឯតមត្ថំ ព្យាករេយ្យ...
បញ្ច រត្តិន្ទិវានិ ចេបហំ សារីបុត្តំ ឯតមត្ថំ បុច្ឆេយ្យំ...
បញ្ច រត្តិន្ទិវានិបិ មេ សារីបុត្តោ ឯតមត្ថំ ព្យាករេយ្យ...
ឆ រត្តិន្ទិវានិ ចេបហំ សារីបុត្តំ ឯតមត្ថំ បុច្ឆេយ្យំ ... ឆ
រត្តិន្ទិវានិបិ មេ សារីបុត្តោ ឯតមត្ថំ ព្យាករេយ្យ ... សត្ត
រត្តិន្ទិវានិ ចេបហំ សារីបុត្តំ ឯតមត្ថំ បុច្ឆេយ្យំ អញ្ញមញ្ញេ-
ហិ បទេហិ អញ្ញមញ្ញេហិ បរិយាយេហិ សត្ត រត្តិន្ទិវា-
និបិ មេ សារីបុត្តោ ឯតមត្ថំ ព្យាករេយ្យ អញ្ញមញ្ញេហិ
បទេហិ អញ្ញមញ្ញេហិ បរិយាយេហីតិ ។ ទុតិយំ ។

(១១៨) សាវត្ថិយំ វិហរតិ ... ចតុចត្តាឡីសំ វោ
ភិក្ខវេ ញាណវត្ថូនិ ទេសេស្សាមិ តំ សុណាថ សា-
ធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ
តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

ប្រសិនបើតថាគត សួរសេចក្តីនុ៎ះ ចំពោះសារីបុត្ត អស់ ៤ យប់ ៤ ថ្ងៃ ... សារីបុត្តក៏គប្បីដោះស្រាយសេចក្តីនុ៎ះ ប្រាប់តថាគត អស់ ៤ យប់ ៤ ថ្ងៃ ... ប្រសិនបើតថាគត សួរសេចក្តីនុ៎ះ ចំពោះសារីបុត្ត អស់ ៥ យប់ ៥ ថ្ងៃ ... សារីបុត្តក៏គប្បីដោះស្រាយសេចក្តីនុ៎ះ ប្រាប់តថាគត អស់ ៥ យប់ ៥ ថ្ងៃ ... ប្រសិនបើតថាគតសួរសេចក្តីនុ៎ះ ចំពោះសារីបុត្ត អស់ ៦ យប់ ៦ ថ្ងៃ ... សារីបុត្តក៏គប្បីដោះស្រាយសេចក្តីនុ៎ះ ប្រាប់តថា-គត អស់ ៦ យប់ ៦ ថ្ងៃ ... ប្រសិនបើតថាគតសួរសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ចំពោះសារីបុត្ត អស់ ៧ យប់ ៧ ថ្ងៃ សារីបុត្តក៏គប្បីដោះស្រាយសេចក្តីនុ៎ះ ដោយបទដទៃ ៗ ដោយបរិយាយដទៃ ៗ ប្រាប់តថាគត អស់ ៧ យប់ ៧ ថ្ងៃបាន ។ ចប់សូត្រ ទី ២ ។

(១១៨) ទ្រង់គង់ជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ តថា-គត នឹងសំដែងនូវញាណវត្ថុ ៤៤ ប្រការ ដល់អ្នកទាំងឡាយ អ្នកទាំង-ឡាយ ចូរយកចិត្តទុកដាក់ ប្រុងស្តាប់ពាក្យនោះ ឲ្យប្រពៃចុះ តថា-គតនឹងពោលឲ្យស្តាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១១៩] ភគវា ឯតទវោច កតមានិ ច ភិក្ខវេ ចតុចត្តារីសំ ញាណវត្ថូនិ ជរាមរណេ ញាណំ ជរាមរណសមុទយេ ញាណំ ជរាមរណនិរោធេ ញាណំ ជរាមរណនិរោធគាមិនិយា បដិបទាយ ញាណំ ជាតិយា ញាណំ ជាតិសមុទយេ ញាណំ ជាតិនិរោធេ ញាណំ ជាតិនិរោធគាមិនិយា បដិបទាយ ញាណំ ភវេ ញាណំ ភវសមុទយេ ញាណំ ភវនិរោធេ ញាណំ ភវនិរោធគាមិនិយា បដិបទាយ ញាណំ ឧបាទានេ ញាណំ ឧបាទានសមុទយេ ញាណំ ឧបាទាននិរោធេ ញាណំ ឧបាទាននិរោធគាមិនិយា បដិបទាយ ញាណំ តណ្ហាយ ញាណំ តណ្ហាសមុទយេ ញាណំ តណ្ហានិរោធេ ញាណំ តណ្ហានិរោធគាមិនិយា បដិបទាយ ញាណំ វេទនាយ ញាណំ វេទនាសមុទយេ ញាណំ វេទនានិរោធេ ញាណំ វេទនានិរោធគាមិនិយា បដិបទាយ ញាណំ ផស្សេ ញាណំ ...

( ១១៩ ) ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះញាណវត្ថុទាំង ៤៤ តើដូចម្តេចខ្លះ គឺសេចក្តីដឹងក្នុងជរានិងមរណៈ ១ សេចក្តីដឹងក្នុងហេតុជាទីកើតឡើងនៃជរានិងមរណៈ ១ សេចក្តីដឹងក្នុងទីរលត់នៃជរានិងមរណៈ ១ សេចក្តីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ ១ សេចក្តីដឹងក្នុងជាតិ ១ សេចក្តីដឹងក្នុងហេតុជាទីកើតឡើងនៃជាតិ ១ សេចក្តីដឹងក្នុងទីរលត់នៃជាតិ ១ សេចក្តីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់នៃជាតិ ១ សេចក្តីដឹងក្នុងភព ១ សេចក្តីដឹងក្នុងហេតុជាទីកើតឡើងនៃភព ១ សេចក្តីដឹងក្នុងទីរលត់នៃភព ១ សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃភព ១ សេចក្តីដឹងក្នុងឧបាទាន ១ សេចក្តីដឹងក្នុងហេតុជាទីកើតឡើងនៃឧបាទាន ១ សេចក្តីដឹងក្នុងទីរលត់នៃឧបាទាន ១ សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃឧបាទាន ១ សេចក្តីដឹងក្នុងតណ្ហា ១ សេចក្តីដឹងក្នុងហេតុជាទីកើតឡើងនៃតណ្ហា ១ សេចក្តីដឹងក្នុងទីរលត់នៃតណ្ហា ១ សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃតណ្ហា ១ សេចក្តីដឹងក្នុងវេទនា ១ សេចក្តីដឹងក្នុងហេតុជាទីកើតឡើងនៃវេទនា ១ សេចក្តីដឹងក្នុងទីរលត់នៃវេទនា ១ សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃវេទនា ១ សេចក្តីដឹងក្នុងផស្សៈ ១ ...

សឡាយតនេ ញាណំ ... នាមរូបេ ញាណំ ... វិញ្ញាណេ ញាណំ ... សង្ខារេសុ ញាណំ សង្ខារសមុទយេ ញាណំ សង្ខារនិរោធេ ញាណំ សង្ខារនិរោធគាមិនិយា បដិបទាយ ញាណំ ឥមានិ វុច្ចន្តិ ភិក្ខវេ ចតុច្ចត្តាឡីសំ ញាណវត្ថូនិ ។

(១២០) កតមញ្ច ភិក្ខវេ ជរាមរណំ ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ជរា ។ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ មរណំ ។ ឥតិ អយញ្ច ជរា ឥទញ្ច មរណំ ឥទំ វុច្ចតិ ភិក្ខវេ ជរាមរណំ ។ ជាតិសមុទយា ជរាមរណសមុទយោ

សេចក្តីដឹងក្នុងសឡាយតនៈ ១ ... សេចក្តីដឹងក្នុងនាមរូប ១ ... សេចក្តីដឹងក្នុងវិញ្ញាណ ១ ... សេចក្តីដឹងក្នុងសង្ខារទាំងឡាយ ១ សេចក្តីដឹងក្នុងហេតុជាទីកើតឡើងនៃសង្ខារ ១ សេចក្តីដឹងក្នុងទីរលត់នៃសង្ខារ ១ សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ញាណវត្ថុ ៤៤ ប្រការ ។

(១២០) ម្នាលភិក្ខុទាំងឡាយ ជរានិងមរណៈ តើដូចម្តេច ។ សេចក្តីគ្រាំគ្រា ភាពគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ ដំណើរថយអាយុ ដំណើរចាស់ទុំនៃឥន្ទ្រិយទាំងឡាយ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ នេះហៅថា ជរា ។ ចុតិ ការឃ្លាត ការបែកធ្លាយ ការបាត់បង់ សេចក្តីស្លាប់ ដំណើរស្លាប់ ការធ្វើនូវមរណកាល ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការដាច់នៃជីវិតិន្ទ្រិយ ណា របស់សត្វទាំងឡាយនោះ ៗ ចាកសត្តនិកាយនោះ ៗ នេះហៅថា មរណៈ ។ ម្នាលភិក្ខុទាំងឡាយ ជរានេះផង មរណៈនេះផង នេះហៅថា ជរានិងមរណៈ ដោយប្រការដូច្នេះឯង ។ ការកើតឡើងនៃជរានិងមរណៈ ព្រោះការកើតឡើងនៃជាតិ

ជាតិនិរោធា ជរាមរណនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ជរាមរណនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។

(១២១) យតោ ខោ ភិក្ខវេ អរិយសាវកោ ឯវំ ជរាមរណំ បជានាតិ ឯវំ ជរាមរណសមុទយំ បជានាតិ ឯវំ ជរាមរណនិរោធំ បជានាតិ ឯវំ ជរាមរណនិរោធគា-មិនឹ បដិបទំ បជានាតិ ឥទមស្ស ធម្មេ ញាណំ ។ សោ ឥមិនា ធម្មេន ទិដ្ឋេន វិទិតេន អកាលិកេន បត្តេន បរិយោគាឡ្ហេន អតីតានាគតេ នយំ នេតិ យេ ខោ កេចិ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា ជរាមរណំ អព្ភញ្ញិំសុ ជរាមរណសមុទយំ អព្ភញ្ញិំសុ ជរាមរណនិរោធំ អព្ភញ្ញិំសុ ជរាមរណនិរោធគាមិនឹ បដិបទំ អព្ភញ្ញិំសុ សព្វេ តេ ឯវមេវ អព្ភញ្ញិំសុ

ការរលត់នៃជរានិងមរណៈ ព្រោះការរលត់នៃជាតិ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ប្រការនេះឯង ជាបដិបទា ដែលជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ គឺប្រាជ្ញាយល់ឃើញត្រូវ ១ ។ បេ ។ ការតម្កល់ចិត្តត្រូវ ១ ។

(១៦១) ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវ័កដឹងច្បាស់នូវជរានិងមរណៈយ៉ាងនេះ ដឹងច្បាស់នូវហេតុជាទីកើតឡើងនៃជរានិងមរណៈយ៉ាងនេះ ដឹងច្បាស់នូវទីរលត់នៃជរានិងមរណៈយ៉ាងនេះ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈយ៉ាងនេះ នេះជាធម្មញ្ញាណ របស់អរិយសាវ័កនោះ ។ អរិយសាវ័កនោះ តែងនាំទៅនូវន័យ ក្នុងអតីតកាលនិងអនាគតកាល ដោយធម៌នេះ[1] ដែលខ្លួនបានឃើញហើយ ដឹងច្បាស់ហើយ ជាធម៌ឲ្យផលមិនខុសកាល ជាធម៌ដែលខ្លួនបានដល់ហើយ បានជ្រួតជ្រាបហើយ ដោយបញ្ញាថា ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ក្នុងអតីតកាល ដឹងច្បាស់នូវជរានិងមរណៈ ដឹងច្បាស់នូវហេតុជាទីកើតឡើងនៃជរានិងមរណៈ ដឹងច្បាស់នូវទីរលត់ នៃជរានិងមរណៈ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ សមណព្រាហ្មណ៍ទាំងអស់នោះ បានដឹងច្បាស់យ៉ាងនេះឯង

---

១ សំដៅយកចតុសច្ចធម៌ ឬមគ្គញ្ញាណធម៌ ។

សេយ្យថាបិទំ ឯតរហិ ។ យេបិ ហិ កេចិ អនាគត-
មទ្ធានំ សមណា វា ព្រាហ្មណា វា ជរាមរណំ អភិ-
ជានិស្សន្តិ ជរាមរណសមុទយំ អភិជានិស្សន្តិ ជរា-
មរណនិរោធំ អភិជានិស្សន្តិ ជរាមរណនិរោធគាមិនិំ
បដិបទំ អភិជានិស្សន្តិ សព្វេ តេ ឯវមេវ អ-
ភិជានិស្សន្តិ សេយ្យថាបិទំ ឯតរហីតិ ។ ឥទមស្ស
អន្វយេ ញាណំ ។

(១២៨) យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥ-
មានិ ទ្វេ ញាណានិ បរិសុទ្ធានិ ហោន្តិ បរិយោទាតានិ
ធម្មេ ញាណញ្ច អន្វយេ ញាណញ្ច ។ អយំ វុច្ចតិ
ភិក្ខវេ អរិយសាវកោ ទិដ្ឋិសម្បន្នោ ឥតិបិ ទស្សន-
សម្បន្នោ ឥតិបិ អាគតោ ឥមំ សទ្ធម្មំ ឥតិបិ បស្សតិ
ឥមំ សទ្ធម្មំ ឥតិបិ សេក្ខេន ញាណេន សមន្នាគតោ
ឥតិបិ សេក្ខាយ វិជ្ជាយ សមន្នាគតោ ឥតិបិ ធម្ម-
សោតំ សមាបន្នោ ឥតិបិ អរិយោ និព្វេធិកបញ្ញោ
ឥតិបិ អមតទ្វារំ អាហច្ច តិដ្ឋតិ ឥតិបីតិ ។

ដូចជាអាត្មាអញ ក្នុងកាលឥឡូវនេះ ។ ពួកសមណៈឬព្រាហ្មណ៍ណាមួយក្នុងអនាគតកាល នឹងដឹងច្បាស់នូវជរាមរណៈ នឹងដឹងច្បាស់នូវហេតុជាទីកើតឡើងនៃជរាមរណៈ នឹងដឹងច្បាស់នូវទីរលត់នៃជរាមរណៈ នឹងដឹងច្បាស់នូវបដិបទា ដែលជាដំណើរទៅកាន់ទីរលត់នៃជរាមរណៈ សមណព្រាហ្មណ៍ទាំងអស់នោះ នឹងដឹងច្បាស់យ៉ាងនេះឯង ដូចជាអាត្មាអញ ក្នុងកាលឥឡូវនេះ ។ នេះជាអន្វយញាណ(១)របស់អរិយសាវកនោះ ។

(១២២) ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវក មានញាណទាំង ២ នេះ គឺធម្មញាណ ១ អន្វយញាណ ១ បរិសុទ្ធ ផូរផង់ហើយ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកនេះ ហៅថាបរិបូណ៌ដោយទិដ្ឋិក៏បាន ថាបរិបូណ៌ដោយទស្សនៈក៏បាន ថាមកកាន់ព្រះសទ្ធម្មនេះក៏បាន ថាឃើញព្រះសទ្ធម្មនេះក៏បាន ថាប្រកបដោយសេក្ខញាណក៏បាន ថាប្រកបដោយសេក្ខវិជ្ជាក៏បាន ថាដល់ព្រមនូវធម្មស្រោតក៏បាន ថាជាអរិយៈអ្នកមាននិព្វេធិកបញ្ញាក៏បាន ថាឋិតអែបទឹងទ្វារនៃអមតនិព្វានក៏បាន ។

---

១ សេចក្តីដឹងក្នុងធម៌ដែលប្រព្រឹត្តទៅតាមធម្មញាណ បានដល់បច្ចវេក្ខណញាណ ។

(១២៣) កតមា ច ភិក្ខវេ ជាតិ ។ បេ ។ កតមោ ច ភិក្ខវេ ភវោ ... កតមញ្ច ភិក្ខវេ ឧបាទានំ ... កតមា ច ភិក្ខវេ តណ្ហា ... កតមា ច ភិក្ខវេ វេទនា ... កតមោ ច ភិក្ខវេ ផស្សោ ... កតមញ្ច ភិក្ខវេ សឡាយតនំ ... កតមញ្ច ភិក្ខវេ នាមរូបំ ... កតមញ្ច ភិក្ខវេ វិញ្ញាណំ ... កតមេ ច ភិក្ខវេ សង្ខារា តយោមេ ភិក្ខវេ សង្ខារា កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោតិ ឥមេ វុច្ចន្តិ ភិក្ខវេ សង្ខារា ។ អវិជ្ជាសមុទយា សង្ខារសមុទយោ អវិជ្ជានិរោធា សង្ខារនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សង្ខារនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។

(១២៣) ម្នាលភិក្ខុទាំងឡាយ ជាតិ តើដូចម្តេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភព តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ ឧបាទាន តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ តណ្ហា តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ វេទនា តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ ផស្សៈ តើដូចម្តេច... ម្នាលភិក្ខុទាំងឡាយ សឡាយតនៈ តើដូចម្តេច ..., ម្នាលភិក្ខុទាំងឡាយ នាមរូប តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ វិញ្ញាណ តើដូចម្តេច ... ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ សង្ខារនេះ មាន ៣ គឺ កាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សង្ខារទាំងឡាយ ។ ការកើតឡើងនៃសង្ខារ ព្រោះការកើតឡើងនៃអវិជ្ជា ការរលត់នៃសង្ខារ ព្រោះការរលត់នៃអវិជ្ជា មគ្គដ៏ប្រសើរប្រកបដោយអង្គទាំង ៨ ប្រការនេះឯង ជាបដិបទា ដែលជាដំណើរទៅកាន់ទីរលត់នៃសង្ខារ គឺប្រាជ្ញាយល់ឃើញត្រូវ ១ ។ បេ ។ ការតម្កល់ចិត្តត្រូវ ១ ។

(១២៤) យតោ ខោ ភិក្ខវេ អរិយសាវកោ ឯវំ សង្ខារេ បជានាតិ ឯវំ សង្ខារសមុទយំ បជានាតិ ឯវំ សង្ខារនិរោធំ បជានាតិ ឯវំ សង្ខារនិរោធគាមិនឹ បដិបទំ បជានាតិ ឥទមស្ស ធម្មេ ញាណំ ។ សោ ឥមិនា ធម្មេន ទិដ្ឋេន វិទិតេន អកាលិកេន បត្តេន បរិយោគាឡ្ហេន អតីតានាគតេ នយំ នេតិ យេ ខោ កេចិ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា សង្ខារេ អព្ភញ្ញំសុ សង្ខារសមុទយំ អព្ភញ្ញំសុ សង្ខារនិរោធំ អព្ភញ្ញំសុ សង្ខារនិរោធគាមិនឹ បដិបទំ អព្ភញ្ញំសុ សព្វេ តេ ឯវមេវ អព្ភញ្ញំសុ សេយ្យថាបិហំ ឯតរហិ ។ យេបិ ហិ កេចិ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា សង្ខារេ អភិជានិស្សន្តិ សង្ខារសមុទយំ អភិជានិស្សន្តិ សង្ខារនិរោធំ អភិជានិស្សន្តិ

(១២៨) ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវកដឹងច្បាស់នូវសង្ខារទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវហេតុជាទីកើតឡើងនៃសង្ខារយ៉ាងនេះ ដឹងច្បាស់នូវទីរលត់នៃសង្ខារយ៉ាងនេះ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារយ៉ាងនេះ នេះជាធម្មញ្ញាណរបស់អរិយសាវកនោះ ។ អរិយសាវកនោះ តែងនាំទៅនូវន័យ ក្នុងអតីតកាលនិងអនាគតកាល ដោយធម៌នេះ ដែលខ្លួនបានឃើញហើយ ដឹងច្បាស់ហើយ ជាធម៌ឲ្យផលមិនខុសកាល ជាធម៌ដែលខ្លួនបានដល់ហើយ បានជ្រួតជ្រាបហើយដោយបញ្ញាថា ពួកសមណព្រាហ្មណ៍ណាមួយក្នុងអតីតកាល បានដឹងច្បាស់នូវសង្ខារទាំងឡាយ ដឹងច្បាស់នូវហេតុជាទីកើតឡើងនៃសង្ខារ ដឹងច្បាស់នូវទីរលត់នៃសង្ខារ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារ សមណព្រាហ្មណ៍ទាំងអស់នោះ បានដឹងច្បាស់យ៉ាងនេះឯង ដូចជាអាត្មាអញក្នុងកាលឥឡូវនេះដែរ ។ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងអនាគតកាល នឹងដឹងច្បាស់នូវសង្ខារទាំងឡាយ នឹងដឹងច្បាស់ នូវហេតុជាទីកើតឡើងនៃសង្ខារ នឹងដឹងច្បាស់នូវទីរលត់

សង្ខារនិរោធគាមិនឹ បដិបទំ អភិជានិស្សន្តិ សព្វេ តេ
ឯវមេវ អភិជានិស្សន្តិ សេយ្យថាបិហំ ឯតរហីតិ ។
ឥទមស្ស អន្វយេ ញាណំ ។

(១២៥) យតោ ខោ ភិក្ខវេ អរិយសាវកស្ស
ឥមានិ ទ្វេ ញាណានិ បរិសុទ្ធានិ ហោន្តិ បរិយោទា-
តានិ ធម្មេ ញាណញ្ច អន្វយេ ញាណញ្ច ។ អយំ
វុច្ចតិ ភិក្ខវេ អរិយសាវកោ ទិដ្ឋិសម្បន្នោ ឥតិបិ
ទស្សនសម្បន្នោ ឥតិបិ អាគតោ ឥមំ សទ្ធម្មំ ឥតិបិ
បស្សតិ ឥមំ សទ្ធម្មំ ឥតិបិ សេក្ខេន ញាណេន
សមន្នាគតោ ឥតិបិ សេក្ខាយ វិជ្ជាយ សមន្នាគតោ
ឥតិបិ ធម្មសោតំ សមាបន្នោ ឥតិបិ អរិយោ និព្វេធិ-
កបញ្ញោ ឥតិបិ អមតទ្វារំ អាហច្ច តិដ្ឋតិ ឥតិបីតិ ។
តតិយំ ។

(១២៦) សាវត្ថិយំ វិហរតិ ... សត្តសត្តរិ វោ ភិក្ខវេ
ញាណវត្ថូនិ ទេសេស្សាមិ តំ សុណាថ សាធុកំ
មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ
ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

នៃសង្ខារ នឹងដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ សមណព្រាហ្មណ៍ទាំងអស់នោះ នឹងដឹងច្បាស់យ៉ាងនេះឯង ដូចជាអាត្មាអញក្នុងកាលឥឡូវនេះដែរ ។ នេះ ជាអន្វយញ្ញាណ របស់អរិយសាវ័កនោះ ។

( ១២៥ ) ម្នាលភិក្ខុទាំងឡាយ កាលណាបើអរិយសាវ័ក មានញាណទាំង ២ នេះ គឺធម្មញ្ញាណ ១ អន្វយញ្ញាណ ១ បរិសុទ្ធ ផូរផង់ហើយ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះ ហៅថាបរិបូណ៌ដោយទិដ្ឋិក៏បាន ថាបរិបូណ៌ដោយទស្សនៈក៏បាន ថាមកកាន់ព្រះសទ្ធម្មនេះក៏បាន ថាឃើញព្រះសទ្ធម្មនេះក៏បាន ថាប្រកបដោយសេក្ខញ្ញាណក៏បាន ថាប្រកបដោយសេក្ខវិជ្ជាក៏បាន ថាដល់ព្រមនូវធម្មស្រោតក៏បាន ថាជាអរិយៈអ្នកមាននិព្វេធិកប្បញ្ញាក៏បាន ថាបិតអែបនឹងទ្វារនៃអមតនិព្វានក៏បាន ។ ចប់សូត្រ ទី ៣ ។

( ១២៦ ) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងញាណវត្ថុ ៧៧ ប្រការ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរយកចិត្តទុកដាក់ ប្រុងចាំស្តាប់ពាក្យនោះ ឲ្យប្រពៃចុះ តថាគតនឹងពោលឲ្យស្តាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

(១២៧) ភគវា ឯតទវោច កតមានិ ច ភិក្ខវេ សត្តសត្តរិ ញាណវត្ថូនិ ជាតិប្បច្ចយា ជរាមរណន្តិ ញាណំ អសតិ ជាតិយា នត្ថិ ជរាមរណន្តិ ញាណំ អតីតម្បិ អទ្ធានំ ជាតិប្បច្ចយា ជរាមរណន្តិ ញាណំ អសតិ ជាតិយា នត្ថិ ជរាមរណន្តិ ញាណំ អនាគតម្បិ អទ្ធានំ ជាតិប្បច្ចយា ជរាមរណន្តិ ញាណំ អសតិ ជា-តិយា នត្ថិ ជរាមរណន្តិ ញាណំ យម្បិស្ស តំ ធម្មដ្ឋិ-តិញ្ញាណំ តម្បិ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មន្តិ ញាណំ ។ ភវប្បច្ចយា ជាតីតិ ញាណំ ។ បេ ។ ឧបាទានប្បច្ចយា ភវោតិ ញាណំ... តណ្ហាបច្ចយា ឧ-បាទានន្តិ ញាណំ... វេទនាបច្ចយា តណ្ហាតិ ញាណំ...

[ ១៦៧ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ ញាណវត្ថុទាំង ៧៧ ប្រការ តើដូចម្តេច គឺសេចក្តីដឹងថា ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរានិងមរណៈក៏មិនមាន ១ សេចក្តីដឹងថា ជរានិងមរណៈជាអតីត-កាលកើតមាន ព្រោះជាតិជាបច្ច័យ ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរានិងមរណៈក៏មិនមាន ១ សេចក្តីដឹងថា ជរានិងមរណៈជាអនាគតកាលកើតមាន ព្រោះជាតិជាបច្ច័យ ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរានិងមរណៈក៏មិនមាន ១ សេចក្តីដឹងថា ធម្មដ្ឋិតិញាណ (បច្ច័យាការញាណ) ណា គប្បីមាន ធម្មដ្ឋិតិញាណនោះ មានកិរិយាអស់ទៅជាធម្មតា មានកិរិយាសូន្យទៅជាធម្មតា មានកិរិយានិរាសទៅជាធម្មតា មានកិរិយារលត់ទៅជាធម្មតា ១ ។ សេចក្តីដឹងថា ជាតិកើតមាន ព្រោះភពជាបច្ច័យ ១ ។ បេ ។ សេចក្តីដឹងថា ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ១ ... សេចក្តីដឹងថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ១ ... សេចក្តីដឹងថា តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ១ ...

ផស្សប្បច្ចយា វេទនាតិ ញាណំ ... សឡាយតនប្បច្ចយា ផស្សោតិ ញាណំ ... នាមរូបប្បច្ចយា សឡាយតនន្តិ ញាណំ ... វិញ្ញាណប្បច្ចយា នាមរូបន្តិ ញាណំ ... សង្ខារប្បច្ចយា វិញ្ញាណន្តិ ញាណំ ... អវិជ្ជាបច្ចយា សង្ខារាតិ ញាណំ អសតិ អវិជ្ជាយ នត្ថិ សង្ខារាតិ ញាណំ អតីតម្បិ អទ្ធានំ អវិជ្ជាបច្ចយា សង្ខារាតិ ញាណំ អសតិ អវិជ្ជាយ នត្ថិ សង្ខារាតិ ញាណំ អនាគតម្បិ អទ្ធានំ អវិជ្ជាបច្ចយា សង្ខារាតិ ញាណំ អសតិ អវិជ្ជាយ នត្ថិ សង្ខារាតិ ញាណំ យម្បិស្ស តំ ធម្មដ្ឋិតិញ្ញាណំ តម្បិ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មន្តិ ញាណំ ។ ឥមានិ វុច្ចន្តិ ភិក្ខវេ សត្តសត្តរិ ញាណវត្ថូនីតិ ។ ចតុត្ថំ ។

(១២៨) សាវត្ថិយំ វិហរតិ . . . អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ

សេចក្តីដឹងថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ១ ... សេចក្តីដឹងថា ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ១ ... សេចក្តីដឹងថា សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ១ ... សេចក្តីដឹងថានាម-រូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ១ ... សេចក្តីដឹងថា វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ១ ... សេចក្តីដឹងថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ១ សេចក្តីដឹងថា កាលបើអវិជ្ជាមិនមានហើយ សង្ខារទាំងឡាយក៏មិនមាន ១ សេចក្តីដឹងថា សង្ខារទាំងឡាយជាអតីត-កាលកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ១ សេចក្តីដឹងថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ១ សេចក្តីដឹងថា សង្ខារទាំងឡាយជាអនាគតកាលកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ១ សេចក្តីដឹងថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ១ សេចក្តីដឹងថា ធម្មដ្ឋិតិ-ញាណណាគប្បីមាន ធម្មដ្ឋិតិញាណនោះ មានកិរិយាអស់ទៅជាធម្មតា មានកិរិយាសូន្យទៅជាធម្មតា មានកិរិយាវិនាសទៅជាធម្មតា មានកិរិយារលត់ទៅជាធម្មតា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ញាណវត្ថុ ៧៧ ប្រការ ។ ចប់សូត្រ ទី ៤ ។

[១២៨] ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន

។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

(៧២៩) ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច កតមំ នុ ខោ ភន្តេ ជរាមរណំ កស្ស ច បនិទំ ជរាមរណន្តិ ។ នោ កល្លោ បញ្ហោតិ ភគវា អវោច កតមំ ជរាមរណំ កស្ស ច បនិទំ ជរាមរណន្តិ ឥតិ វា ភិក្ខុ យោ វទេយ្យ អញ្ញំ ជរាមរណំ អញ្ញស្ស ច បនិទំ ជរាមរណន្តិ ឥតិ វា ភិក្ខុ យោ វទេយ្យ ឧភយមេតំ ឯកត្ថំ ព្យញ្ជនមេវ នានំ ។ តំ ជីវំ តំ សរីរន្តិ វា ភិក្ខុ ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ ន ហោតិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ភិក្ខុ ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ ន ហោតិ ។ ឯតេ តេ ភិក្ខុ ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ ជាតិប្បច្ចយា ជរាមរណន្តិ ។

ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានឧយ៉ាងនេះ ។

[ ១២៩ ] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុ ១ រូប ក៏ក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ជរានិងមរណៈ តើដូចម្ដេចហ្ន៎ មួយទៀត ជរានិងមរណៈនេះឯង ជារបស់អ្នកណា ។ ព្រះមានព្រះភាគត្រាស់ថា ប្រស្នានេះមិនត្រូវទេ ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលណាពោលថា ជរានិងមរណៈ ដូចម្ដេច មួយទៀត ជរានិងមរណៈនេះឯង ជារបស់អ្នកណា ដូច្នេះក្ដី ម្នាលភិក្ខុ បុគ្គលណាពោលថា ជរានិងមរណៈដទៃ មួយទៀត ជរានិងមរណៈនេះឯង ជារបស់បុគ្គលដទៃ ដូច្នេះក្ដី ពាក្យទាំង ២ នេះ មានអត្ថដូចគ្នា ផ្សេងតែព្យញ្ជនៈ ។ ម្នាលភិក្ខុ កាលបើមានសេចក្ដីឃើញថា ជីវិតនោះ ក៏គឺសរីរៈនោះ ដូច្នេះក្ដី ការប្រព្រឹត្តិព្រហ្មចរិយៈ រមែងមិនមាន ម្នាលភិក្ខុ កាលបើមានសេចក្ដីឃើញថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្ដី ការប្រព្រឹត្តិព្រហ្មចរិយៈ ក៏រមែងមិនមាន ។ ម្នាលភិក្ខុ ព្រះតថាគតមិនប្រកាន់នូវអន្តធម៌ គឺធម៌ដ៏លាមក ទាំង ២ នោះឡើយ តែងសំដែងធម៌ដោយបទកណ្ដាលថា ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ។

(១៣០) កតមា នុ ខោ ភន្តេ ជាតិ កស្ស ច បនាយំ ជាតីតិ ។ នោ កល្លោ បញ្ហោតិ ភគវា អវោច កតមា ជាតិ កស្ស ច បនាយំ ជាតីតិ ឥតិ វា ភិក្ខុ យោ វទេយ្យ អញ្ញា ជាតិ អញ្ញស្ស ច បនាយំ ជាតីតិ ឥតិ វា ភិក្ខុ យោ វទេយ្យ ឧភយមេតំ ឯកត្ថំ ព្យញ្ជនមេវ នានំ ។ តំ ជីវំ តំ សរីរន្តិ វា ភិក្ខុ ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ ន ហោតិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ភិក្ខុ ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ ន ហោតិ ។ ឯតេ តេ ភិក្ខុ ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ ភវប្បច្ចយា ជាតីតិ ។

(១៣១) កតមោ នុ ខោ ភន្តេ ភវោ កស្ស ច បនាយំ ភវោតិ ។ នោ កល្លោ បញ្ហោតិ ភគវា អវោច កតមោ ភវោ កស្ស ច បនាយំ ភវោតិ ឥតិ វា ភិក្ខុ យោ វទេយ្យ អញ្ញោ ភវោ អញ្ញស្ស ច បនាយំ ភវោតិ ឥតិ វា ភិក្ខុ យោ វទេយ្យ ឧភយមេតំ ឯកត្ថំ

( ១៣០ ) បពិត្រព្រះអង្គដ៏ចំរើន ជាតិ តើដូចម្តេចហ្ន៎ មួយទៀត ជាតិនេះឯង ជារបស់អ្នកណា ។ ព្រះមានព្រះភាគត្រាស់ថា ប្រស្នានេះមិនត្រូវទេ ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលណាពោលថា ជាតិ ដូចម្តេច មួយទៀត ជាតិនេះឯង ជារបស់អ្នកណា ដូច្នេះក្តី ម្នាលភិក្ខុ បុគ្គលណាពោលថា ជាតិដទៃ មួយទៀត ជាតិនេះឯង ជារបស់បុគ្គលដទៃ ដូច្នេះក្តី ពាក្យទាំង ២ នេះឯង មានអត្ថដូចគ្នា ផ្សេងតែព្យញ្ជនៈ ។ ម្នាលភិក្ខុ កាលបើមានសេចក្តីឃើញថា ជីវិតនោះ ក៏គឺសរីរៈនោះ ដូច្នេះក្តី ការប្រព្រឹត្តព្រហ្មចរិយៈ រមែងមិនមាន ម្នាលភិក្ខុ កាលបើមានសេចក្តីឃើញថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្តី ការប្រព្រឹត្តព្រហ្មចរិយៈ ក៏រមែងមិនមាន ។ ម្នាលភិក្ខុ ព្រះតថាគត មិនបានប្រកាន់នូវអន្តធម៌ទាំង ២ នោះឡើយ តែងសំដែងធម៌ដោយបទកណ្តាលថា ជាតិកើតមាន ព្រោះភពជាបច្ច័យ ។

( ១៣១ ) បពិត្រព្រះអង្គដ៏ចំរើន ភព តើដូចម្តេចហ្ន៎ មួយទៀត ភពនេះឯង ជារបស់អ្នកណា ។ ព្រះមានព្រះភាគត្រាស់ថា ប្រស្នានេះមិនត្រូវទេ ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលណាពោលថា ភព ដូចម្តេច មួយទៀត ភពនេះឯង ជារបស់អ្នកណា ដូច្នេះក្តី ម្នាលភិក្ខុ បុគ្គលណាពោលថា ភពដទៃ មួយទៀត ភពនេះឯង ជារបស់បុគ្គលដទៃ ដូច្នេះក្តី ពាក្យទាំង ២ នេះឯង មានអត្ថដូចគ្នា

ព្យញ្ជនមេវ នានំ ។ តំ ជីវំ តំ សរីរន្តិ វា ភិក្ខុ ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ ន ហោតិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ភិក្ខុ ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ ន ហោតិ ។ ឯតេ តេ ភិក្ខុ ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ ឧបាទានប្បច្ចយា ភវោតិ ។ បេ ។ តណ្ហាបច្ចយា ឧបាទានន្តិ ... វេទនាបច្ចយា តណ្ហាតិ ... ផស្សប្បច្ចយា វេទនាតិ ... សឡាយតនប្បច្ចយា ផស្សោតិ ... នាមរូបប្បច្ចយា សឡាយតនន្តិ ... វិញ្ញាណប្បច្ចយា នាមរូបន្តិ ... សង្ខារប្បច្ចយា វិញ្ញាណន្តិ ។

ផ្សេងតែព្យញ្ជនៈ ។ ម្នាលភិក្ខុ កាលបើមានសេចក្ដីឃើញថា ជីវិតនោះ ក៏គឺសរីរៈនោះ ដូច្នេះក្ដី ការប្រព្រឹត្តព្រហ្មចរិយៈ រមែងមិនមាន ម្នាលភិក្ខុ កាលបើមានសេចក្ដីឃើញថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្ដី ការប្រព្រឹត្តព្រហ្មចរិយៈ ក៏រមែងមិនមាន ។ ម្នាលភិក្ខុ ព្រះតថាគត មិនប៉ះពាល់នូវអន្តធម៌ទាំង ២ នោះឡើយ តែងសំដែងធម៌ដោយបទកណ្ដាលថា ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ។ បេ ។ ថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ... ថា តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ... ថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ... ថា ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ... ថា សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ... ថា នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ... ថា វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។

(១៣២) កតមេ នុ ខោ ភន្តេ សង្ខារា កស្ស ច បនិមេ សង្ខារាតិ ។ នោ កល្លោ បញ្ហោតិ ភគវា អវោច កតមេ សង្ខារា កស្ស ច បនិមេ សង្ខារាតិ ឥតិ វា ភិក្ខុ យោ វទេយ្យ អញ្ញេ សង្ខារា អញ្ញស្ស ច បនិមេ សង្ខារាតិ ឥតិ វា ភិក្ខុ យោ វទេយ្យ ឧភយមេតំ ឯកត្ថំ ព្យញ្ជនមេវ នានំ ។ តំ ជីវំ តំ សរីរន្តិ វា ភិក្ខុ ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ ន ហោតិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ភិក្ខុ ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ ន ហោតិ ។ ឯតេ តេ ភិក្ខុ ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ អវិជ្ជាបច្ចយា សង្ខារាតិ ។

(១៣៣) អវិជ្ជាយ ត្វេវ ភិក្ខុ អសេសវិរាគនិរោធា យានិស្ស តានិ វិសូកាយិតានិ វិសេវិតានិ វិប្ផន្ទិតានិ កានិចិ កានិចិ កតមំ ជរាមរណំ កស្ស ច បនិទំ ជរា-
មរណំ ឥតិ វា អញ្ញំ ជរាមរណំ អញ្ញស្ស ច បនិទំ ជរា-

( ១៣២ ) បពិត្រព្រះអង្គដ៏ចម្រើន សង្ខារទាំងឡាយ តើដូចម្តេច មួយទៀត សង្ខារទាំងនេះឯង ជារបស់អ្នកណា ។ ព្រះមានព្រះភាគត្រាស់ថា ប្រស្នានេះមិនត្រូវទេ ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលណាពោលថា សង្ខារទាំងឡាយ ដូចម្តេច មួយទៀត សង្ខារទាំងនេះឯងជារបស់អ្នកណា ដូច្នេះក្តី ម្នាលភិក្ខុ បុគ្គលណាពោលថា សង្ខារទាំងឡាយដទៃ មួយទៀត សង្ខារទាំងនេះឯងជារបស់បុគ្គលដទៃ ដូច្នេះក្តី ពាក្យទាំង ២ នេះមានអត្ថដូចគ្នា ផ្សេងតែព្យញ្ជនៈ ។ ម្នាលភិក្ខុ កាលបើមានសេចក្តីឃើញថា ជីវិតនោះ ក៏គឺសរីរៈនោះ ដូច្នេះក្តី ការប្រព្រឹត្តព្រហ្មចរិយៈ រមែងមិនមាន ម្នាលភិក្ខុ កាលបើមានសេចក្តីឃើញថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្តី ការប្រព្រឹត្តព្រហ្មចរិយៈ ក៏រមែងមិនមាន ។ ម្នាលភិក្ខុ ព្រះតថាគត មិនប៉ះពាល់នូវអន្តធម៌ទាំង ២ នោះឡើយ តែងសំដែងធម៌ដោយបទបណ្តាលថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

( ១៣៣ ) ម្នាលភិក្ខុ សេចក្តីបម្រះបម្រាស សេចក្តីប្រកាន់ទទឹងទទែង សេចក្តីប្រកាន់ឆ្វេងណានីមួយ ៗ របស់បុគ្គលនោះ ជាជរានិងមរណៈ ដូចម្តេច មួយទៀត ជរានិងមរណៈនេះឯងជារបស់អ្នកណា ដូច្នេះក្តី ជាជរានិងមរណៈដទៃ មួយទៀត ជរានិងមរណៈនេះឯងជារបស់បុគ្គល

មរណំ ឥតិ វា តំ ជីវំ តំ សរីរំ ឥតិ វា អញ្ញំ ជីវំ អញ្ញំ សរីរំ ឥតិ វា សព្វានិស្ស តានិ បហីនានិ ហោន្តិ ឧច្ឆិន្នមូលានិ តាលាវត្ថុកតានិ អនភាវង្កតានិ អាយតឹ អនុប្បាទធម្មានិ ។

(១៣៤) អវិជ្ជាយ ត្វេវ ភិក្ខុ អសេសវិរាគនិរោធា យានិស្ស តានិ វិសូកាយិកានិ វិសេវិតានិ វិប្ផន្ទិតានិ កានិចិ កានិចិ កតមា ជាតិ កស្ស ច បនាយំ ជាតិ ឥតិ វា អញ្ញា ជាតិ អញ្ញស្ស ច បនាយំ ជាតិ ឥតិ វា តំ ជីវំ តំ សរីរំ ឥតិ វា អញ្ញំ ជីវំ អញ្ញំ សរីរំ ឥតិ វា សព្វានិស្ស តានិ បហីនានិ ហោន្តិ ឧច្ឆិន្នមូលានិ តាលាវត្ថុកតានិ អនភាវង្កតានិ អាយតឹ អនុប្បាទធម្មានិ ។

(១៣៥) អវិជ្ជាយ ត្វេវ ភិក្ខុ អសេសវិរាគនិរោធា យានិស្ស តានិ វិសូកាយិកានិ វិសេវិតានិ វិប្ផន្ទិតានិ កានិចិ កានិចិ កតមោ ភវោ ។បេ។ កតមំ ឧបាទានំ ... កតមា តណ្ហា ... កតមា វេទនា ...

ដទៃ ដូច្នេះក្តី ថា ជីវិតនោះ ក៏គឺសរីរៈនោះ ដូច្នេះក្តី ថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្តី ធម្មជាតទាំងអស់នោះ បុគ្គលនោះ បានលះបង់ហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ជាធម្មជាតដល់នូវការមិនមានបែបភាព មានសភាពមិនកើតឡើងតទៅ ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃអវិជ្ជា ។

[១៣៦] ម្នាលភិក្ខុ សេចក្តីចម្រូងចម្រាស សេចក្តីប្រកាន់ទទឹងទទែង សេចក្តីប្រកាន់ខ្វេងណាមួយ ៗ របស់បុគ្គលនោះថា ជាតិ ដូចម្តេច មួយទៀត ជាតិនេះឯងជារបស់អ្នកណា ដូច្នេះក្តី ថា ជាតិដទៃ មួយទៀត ជាតិនេះឯងជារបស់បុគ្គលដទៃ ដូច្នេះក្តី ថា ជីវិតនោះ ក៏គឺសរីរៈនោះ ដូច្នេះក្តី ថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្តី ធម្មជាតទាំងអស់នោះ បុគ្គលនោះ បានលះបង់ហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ជាធម្មជាតដល់នូវការមិនមានបែបភាព មានសភាពមិនកើតឡើងតទៅ ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃអវិជ្ជា ។

[១៣៧] ម្នាលភិក្ខុ សេចក្តីចម្រូងចម្រាស សេចក្តីប្រកាន់ទទឹងទទែង សេចក្តីប្រកាន់ខ្វេងណាមួយ ៗ របស់បុគ្គលនោះថា ភព ដូចម្តេច ។ បេ ។ ឧបាទាន ដូចម្តេច ... តណ្ហា ដូចម្តេច ... វេទនា ដូចម្តេច ...

កតមោ ផស្សោ ... កតមំ សឡាយតនំ ... កតមំ នាមរូបំ ... កតមំ វិញ្ញាណំ ... ។

(១៣៦) អវិជ្ជាយ ត្វេវ ភិក្ខុ អសេសវិរាគនិរោធា យានិស្ស តានិ វិសូកាយិតានិ វិសេវិតានិ វិប្ផន្ទិតា-និ កានិចិ កានិចិ កតមេ សង្ខារា កស្ស ច បនិមេ សង្ខារា ឥតិ វា អញ្ញេ សង្ខារា អញ្ញស្ស ច បនិមេ សង្ខារា ឥតិ វា តំ ជីវំ តំ សរីរំ ឥតិ វា អញ្ញំ ជីវំ អញ្ញំ សរីរំ ឥតិ វា សព្វានិស្ស តានិ បហីនា-និ ភវន្តិ ឧច្ឆិន្នមូលានិ តាលាវត្ថុកតានិ អនភាវង្កតានិ អាយតឹ អនុប្បាទធម្មានិ ។ បញ្ចមំ ។

(១៣៧) សាវត្ថិយំ វិហរតិ ... តត្រ ខោ ។ បេ ។ អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុ-ទយោ ហោតិ ។

ផស្សៈ ដូចម្តេច ... សឡាយតនៈ ដូចម្តេច ... នាមរូប ដូចម្តេច ... វិញ្ញាណ ដូចម្តេច ... ព្រោះការវិនាសនិងការលត់មិនសេសសល់នៃអវិជ្ជា ។

[ ១៣៦ ] ម្នាលភិក្ខុ សេចក្តីបម្រុងបម្រាស សេចក្តីប្រកាន់ទទឹងទទែង សេចក្តីប្រកាន់ឆ្វេងណានីមួយ ៗ របស់បុគ្គលនោះថា សង្ខារទាំងឡាយ ដូចម្តេច មួយទៀត សង្ខារទាំងនេះឯងជារបស់អ្នកណា ដូច្នេះក្តី ថា សង្ខារទាំងឡាយដទៃ មួយទៀត សង្ខារទាំងនេះឯងជារបស់បុគ្គលដទៃ ដូច្នេះក្តី ថា ជីវិតនោះ ក៏គឺសរីរៈនោះ ដូច្នេះក្តី ថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្តី ធម្មជាតទាំងអស់នោះ បុគ្គលនោះ បានលះបង់ហើយ បានកាត់ផ្តាច់ឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ជាធម្មជាតដល់នូវការមិនមានវិបាក មានសភាពមិនកើតឡើងតទៅ ព្រោះការវិនាសនិងការលត់មិនសេសសល់នៃអវិជ្ជា ។ ចប់សូត្រ ទី ៩ ។

[ ១៣៧ ] ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ក្នុងទីនោះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(១៣៨) កតមំ ជរាមរណំ កស្ស ច បនិទំ ជរាមរណន្តិ ឥតិ វា ភិក្ខវេ យោ វទេយ្យ អញ្ញំ ជរាម-រណំ អញ្ញស្ស ច បនិទំ ជរាមរណន្តិ ឥតិ វា ភិក្ខវេ យោ វទេយ្យ ឧភយមេតំ ឯកត្ថំ ព្យញ្ជនមេវ នានំ ។ តំ ជីវំ តំ សរីរន្តិ វា ភិក្ខវេ ទិដ្ឋិយា សតិ ព្រហ្ម-ចរិយវាសោ ន ហោតិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ភិក្ខវេ ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ ន ហោតិ ។ ឯតេ តេ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ ជាតិប្បច្ចយា ជរាមរណន្តិ ។ បេ ។ កតមា ជាតិ... កតមោ ភវោ... កតមំ ឧបាទានំ.. កតមា តណ្ហា... កតមា វេទនា... កតមោ ផស្សោ... កតមំ សឡាយតនំ ... កតមំ នាមរូបំ ... កតមំ វិញ្ញាណំ... ។

(១៣៩) កតមេ សង្ខារា កស្ស ច បនិមេ សង្ខារាតិ ឥតិ វា ភិក្ខវេ យោ វទេយ្យ អញ្ញេ សង្ខារា អញ្ញស្ស ច បនិមេ សង្ខារាតិ ឥតិ វា ភិក្ខវេ យោ វទេយ្យ ឧភយមេតំ ឯកត្ថំ ព្យញ្ជនមេវ នានំ ។

(១៣៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលណាពោលថា ជរាមរណៈ ដូចម្តេច មួយទៀត ជរាមរណៈនេះជារបស់អ្នកណា ដូច្នេះក្តី ម្នាលភិក្ខុទាំងឡាយ បុគ្គលណាពោលថា ជរាមរណៈដទៃ មួយទៀត ជរាមរណៈនេះជារបស់បុគ្គលដទៃ ដូច្នេះក្តី ពាក្យទាំង ២ នេះមានអត្ថដូចគ្នា ផ្សេងតែព្យញ្ជនៈ ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្តីឃើញថា ជីវិតនោះ គឺសរីរៈនោះ ដូច្នេះក្តី ការប្រព្រឹត្តព្រហ្មចរិយៈ រមែងមិនមាន ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្តីឃើញថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្តី ការប្រព្រឹត្តព្រហ្មចរិយៈ ក៏រមែងមិនមាន ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតមិនប៉ះពាល់នូវអន្តធម៌ទាំង២នោះឡើយ តែងសំដែងធម៌ដោយបទកណ្តាលថា ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ។ បេ ។ ជាតិ ដូចម្តេច ... ភព ដូចម្តេច ... ឧបាទាន ដូចម្តេច ... តណ្ហា ដូចម្តេច ... វេទនា ដូចម្តេច ... ផស្សៈ ដូចម្តេច ... សឡាយតនៈ ដូចម្តេច ... នាមរូប ដូចម្តេច ... វិញ្ញាណ ដូចម្តេច ... ។

(១៣៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលណាពោលថា សង្ខារទាំងឡាយ ដូចម្តេច មួយទៀត សង្ខារទាំងនេះជារបស់អ្នកណា ដូច្នេះក្តី ម្នាលភិក្ខុទាំងឡាយ បុគ្គលណាពោលថា សង្ខារទាំងឡាយដទៃ មួយទៀត សង្ខារទាំងនេះ ជារបស់បុគ្គលដទៃ ដូច្នេះក្តី ពាក្យទាំង ២ នេះ មានអត្ថដូចគ្នា ផ្សេងតែព្យញ្ជនៈ ។

តំ ជីវំ តំ សរីរំ ឥតិ វា ភិក្ខវេ ទិដ្ឋិយា សតិ ព្រហ្មច-
រិយវាសោ ន ហោតិ អញ្ញំ ជីវំ អញ្ញំ សរីរំ ឥតិ វា
ភិក្ខវេ ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ ន ហោតិ ។
ឯតេ តេ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថា-
គតោ ធម្មំ ទេសេតិ អវិជ្ជាបច្ចយា សង្ខារា ។ បេ ។

(១៦០) អវិជ្ជាយ ត្វេវ ភិក្ខវេ អសេសវិរាគនិរោ-
ធា យានិស្ស តានិ វិសូកាយិតានិ វិសេវិតានិ វិប្ផន្ទិ-
តានិ កានិចិ កានិចិ កតមំ ជរាមរណំ កស្ស ច
បនិទំ ជរាមរណំ ឥតិ វា អញ្ញំ ជរាមរណំ អញ្ញស្ស
ច បនិទំ ជរាមរណំ ឥតិ វា តំ ជីវំ តំ សរីរំ ឥតិ
វា អញ្ញំ ជីវំ អញ្ញំ សរីរំ ឥតិ វា សព្ពានិស្ស
តានិ បហីនានិ ភវន្តិ ឧច្ឆិន្នមូលានិ តាលាវត្ថុកតានិ
អនភាវង្កតានិ អាយតឹ អនុប្បាទធម្មានិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្តីឃើញថា ជីវិតនោះ ក៏គឺសរីរៈនោះ ដូច្នេះក្តី ការប្រព្រឹត្តិព្រហ្មចរិយៈ រមែងមិនមាន ម្នាលភិក្ខុទាំង-ឡាយ កាលបើមានសេចក្តីឃើញថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្តី ការប្រព្រឹត្តិព្រហ្មចរិយៈ ក៏រមែងមិនមាន ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតមិនប៉ះពាល់នូវអន្តធម៌ទាំង ២ នោះឡើយ តែងសំដែងធម៌ដោយបទកណ្តាលថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បេ ។

(១៤០) ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រែប្រួលប្រាស សេចក្តីប្រកាន់ទទឹងទទែង សេចក្តីប្រកាន់ឆ្វេងណាមួយ ។ របស់បុគ្គលនោះថា ជរាមរណៈ ដូចម្តេច មួយទៀត ជរាមរណៈនេះជារបស់អ្នកណា ដូច្នេះក្តី ថា ជរាមរណៈដទៃ មួយទៀត ជរាមរណៈនេះជារបស់បុគ្គលដទៃ ដូច្នេះក្តី ថា ជីវិតនោះ ក៏គឺសរីរៈនោះ ដូច្នេះក្តី ថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្តី ធម្មជាតទាំងអស់នោះ បុគ្គលនោះ បានលះបង់ហើយ បានកាត់ផ្តាច់ឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ជាធម្មជាតដល់នូវការមិនមានបែបភាព មានសភាពមិនកើតឡើងតទៅ ព្រោះការវិនាសទាំងការលះមិនសេសសល់នៃអវិជ្ជា ។

(១៨១) អវិជ្ជាយ ត្វេវ ភិក្ខវេ អសេសវិរាគនិរោធា យានិស្ស តានិ វិសូកាយិតានិ វិសេវិតានិ វិប្ផន្ទិតានិ កានិចិ កានិចិ កតមា ជាតិ ។ បេ ។ កតមោ ភវោ ... កតមំ ឧបាទានំ ... កតមា តណ្ហា ... កតមា វេទនា ... កតមោ ផស្សោ ... កតមំ សឡាយតនំ ... កតមំ នាមរូបំ ... កតមំ វិញ្ញាណំ ... ។

(១៨២) អវិជ្ជាយ ត្វេវ ភិក្ខវេ អសេសវិរាគនិរោធា យានិស្ស តានិ វិសូកាយិតានិ វិសេវិតានិ វិប្ផន្ទិតានិ កានិចិ កានិចិ កតមេ សង្ខារា កស្ស ច បនិមេ សង្ខារា ឥតិ វា អញ្ញេ សង្ខារា កស្ស ច បនិមេ សង្ខារា ឥតិ វា តំ ជីវំ តំ សរីរំ ឥតិ វា អញ្ញំ ជីវំ អញ្ញំ សរីរំ ឥតិ វា សព្វានិស្ស តានិ បហីនានិ ភវន្តិ ឧច្ឆិន្នមូលានិ តាលាវត្ថុកតានិ អនភាវង្កតានិ អាយតឹ អនុប្បាទធម្មានីតិ ។ ឆដ្ឋំ ។

(១៤១) ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រូងចម្រាស សេចក្តីប្រកាន់ទទឹងទទែង សេចក្តីប្រកាន់ធ្វេងណានីមួយ ៗ របស់បុគ្គលនោះ ថា ជាតិ ដូចម្តេច ។ បេ ។ ភព ដូចម្តេច ... ឧបាទាន ដូចម្តេច ... តណ្ហា ដូចម្តេច ... វេទនា ដូចម្តេច ... ផស្សៈ ដូចម្តេច ... សឡាយតនៈ ដូចម្តេច ... នាមរូប ដូចម្តេច ... វិញ្ញាណ ដូចម្តេច ... ព្រោះការវិនាសទាំងការរលត់មិនសេសសល់នៃអវិជ្ជា ។

(១៤២) ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រូងចម្រាស សេចក្តីប្រកាន់ទទឹងទទែង សេចក្តីប្រកាន់ធ្វេងណានីមួយ ៗ របស់បុគ្គលនោះថា សង្ខារទាំងឡាយ ដូចម្តេច មួយទៀត សង្ខារទាំងនេះជារបស់អ្នកណា ដូច្នេះក្តី ថា សង្ខារទាំងឡាយដទៃ មួយទៀត សង្ខារទាំងនេះជារបស់បុគ្គលដទៃ ដូច្នេះក្តី ថា ជីវិតនោះ គឺសរីរៈនោះ ដូច្នេះក្តី ថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះក្តី ធម្មជាតទាំងអស់នោះ បុគ្គលនោះ បានលះបង់ហើយ បានកាត់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ជាធម្មជាតដល់នូវការមិនមានបែបភាព មានសភាពមិនកើតឡើងតទៅ ព្រោះការវិនាសទាំងការរលត់មិនសេសសល់នៃអវិជ្ជា ។ ចប់សូត្រ ទី ៦ ។

(១៤៣) សាវត្ថិយំ វិហរតិ ... នាយំ ភិក្ខវេ កាយោ តុម្ហាកំ នបិ អញ្ញេសំ ។ បុរាណមិទំ ភិក្ខវេ កម្មំ អភិសង្ខតំ អភិសញ្ចេតយិតំ វេទនិយំ ទដ្ឋព្វំ ។

(១៤៤) តត្រ ភិក្ខវេ សុតវា អរិយសាវកោ បដិច្ចសមុប្បាទញ្ញេវ សាធុកំ យោនិសោ មនសិករោតិ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ សត្តមំ ។

(១៤៣) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ កាយនេះ មិនមែនជារបស់អ្នកទាំងឡាយ ទាំងមិនមែនជារបស់បុគ្គលទាំងឡាយដទៃទេ ។ ម្នាលភិក្ខុទាំងឡាយ បុរាណកម្មនេះ បុគ្គលគប្បីឃើញថា មានបច្ច័យតាក់តែង មានចេតនាជាមូល ជាហេតុនៃវេទនា ។

(១៤៤) ម្នាលភិក្ខុទាំងឡាយ បណ្ដាបុគ្គលទាំងនោះ អរិយសាវ័ក អ្នកចេះដឹង រមែងធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ឲ្យប្រពៃនូវបដិច្ចសមុប្បាទថា កាលបើធម្មជាតនេះមាន ធម្មជាតនេះក៏មានដែរ ព្រោះតែធម្មជាតនេះកើតឡើង បានជាធម្មជាតនេះកើតឡើងដែរ កាលបើធម្មជាតនេះមិនមាន ធម្មជាតនេះក៏មិនមានដែរ ព្រោះតែធម្មជាតនេះរលត់ទៅ បានជាធម្មជាតនេះរលត់ទៅដែរ គឺថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ៧ ។

(១៤៨) សាវត្ថិយំ វិហរតិ ... យញ្ច ភិក្ខវេ ចេតេតិ យញ្ច បកប្បេតិ យញ្ច អនុសេតិ អារម្មណមេតំ ហោតិ វិញ្ញាណស្ស ឋិតិយា អារម្មណេ សតិ បតិដ្ឋា វិញ្ញាណស្ស ហោតិ តស្មឹ បតិដ្ឋិតេ វិញ្ញាណេ វិរុឡ្ហេ អាយតឹ បុនព្ភវាភិនិព្វត្តិ ហោតិ អាយតឹ បុនព្ភវាភិនិព្វត្តិយា សតិ អាយតឹ ជាតិជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ នោ ច ភិក្ខវេ ចេតេតិ នោ ច បកប្បេតិ អថ ច អនុសេតិ អារម្មណមេតំ ហោតិ វិញ្ញាណស្ស ឋិតិយា អារម្មណេ សតិ បតិដ្ឋា វិញ្ញាណស្ស ហោតិ

( ១៨៥ ) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ បុគ្គលញ៉ាំងចេតនាណាឲ្យត្រិះរិះគិត(១)ក្តី ញ៉ាំងកប្ប:ណាឲ្យសម្រេច(២)ក្តី ញ៉ាំងអនុស័យណាឲ្យដេកនៅរឿយ ៗ ក្តី ធម្មជាតមានចេតនាជាដើមនេះ ជាអារម្មណ៍(៣) ប្រព្រឹត្តទៅដើម្បីការតាំងនៅនៃវិញ្ញាណ(៤) កាលបើអារម្មណ៍មាន ការតាំងនៅនៃវិញ្ញាណក៏មានដែរ កាលបើវិញ្ញាណនោះ តាំងនៅហើយ លូតលាស់ឡើងហើយ ការកើតតកតពប្ឋីរមែងមានតទៅ កាលបើការកើតតកតពប្ឋីមានតទៅទៀត ជាតិ ជរា មរណ: សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏កើតមានព្រមតទៅ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលមិនញ៉ាំងចេតនាឲ្យត្រិះរិះគិតក្តី មិនញ៉ាំងកប្ប:ឲ្យសម្រេចក្តី គ្រាន់តែញ៉ាំងអនុស័យឲ្យដេកនៅរឿយ ៗ អនុស័យនេះ ជាអារម្មណ៍ ប្រព្រឹត្តទៅដើម្បីការតាំងនៅនៃវិញ្ញាណ កាលបើអារម្មណ៍មានហើយ ការតាំងនៅ

១ សំដៅយកកុសលចេតនានិងអកុសលចេតនា ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ២ សំដៅយកតណ្ហាកប្ប: និងទិដ្ឋិកប្ប: ដែលមានក្នុងលោភសហគតចិត្តទាំង ៨ ។ ៣ អារម្មណ៍គឺបច្ច័យ ។ ៤ វិញ្ញាណគឺកម្មវិញ្ញាណ ។ ( អដ្ឋកថា ) ។

តស្មឹ បតិដ្ឋិតេ វិញ្ញាណេ វិរុឡ្ហេ អាយតឹ បុនព្ភវាភិនិព្វត្តិ ហោតិ អាយតឹ បុនព្ភវាភិនិព្វត្តិយា សតិ អាយតឹ ជាតិជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(១៤២) យតោ ច ខោ ភិក្ខវេ នោ ច ចេតេតិ នោ ច បកប្បេតិ នោ ច អនុសេតិ អារម្មណមេតំ ន ហោតិ វិញ្ញាណស្ស ឋិតិយា អារម្មណេ អសតិ បតិដ្ឋា វិញ្ញាណស្ស ន ហោតិ តទប្បតិដ្ឋិតេ វិញ្ញាណេ អវិរុឡ្ហេ អាយតឹ បុនព្ភវាភិនិព្វត្តិ ន ហោតិ អាយតឹ បុនព្ភវាភិនិព្វត្តិយា អសតិ អាយតឹ ជាតិជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

អដ្ឋមំ ។

នៃវិញ្ញាណក៏មានដែរ កាលបើវិញ្ញាណនោះតាំងនៅហើយ លូតលាស់ឡើងហើយ ការកើតគឺភពថ្មីក៏រមែងមានតទៅ កាលបើការកើតគឺភពថ្មីមានតទៅទៀត ជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏កើតមានព្រមតទៅ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(១៤៦) ម្នាលភិក្ខុទាំងឡាយ កាលណាបើបុគ្គល មិនញ៉ាំងចេតនាឲ្យត្រិះរិះគិតផង មិនញ៉ាំងកប្បៈឲ្យសម្រេចផង មិនញ៉ាំងអនុស័យឲ្យដេកនៅរឿយ ៗ ផង អារម្មណ៍នេះ មិនប្រព្រឹត្តទៅដើម្បីការតាំងនៅនៃវិញ្ញាណឡើយ កាលបើអារម្មណ៍មិនមាន ការតាំងនៅនៃវិញ្ញាណក៏មិនមានដែរ កាលបើវិញ្ញាណនោះមិនតាំងនៅហើយ មិនលូតលាស់ឡើងហើយ ការកើតគឺភពថ្មីរមែងមិនមានតទៅ កាលបើការកើតគឺភពថ្មីមិនមានតទៅទៀត ជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រលត់ទៅ សេចក្តីរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ៨ ។

(១៦៧) សាវត្ថិយំ វិហរតិ ... យញ្ច ភិក្ខវេ ចេតេតិ យញ្ច បកប្បេតិ យញ្ច អនុសេតិ អារម្មណមេតំ ហោតិ វិញ្ញាណស្ស ឋិតិយា អារម្មណេ សតិ បតិដ្ឋា វិញ្ញាណស្ស ហោតិ តស្មិំ បតិដ្ឋិតេ វិញ្ញាណេ វិរូឡ្ហេ នាមរូបស្ស អវក្កន្តិ ហោតិ នាមរូបបច្ចយា សឡាយតនំ សឡាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា ... តណ្ហា ... ឧបាទានំ ... ភវោ ... ជាតិ ... ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ នោ ចេ ភិក្ខវេ ចេតេតិ នោ ចេ បកប្បេតិ

(១៤៧) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ បុគ្គល ញុំាងចេតនាណាឲ្យត្រិះរិះគិតក្តី ញុំាងកប្បៈណាឲ្យសម្រេចក្តី ញុំាងអនុស័យណាឲ្យដេកនៅរឿយៗក្តី ធម្មជាតមានចេតនាជាដើមនេះ ជាអារម្មណ៍ ប្រព្រឹត្តទៅដើម្បីការតាំងនៅនៃវិញ្ញាណ កាលបើអារម្មណ៍មាន ការតាំងនៅនៃវិញ្ញាណក៏មានដែរ កាលបើវិញ្ញាណនោះតាំងនៅហើយ លូតលាស់ឡើងហើយ អវក្កន្តិគឺបដិសន្ធិនៃនាមរូបក៏មាន សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ... តណ្ហា ... ឧបាទាន ... ភព ... ជាតិ ... ជរានិងមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏កើតមានព្រម ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គល មិនញុំាងចេតនាឲ្យត្រិះរិះគិតផង មិនញុំាងកប្បៈឲ្យសម្រេចផង

អថ ច អនុសេតិ អារម្មណមេតំ ហោតិ វិញ្ញាណស្ស ឋិតិយា អារម្មណេ សតិ បតិដ្ឋា វិញ្ញាណស្ស ហោតិ តស្មឹ បតិដ្ឋិតេ វិញ្ញាណេ វិរុឡ្ហេ នាមរូបស្ស អវក្កន្តិ ហោតិ នាមរូបប្បច្ចយា សឡាយតនំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(១៦៨) យតោ ច ខោ ភិក្ខវេ នោ ច ចេតេតិ នោ ច បកប្បេតិ នោ ច អនុសេតិ អារម្មណមេតំ ន ហោតិ វិញ្ញាណស្ស ឋិតិយា អារម្មណេ អសតិ បតិដ្ឋា វិញ្ញាណស្ស ន ហោតិ តទប្បតិដ្ឋិតេ វិញ្ញាណេ អវិរុឡ្ហេ នាមរូបស្ស អវក្កន្តិ ន ហោតិ នាមរូបនិរោធា សឡាយតននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ឆដ្ឋំ ។

គ្រាន់តែញុំាងអនុស័យឲ្យដេកនៅរឿយ ៗ អនុស័យនេះ ជាអារម្មណ៍ប្រព្រឹត្តទៅដើម្បីការតាំងនៅនៃវិញ្ញាណ កាលបើអារម្មណ៍មាន ការតាំងនៅនៃវិញ្ញាណក៏មានដែរ កាលបើវិញ្ញាណនោះតាំងនៅហើយ លូតលាស់ឡើងហើយ អវក្កន្តិគឺបដិសន្ធិនៃនាមរូបក៏មាន សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(១៤៨) ម្នាលភិក្ខុទាំងឡាយ កាលណាបើបុគ្គល មិនញុំាងចេតនាឲ្យត្រិះរិះគិតផង មិនញុំាងកប្បៈឲ្យសម្រេចផង មិនញុំាងអនុស័យឲ្យដេកនៅរឿយ ៗ ផង ធម្មជាតមានចេតនាជាដើមនេះ ជាអារម្មណ៍មិនប្រព្រឹត្តទៅដើម្បីការតាំងនៅនៃវិញ្ញាណឡើយ កាលបើអារម្មណ៍មិនមាន ការតាំងនៅនៃវិញ្ញាណក៏មិនមានដែរ កាលបើវិញ្ញាណនោះមិនតាំងនៅហើយ មិនលូតលាស់ឡើងហើយ អវក្កន្តិគឺបដិសន្ធិនៃនាមរូបក៏មិនមាន ការរលត់នៃសឡាយតនៈ ព្រោះការរលត់នៃនាមរូប ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ៩ ។

[១៤៩] សាវត្ថិយំ វិហរតិ... យញ្ច ភិក្ខវេ ចេតេតិ យញ្ច បកប្បេតិ យញ្ច អនុសេតិ អារម្មណមេតំ ហោតិ វិញ្ញាណស្ស ឋិតិយា អារម្មណេ សតិ បតិដ្ឋា វិញ្ញាណស្ស ហោតិ តស្មឹ បតិដ្ឋិតេ វិញ្ញាណេ វិរុឡ្ហេ នតិ ហោតិ នតិយា សតិ អាគតិគតិ ហោតិ អាគតិគតិយា សតិ ចុតូបបាតោ ហោតិ ចុតូបបាតេ សតិ អាយតឹ ជាតិជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស ស-មុទយោ ហោតិ ។ នោ ច ភិក្ខវេ ចេតេតិ

(១៤៩) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ បុគ្គល ញុំាងចេតនាណាឲ្យត្រិះរិះគិតក្តី ញុំាងកប្បៈណាឲ្យសម្រេចក្តី ញុំាងអនុស័យណាឲ្យដេកនៅរឿយ ៗ ក្តី ធម្មជាតមានចេតនាជាដើមនេះ ជាអារម្មណ៍ ប្រព្រឹត្តទៅដើម្បីការតាំងនៅនៃវិញ្ញាណ កាលបើអារម្មណ៍មាន ការតាំងនៅនៃវិញ្ញាណក៏មានដែរ កាលបើវិញ្ញាណនោះតាំងនៅហើយ លូតលាស់ឡើងហើយ នតិ(១)គឺតណ្ហាក៏មាន កាលបើនតិគឺតណ្ហាមាន អាគតិគតិ(២)ក៏មានដែរ កាលបើអាគតិគតិមាន ចុតិនិងបដិសន្ធិក៏មានដែរ កាលបើចុតិនិងបដិសន្ធិមាន ជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏កើតព្រមតទៅ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គល មិនញុំាងចេតនាឲ្យត្រិះរិះគិតផង

---

១ ប្រែថា ធម្មជាតឱនទៅក្នុងអារម្មណ៍មានរូបជាដើម ។ ២ ប្រែថា គតិកើតមានក្នុងអាគតិ ។ អាគតិ សំដៅយកកម្ម ឬ កម្មនិមិត្ត ឬគតិនិមិត្ត ដែលប្រាកដឡើង គតិ គឺដំណើរនៃវិញ្ញាណ ដោយអំណាចនៃបដិសន្ធិ ។

នោ ច បកប្បេតិ អថ ច អនុសេតិ អារម្មណមេតំ ហោតិ វិញ្ញាណស្ស ឋិតិយា អារម្មណេ សតិ បតិដ្ឋា វិញ្ញាណស្ស ហោតិ តស្មឹ បតិដ្ឋិតេ វិញ្ញាណេ វិរុឡ្ហេ នតិ ហោតិ នតិយា សតិ អាគតិគតិ ហោតិ អាគតិគតិយា សតិ ចុតូបបាតោ ហោតិ ចុតូបបាតេ សតិ អាយតឹ ជាតិជរាមរណំ សោកបរិទេវទុក្ខទោ-មនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(១៤០) យតោ ច ខោ ភិក្ខវេ នោ ច ចេតេតិ នោ ច បកប្បេតិ នោ ច អនុសេតិ អារម្មណមេតំ ន ហោតិ វិញ្ញាណស្ស ឋិតិយា អារម្មណេ អសតិ បតិដ្ឋា វិញ្ញាណស្ស ន ហោតិ តទប្បតិដ្ឋិតេ វិញ្ញាណេ

មិនញុំាងកប្បៈឲ្យសម្រេចផង គ្រាន់តែញុំាងអនុស័យឲ្យដេកនៅរឿយ ៗ អនុស័យនេះ ជាអារម្មណ៍ ប្រព្រឹត្តទៅដើម្បីការតាំងនៅនៃវិញ្ញាណ កាលបើអារម្មណ៍មាន ការតាំងនៅនៃវិញ្ញាណក៏មានដែរ កាលបើវិញ្ញាណនោះតាំងនៅហើយ លូតលាស់ឡើងហើយ នតិគឺតណ្ហាក៏មានដែរ កាលបើនតិគឺតណ្ហាមាន អាគតិគតិ(១)ក៏មានដែរ កាលបើអាគតិគតិមាន ចុតិនិងបដិសន្ធិក៏មានដែរ កាលបើចុតិនិងបដិសន្ធិមាន ជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏កើតព្រមតទៅ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(១៧០) ម្នាលភិក្ខុទាំងឡាយ កាលណាបើបុគ្គល មិនញុំាងចេតនាឲ្យត្រិះរិះគិតផង មិនញុំាងកប្បៈឲ្យសម្រេចផង មិនញុំាងអនុស័យឲ្យដេកនៅរឿយ ៗ ផង ធម្មជាតមានចេតនាជាដើមនេះ ជាអារម្មណ៍ មិនប្រព្រឹត្តទៅដើម្បីការតាំងនៅនៃវិញ្ញាណឡើយ កាលបើអារម្មណ៍មិនមាន ការតាំងនៅនៃវិញ្ញាណក៏មិនមានដែរ កាលបើវិញ្ញាណនោះមិនតាំងនៅ

---

១ កម្មក្តី កម្មនិមិត្តក្តី គតិនិមិត្តក្តី ដែលមកតាំងនៅចំពោះហើយ ហៅថា អាគតិ, ដំណើរនៃវិញ្ញាណ ដោយអំណាចនៃបដិសន្ធិ ហៅថា គតិ ( អដ្ឋកថា ) ។

អវិរុឡ្ហេ នតិ ន ហោតិ នតិយា អសតិ អាគតិគតិ ន ហោតិ អាគតិគតិយា អសតិ ចុតូបបាតោ ន ហោតិ ចុតូបបាតេ អសតិ អាយតឹ ជាតិជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ នវមំ ។

កឡារខត្តិយវគ្គោ ចតុត្ថោ ។

## តស្ស ឧទ្ទានំ

ភូតមិទំ កឡារញ្ច
ទ្វេ ច ញាណវត្ថូនិ
អវិជ្ជាបច្ចយា ច ទ្វេ
នត្ថិ ចេតនា តយោតិ ។

ហើយ លូតលាស់ឡើងហើយ នតិតណ្ហាក៏មិនមានដែរ កាលបើនតិតណ្ហាមិនមាន អាគតិគតិក៏មិនមានដែរ កាលបើអាគតិគតិមិនមាន ចុតិនិងបដិសន្ធិក៏មិនមានដែរ កាលបើចុតិនិងបដិសន្ធិមិនមាន ជាតិ ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏រលត់ទៅ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ១០ ។

ចប់ កឡារខត្តិយវគ្គ ទី ៤ ។

## ឧទ្ទាននៃកឡារខត្តិយវគ្គនោះគឺ

និយាយអំពីបុគ្គលឃើញថាធម្មជាតនេះជាភូត ១ និយាយអំពីកឡារខត្តិយភិក្ខុ ១ និយាយអំពីញាណវត្ថុមាន ២ លើក និយាយអំពីបច្ច័យគឺអវិជ្ជាមាន ២ លើក និយាយអំពីកាយនេះ មិនមែនជារបស់អ្នកទាំងឡាយ ១ និយាយអំពីចេតនាមាន ៣ លើក ។

# គហបតិវគ្គោ

(១៩១) សាវត្ថិយំ វិហរតិ ... អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច យតោ ខោ គហបតិ អរិយសាវកស្ស បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ចតូហិ ច សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ អរិយោ ចស្ស ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ សោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

# គហបតិវគ្គ

(១៨១) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... គ្រានោះឯង អនាថបិណ្ឌិកគហបតី បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី កាលណាបើភ័យឬពៀរទាំង ៥ ប្រការ អរិយសាវ័កបានរម្ងាប់ហើយ អរិយសាវ័កនោះឈ្មោះថា ប្រកបដោយអង្គនៃសោតាបត្តិ ៤ ប្រការផង បានឃើញច្បាស់ចាក់ធ្លុះនូវញាយធម៌ដ៏ប្រសើរដោយប្រាជ្ញាផង អរិយសាវ័កនោះ បើចង់ព្យាករគេគប្បីព្យាករខ្លួនដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់ប្រេតវិស័យហើយ អស់អបាយទុគ្គតិវិនិបាតហើយ ជាអ្នកបានដល់នូវសោតៈហើយ មានសភាពមិនបានធ្លាក់ចុះជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ដូច្នេះក៏បាន ។

(១៨២) កតមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ។ យំ គហបតិ បាណាតិបាតី បាណាតិបាតបច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ បាណាតិបាតា បដិវិរតស្ស ឯវំ តំ ភយំ វេរំ វូបសន្តំ ហោតិ ។ យំ គហបតិ អទិន្នាទាយី អទិន្នាទានបច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ អទិន្នាទានា បដិវិរតស្ស ឯវំ តំ ភយំ វេរំ វូបសន្តំ ហោតិ ។ យំ គហបតិ កាមេសុមិច្ឆាចារី កាមេសុមិច្ឆាចារបច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ កាមេសុមិច្ឆាចារា បដិវិរតស្ស ឯវំ តំ ភយំ វេរំ វូបសន្តំ ហោតិ ។ យំ គហបតិ

(១៨៦) ចុះភ័យឬពៀរទាំង ៥ គឺអរិយសាវ័ករម្ងាប់ហើយ តើដូចម្តេច ។ ម្នាលគហបតី បុគ្គលអ្នកសម្លាប់សត្វ តែងចួបប្រសព្វនូវភ័យឬពៀរណាក្នុងបច្ចុប្បន្នផង ចួបប្រសព្វនូវភ័យឬពៀរណាក្នុងបរលោកផង ទទួលនូវទុក្ខទោមនស្សប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះតែបាណាតិបាតជាបច្ច័យ ភ័យឬពៀរនោះ អរិយសាវ័កអ្នកវៀរស្រឡះចាកបាណាតិបាត បានរម្ងាប់ហើយ យ៉ាងនេះ ។ ម្នាលគហបតី បុគ្គលអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ តែងចួបប្រសព្វនូវភ័យឬពៀរណា ក្នុងបច្ចុប្បន្នផង ចួបប្រសព្វនូវភ័យឬពៀរណា ក្នុងបរលោកផង ទទួលនូវទុក្ខទោម-នស្សប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះតែអទិន្នាទានជាបច្ច័យ ភ័យឬពៀរនោះ អរិយសាវ័កអ្នកវៀរស្រឡះចាកអទិន្នាទាន បានរម្ងាប់ហើយ យ៉ាងនេះ ។ ម្នាលគហបតី បុគ្គលអ្នកប្រព្រឹត្តកាមេសុមិច្ឆាចារ តែងចួបប្រ-សព្វនូវភ័យឬពៀរណាក្នុងបច្ចុប្បន្នផង ចួបប្រសព្វនូវភ័យឬពៀរណាក្នុងបរលោកផង ទទួលនូវទុក្ខទោមនស្សប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះតែកាមេសុមិច្ឆាចារជាបច្ច័យ ភ័យឬពៀរនោះ អរិយសាវ័កអ្នកវៀរស្រ-ឡះចាកកាមេសុមិច្ឆាចារ បានរម្ងាប់ហើយ យ៉ាងនេះ ។ ម្នាលគហបតី

មុសាវាទី មុសាវាទបច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ
បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ សម្ប-
រាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ
ទោមនស្សំ បដិសំវេទយតិ មុសាវាទា បដិវិរតស្ស
ឯវំ តំ ភយំ វេរំ វូបសន្តំ ហោតិ ។ យំ គហបតិ
សុរាមេរយមជ្ជប្បមាទដ្ឋាយី សុរាមេរយមជ្ជប្បមាទដ្ឋា-
នបច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្ប-
រាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ
ទោមនស្សំ បដិសំវេទយតិ សុរាមេរយមជ្ជប្បមាទដ្ឋានា
បដិវិរតស្ស ឯវំ តំ ភយំ វេរំ វូបសន្តំ ហោតិ ។
ឥមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ។

បុគ្គលអ្នកពោលនូវពាក្យកុហក តែងប្រសព្វនូវភ័យឬពៀរណា ក្នុងបច្ចុប្បន្នផង ប្រសព្វនូវភ័យឬពៀរណាក្នុងបរលោកផង ទទួលនូវទុក្ខនិងទោមនស្សប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះតែមុសាវាទជាបច្ច័យ ភ័យឬពៀរនោះ អរិយសាវ័កអ្នកវៀរស្រឡះចាកមុសាវាទ បានរម្ងាប់ហើយយ៉ាងនេះ ។ ម្នាលគហបតី បុគ្គលអ្នកផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ តែងប្រសព្វនូវភ័យឬពៀរណា ក្នុងបច្ចុប្បន្នផង ប្រសព្វនូវភ័យឬពៀរណាក្នុងបរលោកផង ទទួលនូវទុក្ខនិងទោមនស្សប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះតែហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹងគឺសុរានិងមេរ័យជាបច្ច័យ ភ័យឬពៀរនោះ អរិយសាវ័ក អ្នកវៀរស្រឡះចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹងគឺសុរានិងមេរ័យ បានរម្ងាប់ហើយ យ៉ាងនេះ ។ នេះ ភ័យឬពៀរតាំង ៥ ដែលពួកអរិយសាវ័កបានរម្ងាប់អស់ហើយ ។

(១៨៣) កតមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ ។ ឥធ គហបតិ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុប្បដិបន្នោ ភគវតោ សាវក-

អភិសមយសំយុត្ត គហបតិវគ្គ អង្គនៃសោតាបត្តិ

( ១៨៣ ) អរិយសាវ័កប្រកបដោយអង្គនៃសោតាបត្តិ ៤ ប្រការ គឺអ្វីខ្លះ ។ ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្ត ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ដោយព្រះអង្គឯងដោយប្រពៃ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គអាចប្រដៅបុរសបុគ្គលដូចនាយសារថី ជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ១ អរិយសាវ័ក ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ ជាធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយប្រពៃ ព្រះនព្វលោកុត្តរធម៌ ជាធម៌ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងច្បាស់ដោយខ្លួនឯង ១ អរិយសាវ័ក ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ

សង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញូបសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ ឥមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ ។

(១៤៨) កតមោ ចស្ស អរិយោ ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ ។ ឥធ គហបតិ អរិយសាវកោ បដិច្ចសមុប្បាទញ្ញេវ សាធុកំ យោនិសោ មនសិករោតិ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ

លោកប្រតិបត្តិដោយប្រពៃ ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិដោយត្រង់ ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិដើម្បីការដឹង ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ នេះ ជាសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកគួរទទួលនូវបច្ច័យ គួរទទួលនូវអាគន្តុកទានដែលគេនាំមកបូជា គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ១ អរិយសាវ័ក ប្រកបដោយអរិយកន្តសីលគឺសីល ៨ ដែលជាទីពេញចិត្តរបស់អរិយៈ មិនដាច់ មិនធ្លុះ មិនពព្រុះ មិនពពាល ជាសីលមិនខ្ញុំតណ្ហា ជាសីលដែលពួកអ្នកប្រាជ្ញសរសើរ ដែលមិនបានប៉ះពាល់ដោយតណ្ហា ដែលប្រព្រឹត្តទៅដើម្បីសមាធិ ១ អរិយសាវ័កប្រកបដោយអង្គនៃសោតាបត្តិទាំង ៤ ប្រការនេះឯង ។

[ ១៩៤ ] ចុះញាយធម៌ដ៏ប្រសើរ ដែលអរិយសាវ័កនោះ បានឃើញដោយប្រពៃ បានចាក់ធ្លុះដោយប្រពៃដោយប្រាជ្ញា តើដូចម្តេច ។ ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវបដិច្ចសមុប្បាទធម៌ដោយឧបាយប្រាជ្ញាឲ្យប្រពៃថា កាលបើរបស់នេះមាន របស់នេះក៏មាន របស់នេះកើតឡើង ព្រោះកើតរបស់នេះ កាលបើរបស់នេះ

ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ អយមស្ស អរិយោ ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ ។

(១៨៨) យតោ ខោ គហបតិ អរិយសាវកស្ស ឥមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ឥមេហិ ច ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ អយញ្ចស្ស អរិយោ ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ សោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។ បឋមំ ។

មិនមាន របស់នេះក៏មិនមាន របស់នេះរលត់ទៅ ព្រោះរលត់របស់នេះ សង្ខារទាំងឡាយកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតឡើង ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។បេ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ញាយធម៌ដ៏ប្រសើរនេះហើយ ដែលអរិយសាវ័កនោះ ឃើញដោយប្រពៃ ចាក់ធ្លុះដោយប្រពៃ ដោយប្រាជ្ញា ។

(១៨៥) ម្នាលគហបតី កាលណាបើភ័យឬពៀរទាំង ៥ ប្រការនេះ គឺអរិយសាវ័ករម្ងាប់ហើយ អរិយសាវ័កនោះ ឈ្មោះថាបានប្រកបដោយអង្គនៃសោតាបត្តិ ៤ ប្រការនេះផង ទាំងញាយធម៌ដ៏ប្រសើរនេះ ក៏អរិយសាវ័ក បានឃើញដោយប្រពៃ ចាក់ធ្លុះដោយប្រពៃ ដោយប្រាជ្ញាផង អរិយសាវ័កនោះ បើចង់ព្យាករ ក៏គប្បីព្យាករខ្លួនដោយខ្លួនឯងថា អាត្មាអញ អស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់ប្រេតវិស័យហើយ អស់អបាយទុគ្គតិវិនិបាតហើយ ជាអ្នកបានដល់នូវសោតៈ មានសភាពមិនបានធ្លាក់ចុះ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ដូច្នេះក៏បាន ។ ចប់សូត្រ ទី ១ ។

[១៨៦] សាវត្ថិយំ វិហរតិ ... យតោ ខោ ភិក្ខវេ អរិយសាវកស្ស បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ចតូហិ ច សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ អរិយោ ចស្ស ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ សោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ។បេ។ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។

[ ភិក្ខវេតិ សព្វំ វិត្ថារេតព្វំ ] ។

[១៨៧] កតមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ។ យំ ភិក្ខវេ បាណាតិបាតី ។បេ។ យំ ភិក្ខវេ អទិន្នាទាយី ។បេ។ យំ ភិក្ខវេ កាមេសុមិច្ឆាចារី ។បេ។ យំ ភិក្ខវេ មុសាវាទី ។បេ។ យំ ភិក្ខវេ សុរាមេរយមជ្ជប្បមាទដ្ឋាយី ។បេ។ ឥមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ។

(១៨៦) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ កាលណាបើ ភ័យឬពៀរទាំង ៥ ប្រការ គឺអរិយសាវ័កបានរម្ងាប់ហើយ អរិយសាវ័កនោះ ក៏បានប្រកបដោយអង្គនៃសោតាបត្តិ ៤ ប្រការផង ទាំងញាយធម៌ដ៏ប្រសើរ ក៏អរិយសាវ័កនោះ បានឃើញដោយប្រពៃ ចាក់ធ្លុះដោយប្រពៃ ដោយប្រាជ្ញាផង អរិយសាវ័កនោះ បើចង់ព្យាករក៏គប្បីព្យាករខ្លួនដោយខ្លួនឯងថា អាត្មាអញ អស់នរកហើយ ។ បេ ។ មានសភាពមិនបានធ្លាក់ចុះ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខដូច្នេះក៏បាន ។

( ត្រង់ពាក្យថា ភិក្ខវេ បណ្ឌិតត្រូវធ្វើឲ្យពិស្តារគ្រប់អន្លើផងចុះ ) ។

(១៨៧) ភ័យឬពៀរទាំង ៥ ប្រការ គឺអរិយសាវ័ករម្ងាប់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកសម្លាប់សត្វ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលពាក្យកុហក ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល អ្នកផឹកទឹកស្រវឹងគឺសុរានិងមេរ័យជាហេតុនៃសេចក្តីប្រមាទ ។ បេ ។ នេះ ភ័យឬពៀរទាំង ៥ ប្រការ ដែលអរិយសាវ័កបានរម្ងាប់ហើយ ។

(១៥៨) កតមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ ។ ឥធ ភិក្ខវេ អរិយសាវកោ ពុទ្ធេ ។ បេ ។ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ ។ បេ ។ ឥមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ ។

(១៥៩) កតមោ ចស្ស អរិយោ ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ ។ ឥធ ភិក្ខវេ អរិយសាវកោ បដិច្ចសមុប្បាទញ្ញេវ សាធុកំ យោនិសោ មនសិករោតិ ។ បេ ។ អយមស្ស អរិយោ ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ ។

(១៦០) យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ឥមេហិ ច ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ អយញ្ចស្ស អរិយោ ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ ។ សោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបេត្តិវិសយោ

(១៥៨) ចុះអរិយសាវ័ក ដែលប្រកបដោយអង្គនៃសោតាបត្តិ ៤ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ (ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក) ក្នុងព្រះពុទ្ធ ។ បេ ។ ក្នុងព្រះធម៌ ។ បេ ។ ក្នុងព្រះសង្ឃ ។ បេ ។ ប្រកបដោយអរិយកន្តសីល ។ បេ ។ អរិយសាវ័ក ប្រកបដោយអង្គនៃសោតាបត្តិ ៤ ប្រការនេះឯង ។

(១៥៩) ចុះញាយធម៌ដ៏ប្រសើរ គឺអរិយសាវ័កនោះ ឃើញដោយប្រពៃ ចាក់ធ្លុះដោយប្រពៃ ដោយប្រាជ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវបដិច្ចសមុប្បាទធម៌ ដោយឧបាយប្រាជ្ញា ឲ្យប្រពៃ ។ បេ ។ នេះ ជាញាយធម៌ដ៏ប្រសើរ គឺអរិយសាវ័ក ឃើញដោយប្រពៃ ចាក់ធ្លុះដោយប្រពៃ ដោយប្រាជ្ញា ។

(១៦០) ម្នាលភិក្ខុទាំងឡាយ កាលណាបើភ័យឬពៀរ ៥ ប្រការនេះ គឺអរិយសាវ័កបានរម្ងាប់ហើយ អរិយសាវ័កនោះ ក៏បានប្រកបដោយអង្គនៃសោតាបត្តិ ៤ ប្រការនេះផង ទាំងញាយធម៌ដ៏ប្រសើរនេះ ក៏អរិយសាវ័កឃើញដោយប្រពៃ ចាក់ធ្លុះដោយប្រពៃ ដោយប្រាជ្ញាផង ។ អរិយសាវ័កនោះ បើចង់ព្យាករ ក៏គប្បីព្យាករខ្លួនដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់ប្រេតវិស័យហើយ

ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិ-
បាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។ ទុតិយំ ។

(១៦១) សាវត្ថិយំ វិហរតិ ... ទុក្ខស្ស ភិក្ខវេ សមុទយញ្ច អត្ថង្គមញ្ច ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(១៦២) ភគវា ឯតទវោច កតមោ ច ភិក្ខវេ ទុក្ខស្ស សមុទយោ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា អយំ ខោ ភិក្ខវេ ទុក្ខស្ស សមុទយោ ។ សោតញ្ច បដិច្ច សទ្ទេ ច ...

អស់អបាយទុគ្គតិវិនិបាតហើយ ជាអ្នកដល់នូវសោតៈហើយ មានសភាពមិនធ្លាក់ចុះ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ដូច្នេះក៏បាន ។ ចប់សូត្រ ទី ២ ។

( ១៦១ ) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែង នូវហេតុដែលនាំឲ្យកើតទុក្ខផង នូវសេចក្តីរលត់នៃទុក្ខផង អ្នកទាំងឡាយ ចូរស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

( ១៦២ ) ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ចុះហេតុដែលនាំឲ្យកើតទុក្ខ តើដូចម្តេច ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំរបស់ទាំង ៣ គឺចក្ខុ ១ រូប ១ ចក្ខុវិញ្ញាណ ១ ហៅថាផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា ហេតុនាំឲ្យកើតទុក្ខ ។ ព្រោះអាស្រ័យត្រចៀកនិងសំឡេង ...

ឃានញ្ច បដិច្ច គន្ធេ ច ... ជិវ្ហញ្ច បដិច្ច រសេ ច ... កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ... មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា អយំ ខោ ភិក្ខវេ ទុក្ខស្ស សមុទយោ ។

(១៦៣) កតមោ ច ភិក្ខវេ ទុក្ខស្ស អត្ថង្គមោ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា

ព្រោះអាស្រ័យច្រមុះនិងក្លិន ... ព្រោះអាស្រ័យអណ្តាតនិងរស ... ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ ... មនោវិញ្ញាណកើតឡើងបាន ក៏ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការប្រជុំរបស់ធម៌ ៣ គឺចិត្ត ១ ធម្មារម្មណ៍ ១ មនោវិញ្ញាណ ១ ហៅថា ផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា ហេតុនាំឲ្យកើតទុក្ខ ។

(១៦៣) ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់នៃទុក្ខ តើដូចម្តេច ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំរបស់ធម៌ ៣ ហៅថា ផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ

វេទនាបច្ចយា តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ អយំ ខោ ភិក្ខវេ ... ទុក្ខស្ស អត្ថង្គមោ ។ សោតញ្ច បដិច្ច សទ្ទេ ច ... ឃានញ្ច បដិច្ច គន្ធេ ច ... ជិវ្ហញ្ច បដិច្ច រសេ ច ... កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ... មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ អយំ ខោ ភិក្ខវេ ទុក្ខស្ស អត្ថង្គមោតិ ។ តតិយំ ។

តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ការរលត់នៃឧបាទាន ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃតណ្ហានោះឯង ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ការរលត់នៃជាតិ ព្រោះការរលត់នៃភព ជរាមរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ ក៏រមែងរលត់ ព្រោះការរលត់នៃជាតិ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា សេចក្ដីរលត់នៃទុក្ខ ។ ព្រោះអាស្រ័យត្រចៀកនិងសំឡេង ... ព្រោះអាស្រ័យច្រមុះនិងក្លិន ... ព្រោះអាស្រ័យអណ្ដាតនិងរស ... ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ ... មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការជួបជុំរបស់ទាំង ៣ ហៅថា ផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ការរលត់នៃឧបាទាន ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃតណ្ហានោះឯង ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ការរលត់នៃជាតិ ព្រោះការរលត់នៃភព ជរាមរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ ក៏រមែងរលត់ ព្រោះការរលត់នៃជាតិ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា សេចក្ដីរលត់នៃទុក្ខ ។

ចប់សូត្រ ទី ៣ ។

(១៦៤) សាវត្ថិយំ វិហរតិ ... លោកស្ស ភិក្ខវេ សមុទយញ្ច អត្ថង្គមញ្ច ទេសេស្សាមិ តំ សុណាថ ... កតមោ ច ភិក្ខវេ លោកស្ស សមុទយោ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ អយំ ខោ ភិក្ខវេ លោកស្ស សមុទយោ ។ សោតញ្ច បដិច្ច សទ្ទេ ច ... ឃានញ្ច បដិច្ច គន្ធេ ច ... ជិវ្ហញ្ច បដិច្ច រសេ ច ... កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ... មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា

(១៦៤) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងហេតុដែលនាំឲ្យកើតសង្ខារលោកនិងសេចក្ដីរលត់នៃសង្ខារលោក អ្នកទាំងឡាយចូរស្ដាប់ធម៌នោះចុះ ... ម្នាលភិក្ខុទាំងឡាយ ចុះហេតុដែលនាំឲ្យកើតសង្ខារលោក តើដូចម្ដេច ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំរបស់ទាំង ៣ ហៅថាផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ឧបាទានកើតឡើង ព្រោះតណ្ហាជាបច្ច័យ ភពកើតឡើង ព្រោះឧបាទានជាបច្ច័យ ជាតិកើតឡើង ព្រោះភពជាបច្ច័យ ជរាមរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងព្រម ព្រោះជាតិជាបច្ច័យ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា ហេតុនាំឲ្យកើតសង្ខារលោក ។ ព្រោះអាស្រ័យត្រចៀកនិងសំឡេង ... ព្រោះអាស្រ័យច្រមុះនិងក្លិន ... ព្រោះអាស្រ័យអណ្ដាតនិងរស ... ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ ... មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការប្រជុំរបស់ទាំង ៣ ហៅថា ផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ

។បេ។ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខ-
ទោមនស្សុបាយាសា សម្ភវន្តិ អយំ ខោ ភិក្ខវេ
លោកស្ស សមុទយោ ។

(១៦៩) កតមោ ច ភិក្ខវេ លោកស្ស អត្ថង្គមោ ។
ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ
សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា
តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា
ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ។បេ។
ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ

។ បេ ។ ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងព្រម ព្រោះជាតិជាបច្ច័យ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា ហេតុនាំឲ្យកើតសង្ខារលោក ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់នៃសង្ខារលោក តើដូចម្តេច ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំរបស់ទាំង ៣ ហៅថា ផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ការរលត់នៃឧបាទាន ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃតណ្ហានោះឯង ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុះ+

អយំ ខោ ភិក្ខវេ លោកស្ស អត្ថង្គមោ ។ សោតញ្ច បដិច្ច សទ្ទេ ច ... ឃានញ្ច បដិច្ច គន្ធេ ច ... ជិវ្ហញ្ច បដិច្ច រសេ ច ... កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ... មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាយត្វេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ អយំ ខោ ភិក្ខវេ លោកស្ស អត្ថង្គមោតិ ។ ចតុត្ថំ ។

(១៦៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ញាតិកេ វិហរតិ គិញ្ជកាវសថេ ។ អថខោ ភគវា រហោគតោ បដិសល្លីនោ ឥមំ ធម្មបរិយាយំ អភាសិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា

រមែងមានយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា សេចក្តីរលត់នៃសង្ខារលោក ។ ព្រោះអាស្រ័យត្រចៀកនិងសំឡេង ... ព្រោះអាស្រ័យច្រមុះនិងក្លិន ... ព្រោះអាស្រ័យអណ្តាតនិងរស ... ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ ... មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការប្រជុំរបស់ទាំង ៣ ហៅថាផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ការរលត់នៃឧបាទាន ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃតណ្ហានោះឯង ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា ការរលត់នៃសង្ខារលោក ។ ចប់សូត្រ ទី ៤ ។

[១៦៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទឈ្មោះគិញ្ជកាវសថៈ គឺមហាប្រាសាទដែលគេធ្វើដោយឥដ្ឋរបស់ពួកព្រះញាតិ ។ គ្រានោះឯង ព្រះមានព្រះភាគគង់នៅក្នុងទីស្ងាត់ សម្ងំនៅមួយព្រះអង្គឯង ទ្រង់សំដែងធម្មបរិយាយនេះថា ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំរបស់ទាំង ៣ នេះហៅថាផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ

វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ សោតញ្ច បដិច្ច សទ្ទេ ច ... ឃានញ្ច បដិច្ច គន្ធេ ច ... ជិវ្ហញ្ច បដិច្ច រសេ ច ... កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ... មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(១៦៧) ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ សោតញ្ច បដិច្ច សទ្ទេ ច ។បេ។

តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ឧបាទានកើតឡើង ព្រោះតណ្ហាជាបច្ច័យ ។ បេ ។ ហេតុដែលនាំឲ្យកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ព្រោះអាស្រ័យត្រចៀកនិងសំឡេង ... ព្រោះអាស្រ័យច្រមុះនិងក្លិន ... ព្រោះអាស្រ័យអណ្តាតនិងរស ... ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ .. មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការប្រជុំរបស់ទាំង ៣ ហៅថាផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ឧបាទានកើតឡើង ព្រោះតណ្ហាជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[១៦៧] ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំរបស់ទាំង ៣ ហៅថាផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ការរលត់នៃឧបាទាន ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃតណ្ហានោះឯង ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ព្រោះអាស្រ័យត្រចៀកនិងសំឡេង ។ បេ ។

មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

(១៦៨) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ភគវតោ ឧបស្សុតិ(១) ឋិតោ ហោតិ ។ អទ្ទសា ខោ ភគវា តំ ភិក្ខុំ ឧបស្សុតិំ ឋិតំ ទិស្វាន តំ ភិក្ខុំ ឯតទវោច អស្សោសិ នោ ត្វំ ភិក្ខុ ឥមំ ធម្មបរិយា-យន្តិ ។ ឯវំ ភន្តេតិ ។ ឧគ្គណ្ហាហិ ត្វំ ភិក្ខុ ឥមំ ធម្ម-បរិយាយំ បរិយាបុណាហិ ត្វំ ភិក្ខុ ឥមំ ធម្មបរិយាយំ ធារេហិ ត្វំ ភិក្ខុ ឥមំ ធម្មបរិយាយំ អត្ថសញ្ហិតោយំ ភិក្ខុ ធម្មបរិយាយោ អាទិព្រហ្មចរិយកោតិ ។ បញ្ចមំ ។

---

១ ឱ. ឧបស្សុតឹ ឋិតោ ។

មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការប្រជុំរបស់ធម៌ទាំង ៣ ហៅថាផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ការរលត់នៃឧបាទាន ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃតណ្ហានោះឯង ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

( ១៦៨ ) សម័យនោះឯង ភិក្ខុមួយរូបឈរផែបចាំស្តាប់ព្រះបន្ទូលព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ បានទតឃើញភិក្ខុនោះ ដែលកំពុងឈរផែបចាំស្តាប់ លុះទតឃើញហើយ ទើបទ្រង់ត្រាស់នឹងភិក្ខុនោះយ៉ាងនេះថា ម្នាលភិក្ខុ អ្នកឮធម្មបរិយាយនេះ ឬមិនឮទេ ។ ភិក្ខុនោះក្រាបបង្គំទូលថា ឮ ព្រះអង្គ ។ ម្នាលភិក្ខុ អ្នកចូលរៀនធម្មបរិយាយនេះចុះ ម្នាលភិក្ខុ អ្នកចូរទន្ទេញធម្មបរិយាយនេះចុះ ម្នាលភិក្ខុ អ្នកចូរទ្រទ្រង់ធម្មបរិយាយនេះចុះ ម្នាលភិក្ខុ ឯធម្មបរិយាយនេះ ប្រកបដោយប្រយោជន៍ ជាអាទិព្រហ្មចរិយៈ ។ ចប់សូត្រ ទី ៨ ។

(១៦៩) សាវត្ថិយំ វិហរតិ ... អថ ខោ អញ្ញតរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារា-ណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

(១៧០) ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្ម-ណោ ភគវន្តំ ឯតទវោច កឹ នុ ខោ ភោ គោតម សោ ករោតិ សោ បដិសំវេទយតីតិ ។ សោ ករោតិ សោ បដិសំវេទយតីតិ ខោ ព្រាហ្មណ អយមេកោ អន្តោ ។ កឹ បន ភោ គោតម អញ្ញោ ករោតិ អញ្ញោ បដិសំវេទយតីតិ ។ អញ្ញោ ករោតិ អញ្ញោ បដិ-សំវេទយតីតិ ខោ ព្រាហ្មណ អយំ ទុតិយោ អន្តោ ឯតេ តេ ព្រាហ្មណ ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ អវិជ្ជាបច្ចយា សង្ខារា

(១៦៩) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... គ្រានោះឯង មានព្រាហ្មណ៍ម្នាក់ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏និយាយសំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីសមគួរ ។

(១៧០) លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលនោះធ្វើកម្ម បុគ្គលនោះទទួលផលកម្ម ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពាក្យថា បុគ្គលនោះធ្វើកម្ម បុគ្គលនោះទទួលផលកម្ម នេះជាផ្លូវលាមកទីមួយ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះបុគ្គលដទៃធ្វើកម្ម បុគ្គលដទៃទទួលផលកម្ម ។ ម្នាលព្រាហ្មណ៍ ពាក្យថា បុគ្គលដទៃធ្វើកម្ម បុគ្គលដទៃទទួលផលកម្ម នេះជាផ្លូវលាមកទីពីរ ម្នាលព្រាហ្មណ៍ តថាគតមិនបានប៉ះពាល់ផ្លូវលាមកទាំងពីរខាងនេះទេ សំដែងធម៌តាមផ្លូវកណ្តាល សង្ខារទាំងឡាយកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ

សង្ខារបច្ចយា វិញ្ញាណំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

(១៧១) ឯវំ វុត្តេ សោ ព្រាហ្មណោ ភគវន្តំ ឯ-តទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។បេ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ ឆដ្ឋំ ។

(១៧២) សាវត្ថិយំ វិហរតិ ... អថខោ ជាណុស្សោ-ណិ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧប-សង្កមិត្វា ភគវតា សទ្ធឹ ។បេ។

វិញ្ញាណកើតឡើង ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ការរលត់នៃសង្ខារ ព្រោះការវិនាសទិនការរលត់មិនសេសសល់ នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[ ១៧១ ] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍នោះបានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិត តាំងដើមតាំងអំពីថ្ងៃនេះតទៅ ។ ចប់សូត្រ ទី ៦ ។

(១៧២) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... គ្រានោះឯង ព្រាហ្មណ៍ឈ្មោះជាណុស្សោណិ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ ជាមួយនឹងព្រះមានព្រះភាគ ។

(១៧៣) ឯកមន្តំ និសិន្នោ ខោ ជាណុស្សោណិ ព្រាហ្មណោ ភគវន្តំ ឯតទវោច កិំ នុ ខោ ភោ គោតម សព្វមត្ថីតិ ។ សព្វមត្ថីតិ ខោ ព្រាហ្មណ អយមេកោ អន្តោ ។ កិំ បន ភោ គោតម សព្វំ នត្ថីតិ ។ សព្វំ នត្ថីតិ ខោ ព្រាហ្មណ អយំ ទុតិយោ អន្តោ ឯតេ តេ ព្រាហ្មណ ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិ-រោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

(១៧៤) ឯវំ វុត្តេ ជាណុស្សោណិ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម ។ បេ ។ បាណុបេតំ សរណង្គតន្តិ ។ សត្តមំ ។

[១៧៣] លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន របស់ទាំងអស់ មានឬហ្ន៎ ។ ព្រះអង្គតបថា ម្នាលព្រាហ្មណ៍ ពាក្យថា របស់ទាំងអស់មាន នេះជាផ្លូវលាមកទីមួយ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះរបស់ទាំងអស់ មិនមានទេឬ ។ ម្នាលព្រាហ្មណ៍ ពាក្យថា របស់ទាំងអស់ មិនមាន នេះជាផ្លូវលាមកទីពីរ ម្នាលព្រាហ្មណ៍ តថាគតមិនបានប៉ះពាល់ធម៌លាមក ២ ប្រការនុ៎ះទេ សំដែងធម៌តាមផ្លូវកណ្តាលថា សង្ខារទាំងឡាយកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតឡើង ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[១៧៤] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ជាណុស្សោណិព្រាហ្មណ៍ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ។ បេ ។ អ្នកដល់នូវសរណៈស្មើដោយជីវិត ។ ចប់សូត្រ ទី ៧ ។

(១៧៥) សាវត្ថិយំ វិហរតិ ... អថខោ លោកាយតិកោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ។ បេ ។

(១៧៦) ឯកមន្តំ និសិន្នោ ខោ លោកាយតិកោ ព្រាហ្មណោ ភគវន្តំ ឯតទវោច កិំ នុ ខោ ភោ គោតម សព្វមត្ថីតិ ។ សព្វមត្ថីតិ ខោ ព្រាហ្មណ ជេដ្ឋមេតំ លោកាយតំ ។ កិំ បន ភោ គោតម សព្វំ នត្ថីតិ ។ សព្វំ នត្ថីតិ ខោ ព្រាហ្មណ ទុតិយមេតំ លោកាយតំ ។ កិំ នុ ខោ ភោ គោតម សព្វមេកត្តន្តិ ។ សព្វមេកត្តន្តិ ខោ ព្រាហ្មណ តតិយមេតំ លោកាយតំ ។ កិំ បន ភោ គោតម សព្វំ បុថុត្តន្តិ ។ សព្វំ បុថុត្តន្តិ ខោ ព្រាហ្មណ ចតុត្ថមេតំ លោកាយតំ ឯតេ តេ ព្រាហ្មណ ឧភោ អន្តេ អនុបគម្ម មជ្ឈេន តថាគតោ ធម្មំ ទេសេតិ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(១៧៥) ទ្រង់គង់នៅទៀបក្រុងសាវត្ថី...គ្រានោះឯង ព្រាហ្មណ៍ឈ្មោះលោកាយតិកៈ បានចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។

(១៧៦) លុះលោកាយតិកព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន របស់ទាំងអស់ មានឬហ្ន៎ ។ ព្រះអង្គតបថា ម្នាលព្រាហ្មណ៍ ពាក្យថា របស់ទាំងអស់ មាន នេះជាលោកាយតៈជាច្បង ។ បពិត្រព្រះគោតមដ៏ចម្រើន របស់ទាំងអស់ មិនមានទេឬ ។ ម្នាលព្រាហ្មណ៍ ពាក្យថា របស់ទាំងអស់ មិនមាន នេះជាលោកាយតៈទីពីរ ។ បពិត្រព្រះគោតមដ៏ចម្រើន របស់ទាំងអស់ មានសភាពតែមួយឬ ។ ម្នាលព្រាហ្មណ៍ ពាក្យថា របស់ទាំងអស់ មានសភាពតែមួយ នេះជាលោកាយតៈទីបី ។ បពិត្រព្រះគោតមដ៏ចម្រើន របស់ទាំងអស់ មានសភាពផ្សេងគ្នាឬ ។ ម្នាលព្រាហ្មណ៍ ពាក្យថា របស់ទាំងអស់ មានសភាពផ្សេងគ្នា នេះជាលោកាយតៈទីបួន ម្នាលព្រាហ្មណ៍ តថាគតមិនបានប៉ះពាល់ផ្លូវលាមកទាំង ២ នេះទេ សំដែងធម៌តាមផ្លូវកណ្តាលថា សង្ខារទាំងឡាយកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតឡើង ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

(១៧៧) ឯវំ វុត្តេ លោកាយតិកោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ អដ្ឋមំ ។

(១៧៨) សាវត្ថិយំ វិហរតិ ... តត្រ ខោ ... ន ភិក្ខវេ សុតវតោ អរិយសាវកស្ស ឯវំ ហោតិ កិំ នុ ខោ កិស្មិំ សតិ កិំ ហោតិ កិស្សុប្បាទា កិំ ឧប្បជ្ជតិ កិស្មិំ សតិ សង្ខារា ហោន្តិ កិស្មិំ សតិ វិញ្ញាណំ ហោតិ កិស្មិំ សតិ នាមរូបំ ហោតិ កិស្មិំ សតិ សឡាយតនំ ហោតិ កិស្មិំ សតិ ផស្សោ ហោតិ កិស្មិំ សតិ វេទនា ហោតិ កិស្មិំ សតិ តណ្ហា ហោតិ កិស្មិំ សតិ

ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

( ១៧៧ ) កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ លោកាយតិកព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ។ បេ ។ អ្នកដល់នូវសរណៈស្មើដោយជីវិត តាំងដើមអំពីថ្ងៃនេះតទៅ ។ ចប់សូត្រ ទី ៨ ។

( ១៧៨ ) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ក្នុងទីនោះឯង ... ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើរបស់អ្វីមាន ទើបរបស់អ្វីមានហ្ន៎ របស់អ្វីកើតឡើង ព្រោះការកើតឡើងនៃរបស់អ្វីហ្ន៎ កាលបើរបស់អ្វីមាន ទើបសង្ខារទាំង-ឡាយមាន កាលបើរបស់អ្វីមាន ទើបវិញ្ញាណមាន កាលបើរបស់អ្វីមាន ទើបនាមរូបមាន កាលបើរបស់អ្វីមាន ទើបសឡាយតនៈមាន កាលបើរបស់អ្វីមាន ទើបផស្សៈមាន កាលបើរបស់អ្វីមាន ទើបវេទនាមាន កាលបើរបស់អ្វីមាន ទើបតណ្ហាមាន កាលបើរបស់អ្វីមាន

ឧបាទានំ ហោតិ កិស្មឹ សតិ ភវោ ហោតិ កិស្មឹ សតិ ជាតិ ហោតិ កិស្មឹ សតិ ជរាមរណំ ហោតីតិ ។

(១៧៩) អថខោ ភិក្ខវេ សុតវតោ អរិយសាវកស្ស អបរប្បច្ចយា ញាណមេវេត្ថ ហោតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ អវិជ្ជាយ សតិ សង្ខារា ហោន្តិ សង្ខារេសុ សតិ វិញ្ញាណំ ហោតិ វិញ្ញាណេ សតិ នាមរូបំ ហោតិ នាមរូបេ សតិ សឡាយតនំ ហោតិ សឡាយតនេ សតិ ផស្សោ ហោតិ ផស្សេ សតិ វេទនា ហោតិ វេទនាយ សតិ តណ្ហា ហោតិ តណ្ហាយ សតិ ឧបាទានំ ហោតិ ឧបាទានេ សតិ ភវោ ហោតិ ។បេ។ ជាតិយា សតិ ជរាមរណំ ហោតីតិ ។ សោ ឯវំ បជានាតិ ឯវមយំ លោកោ សមុទយតីតិ ។

ទើបឧបាទានមាន កាលបើរបស់អ្វីមាន ទើបភពមាន កាលបើរបស់អ្វីមាន ទើបជាតិមាន កាលបើរបស់អ្វីមាន ទើបជរាមរណៈមាន ដូច្នេះឡើយ ។

[១៧៩] ម្នាលភិក្ខុទាំងឡាយ ព្រោះនោះឯង អរិយសាវ័កជាអ្នកចេះដឹង មានញាណក្នុងធម៌នោះ ព្រោះបច្ច័យដែលកើតត ៗ គ្នាថា កាលបើរបស់នេះមាន របស់នេះក៏មាន របស់នេះកើតឡើង ព្រោះការកើតនៃរបស់នេះ កាលបើអវិជ្ជាមាន សង្ខារទាំងឡាយក៏មាន កាលបើសង្ខារទាំងឡាយមាន វិញ្ញាណក៏មាន កាលបើវិញ្ញាណមាន នាមរូបក៏មាន កាលបើនាមរូបមាន សឡាយតនៈក៏មាន កាលបើសឡាយតនៈមាន ផស្សៈក៏មាន កាលបើផស្សៈមាន វេទនាក៏មាន កាលបើវេទនាមាន តណ្ហាក៏មាន កាលបើតណ្ហាមាន ឧបាទានក៏មាន កាលបើឧបា-ទានមាន ភពក៏មាន ។ បេ ។ កាលបើជាតិមាន ជរាមរណៈក៏មាន ។ អរិយសាវ័កនោះ តែងដឹងច្បាស់យ៉ាងនេះថា លោកនេះ កើតឡើងព្រមយ៉ាងនេះ ។

[១៨០] ន ភិក្ខវេ សុតវតោ អរិយសាវកស្ស ឯវំ ហោតិ កិំ នុ ខោ កិស្មិំ អសតិ កិំ ន ហោតិ កិស្ស និរោធា កិំ និរុជ្ឈតិ កិស្មិំ អសតិ សង្ខារា ន ហោន្តិ កិស្មិំ អសតិ វិញ្ញាណំ ន ហោតិ កិស្មិំ អសតិ នាមរូបំ ន ហោតិ កិស្មិំ អសតិ សឡាយតនំ ន ហោតិ កិស្មិំ អសតិ ផស្សោ ន ហោតិ កិស្មិំ អសតិ វេទនា ន ហោតិ កិស្មិំ អសតិ តណ្ហា ន ហោតិ កិស្មិំ អសតិ ឧបាទានំ ន ហោតិ កិស្មិំ អសតិ ភវោ ន ហោតិ កិស្មិំ អសតិ ជាតិ ន ហោតិ កិស្មិំ អសតិ ជរាមរណំ ន ហោតីតិ ។

[១៨១] អថខោ ភិក្ខវេ សុតវតោ អរិយសាវក-ស្ស អបរប្បច្ចយា ញាណមេវេត្ថ ហោតិ ឥមស្មិំ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ វិញ្ញាណេ អសតិ នាមរូបំ ន ហោតិ នាមរូបេ អសតិ សឡាយតនំ ន ហោតិ ។ បេ ។ ឧបាទានំ ន ហោតិ ... ភវោ ន ហោតិ ... ជាតិ ន ហោតិ ជាតិយា

[ ១៨០ ] ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កជាអ្នកចេះដឹង មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើរបស់អ្វីមិនមាន របស់អ្វីក៏មិនមាន របស់អ្វីរលត់ ព្រោះការរលត់នៃរបស់អ្វី កាលបើរបស់អ្វីមិនមាន សង្ខារទាំងឡាយក៏មិនមាន កាលបើរបស់អ្វីមិនមាន វិញ្ញាណក៏មិនមាន កាលបើរបស់អ្វីមិនមាន នាមរូបក៏មិនមាន កាលបើរបស់អ្វីមិនមាន សឡាយតនៈក៏មិនមាន កាលបើរបស់អ្វីមិនមាន ផស្សៈក៏មិនមាន កាលបើរបស់អ្វីមិនមាន វេទនាក៏មិនមាន កាលបើរបស់អ្វីមិនមាន តណ្ហាក៏មិនមាន កាលបើរបស់អ្វីមិនមាន ឧបាទានក៏មិនមាន កាលបើរបស់អ្វីមិនមាន ភពក៏មិនមាន កាលបើរបស់អ្វីមិនមាន ជាតិក៏មិនមាន កាលបើរបស់អ្វីមិនមាន ជរាមរណៈក៏មិនមាន ដូច្នេះឡើយ ។

[ ១៨១ ] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង អរិយសាវ័កជាអ្នកចេះដឹង មានញាណក្នុងធម៌នោះ ព្រោះបច្ច័យដែលកើតឯង ៗ គឺថា កាលបើរបស់នេះមិនមាន របស់នេះក៏មិនមាន របស់នេះរលត់ ព្រោះការរលត់នៃរបស់នេះ កាលបើវិញ្ញាណមិនមាន នាមរូបក៏មិនមាន កាលបើនាមរូបមិនមាន សឡាយតនៈក៏មិនមាន ។ បេ ។ ឧបាទានក៏មិនមាន ... ភពក៏មិនមាន ... ជាតិក៏មិនមាន កាលបើជាតិ

អសតិ ជរាមរណំ ន ហោតីតិ ។ សោ ឯវំ បជានាតិ ឯវមយំ លោកោ និរុជ្ឈតីតិ ។

(១៨២) យតោ ខោ ភិក្ខវេ អរិយសាវកោ ឯវំ លោកស្ស សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជានាតិ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ ទិដ្ឋិសម្បន្នោ ឥតិបិ ។ បេ ។ អមតទ្វារំ អាហច្ច តិដ្ឋតិ ឥតិបីតិ ។ ទសមំ ។

(១៨៣) សាវត្ថិយំ វិហរតិ ... តត្រ ខោ ... ន ភិក្ខវេ សុតវតោ អរិយសាវកស្ស ឯវំ ហោតិ កឹ នុ ខោ កិស្មឹ សតិ កឹ ហោតិ កិស្សុប្បាទា កឹ ឧប្បជ្ជតិ កិស្មឹ សតិ សង្ខារា ហោន្តិ កិស្មឹ សតិ វិញ្ញាណំ ហោតិ កិស្មឹ សតិ នាមរូបំ ហោតិ កិស្មឹ សតិ សឡាយតនំ ហោតិ កិស្មឹ សតិ ផស្សោ ហោតិ កិស្មឹ សតិ វេទនា ហោតិ កិស្មឹ សតិ តណ្ហា ហោតិ កិស្មឹ សតិ ឧបាទានំ ហោតិ កិស្មឹ សតិ ភវោ ហោតិ កិស្មឹ សតិ ជាតិ ហោតិ កិស្មឹ សតិ ជរាមរណំ ហោតីតិ ។

មិនមាន ជរាមរណៈក៏មិនមាន ។ អរិយសាវ័កនោះ រមែងដឹងច្បាស់យ៉ាងនេះថា លោកនេះ តែងរលត់យ៉ាងនេះ ។

(១៨២) ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ដឹងច្បាស់តាមពិតនូវហេតុដែលនាំឲ្យកើតឡើង និងសេចក្តីរលត់នៃលោកយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះ តថាគតហៅថា អ្នកបរិបូណ៌ដោយទិដ្ឋិដូច្នេះខ្លះ ។ បេ ។ ថាអ្នកឋិតអែបនឹងទ្វារនៃអមតនិព្វាន ដូច្នេះខ្លះ ក្នុងកាលនោះ ។ ចប់សូត្រ ទី ៩ ។

(១៨៣) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ... ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កជាអ្នកចេះដឹង មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើរបស់អ្វីមាន ទើបរបស់អ្វីមានឬ របស់អ្វីមានព្រោះការកើតឡើងនៃរបស់អ្វី កាលបើរបស់អ្វីមាន ទើបសង្ខារទាំង-ឡាយមាន កាលបើរបស់អ្វីមាន ទើបវិញ្ញាណមាន កាលបើរបស់អ្វីមាន ទើបនាមរូបមាន កាលបើរបស់អ្វីមាន ទើបសឡាយតនៈមាន កាលបើរបស់អ្វីមាន ទើបផស្សៈមាន កាលបើរបស់អ្វីមាន ទើបវេទនាមាន កាលបើរបស់អ្វីមាន ទើបតណ្ហាមាន កាលបើរបស់អ្វីមាន ទើបឧបា-ទានមាន កាលបើរបស់អ្វីមាន ទើបភពមាន កាលបើរបស់អ្វីមាន ទើបជាតិមាន កាលបើរបស់អ្វីមាន ទើបជរាមរណៈមាន ។

(១៨៦) អថខោ ភិក្ខវេ សុតវតោ អរិយសាវកស្ស អបរប្បច្ចយា ញាណមេវេត្ថ ហោតិ ឥមស្មិំ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ អវិជ្ជាយ សតិ សង្ខារា ហោន្តិ សង្ខារេសុ សតិ វិញ្ញាណំ ហោតិ វិញ្ញាណេ សតិ នាមរូបំ ហោតិ នាមរូបេ សតិ សឡាយតនំ ហោតិ សឡាយតនេ សតិ ផស្សោ ហោតិ ផស្សេ សតិ វេទនា ហោតិ វេទនាយ សតិ តណ្ហា ហោតិ តណ្ហាយ សតិ ឧបាទានំ ហោតិ ឧបាទានេ សតិ ភវោ ហោតិ ភវេ សតិ ជាតិ ហោតិ ជាតិយា សតិ ជរាមរណំ ហោតីតិ ។ សោ ឯវំ បជានាតិ ឯវមយំ លោកោ សមុទយតីតិ ។

(១៨៧) ន ភិក្ខវេ សុតវតោ អរិយសាវកស្ស ឯវំ ហោតិ កិំ នុ ខោ កិស្មិំ អសតិ កិំ ន ហោតិ កិស្ស និរោធា កិំ និរុជ្ឈតិ កិស្មិំ អសតិ

(១៨៤) ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង អរិយសាវ័កជាអ្នកចេះដឹង មានញាណក្នុងធម៌នោះ ព្រោះបច្ច័យដែលកើតត ៗ គ្នាថា កាលបើរបស់នេះមាន របស់នេះក៏មាន របស់នេះកើតឡើង ព្រោះការកើតឡើងនៃរបស់នេះ គឺកាលបើអវិជ្ជាមាន សង្ខារទាំងឡាយក៏មាន កាលបើសង្ខារទាំងឡាយមាន វិញ្ញាណក៏មាន កាលបើវិញ្ញាណមាន នាមរូបក៏មាន កាលបើនាមរូបមាន សឡាយតនៈក៏មាន កាលបើសឡាយតនៈមាន ផស្សៈក៏មាន កាលបើផស្សៈមាន វេទនាក៏មាន កាលបើវេទនាមាន តណ្ហាក៏មាន កាលបើតណ្ហាមាន ឧបាទានក៏មាន កាលបើឧបាទានមាន ភពក៏មាន កាលបើភពមាន ជាតិក៏មាន កាលបើជាតិមាន ជរាមរណៈក៏មាន ៗ អរិយសាវ័កនោះ តែងដឹងច្បាស់យ៉ាងនេះថា លោកនេះ រមែងកើតឡើងព្រម យ៉ាងនេះ ៗ

(១៨៥) ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កជាអ្នកចេះដឹង មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើមិនមានរបស់អ្វី ទើបមិនមានរបស់អ្វីហ្ន៎+ របស់អ្វីរលត់ទៅ ព្រោះការរលត់ទៅនៃរបស់អ្វី កាលបើរបស់អ្វីមិនមាន

សង្ខារា ន ហោន្តិ កិស្មឹ អសតិ វិញ្ញាណំ ន ហោតិ កិស្មឹ អសតិ នាមរូបំ ន ហោតិ កិស្មឹ អសតិ សឡាយតនំ ន ហោតិ កិស្មឹ អសតិ ផស្សោ ន ហោតិ កិស្មឹ អសតិ វេទនា ន ហោតិ កិស្មឹ អសតិ តណ្ហា ន ហោតិ ។បេ។ ឧបាទានំ ... ភវោ ... ជាតិ ... កិស្មឹ អសតិ ជរាមរណំ ន ហោតីតិ ។

(១៨៦) អថខោ ភិក្ខវេ សុតវតោ អរិយសាវកស្ស អបរប្បច្ចយា ញាណមេវេត្ថ ហោតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ អវិជ្ជាយ អសតិ សង្ខារា ន ហោន្តិ សង្ខារេសុ អសតិ វិញ្ញាណំ ន ហោតិ វិញ្ញាណេ អសតិ នាមរូបំ ន ហោតិ នាមរូបេ អសតិ សឡាយតនំ ន ហោតិ ។បេ។ ជាតិយា អសតិ ជរាមរណំ ន ហោតីតិ ។ សោ ឯវំ បជានាតិ ឯវមយំ លោកោ និរុជ្ឈតីតិ ។

(១៨៧) យតោ ខោ ភិក្ខវេ អរិយសាវកោ ឯវំ លោកស្ស សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជានាតិ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ

ទើបសង្ខារទាំងឡាយមិនមាន កាលបើរបស់អ្វីមិនមាន ទើបវិញ្ញាណមិនមាន កាលបើរបស់អ្វីមិនមាន ទើបនាមរូបមិនមាន កាលបើរបស់អ្វីមិនមាន ទើបសឡាយតនៈមិនមាន កាលបើរបស់អ្វីមិនមាន ទើបផស្សៈមិនមាន កាលបើរបស់អ្វីមិនមាន ទើបវេទនាមិនមាន កាលបើរបស់អ្វីមិនមាន ទើបតណ្ហាមិនមាន ។ បេ ។ ឧបាទាន ... ភព ... ជាតិ ... កាលបើរបស់អ្វីមិនមាន ទើបជរាមរណៈមិនមាន ដូច្នេះឡើយ ។

(១៨៦) ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង អរិយសាវកជាអ្នកចេះដឹង មានញាណក្នុងធម៌នោះ ព្រោះបច្ច័យដែលកើតតៗគ្នាថា កាលបើរបស់នេះមិនមាន របស់នេះក៏មិនមាន របស់នេះរលត់ទៅ ព្រោះការរលត់នៃរបស់នេះ គឺកាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន កាលបើសង្ខារទាំងឡាយមិនមាន វិញ្ញាណក៏មិនមាន កាលបើវិញ្ញាណមិនមាន នាមរូបក៏មិនមាន កាលបើនាមរូបមិនមាន សឡាយតនៈក៏មិនមាន ។ បេ ។ កាលបើជាតិមិនមាន ជរាមរណៈក៏មិនមាន ។ អរិយ-សាវកនោះ រមែងដឹងច្បាស់យ៉ាងនេះថា លោកនេះតែងរលត់យ៉ាងនេះ ។

(១៨៧) ម្នាលភិក្ខុទាំងឡាយ អរិយសាវក ដឹងច្បាស់តាមពិត នូវហេតុដែលនាំឲ្យកើតសង្ខារលោក និងសេចក្តីរលត់នៃសង្ខារ-លោកយ៉ាងនេះ ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ អរិយសាវកនេះ

ទិដ្ឋិសម្បន្នោ ឥតិបិ ទស្សនសម្បន្នោ ឥតិបិ អាគតោ ឥមំ សទ្ធម្មំ ឥតិបិ បស្សតិ ឥមំ សទ្ធម្មំ ឥតិបិ សេក្ខេន ញាណេន សមន្នាគតោ ឥតិបិ សេក្ខាយ វិជ្ជាយ សមន្នាគតោ ឥតិបិ ធម្មសោតំ សមាបន្នោ ឥតិបិ អរិយោ និព្វេធិកបញ្ញោ ឥតិបិ អមតទ្វារំ អាហច្ច តិដ្ឋតិ ឥតិបីតិ ។ ទសមំ ។

គហបតិវគ្គោ បញ្ចមោ ។

## តស្សុទ្ទានំ

ទ្វេ បញ្ចវេរភយា វុត្តា
ទុក្ខំ លោកោ ច ញាតិកំ
អញ្ញតរំ ជាណុស្សោណិ ច
លោកាយតិកេន អដ្ឋមំ
ទ្វេ អរិយសាវកា វុត្តា
វគ្គោ តេន បវុច្ចតីតិ ។

ហៅថា ជាអ្នកបរិបូណ៌ដោយទិដ្ឋិដូច្នេះខ្លះ ថាអ្នកបរិបូណ៌ដោយទស្សនៈដូច្នេះខ្លះ ថាជាអ្នកមកកាន់ព្រះសទ្ធម្មដូច្នេះខ្លះ ថាជាអ្នកឃើញព្រះសទ្ធម្មដូច្នេះខ្លះ ថាជាអ្នកប្រកបដោយញាណជាសេក្ខៈដូច្នេះខ្លះ ថាជាអ្នកប្រកបដោយវិជ្ជាសេក្ខៈដូច្នេះខ្លះ ថាជាអ្នកសម្រេចធម្មស្រោតដូច្នេះខ្លះ ថាជាអរិយៈអ្នកមាននិព្វេធិកប្បញ្ញា (ប្រាជ្ញាទម្លាយបង់នូវកិលេស) ដូច្នេះខ្លះ ថាឋិតអែបនឹងទ្វារនៃអមតនិព្វានដូច្នេះខ្លះ ក្នុងកាលនោះ ។ ចប់សូត្រទី ១០ ។

ចប់ គហបតិវគ្គ ទី ៥ ។

## បញ្ជីរឿងនៃគហបតិវគ្គនោះគឺ

បញ្ចវេរភយសូត្រ លោកពោលអស់ ២ លើក ទ្រង់សំដែងហេតុដែលឲ្យកើតទុក្ខ ហេតុដែលឲ្យកើតលោក ព្រះអង្គគង់ក្នុងស្រុកជារបស់ព្រះញាតិ រឿងអញ្ញតរព្រាហ្មណ៍ រឿងជាណុស្សោណិព្រាហ្មណ៍ រឿងលោកាយតិកព្រាហ្មណ៍ត្រូវជា ៨ លោកពោលថាអរិយសាវ័ក ២ លើក វគ្គពោលតាមរឿងនោះ ។

## ទុក្ខវគ្គោ

(១៨៨) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កិត្តាវតា នុ ខោ ភិក្ខវេ ភិក្ខុ បរិវីមំសមានោ បរិវីមំសេយ្យ សព្វសោ សម្មា ទុក្ខក្ខយាយាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

# ទុក្ខវគ្គ

( ១៨៨ ) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំង-ឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលនឹងពិចារណា គួរពិចារណាដើម្បីក្ស័យអស់ទៅនៃសេចក្តីទុក្ខ ដោយប្រពៃគ្រប់ប្រការ ដោយហេតុដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ពួកយើងខ្ញុំ មានព្រះមានព្រះភាគជាឫសគល់ មានព្រះមានព្រះភាគជាអ្នកដឹកនាំ មានព្រះមានព្រះភាគជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់មេត្តាប្រោស សូមព្រះមានព្រះភាគបំភ្លឺសេចក្តីនៃភាសិតនុ៎ះ ពួកភិក្ខុបានស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគហើយ នឹងបានចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

(១៨៩) ភគវា ឯតទវោច ឥធ ភិក្ខវេ ភិក្ខុ បរិវីមំសមានោ បរិវីមំសតិ យំ ខោ ឥទំ អនេកវិធំ នានប្បការកំ ទុក្ខំ លោកេ ឧប្បជ្ជតិ ជរាមរណំ ឥទំ នុ ខោ ទុក្ខំ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវំ កិស្មឹ សតិ ជរាមរណំ ហោតិ កិស្មឹ អសតិ ជរាមរណំ ន ហោតីតិ ។ សោ បរិវីមំសមានោ ឯវំ បជានាតិ យំ ខោ ឥទំ អនេកវិធំ នានប្បការកំ ទុក្ខំ លោកេ ឧប្បជ្ជតិ ជរាមរណំ ឥទំ ខោ ទុក្ខំ ជាតិនិទានំ ជាតិសមុទយំ ជាតិជាតិកំ ជាតិប្បភវំ ជាតិយា សតិ ជរាមរណំ ហោតិ ជាតិយា អសតិ ជរាមរណំ ន ហោតីតិ ។ សោ ជរាមរណញ្ច បជានាតិ ជរាមរណសមុទយញ្ច បជានាតិ ជរាមរណនិរោធញ្ច បជានាតិ យា ច ជរាមរណនិរោធសារុប្បគាមិនី បដិបទា តញ្ច បជានាតិ តថា បដិបន្នោ ច ហោតិ អនុធម្មចារី ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សព្វសោ សម្មា ទុក្ខក្ខយាយ បដិបន្នោ ជរាមរណនិរោធាយ ។

(១៨៩) ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលនឹងពិចារណា ក៏ពិចារណាថា ជរាមរណៈណា ជាទុក្ខ មានប្រការច្រើន មានប្រការផ្សេង ៗ កើតឡើងក្នុងលោក សេចក្តីទុក្ខនេះឯង មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព កាលបើអ្វីមាន ទើបជរាមរណៈមាន កាលបើអ្វីមិនមាន ទើបជរាមរណៈមិនមាន ។ កាលភិក្ខុនោះពិចារណា ក៏ដឹងច្បាស់យ៉ាងនេះថា ជរាមរណៈណា ជាទុក្ខ មានប្រការច្រើន មានប្រការផ្សេង ៗ កើតឡើងក្នុងលោក សេចក្តីទុក្ខនេះឯង មានជាតិជាហេតុ មានជាតិនាំឲ្យកើត មានជាតិជាកំណើត មានជាតិជាប្រភព កាលបើជាតិមាន ជរាមរណៈក៏មាន កាលបើជាតិមិនមាន ជរាមរណៈក៏មិនមាន ។ ភិក្ខុនោះ ក៏ដឹងច្បាស់នូវជរាមរណៈផង ដឹងច្បាស់នូវហេតុជាទីកើតនៃជរាមរណៈផង ដឹងច្បាស់នូវទីរលត់ទៅនៃជរាមរណៈផង ដឹងច្បាស់នូវបដិបទាដ៏សមគួរ ជាដំណើរទៅកាន់ទីរលត់នៃជរាមរណៈផង ហើយប្រតិបត្តិតាមលំអាននោះ ជាអ្នកប្រព្រឹត្តធម៌តាមសមគួរផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថា ជាអ្នកប្រតិបត្តិ ដើម្បីក្ស័យអស់ទៅនៃទុក្ខ ដើម្បីការរលត់នូវជរាមរណៈ ដោយប្រពៃ ដោយប្រការទាំងពួង ។

[១៩០] អថាបរំ បរិវីមំសមានោ បរិវីមំសតិ ជាតិ បនាយំ កិំនិទានា កិំសមុទយា កិំជាតិកា កិំបភវា កិស្មិំ សតិ ជាតិ ហោតិ កិស្មិំ អសតិ ជាតិ ន ហោតីតិ ។ សោ បរិវីមំសមានោ ឯវំ បជានាតិ ជាតិ ភវនិទានា ភវសមុទយា ភវជាតិកា ភវប្បភវា ភវេ សតិ ជាតិ ហោតិ ភវេ អសតិ ជាតិ ន ហោតីតិ ។ សោ ជាតិញ្ច បជានាតិ ជាតិសមុទយញ្ច បជានាតិ ជាតិនិរោធញ្ច បជានាតិ យា ច ជាតិនិរោធសារុប្បគាមិនី បដិបទា តញ្ច បជានាតិ តថា បដិបន្នោ ច ហោតិ អនុធម្មចារី ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សព្វសោ សម្មា ទុក្ខក្ខយាយ បដិបន្នោ ជាតិនិរោធាយ ។

[១៩១] អថាបរំ បរិវីមំសមានោ បរិវីមំសតិ ភវោ បនាយំ កិំនិទានោ ។ បេ ។ ឧបាទានំ បនិទំ កិំនិទានំ ... តណ្ហា បនាយំ កិំនិទានា ... វេទនា បនាយំ កិំនិទានា ... ផស្សោ បនាយំ កិំនិទានោ ... សឡាយតនំ បនិទំ កិំនិទានំ ... នាមរូបំ បនិទំ កិំនិទានំ ...

[ ១៩០ ] បើភិក្ខុពិចារណាតទៅទៀត រមែងពិចារណាថា ចុះជាតិនេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព កាលបើអ្វីមាន ទើបជាតិមាន កាលបើអ្វីមិនមាន ទើបជាតិមិនមាន ។ កាលភិក្ខុនោះពិចារណា ក៏ដឹងច្បាស់យ៉ាងនេះថា ជាតិមានភពជាហេតុ មានភពនាំឲ្យកើត មានភពជាកំណើត មានភពជាប្រភព កាលបើភពមាន ជាតិក៏មាន កាលបើភពមិនមាន ជាតិក៏មិនមាន ។ ភិក្ខុនោះ រមែងដឹងច្បាស់នូវជាតិផង ដឹងច្បាស់នូវហេតុជាទីកើតនៃជាតិផង ដឹងច្បាស់នូវទីរលត់នៃជាតិផង ដឹងច្បាស់នូវបដិបទាដ៏សមគួរ ជាដំណើរទៅកាន់ទីរលត់នៃជាតិផង ហើយប្រតិបត្តិតាមលំអាននោះ ជាអ្នកប្រព្រឹត្តធម៌តាមសមគួរផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថា ជាអ្នកប្រតិបត្តិ ដើម្បីកិរិយាអស់ទៅនៃទុក្ខ ដោយប្រពៃ ដើម្បីរំលត់ជាតិ ដោយសព្វគ្រប់ ។

[ ១៩១ ] បើភិក្ខុពិចារណាតទៅទៀត រមែងពិចារណាថា ចុះភពនេះ មានអ្វីជាហេតុ ។ បេ ។ ចុះឧបាទាននេះ មានអ្វីជាហេតុ ... ចុះតណ្ហានេះ មានអ្វីជាហេតុ ... ចុះវេទនានេះ មានអ្វីជាហេតុ ... ចុះផស្សៈនេះ មានអ្វីជាហេតុ ... ចុះសឡាយតនៈនេះ មានអ្វីជាហេតុ ... ចុះនាមរូបនេះ មានអ្វីជាហេតុ ...

វិញ្ញាណំ បនិទំ កិំនិទានំ ... សង្ខារា បនិមេ កិំនិទានា កិំសមុទយា កិំជាតិកា កិំបភវា កិស្មឹ សតិ សង្ខារា ហោន្តិ កិស្មឹ អសតិ សង្ខារា ន ហោន្តីតិ ។ សោ បរិវីមំសមានោ ឯវំ បជានាតិ សង្ខារា អវិជ្ជានិទានា អវិជ្ជាសមុទយា អវិជ្ជាជាតិកា អវិជ្ជាបភវា អវិជ្ជាយ សតិ សង្ខារា ហោន្តិ អវិជ្ជាយ អសតិ សង្ខារា ន ហោន្តីតិ ។ សោ សង្ខារេ ច បជានាតិ សង្ខារសមុទយញ្ច បជានាតិ សង្ខារនិរោធញ្ច បជានាតិ យា ច សង្ខារនិរោធសារុប្បគាមិនី បដិបទា តញ្ច បជានាតិ តថា បដិបន្នោ ច ហោតិ អនុធម្មចារី ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សព្វសោ សម្មា ទុក្ខក្ខយាយ បដិបន្នោ សង្ខារនិរោធាយ ។ អវិជ្ជាគតោ(១) ភិក្ខវេ បុរិសបុគ្គលោ បុញ្ញញ្ចេ សង្ខារំ អភិសង្ខរោតិ បុញ្ញូបគំ ហោតិ វិញ្ញាណំ អបុញ្ញញ្ចេ សង្ខារំ អភិសង្ខរោតិ អបុញ្ញូបគំ ហោតិ វិញ្ញាណំ អនេញ្ជញ្ចេ(២) សង្ខារំ អភិសង្ខរោតិ អនេញ្ជូបគំ ហោតិ វិញ្ញាណំ ។

---

១ ឱ.ម. អវិជ្ជាគតោយំ ។ ២ អនេញ្ជញ្ចេតិបត្តិ ។

វិញ្ញាណនេះ មានអ្វីជាហេតុ ... សង្ខារទាំងឡាយនេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាប្រភព កាលបើអ្វីមាន ទើបសង្ខារទាំងឡាយមាន កាលបើអ្វីមិនមាន ទើបសង្ខារទាំងឡាយមិនមាន ។ កាលភិក្ខុនោះពិចារណា ក៏ដឹងច្បាស់យ៉ាងនេះថា សង្ខារទាំងឡាយ មានអវិជ្ជាជាហេតុ មានអវិជ្ជានាំឲ្យកើត មានអវិជ្ជាជាកំណើត មានអវិជ្ជាជាប្រភព កាលបើអវិជ្ជាមាន សង្ខារទាំងឡាយក៏មាន កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ។ ភិក្ខុនោះ រមែងដឹងច្បាស់នូវសង្ខារទាំងឡាយផង ដឹងច្បាស់នូវហេតុជាទីកើតនៃសង្ខារផង ដឹងច្បាស់នូវទីរលត់នៃសង្ខារផង ដឹងច្បាស់នូវបដិបទាដ៏សមគួរជាដំណើរទៅកាន់ទីរលត់នៃសង្ខារផង ហើយប្រតិបត្តិតាមលំអាននោះ ជាអ្នកប្រព្រឹត្តធម៌តាមសមគួរផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថា ជាអ្នកប្រតិបត្តិ ដើម្បីកិរិយាអស់ទៅនៃសេចក្តីទុក្ខ ដោយប្រពៃ ដើម្បីការរលត់នៃសង្ខារ ដោយប្រការទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ បើបុរសបុគ្គល លុះក្នុងអំណាចអវិជ្ជាហើយ រមែងតាក់តែងសង្ខារជាបុណ្យ(១) វិញ្ញាណក៏ចូលទៅកៀកនឹងបុណ្យ បើតាក់តែងសង្ខារជាបាប(២) វិញ្ញាណក៏ចូលទៅកៀកនឹងបាប បើតាក់តែងសង្ខារជាអនេជៈ(៣) វិញ្ញាណក៏ចូលទៅកៀកនឹងអនេជៈ ។

---

១ សំដៅយកកាមាវចរកុសលចេតនា ៨ និងរូបាវចរកុសលចេតនា ៥ រួមជា ១៣ ។
២ បានដល់អកុសលចេតនា ២ ។ ៣ បានដល់អរូបាវចរកុសលចេតនា ៤ ។

(១៩២) យតោ ខោ ភិក្ខវេ ភិក្ខុនោ អវិជ្ជា បហីនា ហោតិ វិជ្ជា ឧប្បន្នា ។ សោ អវិជ្ជាវិរាគា វិជ្ជុប្បាទា នេវ បុញ្ញាភិសង្ខារំ អភិសង្ខរោតិ ន អបុញ្ញាភិសង្ខារំ អភិសង្ខរោតិ ន អនេជាភិសង្ខារំ អភិសង្ខរោតិ អនភិសង្ខរោន្តោ អនភិសញ្ចេតយន្តោ ន កិញ្ចិ លោកេ ឧបាទិយតិ អនុបាទិយំ ន បរិតស្សតិ អបរិតស្សំ បច្ចត្តំយេវ បរិនិព្វាយតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជា-នាតិ ។ សោ សុខញ្ចេ វេទនំ វេទយតិ សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ ។ ទុក្ខញ្ចេ វេទនំ វេទយតិ សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតា-តិ បជានាតិ ។ អទុក្ខមសុខញ្ចេ វេទនំ វេទយតិ

អភិសមយសំយុត្ត ទុក្ខវគ្គ ការលះបង់អវិជ្ជា

[ ១៨២ ] ម្នាលភិក្ខុទាំងឡាយ កាលដែលភិក្ខុលះបង់អវិជ្ជាហើយ វិជ្ជាក៏កើតឡើង ។ ព្រោះតែការបាត់ទៅនៃអវិជ្ជា ព្រោះតែការកើតឡើងនៃវិជ្ជា បានជាភិក្ខុនោះ លែងតាក់តែងបុញ្ញាភិសង្ខារ លែងតាក់តែងអបុញ្ញាភិសង្ខារ លែងតាក់តែងអនេជាភិសង្ខារ កាលបើលែងតាក់តែង លែងសន្សំហើយ ក៏លែងប្រកាន់អ្វីតិចតួចក្នុងលោកសោះឡើយ កាលបើលែងប្រកាន់ហើយ ក៏ឥតតក់ស្លុត កាលបើឥតតក់ស្លុតហើយ រមែងរលត់កិលេស ដោយចំពោះខ្លួនឯង ទើបដឹងច្បាស់ថា ជាតិ ( របស់អាត្មាអញ ) អស់ហើយ ព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បើភិក្ខុនោះទទួលវេទនាជាសុខ ក៏ដឹងច្បាស់ថា វេទនានោះ មិនទៀង ដឹងច្បាស់ថា លោកមិនប្រកាន់ហើយ ដឹងច្បាស់ថា លោកមិនត្រេកអរហើយ ។ បើភិក្ខុនោះ ទទួលវេទនាជាទុក្ខ ក៏ដឹងច្បាស់ថា វេទនានោះ មិនទៀង ដឹងច្បាស់ថា លោកមិនប្រកាន់ហើយ ដឹងច្បាស់ថា លោកមិនត្រេកអរហើយ ។ បើភិក្ខុនោះ ទទួលវេទនា មិនមែនជាទុក្ខមិនមែនជាសុខ

សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ ។ សោ សុខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ ទុក្ខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ អទុក្ខមសុខញ្ចេ វេទនំ វេទយតិ វិសញ្ញុត្តោ នំ វេទយតិ ។ សោ កាយបរិយន្តិកំ វេទនំ វេទយមានោ កាយបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ ។ ជីវិតបរិយន្តិកំ វេទនំ វេទយមានោ ជីវិតបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ ។ កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតីភវិស្សន្តិ សរីរានិ អវសិស្សន្តីតិ បជានាតិ ។

ក៏ដឹងច្បាស់ថា វេទនានោះ មិនទៀង ដឹងច្បាស់ថា លោកមិនប្រកាន់ហើយ ដឹងច្បាស់ថា លោកមិនត្រេកអរហើយ ។ បើភិក្ខុនោះទទួលសុខវេទនា លុះប្រាសចេញហើយ ក៏នៅតែទទួលសុខវេទនានោះ បើភិក្ខុនោះទទួលទុក្ខវេទនា លុះប្រាសចេញហើយ ក៏នៅតែទទួលទុក្ខវេទនានោះ បើភិក្ខុនោះទទួលអទុក្ខមសុខវេទនា លុះប្រាសចេញហើយ ក៏នៅតែទទួលអទុក្ខមសុខវេទនានោះ ។ កាលភិក្ខុនោះ ទទួលវេទនាមានកាយជាទីបំផុត ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានកាយជាទីបំផុត ។ កាលភិក្ខុនោះ ទទួលវេទនាមានជីវិតជាទីបំផុត ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានជីវិតជាទីបំផុត ។ ភិក្ខុនោះ លុះបែកធ្លាយរាងកាយខាងលើអំពីការអស់ជីវិតទៅ ក៏ដឹងច្បាស់ថា វេទនាទាំងពួង ក្នុងលោកនេះ អាត្មាអញមិនត្រេកអរទេ នឹងជាវេទនាដ៏ត្រជាក់ នឹងនៅសល់តែសរីរៈប៉ុណ្ណោះ ។

(១៩៣) សេយ្យថាបិ ភិក្ខវេ បុរិសោ កុម្ភកា-របាកា ឧណ្ហំ កុម្ភំ ឧទ្ធរិត្វា សមេ ភូមិភាគេ បតិដ្ឋ-បេយ្យ តត្រ យាយំ ឧស្មា សា តត្ថេវ វូបសមេយ្យ កបល្លានិ អវសិស្សេយ្យុំ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ កាយបរិយន្តិកំ វេទនំ វេទយមានោ កាយបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ ។ ជីវិតបរិយន្តិកំ វេទនំ វេទយមានោ ជីវិតបរិយន្តិកំ វេទនំ វេទយាមីតិ បជា-នាតិ ។ កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតីភវិស្សន្តិ សរីរានិ អវសិស្សន្តីតិ បជានាតិ ។

(១៩៤) តំ កិំ មញ្ញថ ភិក្ខវេ អបិ នុ ខោ ខីណាសវោ ភិក្ខុ បុញ្ញាភិសង្ខារំ វា អភិសង្ខរេយ្យ អបុញ្ញាភិសង្ខារំ វា អភិសង្ខរេយ្យ អនេជាភិសង្ខារំ វា អភិសង្ខរេយ្យាតិ ។ នោ ហេតំ ភន្តេ ។ សព្វសោ វា បន សង្ខារេសុ អសតិ សង្ខារនិរោធា អបិ នុ ខោ វិញ្ញាណំ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។

(១៨៣) ម្នាលភិក្ខុទាំងឡាយ ដូចជាបុរស រើយកឆ្នាំងក្តៅអំពីកន្ទ្រងដុតឆ្នាំង ហើយដាក់លើផែនដីដ៏ស្មើ ចំហាយណា ដែលនៅក្នុងទីនោះ ចំហាយនោះ ក៏ស្ងប់ស្ងាប់នៅក្នុងទីនោះឯង នៅសល់តែអំបែងយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ដូចជាភិក្ខុទទួលវេទនាមានកាយជាទីបំផុត ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានកាយជាទីបំផុត យ៉ាងនោះឯង ។ កាលភិក្ខុទទួលវេទនាមានជីវិតជាទីបំផុត ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានជីវិតជាទីបំផុត ។ លុះភិក្ខុនោះបែកធ្លាយកាយខាងលើអំពីកិរិយាអស់ជីវិតទៅ ក៏ដឹងច្បាស់ថា វេទនាទាំងពួងក្នុងលោកនេះ អាត្មាអញមិនត្រេកអរទេ នឹងជាវេទនាដ៏ត្រជាក់ នឹងនៅសល់តែសរីរៈប៉ុណ្ណោះ ។

(១៨៤) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច ភិក្ខុជាខីណាស្រពគួរតាក់តែងបុញ្ញាភិសង្ខារ តាក់តែងអបុញ្ញាភិសង្ខារ តាក់តែងអនេជាភិសង្ខារដែរឬទេ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ហេតុនុ៎ះមិនមានទេ ។ កាលបើសង្ខារទាំងឡាយមិនមាន ព្រោះការរលត់នៃសង្ខារដោយប្រការទាំងពួង តើវិញ្ញាណនៅប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនុ៎ះមិនប្រាកដទេ ។

សព្វសោ ភិក្ខវេ វិញ្ញាណេ អសតិ វិញ្ញាណនិរោធា អបិ នុ ខោ នាមរូបំ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ សព្វសោ ភិក្ខវេ នាមរូបេ អសតិ នាមរូបនិរោធា អបិ នុ ខោ សឡាយតនំ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ សព្វសោ ភិក្ខវេ សឡាយតនេ អសតិ សឡាយតននិរោធា អបិ នុ ខោ ផស្សោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ សព្វសោ ភិក្ខវេ ផស្សេ អសតិ ផស្សនិរោធា អបិ នុ ខោ វេទនា បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ សព្វសោ ភិក្ខវេ វេទនាយ អសតិ វេទនានិរោធា អបិ នុ ខោ តណ្ហា បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ សព្វសោ ភិក្ខវេ តណ្ហាយ អសតិ តណ្ហានិរោធា អបិ នុ ខោ ឧបាទានំ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ សព្វសោ ភិក្ខវេ ឧបាទានេ អសតិ ឧបាទាននិរោធា អបិ នុ ខោ ភវោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។

កាលបើវិញ្ញាណមិនមាន ព្រោះការរលត់នៃវិញ្ញាណ ដោយប្រការទាំងពួង តើនាមរូបនៅប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនប្រាកដទេ ។ កាលបើនាមរូបមិនមាន ព្រោះការរលត់នៃនាមរូប ដោយប្រការទាំងពួង តើសឡាយតនៈនៅប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនប្រាកដទេ ។ កាលបើសឡាយតនៈមិនមាន ព្រោះការរលត់នៃសឡាយតនៈ ដោយប្រការទាំងពួង តើផស្សៈនៅប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនប្រាកដទេ ។ កាលបើផស្សៈមិនមាន ព្រោះការរលត់នៃផស្សៈ ដោយប្រការទាំងពួង តើវេទនានៅប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនប្រាកដទេ ។ កាលបើវេទនាមិនមាន ព្រោះការរលត់នៃវេទនា ដោយប្រការទាំងពួង តើតណ្ហានៅប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនប្រាកដទេ ។ កាលបើតណ្ហាមិនមាន ព្រោះការរលត់នៃតណ្ហា ដោយប្រការទាំងពួង តើឧបាទាននៅប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនប្រាកដទេ ។ កាលបើឧបាទានមិនមាន ព្រោះការរលត់នៃឧបាទាន ដោយប្រការទាំងពួង តើភពនៅប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនប្រាកដទេ ។

សព្វសោ វា បន ភវេ អសតិ ភវនិរោធា អបិ នុ ខោ ជាតិ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ សព្វសោ វា បន ជាតិយា អសតិ ជាតិនិរោធា អបិ នុ ខោ ជរាមរណំ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។

(១៩៥) សាធុ សាធុ ភិក្ខវេ ឯវមេតំ ភិក្ខវេ មញ្ញថ សទ្ទហថ ឯវមេតំ ភិក្ខវេ អធិមុច្ចថ និក្កង្ខា ឯត្ថ ហោថ និព្វិចិកិច្ឆា ឯសេវន្តោ ទុក្ខស្សាតិ ។ បឋមំ ។

(១៩៦) សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... ឧបាទានីយេសុ ភិក្ខវេ ធម្មេសុ អស្សាទានុបស្សិនោ

កាលបើភពមិនមាន ព្រោះការរលត់នៃភព ដោយប្រការទាំងពួង តើជាតិនៅប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុះមិនប្រាកដទេ ។ កាលបើជាតិមិនមាន ព្រោះការរលត់នៃជាតិ ដោយប្រការទាំងពួង តើជរាមរណៈនៅប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុះមិនប្រាកដទេ ។

(១៨៥) ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ត្រូវហើយ អ្នកទាំងឡាយ ចូរសំគាល់ ចូរជឿសេចក្តីនុះ យ៉ាងនេះចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំងឿងឆ្ងល់ កុំសង្ស័យក្នុងដំណើរនុះឡើយ នេះឯង ជាទីបំផុតនៃសេចក្តីទុក្ខ ។ ចប់សូត្រ ទី ១ ។

(១៨៦) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញ នូវសេចក្តីត្រេកអរ ក្នុងឧបាទានិយធម៌ទាំងឡាយ (ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣

វិហរតោ តណ្ហា បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ ឧ-
បាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា
ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា ស-
ម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ
ហោតិ ។

(១៩៧) សេយ្យថាបិ ភិក្ខវេ ទសន្នំ វា កដ្ឋ-
វាហានំ វីសាយ វា កដ្ឋវាហានំ តឹសាយ វា កដ្ឋវា-
ហានំ ចត្តារីសាយ វា កដ្ឋវាហានំ មហា អគ្គិក្ខន្ធោ
ជលេយ្យ តត្រ បុរិសោ កាលេន កាលំ សុក្ខានិ
ចេវ តិណានិ បក្ខិបេយ្យ សុក្ខានិ ច គោមយានិ
បក្ខិបេយ្យ សុក្ខានិ ច កដ្ឋានិ បក្ខិបេយ្យ ឯវញ្ហិ សោ
ភិក្ខវេ មហា អគ្គិក្ខន្ធោ តទាហារោ តទុបាទានោ
ចិរំ ទីឃមទ្ធានំ ជលេយ្យ ឯវមេវ ខោ ភិក្ខវេ ឧបាទា-
និយេសុ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ តណ្ហា
បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ ។ បេ ។ ឯវមេតស្ស
កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

ជាបច្ច័យនៃឧបាទានទាំង ៤ ) តណ្ហារមែងចម្រើនឡើង ឧបាទានកើតឡើង ព្រោះតណ្ហាជាបច្ច័យ ភពកើតឡើង ព្រោះឧបាទានជាបច្ច័យ ជាតិកើតឡើង ព្រោះភពជាបច្ច័យ ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងព្រម ព្រោះជាតិជាបច្ច័យ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[ ១៨៧ ] ម្នាលភិក្ខុទាំងឡាយ គំនរភ្លើងធំ របស់អ្នករកឧស ១០ នាក់ក្តី អ្នករកឧស ២០ នាក់ក្តី អ្នករកឧស ៣០ នាក់ក្តី អ្នករកឧស ៤០ នាក់ក្តី ឆេះឡើង ( បើ ) មានបុរសយកស្មៅស្ងួត គោម័យស្ងួត និងឈើស្ងួតទៅដាក់លើគំនរភ្លើងនោះសព្វកាល ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ គំនរភ្លើងធំ ដែលមានស្មៅស្ងួតជាដើមនោះជាអាហារ មានស្មៅស្ងួតជាដើមនោះជាគ្រឿងឆេះ មុខជាឆេះអស់កាលយូរអង្វែង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញ នូវសេចក្តីត្រេកអរ ក្នុងឧបាទានិយធម៌ទាំងឡាយហើយ តណ្ហារមែងចម្រើនឡើង ឧបាទានកើតឡើង ព្រោះតណ្ហាជាបច្ច័យ ។ បេ ។ ក៏យ៉ាងនោះឯង ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(១៩៨) ឧបាទានិយេសុ ភិក្ខវេ ធម្មេសុ អស្សា-
ទានុបស្សិនោ វិហរតោ តណ្ហា បវឌ្ឍតិ តណ្ហាប-
ច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា
ជាតិ ជាតិបច្ចយា ជរាមរណំ សោ-
កបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស
កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(១៩៩) សេយ្យថាបិ ភិក្ខវេ ទសន្នំ វា កដ្ឋ-
វាហានំ វីសាយ វា កដ្ឋវាហានំ តិំសាយ វា កដ្ឋវា-
ហានំ ចត្តារីសាយ វា កដ្ឋវាហានំ មហា អគ្គិក្ខន្ធោ
ជលេយ្យ តត្រ បុរិសោ កាលេន កាលំ សុក្ខានិ
ចេវ តិណានិ បក្ខិបេយ្យ សុក្ខានិ ច គោម-
យានិ បក្ខិបេយ្យ សុក្ខានិ ច កដ្ឋានិ បក្ខិបេយ្យ

(១៩៨) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោសក្នុងឧបាទានិយធម៌ទាំងឡាយហើយ តណ្ហាក៏រលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ការរលត់នៃជាតិ ព្រោះការរលត់នៃភព ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏រលត់ទៅ ព្រោះការរលត់នៃជាតិ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(១៩៩) ម្នាលភិក្ខុទាំងឡាយ គំនរភ្លើងធំ របស់អ្នកកេទស ១០ នាក់ក្តី អ្នកកេទស ២០ នាក់ក្តី អ្នកកេទស ៣០ នាក់ក្តី អ្នកកេទស ៤០ នាក់ក្តី គប្បីឆេះ (តែបើ) បុរសមិនយកស្មៅស្ងួត មិនយកគោម័យស្ងួត មិនយកកំណាត់ឈើស្ងួត ទៅដាក់ក្នុងគំនរភ្លើងនោះគ្រប់កាលវេ

ឯវញ្ហិ សោ ភិក្ខវេ មហា អគ្គិក្ខន្ធោ បុរិមស្ស ច ឧបាទានស្ស បរិយាទានា អញ្ញស្ស ច អនុបាហារា អនាហារោ និព្វាយេយ្យ ឯវមេវ ខោ ភិក្ខវេ ឧបាទានិយេសុ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា ឧបាទាននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ទុតិយំ ។

[២០០] សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... សញ្ញោជនីយេសុ ភិក្ខវេ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ តណ្ហា បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

( គំនរភ្លើងនោះក៏មិនអាចឆេះបាន ) ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នេះ គំនរភ្លើងធំនោះមិនមានអាហារ គប្បីរលត់ទៅ ព្រោះការអស់គ្រឿងឆេះមុនផង ព្រោះការមិនបានបន្ថែមវត្ថុដទៃផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោស ក្នុងឧបាទានិយធម៌ទាំង-ឡាយហើយ តណ្ហារមែងរលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ។ បេ ។ ក៏យ៉ាងនោះឯង ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ២ ។

[ ២០០ ] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរ ក្នុងសញ្ញោជនិយធម៌ទាំងឡាយ ( ធម៌ជាគ្រឿងប្រកបព្រម ) ហើយ តណ្ហារមែងចម្រើន ឧបាទានកើតឡើង ព្រោះតណ្ហាជាបច្ច័យ ភពកើតឡើង ព្រោះឧបាទានជាបច្ច័យ ជាតិកើតឡើង ព្រោះភពជាបច្ច័យ ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងព្រម ព្រោះជាតិជាបច្ច័យ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(២០១) សេយ្យថាបិ ភិក្ខវេ តេលញ្ច បដិច្ច វដ្តិញ្ច បដិច្ច តេលប្បទីបោ ឈាយេយ្យ តត្រ បុរិសោ កាលេន កាលំ តេលំ អាសិញ្ចេយ្យ វដ្តឹ ឧបសំហរេយ្យ ឯវញ្ហិ សោ ភិក្ខវេ តេលប្បទីបោ តទាហារោ តទុបាទានោ ចិរំ ទីឃមទ្ធានំ ជលេយ្យ ឯវមេវ ខោ ភិក្ខវេ សញ្ញោជនីយេសុ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ តណ្ហា បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(២០២) សញ្ញោជនីយេសុ ភិក្ខវេ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ

(២០១) ម្នាលភិក្ខុទាំងឡាយ ប្រទីបប្រេង ឆេះបាន ព្រោះអាស្រ័យប្រេងផង ព្រោះអាស្រ័យប្រឆេះផង (បើ) បុរស ចាក់ប្រេងពេញប្រឆេះ ដាក់ក្នុងប្រទីបប្រេងនោះគ្រប់កាល ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នេះ ប្រទីបប្រេង ដែលមានប្រេងនិងប្រឆេះនោះជាអាហារ មានប្រេងនិងប្រឆេះនោះជាគ្រឿងឆេះ គប្បីឆេះឡើង អស់កាលយូរអង្វែង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរ ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ តណ្ហារមែងចម្រើនឡើង ឧបាទានចម្រើនឡើង ព្រោះតណ្ហាជាបច្ច័យ ភពចម្រើនឡើង ព្រោះឧបាទានជាបច្ច័យ ជាតិកើតឡើង ព្រោះភពជាបច្ច័យ ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងព្រម ព្រោះជាតិជាបច្ច័យ ក៏យ៉ាងនោះឯង ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(២០២) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោសក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ តណ្ហារមែងរលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ការរលត់នៃភព ព្រោះការរលត់នៃ

ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

[២០៣] សេយ្យថាបិ ភិក្ខវេ តេលញ្ច បដិច្ច វដ្ដិញ្ច បដិច្ច តេលប្បទីបោ ឈាយេយ្យ តត្រ បុរិសោ ន កាលេន កាលំ តេលំ អាសិញ្ចេយ្យ ន វដ្ដឹ ឧបសំហរេយ្យ ឯវញ្ហិ សោ ភិក្ខវេ តេលប្បទីបោ បុរិមស្ស ច ឧបាទានស្ស បរិយាទានា អញ្ញស្ស ច អនុបាហារា អនាហារោ និព្វាយេយ្យ ឯវមេវ ខោ ភិក្ខវេ សញ្ញោជនីយេសុ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា ឧបាទាននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ តតិយំ ។

ឧបាទាន ការរលត់នៃជាតិ ព្រោះការរលត់នៃភព ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏រលត់ទៅ ព្រោះការរលត់នៃជាតិ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[ ២០៣ ] ម្នាលភិក្ខុទាំងឡាយ ប្រទីបប្រេង ឆេះឡើងបាន ព្រោះអាស្រ័យប្រេងផង ព្រោះអាស្រ័យប្រឆេះផង (តែបើ) បុរស មិនចាក់ប្រេង មិនវេញប្រឆេះ ដាក់ក្នុងប្រទីបប្រេងនោះគ្រប់កាលទេ (ប្រទីបប្រេងនោះក៏មិនអាចឆេះឡើងបាន) ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នេះ ប្រទីបដែលមិនមានអាហារនោះ គប្បីរលត់ទៅ ព្រោះការអស់គ្រឿងឆេះមុនផង ព្រោះការមិនបន្ថែមគ្រឿងទៀតផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោស ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ តណ្ហាក៏រលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ។ បេ ។ ក៏យ៉ាងនោះឯង ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ៣ ។

[២០៤] សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... សេយ្យថាបិ ភិក្ខវេ តេលញ្ច បដិច្ច វដ្ដិញ្ច បដិច្ច តេលប្បទីបោ ឈាយេយ្យ តត្រ បុរិសោ កាលេន កាលំ តេលំ អាសិញ្ចេយ្យ វដ្ដឹ ឧបសំហរេយ្យ ឯវញ្ហិ សោ ភិក្ខវេ តេលប្បទីបោ តទាហារោ តទុបាទានោ ចិរំ ទីឃមទ្ធានំ ជលេយ្យ ឯវមេវ ខោ ភិក្ខវេ សញ្ញោជនីយេសុ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ តណ្ហា បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[២០៥] សេយ្យថាបិ ភិក្ខវេ តេលញ្ច បដិច្ច វដ្ដិញ្ច បដិច្ច តេលប្បទីបោ ឈាយេយ្យ តត្រ បុរិសោ ន កាលេន កាលំ តេលំ អាសិញ្ចេយ្យ ន វដ្ដឹ ឧបសំហរេយ្យ ឯវញ្ហិ សោ ភិក្ខវេ តេលប្បទីបោ បុរិមស្ស ច ឧបាទានស្ស បរិយាទានា អញ្ញស្ស ច អនុបាហារា អនាហារោ និព្វាយេយ្យ

( ២០៤ ) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះ ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ប្រទីបប្រេង ឆេះឡើងបាន ព្រោះអាស្រ័យប្រេងផង ព្រោះអាស្រ័យប្រឆេះផង ( បើ ) បុរស ចាក់ប្រេង វេញប្រឆេះ ដាក់ក្នុងប្រទីបប្រេងនោះគ្រប់កាលហើយ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នេះ ប្រទីបប្រេង ដែលមានប្រេងនិងប្រឆេះនោះជាអាហារផង មានប្រេងនិងប្រឆេះនោះជាគ្រឿងឆេះផង មុខជាឆេះអស់កាលយូរអង្វែង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញ នូវសេចក្តីត្រេកអរ ក្នុងសញ្ញោជនីយធម៌ទាំងឡាយហើយ តណ្ហារមែងចម្រើនឡើង ឧបាទានចម្រើនឡើង ព្រោះតណ្ហាជាបច្ច័យ ។ បេ ។ ក៏យ៉ាងនោះឯង ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

( ២០៥ ) ម្នាលភិក្ខុទាំងឡាយ ប្រទីបប្រេង ឆេះបាន ព្រោះអាស្រ័យប្រេងផង ព្រោះអាស្រ័យប្រឆេះផង ( តែបើ ) បុរស មិនបានចាក់ប្រេង មិនវេញប្រឆេះ ដាក់ក្នុងប្រទីបប្រេងនោះគ្រប់កាលទេ ( ប្រទីបប្រេងនោះ មិនអាចឆេះបាន ) ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នេះ ប្រទីបប្រេង ដែលមិនមានអាហារនោះ ក៏រលត់ទៅ ព្រោះការអស់គ្រឿងឆេះពីមុនផង ព្រោះការមិនបន្ថែមរបស់ឯទៀតផង យ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ សញ្ញោជនីយេសុ ធម្មេសុ អាទីន-វានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា ឧបាទាននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ចតុត្ថំ ។

(២០៦) សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... ឧបាទានីយេសុ ភិក្ខវេ ធម្មេសុ អស្សាទានុបស្សិ-នោ វិហរតោ តណ្ហា បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(២០៧) សេយ្យថាបិ ភិក្ខវេ មហារុក្ខោ តស្ស យានិ ចេវ មូលានិ អធោគមានិ យានិ ច តិរិយង្គមានិ សព្វានិ តានិ ឧទ្ធំ ឱជំ អភិហរន្តិ ឯវញ្ហិ សោ ភិក្ខវេ មហារុក្ខោ តទាហារោ តទុបាទានោ ចិរំ ទីឃ-មទ្ធានំ តិដ្ឋេយ្យ ឯវមេវ ខោ ភិក្ខវេ ឧបាទានីយេសុ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ តណ្ហា បវឌ្ឍតិ

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុពិចារណាឃើញទោស ក្នុងសញ្ញោជនីយធម៌ទាំងឡាយហើយ តណ្ហាក៏រលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ។ បេ ។ ក៏យ៉ាងនោះឯង ការរលត់ទៅនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ៤ ។

(២០៦) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ក្នុងទីនោះ ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរ ក្នុងឧបាទានិយធម៌ទាំងឡាយ តណ្ហារមែងចម្រើនឡើង ឧបាទានចម្រើនឡើង ព្រោះតណ្ហាជាបច្ច័យ ភពចម្រើនឡើង ព្រោះឧបាទានជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(២០៧) ម្នាលភិក្ខុទាំងឡាយ ដូចជាឈើធំ ឫសទាំងអស់របស់ឈើធំនោះ ដែលដុះចាក់ទៅក្រោម ដុះចាក់ទៅទទឹង រមែងនាំឱជារសទៅចុងខាងលើ កាលបើដូច្នេះ ម្នាលភិក្ខុទាំងឡាយ ឈើធំនោះ ដែលមានឫសនោះជាអាហារផង មានឫសនោះជាគ្រឿងបំប៉នផង មុខជាឋិតនៅ អស់កាលយូរអង្វែង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញ នូវសេចក្តីត្រេកអរ ក្នុងឧបាទានិយធម៌ទាំងឡាយហើយ តណ្ហារមែងចម្រើនឡើង

តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ
។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទ-
យោ ហោតិ ។

(២០៨) ឧបាទានីយេសុ ភិក្ខវេ ធម្មេសុ អាទីន-
វានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា
ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ។ បេ ។
ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

(២០៩) សេយ្យថាបិ ភិក្ខវេ មហា រុក្ខោ អថ
បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ សោ តំ
រុក្ខំ មូលេ ឆិន្ទេយ្យ មូលេ ឆេត្វា បលិខណេយ្យ បលិ-
ខណិត្វា មូលានិ ឧទ្ធរេយ្យ អន្តមសោ ឧសីរនាឡិ-
មត្តានិបិ ។ សោ តំ រុក្ខំ ខណ្ឌាខណ្ឌិកំ ឆិន្ទេយ្យ
ខណ្ឌាខណ្ឌិកំ ឆិន្ទិត្វា ផាលេយ្យ ផាលេត្វា សកលិកំ
សកលិកំ ករេយ្យ សកលិកំ សកលិកំ ករិត្វា
វាតាតបេ វិសោសេយ្យ វាតាតបេ វិសោសេត្វា អគ្គិនា
ឌហេយ្យ អគ្គិនា ឌហិត្វា មសឹ ករេយ្យ មសឹ ករិត្វា

ឧបាទានបម្រើនឡើង ព្រោះតណ្ហាជាបច្ច័យ ភពបម្រើនឡើង ព្រោះឧបាទានជាបច្ច័យ ។ បេ ។ ក៏យ៉ាងនោះឯង ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(២០៨) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោសក្នុងឧបាទានិយធម៌ទាំងឡាយហើយ តណ្ហារមែងរលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(២០៩) ម្នាលភិក្ខុទាំងឡាយ ដូចជាឈើធំមួយដើម កាលនោះ បុរសម្នាក់កាន់ចបនិងកញ្ច្រែមក កាត់ឈើធំនោះត្រង់ឫស លុះកាត់រួចហើយ ទើបគាស់រំលើង លុះគាស់រំលើងរួចហើយ ក៏រើឫស ដោយហោចទៅសូម្បីទៅសល់ប៉ុនទងស្បូវក្តាំងក៏មិនមាន ។ បុរសនោះ កាត់ឈើនោះ ឲ្យមានកំណាត់តូចកំណាត់ធំ លុះកាត់ឲ្យជាកំណាត់តូចកំណាត់ធំហើយ ទើបពុះ លុះពុះរួចហើយ ក៏ធ្វើឲ្យជាបន្ទះតូច ៗ លុះធ្វើឲ្យជាបន្ទះតូច ៗ ហើយ ក៏យកទៅហាលខ្យល់និងកំដៅថ្ងៃ លុះហាលខ្យល់និងកំដៅថ្ងៃហើយ ទើបយកភ្លើងដុត លុះយកភ្លើងដុតរួចហើយ ទើបធ្វើឲ្យជាកម្ទេចធ្យូង ធ្វើឲ្យជាកម្ទេចធ្យូងហើយ

មហាវាតេ វា ឱផុណេយ្យ នទិយា វា សីឃសោតាយ បវាហេយ្យ ឯវញ្ហិ សោ ភិក្ខវេ មហារុក្ខោ ឧច្ឆិន្ន-មូលោ អស្ស តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ ឯវមេវ ខោ ភិក្ខវេ ឧបាទានីយេសុ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខ-ក្ខន្ធស្ស និរោធោ ហោតីតិ ។ បញ្ចមំ ។

(២១០) សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... សេយ្យថាបិ ភិក្ខវេ មហារុក្ខោ តស្ស យានិ ចេវ មូលានិ អធោគមានិ យានិ ច តិរិយង្គមានិ សព្វានិ តានិ ឧទ្ធំ ឱជំ អភិហរន្តិ ឯវញ្ហិ សោ ភិក្ខវេ មហារុក្ខោ តទាហារោ តទុបាទានោ ចិរំ ទីឃមទ្ធានំ តិដ្ឋេយ្យ ឯវមេវ ខោ ភិក្ខវេ ឧបាទានីយេសុ ធម្មេសុ អស្សាទានុបស្សិនោ វិហ-រតោ តណ្ហា បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ

ក៏បាចទៅតាមខ្យល់ធំ ឬក៏បណ្តែតទៅក្នុងស្ទឹងដែលមានខ្សែទឹកហូរខ្លាំង ម្នាលភិក្ខុទាំងឡាយ ក៏កាលបើដូច្នេះ ឈើធំនោះ ឈ្មោះថាគេបាន ផ្តាច់ផ្តិលឫសគល់ចោលហើយ បានធ្វើឲ្យលែងមានទីកន្លែងដុះទៀត ជាឈើដល់នូវភាពមិនមានតទៅ មិនមានការកើតឡើងតទៅទៀតជាធម្មតា យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោសក្នុងឧបាទានិយធម៌ទាំងឡាយហើយ តណ្ហារមែងរលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ។ បេ ។ ក៏យ៉ាងនោះឯង ការរលត់ទៅនៃកងទុក្ខទាំងអស់នុះ តែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ៥ ។

( ២១០ ) ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើធំ ឫសរបស់ឈើធំនោះទាំងអស់ ដែលដុះចាក់ទៅខាងក្រោម ដុះចាក់ទៅទទឹង រមែងនាំឱជារសទៅចុងខាងលើ ម្នាលភិក្ខុទាំងឡាយ ក៏កាលបើដូច្នេះ ឈើធំនោះដែលមានឫសនោះជាអាហារផង មានឫសនោះជាកម្លាំងមាំផង មុខជាឋិតនៅអស់កាលយូរអង្វែង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញសេចក្តីត្រេកអរ ក្នុងឧបាទានិយធម៌ទាំងឡាយហើយ តណ្ហារមែងចម្រើនឡើង ឧបាទានចម្រើនឡើង ព្រោះតណ្ហាជាបច្ច័យ

។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(២១១) សេយ្យថាបិ ភិក្ខវេ មហា រុក្ខោ អថ បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ សោ តំ រុក្ខំ មូលេ ឆិន្ទេយ្យ មូលេ ឆេត្វា បលិខណេយ្យ បលិខណិត្វា មូលានិ ឧទ្ធរេយ្យ ។ បេ ។ នទិយា វា សីឃសោតាយ បវាហេយ្យ ឯវញ្ហិ សោ ភិក្ខវេ មហា រុក្ខោ ឧច្ឆិន្នមូលោ អស្ស តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ ឯវមេវ ខោ ភិក្ខវេ ឧបាទានីយេសុ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា ឧបាទាននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ឆដ្ឋំ ។

។ បេ ។ ក៏យ៉ាងនោះដែរ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែង

មានយ៉ាងនេះ ។

(២១១) ម្នាលភិក្ខុទាំងឡាយ ដូចជាឈើធំមួយដើម កាលនោះ

បុរសម្នាក់ កាន់យកចបចនឹងកញ្ច្រែដើរមក កាត់ឈើធំនោះត្រង់ឫស លុះ

កាត់ឫសហើយ ក៏គាស់រំលើង លុះគាស់រំលើងហើយ ក៏រើឫស ។ បេ ។

ឬក៏បណ្តែតទៅក្នុងស្ទឹងដែលមានខ្សែទឹកហូរខ្លាំង ម្នាលភិក្ខុទាំងឡាយ

កាលបើដូច្នេះ ឈើធំនោះ ឈ្មោះថា គេបានផ្តាច់ផ្តិលឫសគល់ចោល

ហើយ បានធ្វើឲ្យលែងមានទីកន្លែងដុះទៀត ជាឈើដល់នូវភាពមិនមាន

តទៅ មិនមានការកើតឡើងតទៅទៀតជាធម្មតា យ៉ាងណាមិញ ម្នាល

ភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោស ក្នុងឧបាទានិយធម៌ទាំង-

ឡាយហើយ តណ្ហារមែងរលត់ទៅ ការរលត់នៃឧបាទាន ព្រោះការ

រលត់នៃតណ្ហា ។ បេ ។ ក៏យ៉ាងនោះឯង ការរលត់នៃកងទុក្ខទាំងអស់

នុ៎ះ តែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ៦ ។

[២១២] សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... សញ្ញោជនីយេសុ ភិក្ខវេ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ តណ្ហា បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[២១៣] សេយ្យថាបិ ភិក្ខវេ តរុណោ រុក្ខោ តស្ស បុរិសោ កាលេន កាលំ មូលានិ បលិសជ្ជេយ្យ កាលេន កាលំ បំសុំ ទទេយ្យ កាលេន កាលំ ឧទកំ ទទេយ្យ ឯវញ្ហិ សោ ភិក្ខវេ តរុណោ រុក្ខោ តទាហារោ តទុបាទានោ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជេយ្យ ឯវមេវ ខោ ភិក្ខវេ សញ្ញោជនីយេសុ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ តណ្ហា បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[ ២១៦ ] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... គ្រានោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរ ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ តណ្ហារមែងចំរើនឡើង ឧបាទានចំរើនឡើង ព្រោះតណ្ហាជាបច្ច័យ ។ បេ ។ ការកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[ ២១៧ ] ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើធំ បុរសផ្គុំឫសរបស់ឈើធំគ្រប់កាល ដាក់ដីគ្រប់កាល ស្រោចទឹកគ្រប់កាល ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នេះ ឈើធំនោះ ដែលមានរបស់ទាំងនោះជាអាហារ មានរបស់ទាំងនោះជាកម្លាំង គឺដល់នូវសេចក្តីចំរើន ដុះដាលធំទូលាយឡើង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ តណ្ហារមែងចំរើនឡើង ឧបាទានចំរើនឡើង ព្រោះតណ្ហាជាបច្ច័យ ។ បេ ។ គឺយ៉ាងនោះឯង ការកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ តែងមានដោយប្រការដូច្នេះឯង ។

(២១៦) សញ្ញោជនីយេសុ ភិក្ខវេ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា ឧបាទាននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

(២១៧) សេយ្យថាបិ ភិក្ខវេ តរុណោ រុក្ខោ អថ បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ ។ បេ ។ នទិយា វា សីឃសោតាយ បវាហេយ្យ ឯវញ្ហិ សោ ភិក្ខវេ តរុណោ រុក្ខោ ឧច្ឆិន្នមូលោ អស្ស តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ ឯវមេវ ខោ ភិក្ខវេ សញ្ញោជនីយេសុ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា ឧបាទាននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ សត្តមំ ។

អភិសមយសំយុត្ត ទុក្ខវគ្គ ឧបមាដោយឈើខ្ចី

( ២១៤ ) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោស ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ តណ្ហារមែងរលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

( ២១៥ ) ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើខ្ចី កាលនោះ បុរសកាន់យកចបនិងកញ្ជើដើរមក កាត់ឈើខ្ចីត្រង់ឫស ។ បេ ។ បណ្តែតទៅក្នុងស្ទឹងដែលមានទឹកហូរខ្លាំង ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នេះ ឈើខ្ចីនោះ ឈ្មោះថាគេបានផ្តាច់ផ្តិលឫសគល់ចោលហើយ បានធ្វើឲ្យលែងមានទីកន្ទុំដុះទៀតហើយ ជាឈើដល់នូវភាពមិនមានតទៅ មិនមានការកើតឡើងតទៅទៀតជាធម្មតា យ៉ាងណាមិញ ម្នាលភិក្ខុទាំង-ឡាយ កាលភិក្ខុពិចារណាឃើញទោស ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ តណ្ហារមែងរលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ។ បេ ។ ក៏យ៉ាងនោះឯង ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ៧ ។

(២០៦) សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... សញ្ញោជនីយេសុ ភិក្ខវេ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ នាមរូបស្ស អវក្កន្តិ ហោតិ នាមរូបប្បច្ចយា សឡាយតនំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(២០៧) សេយ្យថាបិ ភិក្ខវេ មហារុក្ខោ តស្ស យានិ ចេវ មូលានិ អធោគមានិ យានិ ច តិរិយង្គមានិ សព្វានិ តានិ ឧទ្ធំ ឱជំ អភិហរន្តិ ឯវញ្ហិ សោ ភិក្ខវេ មហារុក្ខោ តទាហារោ តទុបាទានោ ចិរំ ទីឃមទ្ធានំ តិដ្ឋេយ្យ ឯវមេវ ខោ ភិក្ខវេ សញ្ញោជនីយេសុ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ នាមរូបស្ស អវក្កន្តិ ហោតិ នាមរូបប្បច្ចយា សឡាយតនំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[ ២១៦ ] ត្រង់គង់នៅទៀបក្រុងសាវត្ថី ... គង់ទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញ នូវសេចក្តីត្រេកអរ ក្នុងសញ្ញោជនីយធម៌ទាំងឡាយហើយ ការចាប់កំណើតនៃនាមរូបក៏មាន សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[ ២១៧ ] ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើធំ ឫសទាំងអស់របស់ឈើធំនោះ ដែលដុះចាក់ទៅខាងក្រោម ដុះចាក់ទៅទទឹង តែងនាំឱជារសទៅចុងខាងលើ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នេះ ដើមឈើធំនោះ ដែលមានឫសនោះជាអាហារ មានឫសនោះជាកម្លាំង ក៏ឋិតនៅអស់កាលយូរអង្វែង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរ ក្នុងសញ្ញោជនីយធម៌ទាំងឡាយហើយ ការចាប់កំណើតនៃនាមរូបក៏មាន សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ។ បេ ។ ក៏យ៉ាងនោះឯង ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[២១៨] សញ្ញោជនីយេសុ ភិក្ខវេ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ នាមរូបស្ស អវក្កន្តិ ន ហោតិ នាមរូបនិរោធា សឡាយតននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

[២១៩] សេយ្យថាបិ ភិក្ខវេ មហា រុក្ខោ អថ បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ ។ បេ ។ អាយតិំ អនុប្បាទធម្មោ ឯវមេវ ខោ ភិក្ខវេ សញ្ញោជនីយេសុ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ នាមរូបស្ស អវក្កន្តិ ន ហោតិ នាមរូបនិរោធា សឡាយតននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ អដ្ឋមំ ។

[២២០] សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... សញ្ញោជនីយេសុ ភិក្ខវេ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ វិញ្ញាណស្ស អវក្កន្តិ ហោតិ វិញ្ញាណបច្ចយា នាមរូបំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

អភិសមយសំយុត្ត ទុក្ខវគ្គ ហេតុនាំឲ្យកើតកងទុក្ខ

[២១៨] ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោស ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ ការចាប់កំណើតឡើងនៃនាមរូបក៏មិនមាន សឡាយតនៈរលត់ ព្រោះការរលត់នៃនាមរូប ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[២១៩] ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើធំ កាលនោះបុរសកាន់យកចបនិងកញ្ជើដើរមក កាត់ឈើធំនោះត្រង់ឫស ។ បេ ។ ជាឈើដល់នូវភាពមិនមានតទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោស ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ ការចាប់កំណើតនៃនាមរូបក៏មិនមាន ការរលត់នៃសឡាយតនៈ ព្រោះការរលត់នៃនាមរូប ។ បេ ។ ក៏យ៉ាងនោះឯង ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ៨ ។

[២២០] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរ ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ ការចាប់កំណើតឡើងនៃវិញ្ញាណរមែងមាន នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[២២១] សេយ្យថាបិ ភិក្ខវេ មហារុក្ខោ តស្ស យានិ ចេវ មូលានិ ។ បេ ។ ឯវមេវ ខោ ភិក្ខវេ សញ្ញោជនិយេសុ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ វិញ្ញាណស្ស អវក្កន្តិ ហោតិ វិញ្ញាណបច្ចយា នាមរូបំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[២២២] សញ្ញោជនិយេសុ ភិក្ខវេ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ វិញ្ញាណស្ស អវក្កន្តិ ន ហោតិ វិញ្ញាណនិរោធា នាមរូបនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

[២២៣] សេយ្យថាបិ ភិក្ខវេ មហារុក្ខោ អថ បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ ។ បេ ។ អាយតឹ អនុប្បាទធម្មោ ឯវមេវ ខោ ភិក្ខវេ សញ្ញោជនិយេសុ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ វិញ្ញាណស្ស អវក្កន្តិ ន ហោតិ វិញ្ញាណនិរោធា នាមរូបនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ឆដ្ឋំ ។

(២២១) ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើធំ ឫសទាំងអស់របស់ឈើធំនោះ ។ បេ ។ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរ ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ ការចាប់កំណើតនៃវិញ្ញាណរមែងមាន នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បេ ។ ក៏យ៉ាងនោះឯង ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(២២២) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោស ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ ការចាប់កំណើតនៃវិញ្ញាណក៏មិនមាន ការរលត់នៃនាមរូប ព្រោះការរលត់នៃវិញ្ញាណ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(២២៣) ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើធំ គ្រានោះបុរសកាន់យកចបនិងកញ្ច្រែងមក កាត់ឈើធំនោះត្រង់ឫស ។ បេ ។ ជាឈើដល់នូវភាពមិនមានតទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញទោស ក្នុងសញ្ញោជនិយធម៌ទាំងឡាយហើយ ការចាប់កំណើតនៃវិញ្ញាណរមែងមិនមាន ការរលត់នៃនាមរូប ព្រោះការរលត់នៃវិញ្ញាណ ។ បេ ។ ក៏យ៉ាងនោះឯង ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ចប់សូត្រ ទី ៩ ។

(២២៦) ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសទម្មំ(១) នាម កុរូនំ និគមោ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវគម្ភីរោ ចាយំ ភន្តេ បដិច្ចសមុប្បាទោ គម្ភីរាវភាសោ ច អថ ច បន មេ ឧត្តានកុត្តានកោ វិយ ខាយតីតិ ។

(២២៧) មា ហេវំ អានន្ទ មា ហេវំ អានន្ទ គម្ភីរោ ចាយំ អានន្ទ បដិច្ចសមុប្បាទោ គម្ភីរាវភាសោ ច ឯតស្ស អានន្ទ ធម្មស្ស អញ្ញាណា អននុពោធា អប្បដិវេធា ឯវមយំ បជា តន្តាកុលជាតា(២) គុឡគុណ្ឋិកជាតា មុញ្ជបព្វជភូតា អបាយំ ទុគ្គតឹ វិនិបាតំ សំសារំ នាតិវត្តតិ ។

---

១ កម្មាសធម្មន្តិបិ បាឋោ ។ ២ ឱ. ម. កុលកជាតា ។

អភិសមយសំយុត្ត និទានវគ្គ ជម្រៅរបស់បដិច្ចសមុប្បាទ

[២២៨] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគម ឈ្មោះកម្មាសទម្មៈ របស់អ្នកដែនកុរុ ក្នុងដែនកុរុ ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន បដិច្ចសមុប្បាទធម៌នេះ មានជម្រៅពេកផង មានឱភាសដ៏ជ្រៅផង ក៏ប៉ុន្តែហាក់ដូចជារាក់ ៗ ប្រាកដដល់ខ្ញុំព្រះអង្គ ។

[២២៩] ម្នាលអានន្ទ មិនមែនយ៉ាងនេះទេ ម្នាលអានន្ទ មិនមែនយ៉ាងនេះទេ ម្នាលអានន្ទ បដិច្ចសមុប្បាទធម៌នេះ មានជម្រៅផង មានឱភាសដ៏ជ្រៅផង ម្នាលអានន្ទ ពពួកសត្វនេះ ជាប់ចំពាក់កែវពាក់ស្រែះស្មុកស្មាញ ដូចជាស្មៅយាប្លងនិងស្មៅជំណេកទន្សាយ រមែងមិនកន្លងអបាយ ទុគ្គតិ វិនិបាត និងសង្សារ ព្រោះតែការមិនស្គាល់ ការមិនត្រាស់ដឹង ការមិនចាក់ធ្លុះ នូវបដិច្ចសមុប្បាទធម៌នុះ ។

[២២៦] ឧបាទានីយេសុ អានន្ទ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ តណ្ហា បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[២២៧] សេយ្យថាបិ អានន្ទ មហារុក្ខោ តស្ស យានិ ចេវ មូលានិ អធោគមានិ យានិ ច តិរិយង្គមានិ សព្វានិ តានិ ឧទ្ធំ ឱជំ អភិហរន្តិ ឯវញ្ហិ សោ អានន្ទ មហារុក្ខោ តទាហារោ តទុបាទានោ ចិរំ ទីឃមទ្ធានំ តិដ្ឋេយ្យ ឯវមេវ ខោ អានន្ទ ឧបាទានីយេសុ ធម្មេសុ អស្សាទានុបស្សិនោ វិហរតោ តណ្ហា បវឌ្ឍតិ តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(២២៦) ម្នាលអានន្ទ កាលភិក្ខុពិចារណាឃើញ នូវសេចក្តីត្រេកអរ ក្នុងឧបាទានិយធម៌ទាំងឡាយហើយ តណ្ហារមែងចម្រើនឡើង ឧបាទានចម្រើនឡើង ព្រោះតណ្ហាជាបច្ច័យ ភពចម្រើនឡើង ព្រោះឧបាទានជាបច្ច័យ ជាតិចម្រើនឡើង ព្រោះភពជាបច្ច័យ ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងព្រម ព្រោះជាតិជាបច្ច័យ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(២២៧) ម្នាលអានន្ទ ដូចជាដើមឈើធំ ឫសទាំងអស់របស់ឈើធំនោះ ដែលដុះចាក់ទៅក្រោម ដុះចាក់ទៅខាងទទឹង រមែងនាំឧ-ជារសទៅចុងខាងលើ ម្នាលអានន្ទ កាលបើដូច្នោះ ឈើធំនោះ ឈ្មោះថា មានឫសនោះជាអាហារ មានឫសនោះជាកម្លាំង មុខជាឋិតថេរនៅអស់កាលយូរ យ៉ាងណាមិញ ម្នាលអានន្ទ កាលភិក្ខុ ពិចារណាឃើញនូវសេចក្តីត្រេកអរ ក្នុងឧបាទានិយធម៌ទាំងឡាយហើយ តណ្ហារមែងចម្រើនឡើង ឧបាទានចម្រើនឡើង ព្រោះតណ្ហាជាបច្ច័យ ភពចម្រើនឡើង ព្រោះឧបាទានជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(២២៨) ឧបាទានិយេសុ អានន្ទ ធម្មេសុ អាទីន-វានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

(២២៩) សេយ្យថាបិ អានន្ទ មហារុក្ខោ អថ បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ សោ តំ រុក្ខំ មូលេ ឆិន្ទេយ្យ មូលេ ឆេត្វា បលិខណេយ្យ បលិខណិត្វា មូលានិ ឧទ្ធរេយ្យ អន្តមសោ ឧសីរ-នាឡិមត្តានិបិ ។ សោ តំ រុក្ខំ ខណ្ឌាខណ្ឌិកំ ឆិន្ទេយ្យ ខណ្ឌាខណ្ឌិកំ ឆេត្វា ផាលេយ្យ ផាលេត្វា សកលិកំ សកលិកំ ករេយ្យ សកលិកំ ស-កលិកំ ករិត្វា វាតាតបេ វិសោសេយ្យ វាតាតបេ វិសោសេត្វា អគ្គិនា ឌហេយ្យ អគ្គិនា ឌហិត្វា មសឹ ករេយ្យ មសឹ ករិត្វា មហាវាតេ វា ឱផុណេយ្យ នទិយា វា សីឃសោតាយ បវាហេយ្យ

[២២៨] ម្នាលអានន្ទ កាលភិក្ខុពិចារណាឃើញទោស ក្នុងឧបាទានីយធម៌ទាំងឡាយ តណ្ហារមែងរលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ។បេ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

[២២៩] ម្នាលអានន្ទ ដូចជាដើមឈើធំ កាលនោះ បុរសកាន់ចប និងកញ្ជើរមក កាត់ឈើនោះត្រង់ឫស លុះកាត់ឫសរួចហើយ ក៏គាស់រំលើង លុះគាស់រំលើងហើយ ក៏រើឫសចេញ ដោយហោចទៅសូម្បីនៅសល់តែប៉ុនទងស្បូវក្រាំងក៏មិនមាន ។ បុរសនោះ កាត់ឈើនោះ ឲ្យជាកំណាត់តូចកំណាត់ធំ លុះកាត់ឲ្យជាកំណាត់តូចកំណាត់ធំហើយ ក៏ពុះ លុះពុះហើយ ធ្វើឲ្យជាបន្ទះតូច ៗ លុះធ្វើឲ្យជាបន្ទះតូច ៗ ហើយ ហាលខ្យល់និងកំដៅថ្ងៃ លុះហាលខ្យល់និងកំដៅថ្ងៃហើយ យកភ្លើងដុត លុះយកភ្លើងដុតហើយ ធ្វើឲ្យជាកម្ទេចធ្យូង លុះធ្វើឲ្យជាកម្ទេចធ្យូងហើយ ផាចទៅលើខ្យល់ធំ ឬបណ្តែតទៅក្នុងស្ទឹង ដែលមានខ្សែទឹកហូរខ្លាំង

ឯវញ្ហិ សោ អានន្ទ មហារុក្ខោ ឧច្ឆិន្នមូលោ អស្ស តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ ឯវមេវ ខោ អានន្ទ ឧបាទានិយេសុ ធម្មេសុ អាទីនវានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ នវមំ ។

រុក្ខវគ្គោ ឆដ្ឋោ ។

ម្នាលអានន្ទ កាលបើដូច្នេះ ឈើធំនោះ ឈ្មោះថាគេបានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យលែងមានទីកន្លែងដុះទៀតហើយ ជាឈើដល់នូវភាពមិនមានតទៅ មិនមានការកើតឡើងតទៅទៀតជាធម្មតា ម្នាលអានន្ទ កាលភិក្ខុពិចារណាឃើញទោស ក្នុងឧបាទានិយធម៌ទាំងឡាយហើយ តណ្ហារមែងរលត់ទៅ ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ការរលត់នៃជាតិ ព្រោះការរលត់នៃភព ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏រលត់ទៅ ព្រោះការរលត់នៃជាតិ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

ចប់សូត្រ ទី ១០ ។

ចប់ ទុក្ខវគ្គ ទី ៦ ។

## តស្ស ឧទ្ទានំ

បរិវីមំសនុបាទានំ

ទ្វេ ច សញ្ញោជនានិ ច

មហារុក្ខេន ទ្វេ វុត្តា

តរុណេន ច សត្តមំ

នាមរូបញ្ច វិញ្ញាណំ

និទានេន ច តេទសាតិ ៗ

---

អភិសមយសំយុត្ត និទានវគ្គ ឧទ្ទាន

## ឧទ្ទាននៃទុក្ខវគ្គនោះគឺ

និយាយពីកិច្ចពិចារណាសេចក្ដីទុក្ខ ១ និយាយពីកិច្ចឃើញទោស និងសេចក្ដីត្រេកអរ ក្នុងឧបាទានិយធម៌ ២ លើក និយាយពីសញ្ញោជនិយធម៌ ២ លើក ពោលប្រៀបពីដើមឈើធំ ២ លើក សេចក្ដីប្រៀបដោយដើមឈើខ្ចីជាគម្រប់ ៧ និយាយពីការចាប់កំណើតនៃនាមរូប ១ និយាយពីវិញ្ញាណ ចើកប់តាមនិទាន មាន ១៣ ។

# មហាវគ្គោ

(២៣០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា... អស្សុតវា ភិក្ខវេ បុថុជ្ជនោ ឥមស្មឹ ចាតុម្មហាភូតិកស្មឹ កាយស្មឹ និព្វិន្ទេយ្យបិ វិរជ្ជេយ្យបិ វិមុច្ចេយ្យបិ តំ កិស្ស ហេតុ ទិស្សតិ ហិ ភិក្ខវេ ឥមស្ស ចាតុម្មហាភូតិកស្ស កាយស្ស អាចយោបិ អបចយោបិ អាទានម្បិ និក្ខេបនម្បិ តស្មា តត្រាស្សុតវា បុថុជ្ជនោ និព្វិន្ទេយ្យបិ វិរជ្ជេយ្យបិ វិមុច្ចេយ្យបិ ។ យញ្ច ខោ ឯតំ ភិក្ខវេ វុច្ចតិ ចិត្តំ ឥតិបិ មនោ ឥតិបិ វិញ្ញាណំ ឥតិបិ តត្រាស្សុតវា បុថុជ្ជនោ នាលំ និព្វិន្ទិតុំ នាលំ វិរជ្ជិតុំ នាលំ វិមុច្ចិតុំ តំ កិស្ស ហេតុ

# មហាវគ្គ

(២៣០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង គប្បីនឿយណាយផង ធុញទ្រាន់ផង ផុតស្រឡះផង ក្នុងកាយដែលកើតអំពីមហាភូតទាំង ៤ នេះ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា សេចក្តីចម្រើនក្តី សេចក្តីវិនាសក្តី ដំណើរកើតឡើងក្តី ដំណើរបែកធ្លាយក្តី នៃកាយដែលកើតអំពីមហាភូតទាំង ៤ នេះ តែងប្រាកដ ហេតុនោះ បានជាបុថុជ្ជនអ្នកមិនចេះដឹង គប្បីនឿយណាយផង ធុញទ្រាន់ផង ផុតស្រឡះផង ក្នុងកាយដែលកើតអំពីមហាភូតទាំង ៤ នោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងធម្មជាតណា ដែលហៅថាចិត្តខ្លះ ហៅថាមនោខ្លះ ហៅថាវិញ្ញាណខ្លះ បុថុជ្ជនអ្នកមិនចេះដឹង មិនអាចនឿយណាយ មិនអាចធុញទ្រាន់ មិនអាចផុតស្រឡះ ក្នុងធម្មជាតនោះបានឡើយ ដំណើរនោះ ព្រោះហេតុអ្វី

ទីឃរត្តំ ហេតំ ភិក្ខវេ អស្សុតវតោ បុថុជ្ជនស្ស អជ្ឈោសិតំ មមាយិតំ បរាមដ្ឋំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ តស្មា តត្រាស្សុតវា បុថុជ្ជនោ នាលំ និព្វិន្ទិតុំ នាលំ វិរជ្ជិតុំ នាលំ វិមុច្ចិតុំ ។

[២៣១] វរំ ភិក្ខវេ អស្សុតវា បុថុជ្ជនោ ឥមំ ចាតុម្មហាភូតិកំ កាយំ អត្តតោ ឧបគច្ឆេយ្យ ន ត្វេវ ចិត្តំ តំ កិស្ស ហេតុ ទិស្សតាយំ ភិក្ខវេ ចាតុម្មហាភូតិកោ កាយោ ឯកម្បិ វស្សំ តិដ្ឋមានោ ទ្វេបិ វស្សានិ តិដ្ឋមានោ តីណិបិ វស្សានិ តិដ្ឋមានោ ចត្តារិបិ វស្សានិ តិដ្ឋមានោ បញ្ចបិ វស្សានិ តិដ្ឋមានោ ទសបិ វស្សានិ តិដ្ឋមានោ វីសតិបិ វស្សានិ តិដ្ឋមានោ តឹសម្បិ វស្សានិ តិដ្ឋមានោ ចត្តាឡីសម្បិ វស្សានិ តិដ្ឋមានោ បញ្ញាសម្បិ វស្សានិ តិដ្ឋមានោ វស្សសតម្បិ តិដ្ឋមានោ ភិយ្យោបិ តិដ្ឋមានោ ។ យញ្ច ខោ ឯតំ ភិក្ខវេ វុច្ចតិ ចិត្តំ ឥតិបិ មនោ ឥតិបិ វិញ្ញាណំ ឥតិបិ តំ រត្តិយា ច ទិវសស្ស ច អញ្ញទេវ ឧប្បជ្ជតិ អញ្ញំ និរុជ្ឈតិ ។

ម្នាលភិក្ខុទាំងឡាយ ព្រោះថាធម្មជាតនុ៎ះ បុថុជ្ជនអ្នកមិនចេះដឹង ធ្លាប់ចូលចិត្ត ពប់ភាន ប្រកាន់មកហើយអស់កាលជាអង្វែងថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះ ហេតុនោះ បានជាបុថុជ្ជនអ្នកមិនចេះដឹង មិនអាចនឿយណាយ មិនអាចធុញទ្រាន់ មិនអាចផុតស្រឡះ ក្នុងធម្មជាតនោះបានឡើយ ។

(២៣១) ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងប្រកាន់កាយដែលកើតអំពីមហាភូតទាំង ៤ នេះ ថាប្រសើរ ដោយថាជាខ្លួន តែមិនប្រកាន់នូវចិត្តឡើយ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា កាយដែលកើតអំពីមហាភូតទាំង ៤ នេះ កាលបើឋិតនៅបានមួយឆ្នាំខ្លះ ឋិតនៅបានពីរឆ្នាំខ្លះ ឋិតនៅបានបីឆ្នាំខ្លះ ឋិតនៅបានបួនឆ្នាំខ្លះ ឋិតនៅបានប្រាំឆ្នាំខ្លះ ឋិតនៅបាន ១០ ឆ្នាំខ្លះ ឋិតនៅបាន ២០ ឆ្នាំខ្លះ ឋិតនៅបាន ៣០ ឆ្នាំខ្លះ ឋិតនៅបាន ៤០ ឆ្នាំខ្លះ ឋិតនៅបាន ៥០ ឆ្នាំខ្លះ ឋិតនៅបាន ១០០ ឆ្នាំខ្លះ ឋិតនៅជាង ១០០ ឆ្នាំខ្លះ តែងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកឯធម្មជាត ដែលហៅថាចិត្តខ្លះ មនោខ្លះ វិញ្ញាណខ្លះនោះ តែងកើតឡើងផ្សេង រលត់ទៅផ្សេង ទាំងយប់ទាំងថ្ងៃ ។

(២៣២) សេយ្យថាបិ ភិក្ខវេ មក្កដោ អរញ្ញេ ច ព្រហាវនេ(១) ចរមានោ សាខំ គណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ គណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ គណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ គណ្ហាតិ ឯវមេវ ខោ ភិក្ខវេ យទិទំ វុច្ចតិ ចិត្តំ ឥតិបិ មនោ ឥតិបិ វិញ្ញាណំ ឥតិបិ តំ រត្តិយា ច ទិវសស្ស ច អញ្ញទេវ ឧប្បជ្ជតិ អញ្ញំ និរុជ្ឈតិ ។

(២៣៣) តត្រ ភិក្ខវេ សុតវា អរិយសាវកោ បដិច្ចសមុប្បាទញ្ញេវ សាធុកំ យោនិសោ មនសិការោតិ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

---

១ ម. បវនេ ។

( ២៣៦ ) ម្នាលភិក្ខុទាំងឡាយ ដូចស្វា ត្រាច់ទៅក្នុងព្រៃតូចព្រៃធំ តែងចាប់មែកឈើ លែងមែកដែលចាប់នោះហើយ ចាប់មែកដទៃ លែងមែកដទៃនោះហើយ ចាប់មែកដទៃទៀត លែងមែកដទៃទៀតនោះហើយ ចាប់មែកដទៃតទៅទៀត យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ធម្មជាត ដែលហៅថាចិត្តខ្លះ មនោខ្លះ វិញ្ញាណខ្លះនោះ តែងកើតឡើងផ្សេង រលត់ទៅវិញផ្សេង ទាំងយប់ទាំងថ្ងៃ ក៏យ៉ាងនោះឯង ។

( ២៣៧ ) ម្នាលភិក្ខុទាំងឡាយ ក្នុងសេចក្តីនោះ អរិយសាវ័កអ្នកចេះដឹង តែងធ្វើទុកក្នុងចិត្តនូវបដិច្ចសមុប្បាទធម៌ ដោយឧបាយនៃប្រាជ្ញាឲ្យប្រពៃថា កាលបើវត្ថុនេះមាន ទើបវត្ថុនេះមាន ព្រោះតែវត្ថុនេះកើតឡើង បានជាវត្ថុនេះកើតឡើងដែរ កាលបើវត្ថុនេះមិនមាន វត្ថុនេះក៏មិនមានដែរ ព្រោះតែវត្ថុនេះរលត់ បានជាវត្ថុនេះរលត់ដែរ គឺថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ឯការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់មិនសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។

(២៣៦) ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មិំបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មិំបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មិំ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

បឋមំ ។

(២៣៧) សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... អស្សុតវា ភិក្ខវេ បុថុជ្ជនោ ឥមស្មិំ ចាតុម្មហាភូតិកស្មិំ កាយស្មិំ និព្វិន្ទេយ្យបិ វិរជ្ជេយ្យបិ វិមុច្ចេយ្យបិ តំ កិស្ស ហេតុ ទិស្សតិ ហិ ភិក្ខវេ ឥមស្ស ចាតុម្មហាភូតិកស្ស កាយស្ស អាចយោបិ អបចយោបិ អាទានម្បិ និក្ខេបនម្បិ តស្មា តត្រាស្សុតវា បុថុជ្ជនោ និព្វិន្ទេយ្យបិ វិរជ្ជេយ្យបិ វិមុច្ចេយ្យបិ ។

[ ២៣៦ ] ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ តែងនឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំង-ឡាយផង នឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយ ក៏តែងធុញទ្រាន់ ព្រោះតែការធុញទ្រាន់ ចិត្តក៏ផុតស្រឡះបាន ។ កាលបើចិត្តផុតស្រឡះហើយ សេចក្ដីដឹងថា ចិត្តផុតស្រឡះហើយ ដូច្នេះក៏កើតមាន ។ អរិយសាវកនោះ តែងដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោ-ឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រទី ១ ។

[ ២៣៧ ] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង គប្បីនឿយណាយផង ធុញទ្រាន់ផង ផុតស្រឡះផង ក្នុងកាយដែលកើតអំពីមហាភូតទាំង ៤ នេះ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា សេចក្ដីចម្រើនក្ដី សេចក្ដីវិនាសក្ដី ដំណើរកើតក្ដី ដំណើរបែកធ្លាយក្ដី របស់កាយដែលកើតអំពីមហាភូតទាំង ៤ នេះ តែងប្រាកដ ហេតុនោះ បានជាបុថុជ្ជនអ្នកមិនចេះដឹង គប្បីនឿយណាយផង ធុញទ្រាន់ផង ផុតស្រឡះផង ក្នុងកាយនោះ ។

យញ្ច ខោ ឯតំ ភិក្ខវេ វុច្ចតិ ចិត្តំ ឥតិបិ មនោ ឥតិបិ វិញ្ញាណំ ឥតិបិ តត្រាស្សុតវា បុថុជ្ជនោ នាលំ និព្វិន្ទិតុំ នាលំ វិរជ្ជិតុំ នាលំ វិមុច្ចិតុំ តំ កិស្ស ហេតុ ទីឃរត្តំ ហេតំ ភិក្ខវេ អស្សុតវតោ បុថុជ្ជនស្ស អជ្ឈោសិតំ មមាយិតំ បរាមដ្ឋំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ តស្មា តត្រាស្សុតវា បុថុជ្ជនោ នាលំ និព្វិន្ទិតុំ នាលំ វិរជ្ជិតុំ នាលំ វិមុច្ចិតុំ ។

[២៣៦] វរំ ភិក្ខវេ អស្សុតវា បុថុជ្ជនោ ឥមំ ចាតុម្មហាភូតិកំ កាយំ អត្តតោ ឧបគច្ឆេយ្យ ន ត្វេវ ចិត្តំ តំ កិស្ស ហេតុ ទិស្សតាយំ ភិក្ខវេ ចាតុម្មហាភូតិកោ កាយោ ឯកម្បិ វស្សំ តិដ្ឋមានោ ទ្វេបិ វស្សានិ តិដ្ឋមានោ តីណិបិ វស្សានិ តិដ្ឋមានោ ចត្តារិបិ វស្សានិ តិដ្ឋមានោ បញ្ចបិ វស្សានិ តិដ្ឋ-មានោ ទសបិ វស្សានិ តិដ្ឋមានោ វីសំបិ វស្សានិ តិដ្ឋមានោ តឹសំបិ វស្សានិ តិដ្ឋមានោ ចត្តាឡីសម្បិ វស្សានិ តិដ្ឋមានោ បញ្ញាសម្បិ វស្សានិ តិដ្ឋមានោ

ម្នាលភិក្ខុទាំងឡាយ ចំណែកខាងធម្មជាតណា ដែលហៅថា ចិត្តខ្លះ មនោខ្លះ វិញ្ញាណខ្លះ បុថុជ្ជនអ្នកមិនចេះដឹង មិនអាចនឿយណាយ មិនអាចធុញទ្រាន់ មិនអាចផុតស្រឡះ ក្នុងធម្មជាតនោះឡើយ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ធម្មជាតនុ៎ះ បុថុជ្ជនអ្នកមិនចេះដឹង ធ្លាប់ចូលចិត្ត កាន់អាង ប្រកាន់មកហើយ អស់កាលជាអង្វែងថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះ ហេតុនោះ បានជាបុថុជ្ជនអ្នកមិនចេះដឹង មិនអាចនឿយណាយ មិនអាចធុញទ្រាន់ មិនអាចផុតស្រឡះ ក្នុងធម្មជាតនោះឡើយ ។

[២៣៦] ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងប្រកាន់កាយដែលកើតអំពីមហាភូតទាំង ៤ នេះ ថាប្រសើរ ដោយថាជាខ្លួន តែមិនប្រកាន់នូវចិត្តឡើយ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា កាយដែលកើតអំពីមហាភូតទាំង ៤ នេះ កាលបើឋិតនៅបាន ១ ឆ្នាំខ្លះ ឋិតនៅបាន ២ ឆ្នាំខ្លះ ឋិតនៅបាន ៣ ឆ្នាំខ្លះ ឋិតនៅបាន ៤ ឆ្នាំខ្លះ ឋិតនៅបាន ៥ ឆ្នាំខ្លះ ឋិតនៅបាន ១០ ឆ្នាំខ្លះ ឋិតនៅបាន ២០ ឆ្នាំខ្លះ ឋិតនៅបាន ៣០ ឆ្នាំខ្លះ ឋិតនៅបាន ៤០ ឆ្នាំខ្លះ ឋិតនៅបាន ៥០ ឆ្នាំខ្លះ

វស្សសតម្បិ តិដ្ឋមានោ ភិយ្យោបិ តិដ្ឋមានោ ។ យញ្ច ខោ ឯតំ ភិក្ខវេ វុច្ចតិ ចិត្តំ ឥតិបិ មនោ ឥតិបិ វិញ្ញាណំ ឥតិបិ តំ រត្តិយា ច ទិវសស្ស ច អញ្ញទេវ ឧប្បជ្ជតិ អញ្ញំ និរុជ្ឈតិ ។

(២៣៧) តត្រ ភិក្ខវេ សុតវា អរិយសាវកោ បដិច្ចសមុប្បាទំយេវ សាធុកំ យោនិសោ មនសិករោតិ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ ។ សុខវេទនីយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្បជ្ជតិ សុខា វេទនា តស្សេវ សុខវេទនីយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ សុខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា សុខា វេទនា សា និរុជ្ឈតិ

ឋិតនៅបាន ១០០ ឆ្នាំខ្លះ ឋិតនៅច្រើនជាង ១០០ ឆ្នាំខ្លះ តែងប្រាកដ ៗ ម្នាលភិក្ខុទាំងឡាយ ចំណែកឯធម្មជាតណា ដែលហៅថា ចិត្តខ្លះ មនោខ្លះ វិញ្ញាណខ្លះ ធម្មជាតនោះ តែងកើតឡើងផ្សេង រលត់ទៅវិញផ្សេង ទាំងយប់ទាំងថ្ងៃ ។

[២៣៧] ម្នាលភិក្ខុទាំងឡាយ ត្រង់សេចក្តីនោះ អរិយសាវកអ្នកចេះដឹង តែងធ្វើទុកក្នុងចិត្ត នូវបដិច្ចសមុប្បាទធម៌ ដោយឧបាយប្រាជ្ញាឲ្យប្រពៃថា កាលបើវត្ថុនេះមាន ទើបវត្ថុនេះមាន ព្រោះតែវត្ថុនេះកើតឡើង បានជាវត្ថុនេះកើតឡើងដែរ កាលបើវត្ថុនេះមិនមាន វត្ថុនេះក៏មិនមានដែរ ព្រោះតែវត្ថុនេះរលត់ បានជាវត្ថុនេះរលត់ដែរ ។ ម្នាលភិក្ខុទាំង-ឡាយ សុខវេទនារមែងកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃសុខវេទនា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺសុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃសុខវេទនា វេទនានោះ ក៏រលត់ទៅ ស្ងប់រម្ងាប់ទៅ ព្រោះការរលត់នៃផស្សៈដែលជាបច្ច័យ

សា វូបសម្មតិ ។ ទុក្ខវេទនីយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា តស្សេវ ទុក្ខវេទនីយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា ទុក្ខា វេទនា សា និរុជ្ឈតិ សា វូបសម្មតិ ។ អទុក្ខមសុខវេទនីយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា តស្សេវ អទុក្ខមសុខវេទនីយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា អទុក្ខមសុខា វេទនា សា និរុជ្ឈតិ សា វូបសម្មតិ ។

(២៣៨) សេយ្យថាបិ ភិក្ខវេ ទ្វិន្នំ កដ្ឋានំ សង្ឃដ្ដសមោធានា ឧស្មា ជាយតិ តេជោ អភិនិព្វត្តតិ តេសំយេវ ទ្វិន្នំ កដ្ឋានំ នានាកតវិនិព្ភោគា(១) យា តជ្ជា ឧស្មា សា និរុជ្ឈតិ សា វូបសម្មតិ

---

១ ម. នានាភាវវិនិព្ភោគា ។

នៃសុខវេទនានោះឯង ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខវេទនា រមែងកើតឡើង ព្រោះអាស្រ័យផស្សៈជាបច្ច័យនៃទុក្ខវេទនា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺទុក្ខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃទុក្ខវេទនា វេទនានោះ ក៏រលត់ទៅ ស្ងប់រម្ងាប់ទៅ ព្រោះការរលត់នៃផស្សៈដែលជាបច្ច័យនៃទុក្ខវេទនានោះឯង ។ ម្នាលភិក្ខុទាំងឡាយ វេទនាដែលមិនជាទុក្ខមិនជាសុខ រមែងកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃវេទនាមិនជាទុក្ខមិនជាសុខ វេទនាណាដែលកើតអំពីផស្សៈនោះ គឺវេទនាមិនជាទុក្ខមិនជាសុខ ដែលកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃវេទនាមិនជាទុក្ខមិនជាសុខ វេទនានោះ ក៏រលត់ទៅ ស្ងប់រម្ងាប់ទៅ ព្រោះការរលត់នៃផស្សៈដែលជាបច្ច័យនៃវេទនាមិនជាទុក្ខមិនជាសុខនោះឯង ។

[២៣៨] ម្នាលភិក្ខុទាំងឡាយ ដូចជាចំហាយក្តៅ កើតឡើង ភ្លើងក៏កើតឡើង ព្រោះតែការប្រជុំខ្ទប់គ្នានៃឈើពីរកំណាត់ កាលបើឈើទាំងពីរកំណាត់នោះឯង ញែកឃ្លាតចេញពីគ្នាហើយ ចំហាយក្តៅដែលកើតអំពីកំណាត់ឈើនោះ ក៏រលត់ទៅ ស្ងប់រម្ងាប់ទៅ យ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ សុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ សុខា វេទនា តស្សេវ សុខវេទនីយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ សុខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា សុខា វេទនា សា និរុជ្ឈតិ សា វូបសម្មតិ ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា តស្សេវ ទុក្ខវេទនីយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា ទុក្ខា វេទនា សា និរុជ្ឈតិ សា វូបសម្មតិ អទុក្ខ-មសុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា តស្សេវ អទុក្ខមសុខវេទនីយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា អទុក្ខមសុខា វេទនា សា និរុជ្ឈតិ សា វូបសម្មតិ ។

ម្នាលភិក្ខុទាំងឡាយ សុខវេទនា តែងកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃសុខវេទនា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺសុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃសុខវេទនា វេទនានោះ ក៏រលត់ទៅ ស្ងប់រម្ងាប់ទៅ ព្រោះការរលត់នៃផស្សៈដែលជាបច្ច័យនៃសុខវេទនានោះឯង ទុក្ខវេទនា តែងកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃទុក្ខវេទនា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺទុក្ខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈជាបច្ច័យនៃទុក្ខវេទនា វេទនានោះ ក៏រលត់ទៅ ស្ងប់រម្ងាប់ទៅ ព្រោះការរលត់នៃផស្សៈដែលជាបច្ច័យនៃទុក្ខវេទនានោះឯង វេទនាមិនជាទុក្ខមិនជាសុខកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃវេទនាមិនជាទុក្ខមិនជាសុខ វេទនាណា ដែលកើតអំពីផស្សៈនោះ គឺវេទនាមិនជាទុក្ខមិនជាសុខ ដែលកើតឡើង ព្រោះអាស្រ័យផស្សៈដែលជាបច្ច័យនៃវេទនាមិនជាទុក្ខមិនជាសុខ វេទនានោះ ក៏រលត់ទៅ ស្ងប់រម្ងាប់ទៅ ព្រោះការរលត់នៃផស្សៈ ដែលជាបច្ច័យនៃវេទនាមិនជាទុក្ខមិនជាសុខនោះឯង ក៏យ៉ាងនោះឯង ។

(២៣៩) ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ទុតិយំ ។

(២៤០) សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... ចត្តារោមេ ភិក្ខវេ អាហារា ភូតានំ វា សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ ។ កតមេ ចត្តារោ ។ កពឡីការោ អាហារោ ឱឡារិកោ វា សុខុមោ វា ផស្សោ ទុតិយោ មនោសញ្ចេតនា តតិយា វិញ្ញាណំ ចតុត្ថំ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អាហារា ភូតានំ វា សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ ។

( ២៣៩ ) ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ តែងនឿយណាយក្នុងផស្សៈផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំងឡាយផង នឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយក៏តែងធុញទ្រាន់ ព្រោះតែការធុញទ្រាន់ ចិត្តក៏ផុតស្រឡះបាន ។ កាលបើចិត្តផុតស្រឡះហើយ សេចក្ដីដឹងថា ចិត្តផុតស្រះឡះហើយដូច្នេះ ក៏កើតមាន ។ អរិយសាវ័កនោះ តែងដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ ព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡ-សកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ២ ។

( ២៤០ ) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ អាហារ ៤ នេះ ប្រព្រឹត្តទៅដើម្បីការតាំងនៅបាននៃពួកភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសី-សត្វផង ។ អាហារ ៤ តើដូចម្ដេច ។ កវឡីការាហារ ដ៏គ្រោតគ្រាតក្ដី ល្អិតក្ដី ( ជាទីមួយ ) ផស្សាហារ ជាទីពី រមនោសញ្ចេតនា-ហារជាទីបី វិញ្ញាណាហារ ជាទីបួន ។ ម្នាលភិក្ខុទាំងឡាយ អាហារ ៤នេះឯង ប្រព្រឹត្តទៅ ដើម្បីការតាំងនៅបាននៃពួកភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង ។

(២៤១) កថញ្ច ភិក្ខវេ កវឡីការោ អាហារោ ទដ្ឋព្វោ ។ សេយ្យថាបិ ភិក្ខវេ ទ្វេ ជាយបតិកា បរិត្តំ សម្ពលំ អាទាយ កន្តារមគ្គំ បដិបជ្ជេយ្យុំ តេ-សមស្ស ឯកបុត្តកោ បិយោ មនាបោ ។ អថខោ តេសំ ភិក្ខវេ ទ្វិន្នំ ជាយបតិកានំ កន្តារគតានំ យា បរិត្តា សម្ពលមត្តា សា បរិក្ខយំ បរិយាទានំ គច្ឆេយ្យ សិយា បនេស(១) កន្តារាវសេសោ អនិត្ថិណ្ណោ(២) ។ អថខោ តេសំ ភិក្ខវេ ទ្វិន្នំ ជាយបតិកានំ ឯវមស្ស អម្ហាកំ ខោ យា បរិត្តា សម្ពលមត្តា សា បរិក្ខីណា បរិយាទិន្នា អត្ថិ ចាយំ កន្តារាវសេសោ អនិត្ថិណ្ណោ យន្នូន មយំ ឥមំ ឯកបុត្តកំ បិយំ មនាបំ វធិត្វា វល្លូរញ្ច សោណ្ឌិកញ្ច ករិត្វា បុត្តមំសានិ ខាទន្តា ឯវ(៣) ទ្វេបិ តំ កន្តារាវសេសំ និត្ថរេយ្យាម នោ ចេ(៤) សព្វេវ តយោ វិនស្សម្ហាតិ ។ អថខោ តេ ភិក្ខវេ ទ្វេ ជាយបតិកា ឯកំ ឯកបុត្តកំ បិយំ មនាបំ វធិត្វា

---

១ ឱ. ម. សិយា បនេសំ ។ ២ ម. អនតិណ្ណោ ។ ៣ ឱ. ម. ឯវន្តំ កន្តារាវសេសំ ។ ៤ មា សព្វេវ ។

(២៤១) ម្នាលភិក្ខុទាំងឡាយ កវឡីការាហារ តើត្រូវយល់ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជាភរិយាស្វាមីពីរនាក់ គប្បីនាំយកស្បៀងតិចតួចដើរទៅកាន់ផ្លូវលំបាក ស្វាមីភរិយានោះ មានកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្ត ។ ម្នាលភិក្ខុទាំងឡាយ គ្រាកាលដែលភរិយាស្វាមីទាំងពីរនាក់ កំពុងដើរទៅកាន់ផ្លូវលំបាកនោះ ស្បៀងបន្តិចបន្តួចនោះ អស់រលីងទៅ ផ្លូវលំបាកនោះ នៅសល់ធ្លងមិនទាន់ផុត ។ ម្នាលភិក្ខុទាំងឡាយ ទើបភរិយាស្វាមីទាំងពីរនាក់នោះ ប្រឹក្សាគ្នាយ៉ាងនេះថា ស្បៀងអាហារបន្តិចបន្តួចរបស់យើងនោះ អស់រលីងទៅហើយ ផ្លូវលំបាកនៅសល់ធ្លងមិនទាន់ផុតឡើយ បើដូច្នោះ យើងត្រូវសម្លាប់កូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តនេះ ធ្វើជាងៀតផង ជាផ្អកផង កាលបើយើងទាំងពីរនាក់ ស៊ីសាច់កូននោះហើយ នឹងធ្លងផ្លូវលំបាកដែលនៅសល់នោះផុតបាន បើមិនដូច្នោះ យើងទាំងអស់គ្នា មុខជានឹងស្លាប់ទាំងបីនាក់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ភរិយាស្វាមីទាំងពីរនាក់នោះ សម្លាប់កូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តនុ៎ះ

វល្លូរញ្ច សោណ្ឌិកញ្ច ករិត្វា បុត្តមំសានិ ខាទន្តា ឯវំ តំ កន្តារំ និត្ថរេយ្យុំ តេ បុត្តមំសានិ ចេវ ខាទេយ្យុំ ឧរេ ច បដិបិសេយ្យុំ កហំ ឯកបុត្តក កហំ ឯកបុត្តកាតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ តេ ទវាយ វា អាហារំ អាហារេយ្យុំ មទាយ វា អាហារំ អាហារេយ្យុំ មណ្ឌនាយ វា អាហារំ អាហារេយ្យុំ វិភូសនាយ វា អាហារំ អាហារេយ្យុន្តិ ។ នោ ហេតំ ភន្តេ ។ ននុ តេ ភិក្ខវេ យាវទេវ កន្តារស្ស និត្ថរណត្ថាយ អាហារំ អាហារេយ្យុន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខ្វាហំ ភិក្ខវេ កពឡីការោ អាហារោ ទដ្ឋព្វោតិ វទាមិ ។ កពឡីការេ ភិក្ខវេ អាហារេ បរិញ្ញាតេ បញ្ចកាមគុណិកោ រាគោ បរិញ្ញាតោ ហោតិ បញ្ចកាមគុណិកេ រាគេ បរិញ្ញាតេ នត្ថិ តំ សញ្ញោជនំ យេន សញ្ញោជនេន សញ្ញុត្តោ អរិយសាវកោ បុន ឥមំ លោកំ អាគច្ឆេយ្យ ។

ធ្វើជាទៀតផង ជាអ្នកផង កាលបើភរិយាស្វាមីទាំងពីរនាក់ ស៊ីសាច់កូនហើយ ទើបដើរឆ្លងផ្លូវលំបាកដែលនៅសល់នោះឲ្យផុតបាន ភរិយាស្វាមីនោះ ស៊ីសាច់កូនផង តែទ្រូងផងថា នែកូនប្រុសតែមួយ អ្នកឯងនៅឯណា នែកូនប្រុសតែមួយ អ្នកឯងនៅឯណា ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ សំគាល់ដំណើរនោះថាដូចម្តេច ភរិយាស្វាមីនោះ លេបអាហារដើម្បីការលេង លេបអាហារដើម្បីការស្រវឹង លេបអាហារដើម្បីការប្រដាប់តាក់តែង លេបអាហារដើម្បីការស្អិតស្អាង ដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ដំណើរនុ៎ះមិនមែនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ភរិយាស្វាមីនោះ ក្រែងលេបអាហារត្រាន់តែដើម្បីនឹងឆ្លងផ្លូវលំបាកឲ្យផុតតែប៉ុណ្ណោះទេឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ត្រូវអ្នករាល់គ្នា យល់កវឡីការាហារ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងកវឡីការា-ហារហើយ ក៏ឈ្មោះថាបានកំណត់ដឹងរាគៈ ដែលប្រព្រឹត្តទៅក្នុងកាម-គុណទាំង ៥ ដែរ កាលបើកំណត់ដឹងរាគៈដែលប្រព្រឹត្តទៅក្នុងកាមគុណទាំង ៥ ហើយ អរិយសាវ័ក ដែលប្រកបដោយសំយោជនៈណាហើយ ត្រូវត្រឡប់មកកាន់លោកនេះម្តងទៀត សំយោជនៈនោះមិនមានទេ ។

(៦៤៦) កថញ្ច ភិក្ខវេ ផស្សាហារោ ទដ្ឋព្វោ ។ សេយ្យថាបិ ភិក្ខវេ គាវី និច្ចម្មា កុឌ្ឌញ្ចេ និស្សាយ តិដ្ឋេយ្យ យេ កុឌ្ឌនិស្សិតា បាណា តេ នំ ខាទេយ្យុំ រុក្ខញ្ចេ និស្សាយ តិដ្ឋេយ្យ យេ រុក្ខនិស្សិតា បាណា តេ នំ ខាទេយ្យុំ ឧទកញ្ចេ និស្សាយ តិដ្ឋេយ្យ យេ ឧទកនិស្សិតា បាណា តេ នំ ខាទេយ្យុំ អាកាសញ្ចេ និស្សាយ តិដ្ឋេយ្យ យេ អាកាសនិស្សិតា បាណា តេ នំ ខាទេយ្យុំ យញ្ញទេវ ហិ សា ភិក្ខវេ គាវី និច្ចម្មា និស្សាយ តិដ្ឋេយ្យ យេ តំ និស្សិតា តំ និស្សិតា បាណា តេ នំ- ខាទេយ្យុំ ឯវមេវ ខ្វាហំ ភិក្ខវេ ផស្សាហារោ ទដ្ឋព្វោតិ វទាមិ ។ ផស្សេ ភិក្ខវេ អាហារេ បរិញ្ញាតេ តិស្សោ វេទនា បរិញ្ញាតា ហោន្តិ តីសុ វេទនាសុ បរិញ្ញាតាសុ អរិយសាវកស្ស នត្ថិ កិញ្ចិ ឧត្តរិករណីយន្តិ វទាមិ ។

(៤៤២) ម្នាលភិក្ខុទាំងឡាយ ផស្សាហារ តើត្រូវយល់ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជាមេគោដែលមិនមានស្បែក បើឈរផ្អែកនឹងជញ្ជាំង ក៏ត្រូវពួកសត្វដែលអាស្រ័យនៅនឹងជញ្ជាំងនោះខាំ បើឈរផ្អែកនឹងដើមឈើ ក៏ត្រូវពួកសត្វដែលអាស្រ័យនៅនឹងដើមឈើនោះខាំ បើឈរត្រាំនៅក្នុងទឹក ក៏ត្រូវពួកសត្វដែលអាស្រ័យនៅក្នុងទឹកនោះចឹកប្របិច បើឈរកណ្តាលវាល ក៏ត្រូវពួកសត្វដែលអាស្រ័យនៅនឹងអាកាសនោះខាំ ម្នាលភិក្ខុទាំងឡាយ មេគោដែលមិនមានស្បែកនោះ ឈរនៅក្នុងទីណា ៗ ក៏គង់តែពួកសត្វដែលអាស្រ័យនៅក្នុងទីនោះ ៗ ខាំស៊ី យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ត្រូវអ្នកពល់គ្នាយល់ផស្សាហារ ក៏យ៉ាងនោះឯង ៗ ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងផស្សាហារហើយ ក៏ឈ្មោះថាបានកំណត់ដឹងនូវវេទនាទាំងបីដែរ កាលបើកំណត់ដឹងនូវវេទនាទាំងបីហើយ តថាគតពោលថា កិច្ចណាមួយ ដែលអរិយសាវ័កត្រូវធ្វើតទៅទៀត មិនមានឡើយ ។

(៤៤៣) កថញ្ច ភិក្ខវេ មនោសញ្ចេតនាហារោ
ទដ្ឋព្វោ ។ សេយ្យថាបិ ភិក្ខវេ អង្គារកាសុ សាធិ-
កបោរិសា បុណ្ណា អង្គារានំ វីតច្ចិកានំ(១) វីតធូមានំ
អថ បុរិសោ អាគច្ឆេយ្យ ជីវិតុកាមោ អមរិតុកាមោ
សុខកាមោ ទុក្ខប្បដិក្កូលោ តមេនំ ទ្វេ ពលវន្តោ
បុរិសា នានាពាហាសុ គហេត្វា តំ អង្គារកាសុំ ឧប-
កឌ្ឍេយ្យុំ ។ អថខោ ភិក្ខវេ តស្ស បុរិសស្ស អារ-
កាវស្ស ចេតនា អារកា បត្ថនា អារកា បណិធិ តំ
កិស្ស ហេតុ វិទិតញ្ហិ(២) ភិក្ខវេ តស្ស បុរិសស្ស ហោតិ
ឥមញ្ចាហំ អង្គារកាសុំ បបតិស្សាមិ តតោនិទានំ មរ-
ណំ វា និគច្ឆាមិ មរណមត្តំ វា ទុក្ខន្តិ ឯវមេវ ខ្វាហំ
ភិក្ខវេ មនោសញ្ចេតនាហារោ ទដ្ឋព្វោតិ វទាមិ ។
មនោសញ្ចេតនាយ ភិក្ខវេ អាហារេ បរិញ្ញាតេ

---

១ វីតច្ចិកានន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ខ. ម. ឯវិញ្ហិ ។

( ២៤៣ ) ម្នាលភិក្ខុទាំងឡាយ មនោសញ្ចេតនាហារ តើត្រូវយល់ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជារណ្តៅរងើកភ្លើង មានជម្រៅជាងមួយជួរបុរស ពេញដោយរងើកភ្លើង ឥតមានអណ្តាត ឥតមានផ្សែង ចួនជា មានបុរសអ្នកប្រាថ្នាចង់រស់នៅ មិនប្រាថ្នាចង់ស្លាប់ ស្រឡាញ់សុខ ខ្ពើមទុក្ខ ដើរមក ស្រាប់តែបុរសពីនាក់មានកម្លាំង ចាប់បុរសនោះ ត្រង់ដើមដៃម្នាក់ម្នាក់ ទាញទម្លាក់ទៅក្នុងរណ្តៅរងើកភ្លើងនោះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ បុរសនោះ សមជាមានចេតនាគិតចង់ឲ្យឃ្លាត មានប្រាថ្នាចង់ឲ្យឆ្ងាយ មានបំណងចង់ឲ្យឃ្លាង អំពីរណ្តៅរងើកភ្លើងនោះ ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុរសនោះ បានដឹងជាក់លាក់ថា បើអាត្មាអញនឹងធ្លាក់ទៅក្នុងរណ្តៅរងើកភ្លើងនេះ អាត្មាអញមុខជានឹងដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើនឹងស្លាប់ ព្រោះតែការធ្លាក់ទៅក្នុងរណ្តៅរងើកភ្លើងនោះជាហេតុ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ត្រូវអ្នកកល់គាយល់មនោសញ្ចេតនាហារ ក៏ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងនូវមនោសញ្ចេតនាហារហើយ

តិស្សោ តណ្ហា បរិញ្ញាតា ហោន្តិ តិសុ តណ្ហាសុ បរិញ្ញាតាសុ អរិយសាវកស្ស នត្ថិ កិញ្ចិ ឧត្តរិករណីយន្តិ វទាមិ ។

(២៤៤) កថញ្ច ភិក្ខវេ វិញ្ញាណាហារោ ទដ្ឋព្វោ ។ សេយ្យថាបិ ភិក្ខវេ ចោរំ អាគុចារឹ គហេត្វា រញ្ញោ ទស្សេយ្យុំ អយន្តេ ទេវ ចោរោ អាគុចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ តមេនំ រាជា ឯវំ វទេយ្យ គច្ឆថ ភោ ឥមំ បុរិសំ បុព្វណ្ហសមយំ សត្តិសតេន ហនថាតិ តមេនំ បុព្វណ្ហសមយំ សត្តិសតេន ហនេយ្យុំ អថ រាជា មជ្ឈន្តិកសមយំ ឯវំ វទេយ្យ អម្ភោ កថំ សោ បុរិសោតិ តថេវ ទេវ ជីវតីតិ តមេនំ រាជា ឯវំ វទេយ្យ គច្ឆថ ភោ តំ បុរិសំ មជ្ឈន្តិកសមយំ សត្តិសតេន ហនថាតិ

ក៏ឈ្មោះថាបានកំណត់ដឹងនូវតណ្ហាទាំងបីដែរ កាលបើកំណត់ដឹងនូវតណ្ហាទាំងបីហើយ តថាគតពោលថា កិច្ចណាមួយ ដែលអរិយសាវ័កត្រូវធ្វើតទៅទៀត មិនមានឡើយ ។

(២៦៦) ម្នាលភិក្ខុទាំងឡាយ ចុះវិញ្ញាណាហារ តើត្រូវយល់ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជាពួកពលបុរស ចាប់បានចោរដែលប្រព្រឹត្តអំពើអាក្រក់ យកមកថ្វាយដល់ព្រះរាជា បពិត្រព្រះសម្មតិទេព បុគ្គលនេះជាចោររបស់ព្រះអង្គ ជាអ្នកប្រព្រឹត្តអំពើអាក្រក់ សូមទ្រង់ដាក់អាជ្ញាដល់ចោរនេះ តាមព្រះរាជបំណង ព្រះរាជាមានព្រះបន្ទូលចំពោះបុរសនោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយទៅប្រហារបុរសនេះ ១០០ លំពែង ក្នុងវេលាព្រឹក ពលបុរសក៏ប្រហារបុរសនោះ ១០០ លំពែង ក្នុងវេលាព្រឹក លុះដល់សម័យថ្ងៃត្រង់ ព្រះរាជាត្រាស់សួរយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បុរសនោះដូចម្តេចទៅ ពលបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសនោះនៅរស់ដដែលទេ ព្រះរាជាមានព្រះបន្ទូលចំពោះបុរសនោះ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយទៅប្រហារបុរសនោះ ១០០ លំពែង ក្នុងសម័យថ្ងៃត្រង់

តមេនំ មជ្ឈន្តិកសមយំ សត្តិសតេន ហនេយ្យុំ អថ
រាជា សាយណ្ហសមយំ ឯវំ វទេយ្យ អម្ភោ កថំ សោ
បុរិសោតិ តថេវ ទេវ ជីវតីតិ តមេនំ រាជា ឯវំ វទេយ្យ
គច្ឆថ ភោ តំ បុរិសំ សាយណ្ហសមយំ សត្តិសតេន
ហនថាតិ តមេនំ សាយណ្ហសមយំ សត្តិសតេន ហ-
នេយ្យុំ ។ តំ កិំ មញ្ញថ ភិក្ខវេ អបិ នុ ខោ សោ
បុរិសោ ទិវសំ តីហិ សត្តិសតេហិ ហញ្ញមានោ
តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទេយ្យាតិ
ឯកិស្សាបិ ភិក្ខវេ សត្តិយា ហញ្ញមានោ តតោនិទានំ
ទុក្ខំ ទោមនស្សំ បដិសំវេទេយ្យ កោ បន វាទោ
តីហិ សត្តិសតេហិ ហញ្ញមានោតិ ឯវមេវ ខ្វាហំ
ភិក្ខវេ វិញ្ញាណាហារោ ទដ្ឋព្វោតិ វទាមិ ។ វិញ្ញាណេ
ភិក្ខវេ អាហារេ បរិញ្ញាតេ នាមរូបំ បរិញ្ញាតំ ហោតិ

រាជបុរសក៏ប្រហារបុរសនោះ ១០០ លំពែង ក្នុងសម័យថ្ងៃត្រង់ លុះដល់សម័យថ្ងៃសៀល ព្រះរាជាទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បុរសនោះដូចម្តេចទៅ រាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសនោះនៅរស់ដដែលទេ ព្រះរាជាទ្រង់មានព្រះបន្ទូលចំពោះបុរសនោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយទៅប្រហារបុរសនោះ ១០០ លំពែង ក្នុងសម័យថ្ងៃសៀល រាជបុរសក៏ប្រហារបុរសនោះ ១០០ លំពែង ក្នុងសម័យថ្ងៃសៀល ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច កាលបើបុរសនោះ ត្រូវគេប្រហារ ៣០០ លំ-ពែងក្នុងមួយថ្ងៃ នឹងសោយទុក្ខទោមនស្ស ព្រោះហេតុតែគេប្រហារនោះ ម្នាលភិក្ខុទាំងឡាយ កាលបើបុរសនោះត្រូវប្រហារត្រឹម ១ លំពែងប៉ុណ្ណោះ ក៏សោយទុក្ខទោមនស្ស ព្រោះតែគេប្រហារ ១ លំពែងនោះទៅហើយ ចំណង់បើត្រូវគេប្រហារដល់ ៣០០ លំពែងនោះ មិនបាច់និយាយទេ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ត្រូវអ្នករាល់គ្នាយល់វិញ្ញាណាហារ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងវិញ្ញាណាហារហើយ ក៏ឈ្មោះថាបានកំណត់ដឹងនូវនាមនិងរូបដែរ

នាមរូបេ បរិញ្ញាតេ អរិយសាវកស្ស នត្ថិ កិញ្ចិ

ឧត្តរិករណីយន្តិ វទាមីតិ ។ នវមំ ។

[២៦៨] សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ...

ចត្តារោមេ ភិក្ខវេ អាហារា ភូតានំ វា សត្តានំ ឋិតិយា

សម្ភវេសីនំ វា អនុគ្គហាយ ។ កតមេ ចត្តារោ ។

កពឡីការោ អាហារោ ឱឡារិកោ វា សុខុមោ វា

ផស្សោ ទុតិយោ មនោសញ្ចេតនា តតិយា វិញ្ញាណំ

ចតុត្ថំ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អាហារា ភូតានំ

វា សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ ។

កាលបើកំណត់ដឹងនូវនាមនិងរូបហើយ គឺថាគតពោលថា កិច្ចណាមួយ ដែលអរិយសាវកត្រូវធ្វើតទៅទៀត មិនមានឡើយ ។ ចប់សូត្រទី ៣ ។

( ២៤៩ ) ខ្ញុំបានស្តាប់មកយ៉ាងនេះ ... គ្រានោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ អាហារនេះមាន ៤ ប្រព្រឹត្តទៅដើម្បីការតាំងនៅបាននៃពួកភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង ។ អាហារ ៤ តើដូចម្តេចខ្លះ ។ គឺកវឡីការាហារ ដ៏គ្រោតគ្រាតក្តី ល្អិតក្តី ( ជាទីមួយ ) ផស្សាហារជាទីពីរ មនោសញ្ចេតនាហារជាទីបី វិញ្ញាណាហារជាទីបួន ។ ម្នាលភិក្ខុទាំងឡាយ អាហារ ៤ នេះឯង ប្រព្រឹត្តទៅដើម្បីការតាំងនៅបាននៃពួកភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង ។

(២៤៦) កវឡីង្ការេ ចេ ភិក្ខវេ អាហារេ អត្ថិ រាគោ អត្ថិ នន្ទិ អត្ថិ តណ្ហា បតិដ្ឋិតំ តត្ថ វិញ្ញាណំ វិរូឡ្ហំ យត្ថ បតិដ្ឋិតំ វិញ្ញាណំ វិរូឡ្ហំ អត្ថិ តត្ថ នាមរូបស្ស អវក្កន្តិ យត្ថ អត្ថិ នាមរូបស្ស អវក្កន្តិ អត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ យត្ថ អត្ថិ សង្ខារានំ វុឌ្ឍិ អត្ថិ តត្ថ អាយតឹ បុនព្ភវាភិនិព្វត្តិ យត្ថ អត្ថិ អាយតឹ បុនព្ភវាភិនិព្វត្តិ អត្ថិ តត្ថ អាយតឹ ជាតិជរាមរណំ យត្ថ អត្ថិ អាយតឹ ជាតិជរាមរណំ សសោកំ តំ ភិក្ខវេ សរជំ(១) សឧបាយាសន្តិ វទាមិ ។ ផស្សេ ចេ ភិក្ខវេ អាហារេ ... មនោសញ្ចេតនាយ ចេ ភិក្ខវេ

---

១ ឱ.ម. សទរំ ។

[ ៤៤៦ ] ម្នាលភិក្ខុទាំងឡាយ បើតម្រេក សេចក្ដីត្រេកអរ ចំណង់ មានក្នុងកវឡិង្ការាហារហើយ វិញ្ញាណក៏ល្អូតលាស់ តាំងនៅស៊ប់ក្នុងកវឡិង្ការាហារនោះដែរ វិញ្ញាណល្អូតលាស់ តាំងនៅស៊ប់ក្នុងទីណា នាមរូបក៏ឈានចុះក្នុងទីនោះ នាមរូបឈានចុះក្នុងទីណា សង្ខារទាំងឡាយក៏ចម្រើនក្នុងទីនោះ សង្ខារទាំងឡាយចម្រើនក្នុងទីណា ការចាប់កំណើតក្នុងភពថ្មីតទៅទៀត ក៏មានក្នុងទីនោះ ការចាប់កំណើតក្នុងភពថ្មីតទៅទៀត មានក្នុងទីណា ជាតិ ជរា មរណៈតទៅទៀត ក៏មានក្នុងទីនោះ ជាតិ ជរា មរណៈតទៅទៀត មានក្នុងទីណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទីនោះ ប្រកបដោយសោក ប្រកបដោយធុលីគឺរាគាទិក្កិលេស ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ។ ម្នាលភិក្ខុទាំងឡាយ បើក្នុងផស្សាហារ ... ម្នាលភិក្ខុទាំងឡាយ បើក្នុងមនោ-

អាហារេ ... វិញ្ញាណេ ចេ ភិក្ខវេ អាហារេ អត្ថិ រាគោ អត្ថិ នន្ទិ អត្ថិ តណ្ហា បតិដ្ឋិតំ តត្ថ វិញ្ញាណំ វិរូឡ្ហំ យត្ថ បតិដ្ឋិតំ វិញ្ញាណំ វិរូឡ្ហំ អត្ថិ តត្ថ នាមរូបស្ស អវក្កន្តិ យត្ថ អត្ថិ នាមរូបស្ស អវក្កន្តិ អត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ យត្ថ អត្ថិ សង្ខារានំ វុឌ្ឍិ អត្ថិ តត្ថ អាយតឹ បុនព្ភវាភិនិព្វត្តិ យត្ថ អត្ថិ អាយតឹ បុនព្ភវា-ភិនិព្វត្តិ អត្ថិ តត្ថ អាយតឹ ជាតិជរាមរណំ យត្ថ អត្ថិ អាយតឹ ជាតិជរាមរណំ សសោកន្តំ ភិក្ខវេ សរជំ សឧបាយាសន្តិ វទាមិ ។

(៤៤៧) សេយ្យថាបិ ភិក្ខវេ រជកោ វា ចិត្ត-ការកោ វា សតិ រជនាយ វា លាខាយ វា ហលិទ្ទិ-យា វា នីលិយា វា មញ្ជិដ្ឋាយ វា សុមដ្ឋេ(១) វា ផល-កេ វា ភិត្តិយា វា ទុស្សបដេ វា ឥត្ថីរូបំ វា បុរិសរូបំ វា អភិនិម្មិនេយ្យ សព្វង្គបច្ចង្គិំ ឯវមេវ ខោ ភិក្ខវេ

១ សុបរិមដ្ឋេ ឥតិ កត្ថចិ អម្ហាកំ បោត្ថកេ ទិស្សតិ ។

សញ្ចេតនាហារ ... ម្នាលភិក្ខុទាំងឡាយ បើតម្រេក សេចក្តីរីករាយ ចំណង់ មានក្នុងវិញ្ញាណាហារ វិញ្ញាណក៏ល្អូតលាស់ តាំងនៅស៊ប់ក្នុងវិញ្ញាណាហារនោះ វិញ្ញាណល្អូតលាស់ តាំងនៅស៊ប់ក្នុងទីណា នាមរូបក៏ឈានចុះក្នុងទីនោះ នាមរូបឈានចុះក្នុងទីណា សង្ខារទាំង-ឡាយ ក៏ចម្រើនឡើងក្នុងទីនោះ សង្ខារទាំងឡាយចម្រើនឡើងក្នុងទីណា ការចាប់កំណើតក្នុងភពថ្មីតទៅទៀត ក៏មានក្នុងទីនោះ ការចាប់កំណើតក្នុងភពថ្មីតទៅទៀត មានក្នុងទីណា ជាតិ ជរា មរណៈតទៅទៀត ក៏មានក្នុងទីនោះ ជាតិ ជរា មរណៈតទៅទៀត មានក្នុងទីណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទីនោះ ប្រកបដោយសោក ប្រកបដោយធុលីគឺកាមកិលេស ប្រកបដោយសេចក្តីចង្អៀតចង្អល់ចិត្ត ។

[ ៤៤៧ ] ម្នាលភិក្ខុទាំងឡាយ ដូចជាជាងជ្រលក់ ឬជាងគំនូរ កាលបើមានទឹកជ្រលក់ក្តី ល័ក្តក្តី រមៀតក្តី ត្រាំក្តី ស្បែងក្តី ក៏គូររូបស្ត្រី ឬរូបបុរស ឲ្យមានអវយវៈតូចធំសព្វគ្រប់ នាក្រដាស ឬផែនក្តារ នាជញ្ជាំង ឬផ្ទាំងសំពត់ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ

កពឡីការេ ចេ អាហារេ អត្ថិ រាគោ អត្ថិ នន្ទី អត្ថិ តណ្ហា បតិដ្ឋិតំ តត្ថ វិញ្ញាណំ វិរូឡ្ហំ យត្ថ បតិដ្ឋិតំ វិញ្ញាណំ វិរូឡ្ហំ អត្ថិ តត្ថ នាមរូបស្ស អវក្កន្តិ យត្ថ អត្ថិ នាមរូបស្ស អវក្កន្តិ អត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ យត្ថ អត្ថិ សង្ខារានំ វុឌ្ឍិ អត្ថិ តត្ថ អាយតឹ បុនព្ភវាភិនិព្វត្តិ យត្ថ អត្ថិ អាយតឹ បុនព្ភវាភិនិព្វត្តិ អត្ថិ តត្ថ អាយតឹ ជាតិជរាមរណំ យត្ថ អត្ថិ អាយតឹ ជាតិជរាមរណំ សសោកំ តំ ភិក្ខវេ សរជំ សឧបាយាសន្តិ វទាមិ ។ ផស្សេ ចេ ភិក្ខវេ អាហារេ ... មនោសញ្ចេតនាយ ចេ ភិក្ខវេ អាហារេ ... វិញ្ញាណេ ចេ ភិក្ខវេ អាហារេ អត្ថិ រាគោ អត្ថិ នន្ទី អត្ថិ តណ្ហា បតិដ្ឋិតំ តត្ថ វិញ្ញាណំ វិរូឡ្ហំ យត្ថ បតិដ្ឋិតំ វិញ្ញាណំ វិរូឡ្ហំ អត្ថិ តត្ថ នាម-រូបស្ស អវក្កន្តិ យត្ថ អត្ថិ នាមរូបស្ស អវក្កន្តិ

បើតម្រេក សេចក្តីរីករាយ បំណង់ មានក្នុងកវឡិង្ការាហារនោះ វិញ្ញាណក៏លូតលាស់ តាំងនៅស៊ប់ក្នុងកវឡិង្ការាហារនោះ វិញ្ញាណលូតលាស់ តាំងនៅស៊ប់ក្នុងទីណា នាមរូបក៏ឈានចុះក្នុងទីនោះ នាមរូបឈានចុះក្នុងទីណា សង្ខារទាំងឡាយក៏ចម្រើនឡើងក្នុងទីនោះ សង្ខារទាំងឡាយចម្រើនក្នុងទីណា ការតាំងកំណើតក្នុងភពថ្មីតទៅទៀត ក៏មានក្នុងទីនោះ ការតាំងកំណើតក្នុងភពថ្មីតទៅទៀត មានក្នុងទីណា ជាតិ ជរា មរណៈតទៅទៀត ក៏មានក្នុងទីនោះ ជាតិ ជរា មរណៈតទៅទៀត មានក្នុងទីណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទីនោះ ប្រកបដោយសោក ប្រកបដោយធុលីគឺកាមកិលេស ប្រកបដោយសេចក្តីចង្អៀតចង្អល់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ បើក្នុងផស្សាហារ ... ម្នាលភិក្ខុទាំងឡាយ បើក្នុងមនោសញ្ចេតនាហារ ... ម្នាលភិក្ខុទាំងឡាយ បើតម្រេក សេចក្តីរីករាយ បំណង់ មានក្នុងវិញ្ញាណាហារ វិញ្ញាណក៏លូតលាស់ តាំងនៅស៊ប់ក្នុងវិញ្ញាណាហារនោះ វិញ្ញាណលូតលាស់ តាំងនៅស៊ប់ក្នុងទីណា នាមរូបក៏ឈានចុះក្នុងទីនោះ នាមរូបឈានចុះក្នុងទីណា

អត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ យត្ថ អត្ថិ សង្ខារានំ វុឌ្ឍិ អត្ថិ តត្ថ អាយតឹ បុនព្ភវាភិនិព្វត្តិ យត្ថ អត្ថិ អាយតឹ បុនព្ភវាភិនិព្វត្តិ អត្ថិ តត្ថ អាយតឹ ជាតិជរាមរណំ យត្ថ អត្ថិ អាយតឹ ជាតិជរាមរណំ សសោកំ តំ ភិក្ខវេ សរជំ សឧបាយាសន្តិ វទាមិ ។

(២៤៨) កវឡីការេ ចេ ភិក្ខវេ អាហារេ នត្ថិ រាគោ នត្ថិ នន្ទិ នត្ថិ តណ្ហា អប្បតិដ្ឋិតំ តត្ថ វិញ្ញាណំ អវិរុឡ្ហំ យត្ថ អប្បតិដ្ឋិតំ វិញ្ញាណំ អវិរុឡ្ហំ នត្ថិ តត្ថ នាមរូបស្ស អវក្កន្តិ យត្ថ នត្ថិ នាមរូបស្ស អវក្កន្តិ នត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ យត្ថ នត្ថិ សង្ខារានំ វុឌ្ឍិ នត្ថិ តត្ថ អាយតឹ បុនព្ភវាភិនិព្វត្តិ យត្ថ នត្ថិ អាយតឹ បុនព្ភវាភិនិព្វត្តិ នត្ថិ តត្ថ អាយតឹ ជាតិជរ-

សង្ខារទាំងឡាយក៏ចម្រើនឡើងក្នុងទីនោះ សង្ខារទាំងឡាយចម្រើនឡើងក្នុងទីណា ការចាប់កំណើតក្នុងភពថ្មីតទៅទៀត ក៏មានក្នុងទីនោះ ការចាប់កំណើតក្នុងភពថ្មីតទៅទៀត មានក្នុងទីណា ជាតិ ជរា មរណៈតទៅទៀត ក៏មានក្នុងទីនោះ ជាតិ ជរា មរណៈតទៅទៀត មានក្នុងទីណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទីនោះ ប្រកបដោយសោក ប្រកបដោយធុលីគឺរាគាទិក្កិលេស ប្រកបដោយសេចក្តីចង្អៀតចង្អល់ចិត្ត ក៏ដូច្នោះដែរ ។

(២៤៨) ម្នាលភិក្ខុទាំងឡាយ បើតម្រេក សេចក្តីរីករាយ បំណង់ មិនមានក្នុងកវឡីការាហារទេ វិញ្ញាណក៏មិនលូតលាស់ មិនតាំងនៅស៊ប់ក្នុងកវឡីការាហារនោះដែរ វិញ្ញាណមិនលូតលាស់ មិនតាំងនៅស៊ប់ក្នុងទីណា នាមរូបក៏មិនឈានចុះក្នុងទីនោះ នាមរូបមិនឈានចុះក្នុងទីណា សង្ខារទាំងឡាយ ក៏មិនចម្រើនឡើងក្នុងទីនោះ សង្ខារទាំងឡាយ មិនចម្រើនឡើងក្នុងទីណា ការចាប់កំណើតក្នុងភពថ្មីតទៅទៀត ក៏មិនមានក្នុងទីនោះ ការចាប់កំណើតក្នុងភពថ្មីតទៅទៀត មិនមានក្នុងទីណា ជាតិ ជរា មរណៈតទៅទៀត ក៏មិនមានក្នុងទីនោះ

មរណំ យត្ថ នត្ថិ អាយតឹ ជាតិជរាមរណំ អសោកំ តំ ភិក្ខវេ អរជំ អនុបាយាសន្តិ វទាមិ ។ ផស្សេ ចេ ភិក្ខវេ អាហារេ ... មនោសញ្ចេតនាយ ចេ ភិក្ខវេ អាហារេ ... វិញ្ញាណេ ចេ ភិក្ខវេ អាហារេ នត្ថិ រាគោ នត្ថិ នន្ទិ នត្ថិ តណ្ហា អប្បតិដ្ឋិតំ តត្ថ វិញ្ញាណំ អវិរូឡ្ហំ យត្ថ អប្បតិដ្ឋិតំ វិញ្ញាណំ អវិរូឡ្ហំ នត្ថិ តត្ថ នាមរូបស្ស អវក្កន្តិ យត្ថ នត្ថិ នាមរូបស្ស អវក្កន្តិ នត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ យត្ថ នត្ថិ សង្ខារានំ វុឌ្ឍិ នត្ថិ តត្ថ អាយតឹ បុនព្ភវាភិនិព្វត្តិ យត្ថ នត្ថិ អាយតឹ បុនព្ភវាភិនិព្វត្តិ នត្ថិ តត្ថ អាយតឹ ជាតិជរាមរណំ យត្ថ នត្ថិ អាយតឹ ជាតិជរាមរណំ អសោកំ តំ ភិក្ខវេ អរជំ អនុបាយាសន្តិ វទាមិ ។

ជាតិ ជរា មរណៈតទៅទៀត មិនមានក្នុងទីណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទីនោះ មិនមានសោក មិនមានធុលីគឺរាគាទិក្កិលេស មិនមានសេចក្តីចង្អៀតចង្អល់ចិត្តទេ ។ ម្នាលភិក្ខុទាំងឡាយ បើក្នុងផស្សាហារ ... ម្នាលភិក្ខុទាំងឡាយ បើក្នុងមនោសញ្ចេតនាហារ ... ម្នាលភិក្ខុទាំងឡាយ បើតម្រេក សេចក្តីរីករាយ បំណង មិនមានក្នុងវិញ្ញាណាហារទេ វិញ្ញាណក៏មិនលូតលាស់ មិនតាំងនៅស៊ប់ក្នុងវិញ្ញា-ណាហារនោះដែរ វិញ្ញាណមិនលូតលាស់ មិនតាំងនៅស៊ប់ក្នុងទីណា នាមរូបក៏មិនឈានចុះក្នុងទីនោះ នាមរូបមិនឈានចុះក្នុងទីណា សង្ខារទាំងឡាយ ក៏មិនចម្រើនឡើងក្នុងទីនោះ សង្ខារទាំងឡាយមិនចម្រើនឡើងក្នុងទីណា ការចាប់កំណើតក្នុងភពថ្មីតទៅទៀត ក៏មិនមានក្នុងទីនោះ ការចាប់កំណើតក្នុងភពថ្មីតទៅទៀត មិនមានក្នុងទីណា ជាតិ ជរា មរណៈតទៅទៀត ក៏មិនមានក្នុងទីនោះ ជាតិ ជរា មរណៈតទៅទៀត មិនមានក្នុងទីណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទីនោះ មិនមានសោក មិនមានធុលីគឺរាគាទិក្កិលេស មិនមានសេចក្តីចង្អៀតចង្អល់ចិត្តឡើយ ។

(២៤៩) សេយ្យថាបិ ភិក្ខវេ កូដាគារំ វា កូដាគារសាលា វា ឧត្តរាយ វា ទក្ខិណាយ វា បាចីនវាតបានា សុរិយេ ឧគ្គច្ឆន្តេ វាតបានេន រស្មិ បវិសិត្វា ក្វាស្ស បតិដ្ឋិតាតិ ។ បច្ឆិមាយំ ភន្តេ ភិត្តិយន្តិ ។ បច្ឆិមា ចេ ភិក្ខវេ ភិត្តិ នាស្ស ក្វាស្ស បតិដ្ឋិតាតិ ។ បឋវិយំ ភន្តេតិ ។ បឋវី ចេ ភិក្ខវេ នាស្ស ក្វាស្ស បតិដ្ឋិតាតិ ។ អាបស្មឹ ភន្តេតិ ។ អាបោ ចេ ភិក្ខវេ នាស្ស ក្វាស្ស បតិដ្ឋិតាតិ ។ អប្បតិដ្ឋិតា ភន្តេតិ ។ ឯវមេវ ខោ ភិក្ខវេ កពឡីការេ ចេ អាហារេ នត្ថិ រាគោ នត្ថិ នន្ទី នត្ថិ តណ្ហា ... ផស្សេ ចេ ភិក្ខវេ អាហារេ... មនោសញ្ចេតនាយ ចេ ភិក្ខវេ អាហារេ... វិញ្ញាណេ ចេ ភិក្ខវេ អាហារេ នត្ថិ រាគោ នត្ថិ នន្ទី នត្ថិ តណ្ហា អប្បតិដ្ឋិតំ តត្ថ វិញ្ញាណំ អវិរូឡ្ហំ

អភិសមយសំយុត្ត មហាវគ្គ ឧបមាដោយផ្ទះឬសាលាមានកំពូល

(៤៤៩) ម្នាលភិក្ខុទាំងឡាយ ដូចជាផ្ទះមានកំពូល ឬសាលាមានកំពូល ក្នុងទិសខាងជើង ឬក្នុងទិសខាងត្បូង មានបង្អួចខាងកើត កាលបើព្រះអាទិត្យរះឡើង រស្មីរបស់ព្រះអាទិត្យនោះ ក៏ចូលតាមបង្អួច តើទៅតាំងនៅក្នុងទីណា ។ បពិត្រព្រះអង្គដ៏ចម្រើន តាំងនៅត្រង់ជញ្ជាំងទិសខាងលិច ។ ម្នាលភិក្ខុទាំងឡាយ បើជញ្ជាំងទិសខាងលិចមិនមានទេ តើរស្មីរបស់ព្រះអាទិត្យនោះ តាំងនៅក្នុងទីណា ។ បពិត្រព្រះអង្គដ៏ចម្រើន តាំងនៅលើផែនដី ។ ម្នាលភិក្ខុទាំងឡាយ បើផែនដីមិនមានទេ តើរស្មីរបស់ព្រះអាទិត្យនោះ តាំងនៅក្នុងទីណា ។ បពិត្រព្រះអង្គដ៏ចម្រើន លើទឹក ។ ម្នាលភិក្ខុទាំងឡាយ បើទឹកមិនមានទេ តើរស្មីរបស់ព្រះអាទិត្យនោះ តាំងនៅក្នុងទីណា ។ បពិត្រព្រះអង្គដ៏ចម្រើន មិនតាំងនៅទេ ។ ម្នាលភិក្ខុទាំងឡាយ ការនេះក៏យ៉ាងនោះដែរ បើតម្រេក សេចក្តីត្រេកអរ បំណង មិនមានក្នុងកវឡីការាហារទេ ... ម្នាលភិក្ខុទាំងឡាយ ក្នុងផស្សាហារទេ ... ម្នាលភិក្ខុទាំងឡាយ ក្នុងមនោសញ្ចេតនាហារទេ ... ម្នាលភិក្ខុទាំងឡាយ បើតម្រេក សេចក្តីត្រេកអរ បំណង មិនមានក្នុងវិញ្ញាណាហារទេ វិញ្ញាណក៏មិនលូតលាស់ មិនតាំងនៅស៊ប់ក្នុងវិញ្ញាណាហារនោះដែរ

យត្ថ អប្បតិដ្ឋិតំ វិញ្ញាណំ អវិរូឡ្ហំ នត្ថិ តត្ថ នាមរូបស្ស អវក្កន្តិ យត្ថ នត្ថិ នាមរូបស្ស អវក្កន្តិ នត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ យត្ថ នត្ថិ សង្ខារានំ វុឌ្ឍិ នត្ថិ តត្ថ អាយតឹ បុនព្ភវាភិនិព្វត្តិ យត្ថ នត្ថិ អាយតឹ បុនព្ភវាភិនិព្វត្តិ នត្ថិ តត្ថ អាយតឹ ជាតិជរាមរណំ យត្ថ នត្ថិ អាយតឹ ជាតិជរាមរណំ អសោកំ តំ ភិក្ខវេ អរជំ អនុបាយាសន្តិ វទាមីតិ ។ ចតុត្ថំ ។

[២៥០] សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... បុព្វេ មេ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ កិច្ឆំ វតាយំ លោកោ អាបន្នោ ជាយតិ ច ជិយ្យតិ ច មិយ្យតិ ច ចវតិ ច ឧបបជ្ជតិ ច អថ ច បនិមស្ស ទុក្ខស្ស និស្សរណំ នប្បជានាតិ ជរាមរណស្ស កុទាស្សុ នាម ឥមស្ស ទុក្ខស្ស និស្សរណំ បញ្ញាយិស្សតិ ជរាមរណស្សាតិ ។

វិញ្ញាណមិនលូតលាស់ មិនតាំងនៅស៊ប់ក្នុងទីណា នាមរូបក៏មិនឈានចុះក្នុងទីនោះ នាមរូបមិនឈានចុះក្នុងទីណា សង្ខារទាំងឡាយ ក៏មិនចម្រើនឡើងក្នុងទីនោះ សង្ខារទាំងឡាយ មិនចម្រើនឡើងក្នុងទីណា ការចាប់កំណើតក្នុងភពថ្មីតទៅទៀត ក៏មិនមានក្នុងទីនោះ ការចាប់កំណើតក្នុងភពថ្មីតទៅទៀត មិនមានក្នុងទីណា ជាតិ ជរា មរណៈ តទៅទៀត ក៏មិនមានក្នុងទីនោះ ជាតិ ជរា មរណៈ តទៅទៀត មិនមានក្នុងទីណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទីនោះ មិនមានសោក មិនមានធូលីគឺកាមកិលេស មិនមានសេចក្តីចង្អៀតចង្អល់ចិត្តឡើយ ។ ចប់សូត្រ ទី ៤ ។

[ ២៤០ ] ខ្ញុំគង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះ ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុនអំពីការត្រាស់ដឹង កាលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ សត្វលោកនេះ ដល់នូវសេចក្តីលំបាកណាស់ តែងកើត ចាស់ ស្លាប់ ច្យុត និងចាប់បដិសន្ធិ តែមិនដឹងច្បាស់នូវការរលាស់ចោលសេចក្តីទុក្ខ គឺជរាមរណៈនេះទៀតផង កាលណាហ្ន៎ ទើបការរលាស់ចោលនូវសេចក្តីទុក្ខ គឺជរាមរណៈនេះ នឹងប្រាកដឡើងបាន ។

[២៨១] តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិម្ហិ នុ ខោ សតិ ជរាមរណំ ហោតិ កឹបច្ចយា ជរាមរណន្តិ ។ តស្ស មយ្ហំ ភិក្ខវេ យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ជាតិយា ខោ សតិ ជរាមរណំ ហោតិ ជាតិបច្ចយា ជរាមរណន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិម្ហិ នុ ខោ សតិ ជាតិ ហោតិ ។បេ។ ភវោ ហោតិ ... ឧបាទានំ ហោតិ ... តណ្ហា ហោតិ ... វេទនា ហោតិ ... ផស្សោ ហោតិ ... សឡាយតនំ ហោតិ ... នាមរូបំ ហោតិ កឹបច្ចយា នាមរូបន្តិ ។ តស្ស មយ្ហំ ភិក្ខវេ យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ វិញ្ញាណេ ខោ សតិ នាមរូបំ ហោតិ វិញ្ញាណបច្ចយា នាមរូបន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិម្ហិ នុ ខោ សតិ វិញ្ញាណំ ហោតិ កឹបច្ចយា វិញ្ញាណន្តិ ។ តស្ស មយ្ហំ ភិក្ខវេ យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ

[២៨១] ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើមានអ្វីហ្ន៎ ទើបមានជរាមរណៈ ជរាមរណៈមានព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយបញ្ញា ព្រោះយោនិសោមនសិការៈថា កាលបើមានជាតិ ទើបមានជរាមរណៈ ជរានិងមរណៈមាន ព្រោះជាតិជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះ (តទៅទៀត) ថា កាលបើមានអ្វីហ្ន៎ ទើបមានជាតិ ។ បេ ។ ទើបមានភព ... ទើបមានឧបាទាន ... ទើបមានតណ្ហា ... ទើបមានវេទនា ... ទើបមានផស្សៈ ... ទើបមានសឡាយតនៈ ... ទើបមាននាមរូប នាមរូបមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយបញ្ញា ព្រោះយោនិសោមនសិការៈថា កាលបើមានវិញ្ញាណ ទើបមាននាមរូប នាមរូបមាន ព្រោះវិញ្ញាណជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើមានអ្វីហ្ន៎ ទើបមានវិញ្ញាណ វិញ្ញាណមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយបញ្ញា ព្រោះយោនិសោមនសិការៈថា

នាមរូបេ ខោ សតិ វិញ្ញាណំ ហោតិ នាមរូបប្បច្ចយា វិញ្ញាណន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ បច្ចុទាវត្តតិ ខោ ឥទំ វិញ្ញាណំ នាមរូបម្ហា ន បរំ គច្ឆតិ ឯត្តាវតា ជាយេថ វា ជិយ្យេថ វា មិយ្យេថ វា ចវេថ វា ឧបបជ្ជេថ វា យទិទំ នាមរូបប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ។បេ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ សមុទយោ សមុទយោតិ ខោ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

(២៤២) តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិម្ហិ នុ ខោ អសតិ ជរាមរណំ ន ហោតិ កិស្ស និរោធា ជរាមរណនិរោធោតិ ។ តស្ស មយ្ហំ ភិក្ខវេ

កាលបើមាននាមរូប ទើបមានវិញ្ញាណ វិញ្ញាណមាន ព្រោះនាមរូបជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា វិញ្ញាណនេះ តែងត្រឡប់មកអំពីនាមរូប មិនមែនទៅកាន់ទីដទៃទេ សត្វលោកកើតក្តី ចាស់ក្តី ស្លាប់ក្តី ច្យុតក្តី ចាប់បដិសន្ធិក្តី ដោយហេតុមានប្រមាណប៉ុណ្ណេះ គឺថា ព្រោះនាមរូបជាបច្ច័យ ទើបមានវិញ្ញាណ ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ព្រោះនាមរូបជាបច្ច័យ ទើបមានអាយតនៈ ៦ ព្រោះអាយតនៈ ៦ ជាបច្ច័យ ទើបមានផស្សៈ ។ បេ ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតឡើងហើយ មានញាណកើតឡើងហើយ មានបញ្ញាកើតឡើងហើយ មានវិជ្ជាកើតឡើងហើយ មានពន្លឺកើតឡើងហើយ ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានស្តាប់មកក្នុងកាលមុនថា ហេតុជាទីកើតទុក្ខ ហេតុជាទីកើតទុក្ខ ។

[ ២៤២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើមិនមានអ្វីហ្ន៎ ទើបមិនមានជរាមរណៈ ព្រោះតែអ្វីរលត់ ទើបជរាមរណៈរលត់ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ

យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ជាតិយា ខោ អសតិ ជរាមរណំ ន ហោតិ ជាតិនិរោធា ជរាមរណនិរោធោតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិម្ហិ នុ ខោ អសតិ ជាតិ ន ហោតិ ។ បេ ។ ភវោ ន ហោតិ ... ឧបាទានំ ន ហោតិ ... តណ្ហា ន ហោតិ ... វេទនា ន ហោតិ ... ផស្សោ ន ហោតិ ... សឡាយតនំ ន ហោតិ ... នាមរូបំ ន ហោតិ កិស្ស និរោធា នាមរូបនិរោធោតិ ។ តស្ស មយ្ហំ ភិក្ខវេ យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ វិញ្ញាណេ ខោ អសតិ នាមរូបំ ន ហោតិ វិញ្ញាណនិរោធា នាមរូបនិរោធោតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិម្ហិ នុ ខោ អសតិ វិញ្ញាណំ ន ហោតិ កិស្ស និរោធា វិញ្ញាណនិរោធោតិ ។ តស្ស មយ្ហំ ភិក្ខវេ យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ នាមរូបេ ខោ អសតិ វិញ្ញាណំ ន ហោតិ នាមរូបនិរោធា វិញ្ញាណនិរោធោតិ ។

ក៏បានត្រាស់ដឹងដោយបញ្ញា ព្រោះយោនិសោមនសិការៈថា កាលបើមិនមានជាតិ ទើបមិនមានជរាមរណៈ ព្រោះតែជាតិរលត់ ទើបជរាមរណៈរលត់ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើមិនមានអ្វីហ្ន៎ ទើបមិនមានជាតិ ។ បេ ។ ទើបមិនមានភព ... មិនមានឧបាទាន ... មិនមានតណ្ហា ... មិនមានវេទនា ... មិនមានផស្សៈ ... មិនមានសឡាយតនៈ ៦ ... មិនមាននាមរូប ព្រោះតែអ្វីរលត់ ទើបនាមរូបរលត់ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ បានត្រាស់ដឹងដោយបញ្ញា ព្រោះយោនិសោមនសិការៈថា កាលបើមិនមានវិញ្ញាណ ទើបមិនមាននាមរូប ព្រោះតែវិញ្ញាណរលត់ ទើបនាមរូបរលត់ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើមិនមានអ្វីហ្ន៎ ទើបមិនមានវិញ្ញាណ ព្រោះតែអ្វីរលត់ ទើបវិញ្ញាណរលត់ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ បានត្រាស់ដឹងដោយបញ្ញា ព្រោះយោនិសោមនសិការៈថា កាលបើមិនមាននាមរូប ទើបមិនមានវិញ្ញាណ ព្រោះតែនាមរូបរលត់ ទើបវិញ្ញាណរលត់ ។

តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ អធិគតោ ខោ ម្យាយំ មគ្គោ ពោធាយ យទិទំ នាមរូបនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ និរោធោ និរោធោតិ ខោ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

(២៨៣) សេយ្យថាបិ ភិក្ខវេ បុរិសោ អរញ្ញេ បវនេ ចរមានោ បស្សេយ្យ បុរាណមគ្គំ បុរាណញ្ជសំ បុព្វកេហិ មនុស្សេហិ អនុយាតំ ។ សោ តមនុគច្ឆេយ្យ តមនុគច្ឆន្តោ បស្សេយ្យ បុរាណំ នគរំ បុរាណំ រាជធានឹ បុព្វកេហិ មនុស្សេហិ អជ្ឈាវុដ្ឋំ អារាមសម្បន្នំ វនសម្បន្នំ បោក្ខរណីសម្បន្នំ ឧទ្ធាបវន្តំ រមណីយំ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ផ្លូវប្រព្រឹត្តទៅដើម្បីការត្រាស់ដឹងនេះ តថាគតបានត្រាស់ដឹងហើយ គឺថា ព្រោះតែនាមរូបរលត់ ទើបវិញ្ញាណរលត់ ព្រោះតែវិញ្ញាណរលត់ ទើបនាមរូបរលត់ ព្រោះតែនាមរូបរលត់ ទើបអាយតនៈ ៦ រលត់ ព្រោះតែអាយតនៈ ៦ រលត់ ទើបផស្សៈរលត់ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតឡើងហើយ មានញាណកើតឡើងហើយ មានបញ្ញាកើតឡើងហើយ មានវិជ្ជាកើតឡើងហើយ មានពន្លឺកើតឡើងហើយ ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានស្តាប់មកអំពីមុនថា ហេតុជាគ្រឿងរលត់ ហេតុជាគ្រឿងរលត់ ដូច្នេះ ។

(២៤៣) ម្នាលភិក្ខុទាំងឡាយ ដូចជាបុរស កាលដើរទៅក្នុងព្រៃតូច ព្រៃធំ ឃើញផ្លូវចាស់ ច្រកចាស់ ដែលពួកមនុស្សជាន់មុនតែងដើរទៅ ។ បុរសនោះ ដើរទៅតាមផ្លូវនោះ កាលដើរទៅតាមផ្លូវនោះ ក៏ប្រទះឃើញក្រុងបុរាណ រាជធានីបុរាណ ដែលពួកមនុស្សជាន់មុនបានទៅអាស្រ័យហើយ ជាកន្លែងបរិបូណ៌ដោយសួនច្បារ បរិបូណ៌ដោយព្រៃ បរិបូណ៌ដោយស្រះ មានកំពែង ជាទីគួរឲ្យត្រេកអរ ។

អថខោ សោ ភិក្ខវេ បុរិសោ រញ្ញោ វា រាជមហា-
មត្តស្ស វា អារោចេយ្យ យគ្ឃេ ភន្តេ ជានេយ្យាសិ
អហំ អទ្ទសំ អរញ្ញេ បវនេ ចរមានោ បុរាណមគ្គំ
បុរាណញ្ជសំ បុព្វកេហិ មនុស្សេហិ អនុយាតំ សោ(១)
តមនុគច្ឆឹ តមនុគច្ឆន្តោ អទ្ទសំ បុរាណំ នគរំ បុរាណំ
រាជធានឹ បុព្វកេហិ មនុស្សេហិ អជ្ឈាវុត្ថំ អារាម-
សម្បន្នំ វនសម្បន្នំ បោក្ខរណីសម្បន្នំ ឧទ្ធាបវន្តំ
រមណីយំ តំ ភន្តេ នគរំ មាបេហីតិ ។ អថខោ សោ
ភិក្ខវេ រាជា វា រាជមហាមត្តោ វា តំ នគរំ
មាបេយ្យ តទស្ស នគរំ អបរេន សមយេន ឥទ្ធំ
ចេវ ផីតំ ច ពហុជញ្ញំ(២) អាកិណ្ណមនុស្សំ វុឌ្ឍិវេ-
បុល្លប្បត្តំ ។ ឯវមេវ ខ្វាហំ ភិក្ខវេ អទ្ទសំ បុរាណមគ្គំ
បុរាណញ្ជសំ បុព្វកេហិ សម្មាសម្ពុទ្ធេហិ អនុយាតំ ។

---

១ កត្ថចិ អម្ហាកំ ពោត្ថកេ គត្តិ បាឋោ ទិស្សតិ ។ ២ ពហុជនត្តិ បាឋោ ។

ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ បុរសនោះក៏ក្រាបទូលដល់ព្រះរាជា ឬរាជមហាមាត្យថា សូមទ្រង់មេត្តាប្រោស សូមទ្រង់ជ្រាប ខ្ញុំព្រះអង្គត្រាច់ទៅក្នុងព្រៃតូច ព្រៃធំ បានឃើញផ្លូវចាស់ ផ្លាចាស់ ដែលពួកមនុស្ស ជាន់មុន ធ្លាប់ដើរទៅរឿយ ៗ ខ្ញុំព្រះអង្គបានដើរតាមផ្លូវនោះ កាលខ្ញុំព្រះអង្គដើរទៅតាមផ្លូវនោះ បានឃើញក្រុងបុរាណ រាជធានីបុរាណ ដែលមនុស្សទាំងឡាយជាន់ដើម ធ្លាប់នៅអាស្រ័យ ជាកន្លែងបរិបូណ៌ដោយសួនច្បារ បរិបូណ៌ដោយព្រៃ បរិបូណ៌ដោយស្រះ មានកំពែង ជាទីគួរឲ្យត្រេកអរ បពិត្រព្រះអង្គ សូមព្រះអង្គទ្រង់សាងទីក្រុងនោះឡើង ៗ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯងព្រះរាជា ឬរាជមហាមាត្យនោះ ក៏កសាងក្រុងនោះ លុះសម័យតមកក្រុងនោះ ក៏ស្តុកស្តម្ភ សម្បូរ មានរបស់ជាប្រយោជន៍ដល់ជនច្រើនកុះករដោយមនុស្ស ដានតរមានសេចក្តីចម្រើនទូលំទូលាយ ៗ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះក៏ដូច្នោះដែរ តថាគតបានឃើញផ្លូវចាស់ ផ្លាចាស់ ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយជាន់ដើម តែងត្រាច់ទៅ ៗ

កតមោ ច សោ ភិក្ខវេ បុរាណមគ្គោ បុរាណញ្ជសោ បុព្វកេហិ សម្មាសម្ពុទ្ធេហិ អនុយាតោ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ អយំ ខោ សោ ភិក្ខវេ បុរាណមគ្គោ បុរាណញ្ជសោ បុព្វកេហិ សម្មាសម្ពុទ្ធេហិ អនុយាតោ សោ តមនុគច្ឆិំ តមនុគច្ឆន្តោ ជរាមរណំ អព្ភញ្ញាសិំ ជរាមរណសមុទយំ អព្ភញ្ញាសិំ ជរាមរណនិរោធំ អព្ភញ្ញាសិំ ជរាមរណនិរោធគាមិនិំ បដិបទំ អព្ភញ្ញាសិំ តមនុគច្ឆិំ តមនុគច្ឆន្តោ ជាតិំ អព្ភញ្ញាសិំ ។បេ។ ភវំ អព្ភញ្ញាសិំ... ឧបាទានំ អព្ភញ្ញាសិំ... តណ្ហំ អព្ភញ្ញាសិំ... វេទនំ អព្ភញ្ញាសិំ... ផស្សំ អព្ភញ្ញាសិំ.. សឡាយតនំ អព្ភញ្ញាសិំ...នាមរូបំ អព្ភញ្ញាសិំ... វិញ្ញាណំ អព្ភញ្ញាសិំ តមនុគច្ឆិំ តមនុគច្ឆន្តោ សង្ខារេ អព្ភញ្ញាសិំ សង្ខារសមុទយំ អព្ភញ្ញាសិំ សង្ខារនិរោធំ អព្ភញ្ញាសិំ សង្ខារនិរោធគាមិនិំ បដិបទំ អព្ភញ្ញាសិំ តទភិញ្ញាយ

ម្នាលភិក្ខុទាំងឡាយ ផ្លូវចាស់ ច្រកចាស់ ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយ ជាន់ដើម តែងត្រាច់ទៅនោះ តើដូចម្តេច ។ ផ្លូវប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង គឺសេចក្តីយល់ឃើញត្រូវ ១ ។ បេ ។ ការតម្កល់ចិត្ត ត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ជាផ្លូវចាស់ ច្រកចាស់ ដែលព្រះ សម្មាសម្ពុទ្ធទាំងឡាយជាន់ដើម តែងត្រាច់ទៅ តថាគតនោះបានដើរទៅ តាមផ្លូវនោះ កាលដើរទៅតាមផ្លូវនោះ ក៏បានដឹងច្បាស់នូវជរានិងមរណៈ ដឹងច្បាស់នូវហេតុជាទីកើតនៃជរានិងមរណៈ ដឹងច្បាស់នូវទីរលត់នៃជរា និងមរណៈ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃជរានិង មរណៈ តថាគតបានដើរទៅតាមផ្លូវនោះ កាលដើរទៅតាមផ្លូវនោះ ក៏ បានស្គាល់ច្បាស់នូវជាតិ ។ បេ ។ បានស្គាល់ច្បាស់នូវភព ... បានស្គាល់ ច្បាស់នូវឧបាទាន ... បានស្គាល់ច្បាស់នូវតណ្ហា ... បានស្គាល់ច្បាស់ នូវវេទនា ... បានស្គាល់ច្បាស់នូវផស្សៈ ... បានស្គាល់ច្បាស់នូវសឡា-យតនៈ ... បានស្គាល់ច្បាស់នូវនាមរូប ... បានស្គាល់ច្បាស់នូវវិញ្ញាណ តថាគតបានដើរទៅតាមផ្លូវនោះ កាលដើរទៅតាមផ្លូវនោះ ក៏បានដឹង ច្បាស់នូវសង្ខារទាំងឡាយ បានដឹងច្បាស់នូវហេតុជាទីកើត នៃសង្ខារ បានដឹងច្បាស់នូវទីរលត់នៃសង្ខារ បានដឹងច្បាស់នូវបដិបទា ជាដំណើរ ទៅកាន់ទីរលត់នៃសង្ខារ លុះតថាគតបានដឹងច្បាស់ នូវធម៌នោះហើយ

អាចិក្ខី ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកា-នំ ។ តយិទំ ភិក្ខវេ ព្រហ្មចរិយំ ឥទ្ធំ ចេវ ផីតំ ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតន្តិ ។ បឋមំ ។

(២៥២) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសទម្មំ នាម កុរូនំ និគមោ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សម្មសថ នោ តុម្ហេ ភិក្ខវេ អន្តរំ សម្ម-សន្តិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច អហំ ខោ ភន្តេ សម្មសាមិ អន្តរំ សម្មសន្តិ ។

ក៏បានប្រាប់ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនោះឯង ស្កុកស្គម្ភ សម្បូរ ទូលាយ សម្រាប់ជនច្រើនគ្នាបេះដឹង ជាព្រហ្មចរិយៈក្រាស់ក្រែល ដែលព្រះពុទ្ធទាំងឡាយប្រកាសដោយប្រពៃ ដល់ពួកទេវតា និងមនុស្ស ជាកំណត់ ។

ចប់សូត្រ ទី ៨ ។

( ២៨៤ ) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកម្មាសទម្មនិគម របស់ពួកអ្នកកុរុ ក្នុងដែនកុរុ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ពិចារណានូវធម៌ជាគ្រឿងពិចារណាខាងក្នុង ដែរឬទេ ។ កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះ ភិក្ខុមួយរូប បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គតែងពិចារណានូវធម៌ជាគ្រឿងពិចារណាខាងក្នុងដែរ ។

យថាកថំ បន ត្វំ ភិក្ខុ សម្មសសិ អន្តរំ សម្មសន្តិ ។ អថខោ សោ ភិក្ខុ ព្យាកាសិ យថា សោ ភិក្ខុ ព្យាកាសិ ន សោ ភិក្ខុ ភគវតោ ចិត្តំ អារាធេសិ ។

[២៥៥] ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា អន្តរំ សម្មសំ ភាសេយ្យ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហានន្ទ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

ម្នាលភិក្ខុ អ្នកពិចារណានូវធម៌ជាគ្រឿងពិចារណាខាងក្នុង តើដូចម្តេចខ្លះ ។ ភិក្ខុនោះ ក៏បានដោះស្រាយភ្លាម តែភិក្ខុនោះដោះស្រាយយ៉ាងណា ភិក្ខុនោះ ក៏មិនញុំាងព្រះហឫទ័យ របស់ព្រះមានព្រះភាគឲ្យត្រេកអរយ៉ាងនោះបានឡើយ ។

[២៤៤] កាលបើភិក្ខុនោះក្រាបទូលយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា ព្រះមានព្រះភាគ គួរសំដែងនូវធម៌ជាគ្រឿងពិចារណាខាងក្នុងណា បពិត្រព្រះមានព្រះភាគ កាលនេះ ជាកាលគួរដល់ការសំដែងនូវធម៌ជាគ្រឿងពិចារណាខាងក្នុងនុ៎ះហើយ បពិត្រព្រះសុគត កាលនេះ ជាកាលគួរដល់ការសំដែងនូវធម៌ជាគ្រឿងពិចារណាខាងក្នុងនុ៎ះហើយ ភិក្ខុទាំងឡាយ បានស្តាប់ព្រះមានព្រះភាគហើយ នឹងចងចាំទុក ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ បើដូច្នេះ ចូរអ្នកទាំងឡាយ ស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៤៨៦] ភគវា ឯតទវោច ឥធ ភិក្ខវេ ភិក្ខុ សម្មសមានោ សម្មសតិ អន្តរំ សម្មសំ យំ ខោ ឥទំ អនេកវិធំ នានប្បការកំ ទុក្ខំ លោកេ ឧប្បជ្ជតិ ជរាមរណំ ឥទំ នុ ខោ(១) ទុក្ខំ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវំ កិស្មឹ សតិ ជរាមរណំ ហោតិ កិស្មឹ អសតិ ជរាមរណំ ន ហោតីតិ ។ សោ សម្មសមានោ ឯវំ ជានាតិ យំ ខោ ឥទំ អនេកវិធំ នានប្បការកំ ទុក្ខំ លោកេ ឧប្បជ្ជតិ ជរាមរណំ ឥទំ ខោ ទុក្ខំ ឧបធិនិទានំ ឧបធិសមុទយំ ឧបធិជាតិកំ ឧបធិបភវំ ឧបធិស្មឹ សតិ ជរាមរណំ ហោតិ ឧបធិស្មឹ អសតិ ជរាមរណំ ន ហោតីតិ ។ សោ ជរាមរណញ្ច បជានាតិ ជរាមរណសមុទយញ្ច បជានាតិ ជរាមរណនិរោធញ្ច បជានាតិ យា ច ជរាមរណនិរោធសារុប្បគាមិនី បដិបទា តញ្ច បជានាតិ

---

១ ឱ.ម. ឥទំ ខោ ។

[ ២៨៦ ] ព្រះមានព្រះភាគ បានត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលពិចារណាធម៌ ជាគ្រឿងពិចារណាខាងក្នុង រមែងពិចារណាថា ទុក្ខគឺជរានិងមរណៈនេះ មានប្រការច្រើន មានប្រការផ្សេង ៗ តែងកើតឡើងក្នុងលោក ទុក្ខនេះ មានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាប្រភព កាលបើមានអ្វី ទើបមានជរានិងមរណៈ កាលបើគ្មានអ្វី ទើបគ្មានជរានិងមរណៈ ។ កាលភិក្ខុនោះពិចារណា ក៏រមែងដឹងយ៉ាងនេះថា ទុក្ខគឺជរានិងមរណៈនេះ មានប្រការច្រើន មានប្រការផ្សេង ៗ តែងកើតឡើងក្នុងលោក ទុក្ខនេះឯង មានឧបធិជាហេតុ[១] មានឧបធិជាទីកើត មានឧបធិជាកំណើត មានឧបធិជាប្រភព កាលបើមានឧបធិ ទើបមានជរានិងមរណៈ កាលបើឧបធិមិនមាន ជរានិងមរណៈក៏មិនមាន ។ ភិក្ខុនោះ រមែងដឹងច្បាស់នូវជរានិងមរណៈផង ដឹងច្បាស់នូវហេតុជាទីកើតនៃជរានិងមរណៈផង ដឹងច្បាស់នូវទីរលត់ជរានិងមរណៈផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅដ៏សមគួរដល់ការរលត់ នៃជរានិងមរណៈនោះផង

---

១ សំដៅយកឧបធិគឺខន្ធ ៥ ។

តថា បដិបន្នោ ច ហោតិ អនុធម្មចារី ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សព្វសោ សម្មា ទុក្ខក្ខយាយ បដិបន្នោ ជរាមរណនិរោធាយ ។

[២៤៧] អថាបរំ សម្មសមានោ សម្មសតិ អន្តរំ សម្មសំ ឧបធិ បនាយំ កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោ កិស្មឹ សតិ ឧបធិ ហោតិ កិស្មឹ អសតិ ឧបធិ ន ហោតីតិ ។ សោ សម្មសមានោ ឯវំ ជានាតិ ឧបធិ តណ្ហានិទានោ តណ្ហាសមុទយោ តណ្ហាជាតិកោ តណ្ហាបភវោ តណ្ហាយ សតិ ឧបធិ ហោតិ តណ្ហាយ អសតិ ឧបធិ ន ហោតីតិ ។ សោ ឧបធិញ្ច បជានាតិ ឧបធិសមុទយញ្ច បជានាតិ ឧបធិនិរោធញ្ច បជានាតិ យា ច ឧបធិនិរោធសារុប្បគាមិនី បដិបទា តញ្ច បជានាតិ តថា បដិបន្នោ ច ហោតិ អនុធម្មចារី ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សព្វសោ សម្មា ទុក្ខក្ខយាយ បដិបន្នោ ឧបធិនិរោធាយ ។

ជាអ្នកប្រតិបត្តិយ៉ាងនោះ ប្រព្រឹត្តធម៌សមគួរតាមធម៌ផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតពោលថា ជាអ្នកប្រតិបត្តិ ដើម្បីការអស់នៃទុក្ខដោយប្រពៃ ដើម្បីការរលត់នៃជរាមរណៈ ដោយប្រការទាំងពួង ។

[ ២៨៧ ] ប្រការមួយទៀត កាលភិក្ខុនឹងពិចារណាធម៌ជាគ្រឿងពិចារណាខាងក្នុងតទៅទៀត ក៏រមែងពិចារណាថា ទុក្ខនេះសោត មានឧបធិជាហេតុ មានឧបធិជាទីកើត មានឧបធិជាកំណើត មានឧបធិជាប្រភព កាលបើមានឧបធិ ទើបមានទុក្ខ កាលបើគ្មានឧបធិ ទើបគ្មានទុក្ខ ។ កាលភិក្ខុនោះពិចារណា ក៏រមែងដឹងយ៉ាងនេះថា ឧបធិ មានតណ្ហាជាហេតុ មានតណ្ហាជាទីកើត មានតណ្ហាជាកំណើត មានតណ្ហាជាប្រភព កាលបើមានតណ្ហា ទើបមានឧបធិ កាលបើគ្មានតណ្ហា ទើបគ្មានឧបធិ ។ ភិក្ខុនោះ ក៏រមែងដឹងច្បាស់នូវឧបធិផង ដឹងច្បាស់នូវទីកើតនៃឧបធិផង ដឹងច្បាស់នូវទីរលត់នៃឧបធិផង ដឹងច្បាស់នូវបដិបទា ជាដំណើរដ៏សមគួរដល់ការរលត់ឧបធិនោះផង ជាអ្នកប្រតិបត្តិយ៉ាងនោះ ប្រព្រឹត្តធម៌សមគួរតាមធម៌ផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា ជាអ្នកប្រតិបត្តិ ដើម្បីការអស់នៃទុក្ខដោយប្រពៃ ដើម្បីការរលត់នៃឧបធិ ដោយប្រការទាំងពួង ។

[២៤៨] អថាបរំ សមុទយមានោ សមុទយតិ អត្ថំ សមុទយំ តណ្ហា បនាយំ កត្ថ ឧប្បជ្ជមានា ឧប្បជ្ជតិ កត្ថ និវិសមានា និវិសតិ ។ សោ សមុទយមានោ ឯវំ ជានាតិ យំ ខោ លោកេ(១) បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ កិញ្ច លោកេ បិយរូបំ សាតរូបំ ។ ចក្ខុំ លោកេ បិយរូបំ សាតរូបំ ។ បេ ។ សោតំ លោកេ បិយរូបំ សាតរូបំ... ឃានំ លោកេ បិយរូបំ សាតរូបំ... ជិវ្ហា លោកេ បិយរូបំ សាតរូបំ... កាយោ លោកេ បិយរូបំ សាតរូបំ... មនោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។

---

១ យំ ខោ កិញ្ចិ លោកេតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

[២៥៨] ប្រការមួយទៀត កាលភិក្ខុពិចារណាទូវធម៌ជាគ្រឿងពិចារណាខាងក្នុង រមែងពិចារណាថា តណ្ហានេះ កាលដែលកើតឡើង តើកើតឡើងក្នុងទីណា កាលដែលតាំងនៅ តើតាំងនៅក្នុងទីណា ។ កាលភិក្ខុនោះ ពិចារណានៅ ក៏រមែងដឹងយ៉ាងនេះថា អារម្មណ៍ណាក្នុងលោក ដែលជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង តែងកើតឡើងក្នុងអារម្មណ៍នុ៎ះ កាលដែលតាំងនៅ តែងតាំងនៅក្នុងអារម្មណ៍នុ៎ះ ។ តើអារម្មណ៍អ្វីហ្ន៎ ដែលជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ។ ចក្ខុជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ។ បេ ។ សោតៈជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ... ឃានៈជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ... ជិវ្ហាជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ... កាយជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ... ចិត្តជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងអារម្មណ៍នុ៎ះ កាលដែលតាំងនៅ ក៏តាំងនៅក្នុងអារម្មណ៍នុ៎ះ ។

(២៨៩) យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា យំ លោកេ បិយរូបំ សាតរូបំ តំ និច្ចតោ អទ្ទក្ខុំ សុខតោ អទ្ទក្ខុំ អត្តតោ អទ្ទក្ខុំ អារោគ្យតោ អទ្ទក្ខុំ ខេមតោ អទ្ទក្ខុំ តេ តណ្ហំ វឌ្ឍេសុំ ។ យេ តណ្ហំ វឌ្ឍេសុំ តេ ឧបធឹ វឌ្ឍេសុំ យេ ឧបធឹ វឌ្ឍេសុំ តេ ទុក្ខំ វឌ្ឍេសុំ យេ ទុក្ខំ វឌ្ឍេសុំ តេ ន បរិមុច្ចឹសុ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចឹសុ ទុក្ខស្មាតិ វទាមិ ។

[ ២៨៩ ] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណានីមួយ ក្នុងកាលដែលកន្លងទៅហើយ បានឃើញនូវអារម្មណ៍ ដែលជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ថាទៀង បានឃើញថាជាសុខ បានឃើញថាជារបស់ខ្លួន បានឃើញថាជារបស់គ្មានរោគ បានឃើញថាជារបស់ក្សេមក្សាន្ត សមណៈឬព្រាហ្មណ៍ទាំងអម្បាលនោះ ឈ្មោះថាញ៉ាំងតណ្ហាឲ្យចម្រើនឡើង ។ ពួកសមណៈឬព្រាហ្មណ៍ណា ញ៉ាំងតណ្ហាឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាញ៉ាំងឧបធិឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍ណា ញ៉ាំងឧបធិឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាញ៉ាំងទុក្ខឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍ណា ញ៉ាំងទុក្ខឲ្យចម្រើនឡើង តថាគតពោលថា ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាមិនរួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត មិនរួចចាកទុក្ខឡើយ ។

យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា យំ លោកេ បិយរូបំ សាតរូបំ តំ និច្ចតោ ទក្ខិស្សន្តិ(១) សុខតោ ទក្ខិស្សន្តិ អត្តតោ ទក្ខិស្សន្តិ អារោគ្យតោ ទក្ខិស្សន្តិ ខេមតោ ទក្ខិស្សន្តិ តេ តណ្ហំ វឌ្ឍេស្សន្តិ ។ យេ តណ្ហំ វឌ្ឍេស្សន្តិ តេ ឧបធឹ វឌ្ឍេស្សន្តិ យេ ឧបធឹ វឌ្ឍេស្សន្តិ តេ ទុក្ខំ វឌ្ឍេស្សន្តិ យេ ទុក្ខំ វឌ្ឍេស្សន្តិ តេ ន បរិមុច្ចិស្សន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចិស្សន្តិ ទុក្ខស្មាតិ វទាមិ ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា យំ លោកេ បិយរូបំ សាតរូបំ តំ និច្ចតោ បស្សន្តិ សុខតោ បស្សន្តិ

---

១ ម. ទក្ខិន្តិ ។

ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលជាអនាគត នឹងឃើញនូវអារម្មណ៍ដែលជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោកនេះ ថាទៀង នឹងឃើញថាជាសុខ នឹងឃើញថាជារបស់ខ្លួន នឹងឃើញថាជារបស់គ្មានរោគ នឹងឃើញថាជារបស់ក្សេមក្សាន្ត ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថានឹងញុំាងតណ្ហាឲ្យចម្រើនឡើង ។ ពួកសមណៈឬព្រាហ្មណ៍ណា នឹងញុំាងតណ្ហាឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថានឹងញុំាងឧបធិឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍ណា នឹងញុំាងឧបធិឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថានឹងញុំាងទុក្ខឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍ណា នឹងញុំាងទុក្ខឲ្យចម្រើនឡើង តថាគតពោលថា ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថានឹងមិនរួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងមិនរួចចាកទុក្ខឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលឥឡូវនេះ ឃើញនូវអារម្មណ៍ដែលជាសភាពគួរស្រ-ឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ថាទៀង ឃើញថាជាសុខ

អនត្តតោ បស្សន្តិ អារោគ្យតោ បស្សន្តិ ខេមតោ បស្សន្តិ តេ តណ្ហំ វឌ្ឍេន្តិ ។ យេ តណ្ហំ វឌ្ឍេន្តិ តេ ឧបធឹ វឌ្ឍេន្តិ យេ ឧបធឹ វឌ្ឍេន្តិ តេ ទុក្ខំ វឌ្ឍេន្តិ យេ ទុក្ខំ វឌ្ឍេន្តិ តេ ន បរិមុច្ចន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។

(២៦០) សេយ្យថាបិ ភិក្ខវេ អាបានីយកំសោ វណ្ណសម្បន្នោ គន្ធសម្បន្នោ រសសម្បន្នោ ។ សោ ច ខោ វិសេន សំសដ្ឋោ ។ អថ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបា-សិតោ ។ តមេនំ ឯវំ វទេយ្យុំ អយំ តេ អម្ភោ បុរិស អាបានីយកំសោ វណ្ណសម្បន្នោ គន្ធសម្បន្នោ រស-

ឃើញថាជារបស់ខ្លួន ឃើញថាជារបស់គ្មានរោគ ឃើញថាជារបស់ក្សេមក្សាន្ត ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាញុំាងតណ្ហាឲ្យចម្រើនឡើង ។ ពួកសមណៈ ឬព្រាហ្មណ៍ណា ញុំាងតណ្ហាឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាញុំាងឧបធិឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍ណា ញុំាងឧបធិឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាញុំាងទុក្ខឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍ណា ញុំាងទុក្ខឲ្យចម្រើនឡើង តថាគតពោលថា ពួកសមណៈ ឬព្រាហ្មណ៍នោះ ឈ្មោះថាមិនរួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត មិនរួចចាកទុក្ខឡើយ ។

[៦៦០] ម្នាលភិក្ខុទាំងឡាយ ដូចជាផ្តិលដែលពេញដោយសុរា បរិបូណ៌ដោយពណ៌ បរិបូណ៌ដោយក្លិន បរិបូណ៌ដោយរស ។ តែផ្តិលនោះ គេលាយដោយថ្នាំពិស ។ ចួនជាមានបុរសក្តៅក្រហាយដោយកំដៅថ្ងៃ ត្រូវកំដៅថ្ងៃបៀតបៀនហើយ មានកាយលំបាក ក្រហល់ក្រហាយ ស្រេកឃ្លាន មកដល់ ។ មនុស្សទាំងឡាយ និយាយនឹងបុរសនោះឯង យ៉ាងនេះថា នែបុរសដ៏ចម្រើន ផ្តិលពេញដោយសុរានេះ បរិបូណ៌ដោយពណ៌ បរិបូណ៌ដោយក្លិន បរិបូណ៌ដោយរស

សម្បន្នោ សោ ច ខោ វិសេន សំសដ្ឋោ សចេ អាកង្ខសិ បិវ បិវតោ ហិ ខោ តំ ឆាទេស្សតិ វណ្ណេនបិ គន្ធេនបិ រសេនបិ បិវិត្វា ច បន តតោនិទានំ មរណំ វា និគច្ឆសិ មរណមត្តំ វា ទុក្ខន្តិ ។ សោ តំ អាបានីយកំសំ សហសា អប្បដិសង្ខា បិវេយ្យ នប្បដិនិស្សជ្ជេយ្យ ។ សោ តតោនិទានំ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ។ ឯវមេវ ខោ ភិក្ខវេ យេ ហិ កេចិ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា យំ លោកេ បិយរូបំ សាតរូបំ ។ បេ ។ អនាគតមទ្ធានំ ។ បេ ។ ឯតរហិ សមណា វា ព្រាហ្មណា វា យំ លោកេ បិយរូបំ សាតរូបំ តំ

តែផ្តិលនោះ គេលាយដោយថ្នាំពិស បើអ្នកប្រាថ្នា ចូរអ្នកផឹកចុះ ព្រោះថា កាលបើអ្នកផឹកទៅហើយ ទឹកនោះនឹងគាប់ចិត្តអ្នក ដោយពណ៌ផង ដោយក្លិនផង ដោយរសផង ប៉ុន្តែបើអ្នកផឹកទៅហើយ អ្នកនឹងដល់នូវសេចក្តីស្លាប់ ឬនឹងដល់នូវសេចក្តីទុក្ខស្មើរស្លាប់ ព្រោះតែការផឹកនោះជាហេតុ ៗ បុរសនោះ មិនបានពិចារណាផ្តិលដ៏ពេញដោយសុរានោះហើយ ក៏ផឹកដោយរួសរាន់ មិនលះបង់ចោល ៗ បុរសនោះគប្បីដល់នូវសេចក្តីស្លាប់ ឬដល់នូវទុក្ខស្មើរស្លាប់ ព្រោះតែការផឹកនោះជាហេតុ ៗ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមេយ្យក៏ដូច្នោះដែរ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលដែលកន្លងទៅហើយ បានឃើញនូវអារម្មណ៍ណា ជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ៗ បេ ៗ ក្នុងកាលជាអនាគត ៗ បេ ៗ ពួកសមណៈឬព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ ឃើញនូវអារម្មណ៍ដែលជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក

និច្ចតោ បស្សន្តិ សុខតោ បស្សន្តិ អត្តតោ បស្សន្តិ អារោគ្យតោ បស្សន្តិ ខេមតោ បស្សន្តិ តេ តណ្ហំ វឌ្ឍេន្តិ ។ យេ តណ្ហំ វឌ្ឍេន្តិ តេ ឧបធឹ វឌ្ឍេន្តិ យេ ឧបធឹ វឌ្ឍេន្តិ តេ ទុក្ខំ វឌ្ឍេន្តិ យេ ទុក្ខំ វឌ្ឍេន្តិ តេ ន បរិមុច្ចន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។

(២៦៣) យេ ច ខោ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា យំ លោកេ បិយរូបំ សាតរូបំ តំ អនិច្ចតោ អទ្ទក្ខុំ ទុក្ខតោ អទ្ទក្ខុំ អនត្ត-តោ អទ្ទក្ខុំ រោគតោ អទ្ទក្ខុំ ភយតោ អទ្ទក្ខុំ តេ

ថាទៀត ឃើញថាជាសុខ ឃើញថាជារបស់ខ្លួន ឃើញថាជារបស់គ្មានរោគ ឃើញថាជារបស់ក្សេមក្សាន្ត ពួកសមណៈឬព្រាហ្មណ៍ទាំងនោះឈ្មោះថាញ៉ាំងតណ្ហាឲ្យចម្រើនឡើង ។ ពួកសមណៈឬព្រាហ្មណ៍ណាញ៉ាំងតណ្ហាឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាញ៉ាំងឧបធិឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍ណា ញ៉ាំងឧបធិឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍នោះ ឈ្មោះថាញ៉ាំងទុក្ខឲ្យចម្រើនឡើង ពួកសមណៈឬព្រាហ្មណ៍ណា ញ៉ាំងទុក្ខឲ្យចម្រើនឡើង តថាគតពោលថា ពួកសមណៈឬព្រាហ្មណ៍នោះ មិនរួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត មិនរួចចាកទុក្ខឡើយ ។

(២៦១) ម្នាលភិក្ខុទាំងឡាយ ចំណែកពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលដែលកន្លងទៅ បានឃើញនូវអារម្មណ៍ ដែលជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ថាមិនទៀងបានឃើញថាជាទុក្ខ បានឃើញថាមិនមែនជារបស់ខ្លួន បានឃើញថាជារបស់មានរោគ បានឃើញថាគួរខ្លាច ពួកសមណៈឬព្រាហ្មណ៍នោះ

តណ្ហំ បជហឹសុ ។ យេ តណ្ហំ បជហឹសុ តេ ឧបធឹ បជហឹសុ យេ ឧបធឹ បជហឹសុ តេ ទុក្ខំ បជហឹសុ យេ ទុក្ខំ បជហឹសុ តេ បរិមុច្ចឹសុ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចឹសុ ទុក្ខស្មាតិ វទាមិ ។ យេបិ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា យំ លោកេ បិយរូបំ សាតរូបំ តំ អនិច្ចតោ ទក្ខិស្សន្តិ ទុក្ខតោ ទក្ខិស្សន្តិ អនត្តតោ ទក្ខិស្សន្តិ រោគតោ ទក្ខិស្សន្តិ ភយតោ ទក្ខិស្សន្តិ តេ តណ្ហំ បជហិស្សន្តិ ។ យេ តណ្ហំ បជហិស្សន្តិ ។ បេ ។ តេ បរិមុច្ចិស្សន្តិ ទុក្ខស្មាតិ វទាមិ ។ យេបិ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា យំ លោកេ បិយរូបំ សាតរូបំ តំ អនិច្ចតោ បស្សន្តិ

លះតណ្ហាបាន ៗ ពួកសមណៈឬព្រាហ្មណ៍ណា លះតណ្ហាបានហើយ ពួកសមណៈឬព្រាហ្មណ៍នោះ លះឧបធិបាន ពួកសមណៈឬព្រាហ្មណ៍ណា លះឧបធិបានហើយ ពួកសមណៈឬព្រាហ្មណ៍នោះ លះទុក្ខបាន ពួកសមណៈឬព្រាហ្មណ៍ណា លះទុក្ខបានហើយ តថាគតពោលថា ពួកសមណៈឬព្រាហ្មណ៍នោះ បានរួចចាកជាតិ ជរា មរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ សេចក្ដីលំបាកចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត រួចចាកទុក្ខហើយ ៗ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលជាអនាគត នឹងឃើញអារម្មណ៍ ដែលជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ថាមិនទៀង នឹងឃើញថាជាទុក្ខ នឹងឃើញថាមិនមែនរបស់ខ្លួន នឹងឃើញថាមានរោគ នឹងឃើញថាគួរខ្លាច ពួកសមណៈឬព្រាហ្មណ៍នោះ នឹងលះតណ្ហាបាន ៗ ពួកសមណៈឬព្រាហ្មណ៍ណា នឹងលះតណ្ហាបាន ៗ បេ ៗ តថាគតពោលថា ពួកសមណៈឬព្រាហ្មណ៍នោះ នឹងរួចចាកទុក្ខបាន ៗ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលឥឡូវនេះ ឃើញអារម្មណ៍ ដែលជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ថាមិនទៀង

ទុក្ខតោ បស្សន្តិ អនត្តតោ បស្សន្តិ រោគតោ បស្សន្តិ ភយតោ បស្សន្តិ តេ តណ្ហំ បជហន្តិ ។ យេ តណ្ហំ បជហន្តិ តេ ឧបធឹ បជហន្តិ យេ ឧបធឹ បជហន្តិ តេ ទុក្ខំ បជហន្តិ យេ ទុក្ខំ បជហន្តិ តេ បរិមុច្ចន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។

(៤៦៤) សេយ្យថាបិ ភិក្ខវេ អាបានីយកំ-សោ វណ្ណសម្បន្នោ គន្ធសម្បន្នោ រសសម្បន្នោ ។ សោ ច ខោ វិសេន សំសដ្ឋោ ។ អថ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ

ឃើញថាជាទុក្ខ ឃើញថាមិនមែនជារបស់ខ្លួន ឃើញថាជារបស់មានរោគ ឃើញថាគួរខ្លាច ពួកសមណៈឬព្រាហ្មណ៍នោះ រមែងលះតណ្ហាបាន ។ ពួកសមណៈឬព្រាហ្មណ៍ណា លះតណ្ហាបាន ពួកសមណៈឬព្រាហ្មណ៍នោះ រមែងលះឧបធិបាន ពួកសមណៈឬព្រាហ្មណ៍ណា លះឧបធិបាន ពួកសមណៈឬព្រាហ្មណ៍នោះ រមែងលះទុក្ខបាន ពួកសមណៈឬព្រាហ្មណ៍ណា លះទុក្ខបាន តថាគតពោលថា ពួកសមណៈឬព្រាហ្មណ៍នោះ រមែងរួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត រមែងរួចចាកទុក្ខបាន ។

(៤៦៤) ម្នាលភិក្ខុទាំងឡាយ ដូចជាផ្តិលដែលពេញដោយសុរា បរិបូណ៌ដោយពណ៌ បរិបូណ៌ដោយក្លិន បរិបូណ៌ដោយរស ។ តែផ្តិលនោះឯង គេលាយដោយថ្នាំពិស ។ ជួនជាមានបុរស ក្តៅក្រហាយដោយកំដៅថ្ងៃ ត្រូវកំដៅថ្ងៃបៀតបៀនហើយ មានកាយលំបាក

តសិតោ បិបាសិតោ ។ តមេនំ ឯវំ វទេយ្យុំ អយំ តេ អម្ភោ បុរិស អាបានីយកំសោ វណ្ណសម្បន្នោ គន្ធសម្បន្នោ រសសម្បន្នោ សោ ច ខោ វិសេន សំ-សដ្ឋោ សចេ អាកង្ខសិ បិវ បិវតោ ហិ ខោ តំ ឆាទេស្សតិ វណ្ណេនបិ គន្ធេនបិ រសេនបិ បិវិត្វា ច បន តតោនិទានំ មរណំ វា និគច្ឆសិ មរណមត្តំ វា ទុក្ខន្តិ ។ អថខោ ភិក្ខវេ តស្ស បុរិសស្ស ឯវមស្ស សក្កា ខោ មេ អយំ សុរា បិបាសិតា បានីយេន វា វិនេតុំ ទធិមណ្ឌកេន វា វិនេតុំ ភដ្ឋលោ-ណិកាយ វា វិនេតុំ លោណសោចីរកេន(១) វា វិនេតុំ ន ត្វេវ តំ បិវេយ្យំ យំ មម អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ សោ តំ អាបានីយកំសំ បដិសង្ខា ន បិវេយ្យ បដិនិស្សជ្ជេយ្យ ។ សោ តតោនិទានំ មរណំ វា ន និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ។

---

១ ឱ.ម. លោណសោវីរកេន ។

ក្រហល់ក្រហាយ ស្រេកឃ្លាន មកដល់ ។ មនុស្សទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ផ្តិលពេញដោយសុរានេះ បរិបូណ៌ដោយពណ៌ បរិបូណ៌ដោយក្លិន បរិបូណ៌ដោយរស (សមគួរ) ដល់អ្នក តែផ្តិលនោះ គេលាយដោយថ្នាំពិស បើអ្នកចង់ ក៏ចូរផឹកចុះ ព្រោះថាកាលបើអ្នកផឹកហើយ ទឹកនោះនឹងគាប់ចិត្តអ្នក ដោយពណ៌ផង ដោយក្លិនផង ដោយរសផង តែបើអ្នកផឹកទៅហើយ មុខជានឹងដល់នូវសេចក្តីស្លាប់ ឬនឹងដល់នូវទុក្ខស្មើស្លាប់ ព្រោះតែការផឹកនោះជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះ បុរសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា សុរាដែលអាត្មាអញស្រេកហើយនេះ អាចបន្ទោបង់ដោយទឹកត្រជាក់ក៏បាន បន្ទោបង់ដោយទធិថ្លាក៏បាន បន្ទោបង់ដោយទឹកសត្តូវដែលលាយដោយអំបិលក៏បាន បន្ទោបង់ដោយថ្នាំត្រាំឈ្មោះថា លោណសោបិរកៈ[១]ក៏បាន អាត្មាអញ មិនត្រូវផឹកសុរា ដែលប្រព្រឹត្តទៅដើម្បីមិនមែនជាគុណ ដើម្បីទុក្ខអស់កាលដ៏យូរ ដល់អាត្មាអញនោះទេ ។ បុរសនោះ ក៏គប្បីពិចារណានូវផ្តិល ដែលពេញដោយសុរានោះហើយ ក៏មិនបានផឹក លះបង់ចោលចេញ ។ បុរសនោះក៏មិនដល់នូវសេចក្តីស្លាប់ ឬដល់នូវទុក្ខស្មើស្លាប់ ព្រោះតែការផឹកនោះជាហេតុទេ ។

---

១ ថ្នាំដែលគេត្រាំដោយស្រូវគ្រប់យ៉ាងនិងទំពាំងជាដើម ។

ឯវមេវ ខោ ភិក្ខវេ យេ ហិ កេចិ អតីតមទ្ធានំ
សមណា វា ព្រាហ្មណា វា យំ លោកេ បិយរូបំ
សាតរូបំ តំ អនិច្ចតោ អទ្ទក្ខុំ ទុក្ខតោ អទ្ទក្ខុំ
អនត្តតោ អទ្ទក្ខុំ រោគតោ អទ្ទក្ខុំ ភយតោ អទ្ទក្ខុំ
តេ តណ្ហំ បជហិំសុ ។ យេ តណ្ហំ បជហិំសុ តេ
ឧបធឹ បជហិំសុ យេ ឧបធឹ បជហិំសុ តេ ទុក្ខំ
បជហិំសុ យេ ទុក្ខំ បជហិំសុ តេ បរិមុច្ចិំសុ
ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ
ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចិំសុ
ទុក្ខស្មាតិ វទាមិ ។ យេ ហិ កេចិ ភិក្ខវេ
អនាគតមទ្ធានំ ។ បេ ។ ឯតរហិ សមណា វា
ព្រាហ្មណា វា យំ លោកេ បិយរូបំ សាតរូបំ តំ

ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូច ពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលកន្លងទៅហើយ បានឃើញអារម្មណ៍ដែលជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក ថាមិនទៀង បានឃើញថាជាទុក្ខ បានឃើញថាមិនមែនជារបស់ខ្លួន បានឃើញថាជារបស់មានរោគ បានឃើញថាគួរខ្លាច ពួកសមណៈឬព្រាហ្មណ៍នោះ បានលះតណ្ហាហើយ ។ ពួកសមណៈឬព្រាហ្មណ៍ណា លះតណ្ហាបានហើយ ពួកសមណៈឬព្រាហ្មណ៍នោះ លះឧបធិបាន ពួកសមណៈឬព្រាហ្មណ៍ណា លះឧបធិបានហើយ ពួកសមណៈឬព្រាហ្មណ៍នោះ លះទុក្ខបាន ពួកសមណៈឬព្រាហ្មណ៍ណា លះទុក្ខបានហើយ តថាគតពោលថា ពួកសមណៈឬព្រាហ្មណ៍នោះ រួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត រួចចាកទុក្ខបានហើយ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលជាអនាគត ។ បេ ។ ពួកសមណៈឬព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ ឃើញអារម្មណ៍ដែលជាសភាពគួរស្រឡាញ់ ជាសភាពគួរត្រេកអរ ក្នុងលោក

អនិច្ចតោ បស្សន្តិ ទុក្ខតោ បស្សន្តិ អនត្តតោ បស្សន្តិ រោគតោ បស្សន្តិ ភយតោ បស្សន្តិ តេ តណ្ហំ បជហន្តិ ។ យេ តណ្ហំ បជហន្តិ តេ ឧបធឹ បជហន្តិ យេ ឧបធឹ បជហន្តិ តេ ទុក្ខំ បជហន្តិ យេ ទុក្ខំ បជហន្តិ តេ បរិមុច្ចន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបា-យាសេហិ បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមីតិ ។ ឆដ្ឋំ ។

(២៦៣) ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាកោដ្ឋិតោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថខោ អាយស្មា មហា-កោដ្ឋិតោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

ថាមិនទៀង ឃើញថាជាទុក្ខ ឃើញថាមិនមែនខ្លួន ឃើញថាមានរោគ ឃើញថាគួរខ្លាច ពួកសមណៈឬព្រាហ្មណ៍នោះ រមែងលះតណ្ហាបាន ។ ពួកសមណៈឬព្រាហ្មណ៍ណា លះតណ្ហាបាន ពួកសមណៈ ឬព្រាហ្មណ៍នោះ រមែងលះឧបធិបាន ពួកសមណៈឬព្រាហ្មណ៍ណា លះឧបធិបាន ពួកសមណៈឬព្រាហ្មណ៍នោះ រមែងលះទុក្ខបាន ពួកសមណៈឬព្រាហ្មណ៍ណា លះទុក្ខបាន តថាគតពោលថា ពួកសមណៈឬព្រាហ្មណ៍នោះ រមែងរួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត រមែងរួចចាកទុក្ខបាន ។ ចប់សូត្រ ទី ៦ ។

( ៦៦៣ ) សម័យមួយ ព្រះសារីបុត្តមានអាយុ និងព្រះមហាកោដ្ឋិតៈមានអាយុ គង់នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ គ្រានោះ ព្រះមហាកោដ្ឋិតៈមានអាយុ ចេញអំពីទីសម្ងំក្នុងសម័យថ្ងៃរសៀល ក៏ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។

(២៦៤) ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិតោ អាយស្មន្តំ សារីបុត្តំ ឯតទវោច កិំ នុ ខោ អាវុសោ សារីបុត្ត សយំកតំ ជរាមរណំ បរំកតំ ជរាមរណំ សយំកតញ្ច បរំកតញ្ច ជរាមរណំ ឧទាហុ អសយំការំ អបរំការំ អធិច្ចសមុប្បន្នំ ជរាមរណន្តិ ។ ន ខោ អាវុសោ កោដ្ឋិត សយំកតំ ជរាមរណំ ន បរំកតំ ជរាមរណំ ន សយំកតញ្ច បរំកតញ្ច ជរាមរណំ នាបិ អសយំការំ អបរំការំ អធិច្ចសមុប្បន្នំ ជរាមរណំ អបិច ជាតិប្បច្ចយា ជរាមរណន្តិ ។ កិំ នុ ខោ អាវុសោ សារីបុត្ត សយំកតា ជាតិ បរំកតា ជាតិ សយំកតា ច បរំកតា ច ជាតិ ឧទាហុ អសយំការា អបរំការា អធិច្ចសមុប្បន្នា ជាតីតិ ។ ន ខោ អាវុសោ កោដ្ឋិត សយំកតា ជាតិ ន បរំកតា

(២៦៨) លុះព្រះមហាកោដ្ឋិតៈមានអាយុ អង្គុយក្នុងទីសមគួរហើយ បានសួរព្រះសារីបុត្តមានអាយុ យ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ជរានិងមរណៈ គឺបុគ្គលធ្វើខ្លួនឯង ឬជរានិងមរណៈ គឺបុគ្គលដទៃធ្វើឲ្យ ជរានិងមរណៈ គឺបុគ្គលធ្វើខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង ឬជរានិងមរណៈ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់អ្នកដទៃទេ គឺកើតឡើងដោយមិនអាស្រ័យហេតុ ។ ម្នាលអាវុសោកោដ្ឋិតៈ ជរានិងមរណៈ មិនមែនបុគ្គលធ្វើខ្លួនឯងទេ ជរានិងមរណៈ មិនមែនបុគ្គលដទៃធ្វើឲ្យទេ ជរានិងមរណៈ មិនមែនបុគ្គលធ្វើខ្លួនឯងផងមិនមែនបុគ្គលដទៃធ្វើឲ្យផងទេ ជរានិងមរណៈ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់អ្នកដទៃទេ គឺកើតឡើងដោយមិនអាស្រ័យហេតុ ក៏មិនមែនដែរ ប៉ុន្តែជរានិងមរណៈ កើតឡើង ព្រោះជាតិជាបច្ច័យ ។ ម្នាលអាវុសោសារីបុត្ត ជាតិ គឺបុគ្គលធ្វើខ្លួនឯង ឬជាតិ គឺបុគ្គលដទៃធ្វើឲ្យ ឬថាជាតិ គឺបុគ្គលធ្វើខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់អ្នកដទៃទេ គឺកើតឡើងដោយមិនអាស្រ័យហេតុ ។ ម្នាលអាវុសោកោដ្ឋិតៈ ជាតិ មិនមែនបុគ្គលធ្វើខ្លួនឯងទេ ជាតិ មិនមែនបុគ្គលដទៃធ្វើឲ្យទេ

ជាតិ ន សយំកតា ច បរកតា ច ជាតិ នាបិ អសយំ-ការំ អបរការំ អធិច្ចសមុប្បន្នា ជាតិ អបិច ភវប្បច្ច-យា ជាតីតិ ។ កឹ នុ ខោ អាវុសោ សារីបុត្ត សយំក-តោ ភវោ ។បេ។ សយំកតំ ឧបាទានំ... សយំកតា តណ្ហា... សយំកតា វេទនា... សយំកតោ ផស្សោ... សយំកតំ សឡាយតនំ... សយំកតំ នាមរូបំ បរកតំ នាមរូបំ សយំកតញ្ច បរកតញ្ច នាមរូបំ ឧទាហុ អសយំការំ អបរការំ អធិច្ចសមុប្បន្នំ នាមរូបន្តិ ។ ន ខោ អាវុសោ កោដ្ឋិក សយំកតំ នាមរូបំ ន បរ-កតំ នាមរូបំ ន សយំកតញ្ច បរកតញ្ច នាមរូបំ នាបិ អសយំការំ អបរការំ អធិច្ចសមុប្បន្នំ នាមរូបំ អបិច វិញ្ញាណប្បច្ចយា នាមរូបន្តិ ។ កឹ នុ ខោ អាវុសោ សារីបុត្ត សយំកតំ វិញ្ញាណំ បរកតំ វិញ្ញា-ណំ សយំកតញ្ច បរកតញ្ច វិញ្ញាណំ ឧទាហុ អសយំការំ អបរការំ អធិច្ចសមុប្បន្នំ វិញ្ញាណន្តិ ។

ជាតិ មិនមែនបុគ្គលធ្វើខ្លួនឯងផង មិនមែនបុគ្គលដទៃធ្វើឲ្យផងទេ ជាតិមិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់បុគ្គលដទៃទេ គឺកើតឡើងដោយមិនអាស្រ័យហេតុ ក៏មិនមែនដែរ ប៉ុន្តែជាតិកើតឡើង ព្រោះភពជាបច្ច័យ ។ ម្នាលអាវុសោ សារីបុត្ត ភពគឺបុគ្គលធ្វើខ្លួនឯងឬ ។ បេ ។ ឧបាទាន គឺបុគ្គលធ្វើខ្លួនឯង ... តណ្ហាគឺបុគ្គលធ្វើខ្លួនឯង ... វេទនាគឺបុគ្គលធ្វើខ្លួនឯង ... ផស្សៈ គឺបុគ្គលធ្វើខ្លួនឯង ... សឡាយតនៈគឺបុគ្គលធ្វើខ្លួនឯង ... នាមរូប គឺបុគ្គលធ្វើខ្លួនឯង នាមរូបគឺបុគ្គលដទៃធ្វើឲ្យ នាមរូបគឺបុគ្គលធ្វើខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង ឬមួយនាមរូបមិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់បុគ្គលដទៃទេ គឺកើតឡើងដោយមិនអាស្រ័យហេតុ ។ ម្នាលកោដ្ឋិតៈ នាមរូប គឺបុគ្គលធ្វើខ្លួនឯងក៏ទេ នាមរូប គឺបុគ្គលដទៃធ្វើឲ្យក៏ទេ នាមរូប មិនមែនបុគ្គលធ្វើខ្លួនឯងផង មិនមែនបុគ្គលដទៃធ្វើឲ្យផងក៏ទេ នាមរូបមិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់បុគ្គលដទៃទេ គឺកើតឡើង ដោយមិនអាស្រ័យហេតុក៏ទេដែរ ប៉ុន្តែនាមរូបកើតឡើង ព្រោះវិញ្ញាណជាបច្ច័យ ។ ម្នាលអាវុសោសារីបុត្ត វិញ្ញាណ គឺបុគ្គលធ្វើខ្លួនឯង ឬវិញ្ញាណ គឺបុគ្គលដទៃធ្វើឲ្យ វិញ្ញាណ គឺបុគ្គលធ្វើខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផង ឬមួយវិញ្ញាណ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់បុគ្គលដទៃទេ គឺកើតឡើងដោយមិនអាស្រ័យហេតុ ។

ន ខោ អាវុសោ កោដ្ឋិត សយំកតំ វិញ្ញាណំ ន បរកតំ វិញ្ញាណំ ន សយំកតញ្ច បរកតញ្ច វិញ្ញាណំ នាបិ អសយំការំ អបរការំ អធិច្ចសមុប្បន្នំ វិញ្ញាណំ អបិច នាមរូបបច្ចយា វិញ្ញាណន្តិ ។

[២៦៥] ឥទានេវ ខោ មយំ អាយស្មតោ សារិបុត្តស្ស ភាសិតំ ឯវំ អាជានាម ន ខោ អាវុសោ កោដ្ឋិត សយំកតំ នាមរូបំ ន បរកតំ នាមរូបំ ន សយំកតញ្ច បរកតញ្ច នាមរូបំ នាបិ អសយំការំ អបរការំ អធិច្ចសមុប្បន្នំ នាមរូបំ អបិច វិញ្ញាណបច្ចយា នាមរូបន្តិ ។ ឥទានេវ បន មយំ អាយស្មតោ សារិបុត្តស្ស ភាសិតំ ឯវំ អាជានាម ន ខោ អាវុសោ កោដ្ឋិត សយំកតំ វិញ្ញាណំ ន បរកតំ វិញ្ញាណំ ន សយំកតញ្ច បរកតញ្ច វិញ្ញាណំ នាបិ អសយំការំ អបរការំ អធិច្ចសមុប្បន្នំ វិញ្ញាណំ អបិច នាមរូបបច្ចយា វិញ្ញាណន្តិ ។ យថាកថំ បនាវុសោ សារិបុត្ត ឥមស្ស ភាសិតស្ស អត្ថោ ទដ្ឋព្វោ ។

ម្នាលអាវុសោកោដ្ឋិតៈ វិញ្ញាណ គឺបុគ្គលធ្វើខ្លួនឯងក៏ទេ វិញ្ញាណ គឺបុគ្គលដទៃធ្វើឲ្យក៏ទេ វិញ្ញាណ គឺបុគ្គលធ្វើខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផងក៏ទេ វិញ្ញាណ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់បុគ្គលដទៃទេ គឺកើតឡើងដោយមិនអាស្រ័យហេតុ ក៏ទេដែរ ប៉ុន្តែវិញ្ញាណកើតឡើង ព្រោះនាមរូបជាបច្ច័យ ។

(២៦៨) ខ្ញុំនេះឯង យើងយល់ភាសិតរបស់ព្រះសារីបុត្តមានអាយុ យ៉ាងនេះថា ម្នាលអាវុសោកោដ្ឋិតៈ នាមរូប គឺបុគ្គលធ្វើខ្លួនឯងក៏ទេ នាមរូប គឺបុគ្គលដទៃធ្វើឲ្យក៏ទេ នាមរូប គឺបុគ្គលធ្វើខ្លួនឯងផង បុគ្គលដទៃ ធ្វើឲ្យផងក៏ទេ នាមរូប មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់បុគ្គលដទៃទេ គឺកើតឡើងដោយមិនអាស្រ័យហេតុ ក៏ទេដែរ ប៉ុន្តែនាមរូបកើតឡើង ព្រោះវិញ្ញាណជាបច្ច័យ ។ ទើបតែអម្បាញ់មិញនេះឯង យើងយល់ភាសិតរបស់ព្រះសារីបុត្តមានអាយុ យ៉ាងនេះថា ម្នាលអាវុសោកោដ្ឋិតៈ វិញ្ញាណ គឺបុគ្គលដទៃធ្វើខ្លួនឯងក៏ទេ វិញ្ញាណ គឺបុគ្គលដទៃធ្វើឲ្យក៏ទេ វិញ្ញាណ គឺបុគ្គលធ្វើខ្លួនឯងផង បុគ្គលដទៃធ្វើឲ្យផងក៏ទេ វិញ្ញាណ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់បុគ្គលដទៃទេ គឺកើតឡើងដោយមិនអាស្រ័យហេតុ ក៏ទេដែរ ប៉ុន្តែវិញ្ញាណកើតឡើងព្រោះនាមរូបជាបច្ច័យ ។ ម្នាលអាវុសោសារីបុត្ត តើយើងត្រូវយល់ សេចក្តីនៃភាសិតនេះ ដូចម្តេចបាន ។

(២៦៦) តេនហាវុសោ ឧបមន្តេ ករិស្សាមិ ឧបមាយបិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។ សេយ្យថាបិ អាវុសោ ទ្វេ នឡកលាបិយោ អញ្ញមញ្ញំ និស្សាយ តិដ្ឋេយ្យុំ ឯវមេវ ខោ អាវុសោ នាមរូបប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ តាសញ្ចេ អាវុសោ នឡកលាបីនំ ឯកំ អបកឌ្ឍេយ្យ ឯកា បបតេយ្យ អបរញ្ចេ អបកឌ្ឍេយ្យ អបរា បបតេយ្យ ។ ឯវមេវ ខោ អាវុសោ នាមរូបនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

(២៦៦) ម្នាលអាវុសោ បើដូច្នោះ ខ្ញុំនឹងធ្វើសេចក្តីឧបមាប្រាប់លោក ព្រោះបុរសទាំងឡាយដែលមានប្រាជ្ញាពួកខ្លះ ក្នុងលោកនេះ តែងយល់សេចក្តីនៃភាសិតដោយឧបមាបាន ។ ម្នាលអាវុសោ ដូចជាបាច់បបុះពីរបាច់ អាស្រ័យគ្នានឹងគ្នាឋិតនៅបាន យ៉ាងណាមិញ ម្នាលអាវុសោ សេចក្តីនេះ មានឧបមេយ្យដូច វិញ្ញាណកើតមាន ព្រោះនាមរូបជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ។ បេ ។ ការកើតព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលអាវុសោ បើបាច់បបុះទាំងអម្បាលនោះ បុគ្គលទាញយកបាច់បបុះមួយ (បាច់បបុះដែលសល់នៅ) មួយបាច់ មុខជារលំទៅ បើបុគ្គលទាញយកបាច់បបុះម្ខាងចេញ បាច់បបុះម្ខាងក៏រលំទៅ ដូចម្តេចមិញ ។ ម្នាលអាវុសោ សេចក្តីនេះ ក៏មានឧបមេយ្យដូច្នោះដែរ ព្រោះតែនាមរូបរលត់ ទើបវិញ្ញាណរលត់ ព្រោះតែវិញ្ញាណរលត់ ទើបនាមរូបរលត់ ព្រោះតែនាមរូបរលត់ ទើបសឡាយតនៈរលត់ ព្រោះតែសឡាយតនៈរលត់ ទើបផស្សៈរលត់ ។ បេ ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។

(២៦៧) អច្ឆរិយំ អាវុសោ សារីបុត្ត អព្ភុតំ អាវុសោ សារីបុត្ត យាវ សុភាសិតញ្ចិទំ អាយស្មតា សារីបុត្តេន ឥទញ្ច បន មយំ អាយស្មតោ សារីបុត្តស្ស សុភាសិតំ ឥមេហិ ឆត្តឹសាយ វត្ថូហិ អនុមោទាម ជរាមរណស្ស ចេ អាវុសោ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ ជរាមរណស្ស ចេ អាវុសោ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ធម្មានុធម្មប្បដិបន្នោ ភិក្ខូតិ អលំ វចនាយ ។ ជរាមរណស្ស ចេ អាវុសោ ភិក្ខុ និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ទិដ្ឋធម្មនិព្វានប្បត្តោ ភិក្ខូតិ អលំ វចនាយ ។ ជាតិយា ចេ ។ បេ ។ ភវស្ស ចេ ... ឧបាទានស្ស ចេ ... តណ្ហាយ ចេ ... វេទនាយ ចេ ... ផស្សស្ស ចេ ... សឡាយតនស្ស ចេ .. នាមរូបស្ស ចេ ...

(២៦៧) ម្នាលអាវុសោសារីបុត្ត អស្ចារ្យណាស់ ម្នាលអាវុសោសារីបុត្ត ចំឡែកណាស់ ព្រះសារីបុត្តមានអាយុ និយាយនេះត្រូវហើយ មួយទៀត យើងសូមអនុមោទនាសុភាសិត របស់ព្រះសារីបុត្តមានអាយុនេះ ដោយវត្ថុ ៣៦ នេះ ម្នាលអាវុសោ បើភិក្ខុសំដែងធម៌ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃជរាមរណៈ ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។ ម្នាលអាវុសោ បើភិក្ខុជាអ្នកប្រតិបត្តិ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃជរាមរណៈ ទើបគួរហៅថា ភិក្ខុជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលអាវុសោ បើភិក្ខុជាអ្នកមានចិត្តរួចស្រឡះហើយ ព្រោះការនឿយណាយ ព្រោះការវិនាស ព្រោះការរលត់ ព្រោះការមិនប្រកាន់ស្អិត នូវជរាមរណៈ ទើបគួរហៅថា ភិក្ខុជាអ្នកដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។ បើជាតិ ។បេ។ បើភព ... បើឧបាទាន ... បើតណ្ហា ... បើវេទនា ... បើផស្សៈ ... បើសឡាយតនៈ ... បើនាមរូប ...

វិញ្ញាណស្ស ចេ... សង្ខារានញ្ចេ... អវិជ្ជាយ ចេ អាវុសោ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ អវិជ្ជាយ ចេ អាវុសោ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ធម្មានុធម្មប្បដិបន្នោ ភិក្ខូតិ អលំ វចនា-យ ។ អវិជ្ជាយ ចេ អាវុសោ ភិក្ខុ និព្វិទា វិរាគា និ-រោធា អនុបាទា វិមុត្តោ ហោតិ ទិដ្ឋធម្មនិព្វានប្បត្តោ ភិក្ខូតិ អលំ វចនាយាតិ ។ សត្តមំ ។

[៦៦៨] ឯកំ សមយំ អាយស្មា ច មុសិលោ អាយស្មា ច បវិដ្ឋោ(១) អាយស្មា ច នារទោ អាយស្មា ច អានន្ទោ កោសម្ពិយំ វិហរន្តិ ឃោសិតារាមេ ។

---

១ ម. សវិដ្ឋោ ។

បើវិញ្ញាណ ... បើសង្ខារទាំងឡាយ ... ម្នាលអាវុសោ បើភិក្ខុអ្នកសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់ នៃអវិជ្ជា ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។ ម្នាលអាវុសោ បើភិក្ខុជាអ្នកប្រតិបត្តិ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃអវិជ្ជា ទើបគួរហៅថា ភិក្ខុជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលអាវុសោ បើភិក្ខុជាអ្នកមានចិត្តរួចស្រឡះហើយ ព្រោះការនឿយណាយ ព្រោះការវិនាស ព្រោះការរលត់ ព្រោះការមិនប្រកាន់ស្អិតនូវអវិជ្ជា ទើបគួរហៅថា ភិក្ខុជាអ្នកដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

ចប់សូត្រ ទី ៧ ។

[២៦៨] សម័យមួយ ព្រះមុសិលៈមានអាយុ ព្រះបវិដ្ឋៈមានអាយុ ព្រះនារទៈមានអាយុ និងព្រះអានន្ទមានអាយុ នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។

(២៦៩) អថខោ អាយស្មា បវិដ្ឋោ អាយស្មន្តំ មុសិលំ ឯតទវោច អញ្ញត្រ អាវុសោ មុសិល សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អត្ថាយស្មតោ មុសិលស្ស បច្ចត្តមេវ ញាណំ ជាតិបច្ចយា ជរាមរណន្តិ ។ អញ្ញត្រ អាវុសោ បវិដ្ឋ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អហមេតំ ជានាមិ អហមេតំ បស្សាមិ ជាតិបច្ចយា ជរាមរណន្តិ ។ អញ្ញត្រ អាវុសោ មុសិល សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អត្ថាយស្មតោ មុសិលស្ស បច្ចត្តមេវ ញាណំ ភវបច្ចយា ជាតីតិ ។ បេ ។ ឧបាទានបច្ចយា ភវោតិ ... តណ្ហាបច្ចយា ឧបាទានន្តិ ...

(២៦៩) លំដាប់នោះ ព្រះបវិដ្ឋៈមានអាយុ បានសួរព្រះមុសិលៈមានអាយុ យ៉ាងនេះថា ម្នាលអាវុសោមុសិលៈ វៀរចាកសេចក្តីជឿ (តាមគេ) វៀរចាកសេចក្តីចូលចិត្ត (ខ្លួនឯង) វៀរចាកសេចក្តីឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្ត តាមការយល់ឃើញនិងការពិនិត្យ តើមុសិលៈមានអាយុ មានញាណកើតឡើងចំពោះខ្លួនឯងថា ជរានិងមរណៈកើតឡើង ព្រោះជាតិជាបច្ច័យដូច្នេះឬទេ ។ ម្នាលអាវុសោបវិដ្ឋៈ វៀរចាកសេចក្តីជឿ វៀរចាកសេចក្តីចូលចិត្ត វៀរចាកសេចក្តីឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្ត តាមការយល់ឃើញនិងការពិនិត្យ ខ្ញុំក៏ដឹងហេតុនុ៎ះ ខ្ញុំក៏ឃើញហេតុនុ៎ះថា ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ។ ម្នាលអាវុសោមុសិលៈ វៀរចាកសេចក្តីជឿ វៀរចាកសេចក្តីចូលចិត្ត វៀរចាកសេចក្តីឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្ត តាមការយល់ឃើញនិងការពិនិត្យ តើមុសិលៈមានអាយុ មានញាណកើតឡើងចំពោះខ្លួនឯងថា ជាតិកើតមាន ព្រោះភពជាបច្ច័យ ដូច្នេះឬទេ ។ បេ ។ ថា ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ... ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ...

វេទនាបច្ចយា តណ្ហាតិ ... ផស្សបច្ចយា វេទនាតិ ... សឡាយតនបច្ចយា ផស្សោតិ ... នាមរូបបច្ចយា សឡាយតនន្តិ ... វិញ្ញាណបច្ចយា នាមរូបន្តិ ... សង្ខារបច្ចយា វិញ្ញាណន្តិ ... អវិជ្ជាបច្ចយា សង្ខារាតិ ។ អញ្ញត្រេវ អាវុសោ សវិដ្ឋ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អហមេតំ ជានាមិ អហមេតំ បស្សាមិ អវិជ្ជាបច្ចយា សង្ខារាតិ ។

(២៧០) អញ្ញត្រ ច អាវុសោ មុសិល សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អត្ថាយស្មតោ មុសិលស្ស បច្ចត្តមេវ ញាណំ ជាតិបច្ចយា ជរាមរណន្តិ ។ អញ្ញត្រេវ អាវុសោ សវិដ្ឋ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អហមេតំ ជានាមិ អហមេតំ បស្សាមិ ជាតិបច្ចយា ជរាមរណន្តិ ។

តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ .. វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ... ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ... សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ... នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ... វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ... សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះឬទេ ។ ម្នាលអាវុសោបវិដ្ឋៈ វៀរចាកសេចក្តីជឿ វៀរចាកសេចក្តីចូលចិត្ត វៀរចាកសេចក្តីឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្តតាមការយល់ឃើញនិងការពិនិត្យ ខ្ញុំក៏ដឹងហេតុនុ៎ះ ខ្ញុំក៏ឃើញហេតុនុ៎ះថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

(២៧០) ម្នាលអាវុសោមុសិលៈ វៀរចាកសេចក្តីជឿ វៀរចាកសេចក្តីចូលចិត្ត វៀរចាកការឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្ត តាមការយល់ឃើញនិងការពិនិត្យ តើមុសិលៈមានអាយុ មានញាណកើតឡើងចំពោះខ្លួនឯងថា ជាតិរលត់ ទើបជរានិងមរណៈរលត់ ដូច្នេះឬទេ ។ ម្នាលអាវុសោបវិដ្ឋៈ វៀរចាកសេចក្តីជឿ វៀរចាកសេចក្តីចូលចិត្ត វៀរចាកការឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្ត តាមការយល់ឃើញនិងការពិនិត្យ ខ្ញុំក៏ដឹងហេតុនុ៎ះ ខ្ញុំក៏ឃើញហេតុនុ៎ះថា ព្រោះតែជាតិរលត់ ទើបជរានិងមរណៈរលត់ ។

អញ្ញត្រេវ អាវុសោ មុសិល សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អាយស្មតោ មុសិលស្ស បច្ចត្តមេវ ញាណំ ភវនិរោធា ជាតិនិរោធោតិ ។ បេ ។ ឧបាទាននិរោធា ភវនិរោធោតិ ... តណ្ហានិរោធា ឧបាទាននិរោធោតិ ... វេទនានិរោធា តណ្ហានិរោធោតិ ... ផស្សនិរោធា វេទនានិរោធោតិ ... សឡាយតននិរោធា ផស្សនិរោធោតិ ... នាមរូបនិរោធា សឡាយតននិរោធោតិ ... វិញ្ញាណនិរោធា នាមរូបនិរោធោតិ .. សង្ខារនិរោធា វិញ្ញាណនិរោធោតិ ... អវិជ្ជានិរោធា សង្ខារនិរោធោតិ ។ អញ្ញត្រេវ អាវុសោ បវិដ្ឋ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អហមេតំ ជានាមិ អហមេតំ បស្សាមិ អវិជ្ជានិរោធា សង្ខារនិរោធោតិ ។

ម្នាលអាវុសោមុសិលៈ វៀរលែងសេចក្តីជឿ វៀរលែងសេចក្តីចូលចិត្ត វៀរលែងការឮតៗគ្នាមក វៀរលែងសេចក្តីត្រិះរិះដោយអាការៈ វៀរលែងសេចក្តីពេញចិត្តតាមការយល់ឃើញនិងការពិនិត្យ តើមុសិលៈមានអាយុ មានញាណកើតឡើងចំពោះខ្លួនឯងថា ព្រោះតែភពរលត់ ទើបជាតិរលត់ ដូច្នេះឬទេ ។ បេ ។ ថា ព្រោះតែឧបាទានរលត់ ទើបភពរលត់ ... ព្រោះតែតណ្ហារលត់ ទើបឧបាទានរលត់ ... ព្រោះតែវេទនារលត់ ទើបតណ្ហារលត់ ... ព្រោះតែផស្សៈរលត់ ទើបវេទនារលត់ ព្រោះតែសឡាយតនៈរលត់ ទើបផស្សៈរលត់ ... ព្រោះតែនាមរូបរលត់ ទើបសឡាយតនៈរលត់ ... ព្រោះតែវិញ្ញាណរលត់ ទើបនាមរូបរលត់ ... ព្រោះតែសង្ខាររលត់ ទើបវិញ្ញាណរលត់ ... ព្រោះតែអវិជ្ជារលត់ ទើបសង្ខាររលត់ ដូច្នេះឬទេ ។ ម្នាលអាវុសោបវិដ្ឋៈ វៀរលែងសេចក្តីជឿ វៀរលែងសេចក្តីចូលចិត្ត វៀរលែងសេចក្តីឮតៗគ្នាមក វៀរលែងសេចក្តីត្រិះរិះដោយអាការៈ វៀរលែងសេចក្តីពេញចិត្ត តាមការយល់ឃើញនិងការពិនិត្យ ខ្ញុំក៏ដឹងហេតុនុ៎ះ ខ្ញុំក៏ឃើញហេតុនុ៎ះថា ព្រោះតែអវិជ្ជារលត់ ទើបសង្ខាររលត់ ។

(២៧១) អញ្ញត្រេវ អាវុសោ មុសិល សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អាយស្មតោ មុសិលស្ស បច្ចត្តមេវ ញាណំ ភវនិរោធោ និព្វានន្តិ ។ អញ្ញត្រេវ អាវុសោ បវិដ្ឋ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អហមេតំ ជានាមិ អហមេតំ បស្សាមិ ភវនិរោធោ និព្វានន្តិ ។ តេនហាយស្មា មុសិលោ អរហំ ខីណាសវោតិ ។ ឯវំ វុត្តេ អាយស្មា មុសិលោ តុណ្ហី អហោសិ ។

(១៧២) អថខោ អាយស្មា នារទោ អាយស្មន្តំ បវិដ្ឋំ ឯតទវោច សាធាវុសោ បវិដ្ឋ អហំ ឯតំ បញ្ហំ លភេយ្យំ ឯវំ បញ្ហំ បុច្ឆ អហំ តេ ឯតំ បញ្ហំ ព្យាករិស្សាមីតិ ។ លភតិ(១) អាយស្មា នារទោ

---

១ កត្ថចិ អម្ហាកំ បោត្ថកេ លភតន្តិ ជាហេ ។

[២៧១] ម្នាលអាវុសោមុសិលៈ វៀរចាកសេចក្ដីជឿ វៀរចាកសេចក្ដីចូលចិត្ត វៀរចាកការឮត ៗ គ្នាមក វៀរចាកសេចក្ដីត្រិះរិះដោយអាការៈ វៀរចាកសេចក្ដីពេញចិត្តតាមការយល់ឃើញនិងការពិនិត្យ តើមុសិលៈមានអាយុ មានញាណកើតឡើងចំពោះខ្លួនឯងថា សេចក្ដីរលត់នៃភព ជាព្រះនិព្វាន ដូច្នេះឬទេ ។ ម្នាលអាវុសោបវិដ្ឋៈ វៀរចាកសេចក្ដីជឿ វៀរចាកសេចក្ដីចូលចិត្ត វៀរចាកការឮត ៗ គ្នាមក វៀរចាកសេចក្ដីត្រិះរិះដោយអាការៈ វៀរចាកសេចក្ដីពេញចិត្តតាមការយល់ឃើញនិងការពិនិត្យ ខ្ញុំក៏ដឹងហេតុនុ៎ះ ខ្ញុំក៏ឃើញហេតុនុ៎ះថា សេចក្ដីរលត់នៃភពជាព្រះនិព្វាន ។ បើដូច្នោះមានតែព្រះមុសិលៈមានអាយុ ជាព្រះអរហន្តខីណាស្រព ។ កាលបើព្រះបវិដ្ឋៈនិយាយយ៉ាងនេះហើយ ព្រះមុសិលៈមានអាយុ ក៏នៅស្ងៀម ។

[២៧២] លំដាប់នោះ ព្រះនារទៈមានអាយុ បាននិយាយនឹងព្រះបវិដ្ឋៈមានអាយុ យ៉ាងនេះថា ម្នាលអាវុសោបវិដ្ឋៈ ខ្ញុំសូមឱកាស ខ្ញុំគួរតែបានដើម្បីដោះស្រាយប្រស្នានុ៎ះ កាលបើដូច្នេះ លោកចូរសួរប្រស្នានោះមកចុះ ខ្ញុំនឹងព្យាករប្រស្នានុ៎ះដល់លោក ។ បើព្រះនារទៈមានអាយុបាន

ឯតំ បញ្ហំ បុដ្ឋាមហំ អាយស្មន្តំ ណារទំ ឯតំ បញ្ហំ ព្យាករោតុ ច មេ អាយស្មា ណារទោ ឯតំ បញ្ហំ អញ្ញត្រេវ អាវុសោ ណារទ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អត្ថាយស្មតោ ណារទស្ស បច្ចត្តមេវ ញាណំ ជាតិបច្ចយា ជរាមរណន្តិ ។ អញ្ញត្រេវ អាវុសោ បវិដ្ឋ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អហមេតំ ជានាមិ អហមេតំ បស្សាមិ ជាតិបច្ចយា ជរាមរណន្តិ ។ អញ្ញត្រេវ អាវុសោ ណារទ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អត្ថាយស្មតោ ណារទស្ស បច្ចត្តមេវ ញាណំ ភវបច្ចយា ជាតីតិ ។ បេ ។ អវិជ្ជាបច្ចយា សង្ខារាតិ ។

(ឱកាសដើម្បីដោះ) នូវប្រស្នានុះ ខ្ញុំសូមសួរប្រស្នានុះ ចំពោះព្រះនារទៈ មានអាយុ សូមព្រះនារទៈមានអាយុ ព្យាករប្រស្នានុះ ដល់ខ្ញុំ ម្នាលអាវុសោនារទៈ វៀរលែងសេចក្ដីជឿ វៀរលែងសេចក្ដីចូលចិត្ត វៀរលែងការឮត ៗ គ្នាមក វៀរលែងសេចក្ដីត្រិះរិះដោយអាការៈ វៀរលែងសេចក្ដីពេញចិត្តតាមការយល់ឃើញនិងការពិនិត្យ តើនារទៈមានអាយុ មានញាណកើតឡើងចំពោះខ្លួនឯងថា ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យដូច្នេះឬទេ ។ ម្នាលអាវុសោបវិដ្ឋៈ វៀរលែងសេចក្ដីជឿ វៀរលែងសេចក្ដីចូលចិត្ត វៀរលែងការឮត ៗ គ្នាមក វៀរលែងសេចក្ដីត្រិះរិះដោយអាការៈ វៀរលែងសេចក្ដីពេញចិត្ត តាមការយល់ឃើញនិងការពិនិត្យ ខ្ញុំក៏ដឹងនូវហេតុនុះ ខ្ញុំក៏ឃើញហេតុនុះថា ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ។ ម្នាលអាវុសោនារទៈ វៀរលែងសេចក្ដីជឿ វៀរលែងសេចក្ដីចូលចិត្ត វៀរលែងសេចក្ដីឮត ៗ គ្នាមក វៀរលែងសេចក្ដីត្រិះរិះដោយអាការៈ វៀរលែងសេចក្ដីពេញចិត្តតាមការយល់ឃើញនិងការពិនិត្យ តើនារទៈមានអាយុ មានញាណកើតឡើងចំពោះខ្លួនឯងថា ជាតិកើតមាន ព្រោះភពជាបច្ច័យដូច្នេះឬទេ ។ បេ ។ ថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះឬទេ ។

អញ្ញត្រេវ អាវុសោ បវិដ្ឋ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អហមេតំ ជានាមិ អហមេតំ បស្សាមិ អវិជ្ជាបច្ចយា សង្ខារាតិ ។

(៥៧៣) អញ្ញត្រ ច អាវុសោ ណារទ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អត្ថាយស្មតោ ណារទស្ស បច្ចត្តមេវ ញាណំ ជាតិនិរោធា ជរាមរណនិរោធោ ។ បេ ។ អវិជ្ជានិរោធា សង្ខារនិរោធោតិ ។ អញ្ញត្រេវ អាវុសោ បវិដ្ឋ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អហមេតំ ជានាមិ អហមេតំ បស្សាមិ អវិជ្ជានិរោធា សង្ខារនិរោធោតិ ។

ម្នាលអាវុសោបវិដ្ឋៈ វៀរចាកសេចក្តីជឿ វៀរចាកសេចក្តីចូលចិត្ត វៀរចាកសេចក្តីឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្តតាមការយល់ឃើញនិងការពិនិត្យ ខ្ញុំក៏ដឹងហេតុនុះ ខ្ញុំក៏ឃើញហេតុនុះថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

[ ៤៧៣ ] ម្នាលអាវុសោនារទៈ វៀរចាកសេចក្តីជឿ វៀរចាកសេចក្តីចូលចិត្ត វៀរចាកសេចក្តីឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្តតាមការយល់ឃើញនិងការពិនិត្យ តើនារទៈមានអាយុ មានញាណកើតឡើងចំពោះខ្លួនឯងថា ព្រោះតែជាតិរលត់ ទើបជរាមរណៈរលត់ ដូច្នេះឬទេ ។ បេ ។ ថាព្រោះតែអវិជ្ជារលត់ទើបសង្ខាររលត់ដូច្នេះឬទេ ។ ម្នាលអាវុសោបវិដ្ឋៈ វៀរចាកសេចក្តីជឿ វៀរចាកសេចក្តីចូលចិត្ត វៀរចាកសេចក្តីឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្តតាមការយល់ឃើញនិងការពិនិត្យ ខ្ញុំក៏ដឹងហេតុនុះ ខ្ញុំក៏ឃើញហេតុនុះថា ព្រោះតែអវិជ្ជារលត់ ទើបសង្ខាររលត់ ។

[២៧៤] អញ្ញត្រេវ អាវុសោ នារទ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អត្ថាយស្មតោ នារទស្ស បច្ចត្តមេវ ញាណំ ភវនិរោធោ និព្ពានន្តិ ។ អញ្ញត្រេវ អាវុសោ បវិដ្ឋ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អហមេតំ ជានាមិ អហមេតំ បស្សាមិ ភវនិរោធោ និព្ពានន្តិ ។ តេនហាយស្មា នារទោ អរហំ ខីណាសវោតិ ។ ភវនិរោធោ និព្ពានន្តិ ខោ មេ អាវុសោ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ន ចម្ហិ អរហំ ខីណាសវោ សេយ្យថាបិ អាវុសោ កន្តារមគ្គេ ឧទបានោ តត្រ នេវស្ស រជ្ជុ ន ឧទកវារកោ អថ

[២៧៥] ម្នាលអាវុសោនារទៈ វៀរចាកសេចក្តីជឿ វៀរចាកសេចក្តីចូលចិត្ត វៀរចាកសេចក្តីឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្ត តាមការយល់ឃើញទិដ្ឋិការពិនិត្យ តើនារទៈមានអាយុ មានញាណកើតឡើងចំពោះខ្លួនឯងថា សេចក្តីរលត់នៃភព ជាព្រះនិព្វាន ដូច្នេះឬទេ ។ ម្នាលអាវុសោបវិដ្ឋៈ វៀរចាកសេចក្តីជឿ វៀរចាកសេចក្តីចូលចិត្ត វៀរចាកសេចក្តីឮតៗគ្នាមក វៀរចាកសេចក្តីត្រិះរិះដោយអាការៈ វៀរចាកសេចក្តីពេញចិត្តតាមការយល់ឃើញទិដ្ឋិការពិនិត្យ ខ្ញុំក៏ដឹងហេតុនុះ ខ្ញុំក៏ឃើញហេតុនុះថា សេចក្តីរលត់នៃភព ជាព្រះនិព្វាន ។ បើដូច្នោះមានតែ ព្រះនារទៈមានអាយុ ជាព្រះអរហន្តខីណាស្រព ។ ម្នាលអាវុសោ ខ្ញុំយល់ឃើញដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតថា សេចក្តីរលត់ភព ជាព្រះនិព្វាន ដូច្នេះពិតមែន តែខ្ញុំមិនមែនជាព្រះអរហន្តខីណាស្រពទេ ម្នាលអាវុសោ ដូចអណ្តូងទឹកក្នុងផ្លូវលំបាក ខ្សែក៏មិនមានក្នុងទីនោះ យោងសម្រាប់ដងក៏មិនមានក្នុងទីនោះ ស្រាប់តែ

បុរិសោ អាកង្ខេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ សោ តំ ឧទបានំ ឱលោកេយ្យ តស្ស ឧទកន្តិ ហិ ខោ ញាណំ អស្ស ន ច កាយេន ផុសិត្វា វិហរេយ្យ ឯវមេវ ខោ អាវុសោ ភវនិរោធោ និព្ពានន្តិ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ន ចម្ហិ អរហំ ខីណាសវោតិ ។

(២៧៥) ឯវំ វុត្តេ អាយស្មា អានន្ទោ អាយស្មន្តំ បវិដ្ឋំ ឯតទវោច ឯវំវាទី ត្វំ អាវុសោ បវិដ្ឋ អាយស្មន្តំ នារទំ កិំ វទេសីតិ ។ ឯវំវាទាហំ អាវុសោ អានន្ទ អាយស្មន្តំ នារទំ ន កិញ្ចិ វទាមិ អញ្ញត្រ កល្យាណា អញ្ញត្រ កុសលាតិ ។ អដ្ឋមំ ។

(២៧៦) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគ-វា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

បុរស ដែលក្តៅក្រហាយ ព្រោះត្រូវកំដៅថ្ងៃ ត្រូវកំដៅថ្ងៃបៀតបៀន ហើយ លំបាក ក្រហល់ក្រហាយ ស្រេកឃ្លាន ដើរមកដល់ បុរស នោះក្រឡេកមើលឃើញអណ្តូងទឹកនោះ បុរសនោះដឹងថា ទឹកមាន ពិត តែថានឹងប៉ះពាល់ដោយកាយមិនបាន ដូចម្តេចមិញ ម្នាលអាវុសោ ខ្ញុំឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថា សេចក្តីរលត់ភព ជាព្រះនិព្វាន តែខ្ញុំមិនមែនជាព្រះអរហន្តខីណាស្រព ក៏ដូច្នោះដែរ ។

(២៧៥) កាលព្រះនារទៈនិយាយយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ បាននិយាយនឹងព្រះបវិដ្ឋៈមានអាយុ យ៉ាងនេះថា ម្នាលអាវុសោបវិដ្ឋៈ លោកតែងនិយាយយ៉ាងនេះ ចុះលោកនិយាយនឹងព្រះនារទៈមានអាយុដូចម្តេច ។ ម្នាលអាវុសោអានន្ទ ខ្ញុំតែងនិយាយយ៉ាងនេះ តែខ្ញុំមិនបាននិយាយពាក្យអ្វី នឹងព្រះនារទៈមានអាយុ ក្រៅអំពីការល្អ ក្រៅអំពីការកុសលទេ ។ ចប់សូត្រ ទី ៨ ។

(២៧៦) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

(២៧៧) តត្រ ខោ ភគវា ... មហាសមុទ្ទោ ភិក្ខវេ
ឧបយន្តោ មហានទិយោ ឧបយាបេតិ មហានទិយោ
ឧបយន្តិយោ កុន្នទិយោ ឧបយាបេន្តិ កុន្នទិយោ
ឧបយន្តិយោ មហាសោព្ភេ ឧបយាបេន្តិ មហាសោព្ភា
ឧបយន្តា កុស្សោព្ភេ ឧបយាបេន្តិ ឯវមេវ ខោ ភិក្ខវេ
អវិជ្ជា ឧបយន្តី សង្ខារេ ឧបយាបេតិ សង្ខារា ឧប-
យន្តា វិញ្ញាណំ ឧបយាបេន្តិ វិញ្ញាណំ ឧបយន្តំ នាមរូបំ
ឧបយាបេតិ នាមរូបំ ឧបយន្តំ សឡាយតនំ ឧបយា-
បេតិ សឡាយតនំ ឧបយន្តំ ផស្សំ ឧបយាបេតិ
ផស្សោ ឧបយន្តោ វេទនំ ឧបយាបេតិ វេទនា ឧបយន្តី
តណ្ហំ ឧបយាបេតិ តណ្ហា ឧបយន្តី ឧបាទានំ ឧប-
យាបេតិ ឧបាទានំ ឧបយន្តំ ភវំ ឧបយាបេតិ ភវោ
ឧបយន្តោ ជាតឹ ឧបយាបេតិ ជាតិ ឧបយន្តី ជរាម-
រណំ ឧបយាបេតិ ។

[ ២៧៧ ] គន្ធីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំង-ឡាយ កាលមហាសមុទ្រជោរឡើង ទន្លេក៏ជោរ កាលទន្លេជោរឡើង ស្ទឹងក៏ជោរ កាលស្ទឹងជោរឡើង ព្រែកធំក៏ជោរ កាលព្រែកធំជោរឡើង ព្រែកតូចក៏ជោរ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូច អវិជ្ជាកាលចម្រើនឡើង ក៏ញ៉ាំងសង្ខារទាំងឡាយឲ្យចម្រើន កាលសង្ខារទាំងឡាយចម្រើនឡើង ក៏ញ៉ាំងវិញ្ញាណឲ្យចម្រើន កាលវិញ្ញាណចម្រើនឡើង ក៏ញ៉ាំងនាមរូបឲ្យចម្រើន កាលនាមរូបចម្រើនឡើង ក៏ញ៉ាំងអាយតនៈ ៦ ឲ្យចម្រើន កាលអាយតនៈ ៦ ចម្រើនឡើង ក៏ញ៉ាំងផស្សៈឲ្យចម្រើន កាលផស្សៈចម្រើនឡើង ក៏ញ៉ាំងវេទនាឲ្យចម្រើន កាលវេទនាចម្រើនឡើង ក៏ញ៉ាំងតណ្ហាឲ្យចម្រើន កាលតណ្ហាចម្រើនឡើង ក៏ញ៉ាំងឧបាទានឲ្យចម្រើន កាលឧបាទានចម្រើនឡើង ក៏ញ៉ាំងភពឲ្យចម្រើន កាលភពចម្រើនឡើង ក៏ញ៉ាំងជាតិឲ្យចម្រើន កាលជាតិចម្រើនឡើង ក៏ញ៉ាំងជរាមរណៈឲ្យចម្រើន ដូច្នោះឯង ។

(២៧៨) មហាសមុទ្ទោ ភិក្ខវេ អបយន្តោ មហានទិយោ អបយាបេតិ មហានទិយោ អបយន្តិយោ កុន្នទិយោ អបយាបេន្តិ កុន្នទិយោ អបយន្តិយោ មហាសោព្ភេ អបយាបេន្តិ មហាសោព្ភា អបយន្តា កុសោព្ភេ អបយាបេន្តិ ឯវមេវ ខោ ភិក្ខវេ អវិជ្ជា អបយន្តី សង្ខារេ អបយាបេតិ សង្ខារា អបយន្តា វិញ្ញាណំ អបយាបេន្តិ វិញ្ញាណំ អបយន្តំ នាមរូបំ អបយាបេតិ នាមរូបំ អបយន្តំ សឡាយតនំ អបយាបេតិ សឡាយតនំ អបយន្តំ ផស្សំ អបយាបេតិ ផស្សោ អបយន្តោ វេទនំ អបយាបេតិ វេទនា អបយន្តី តណ្ហំ អបយាបេតិ តណ្ហា អបយន្តី ឧបាទានំ អបយាបេតិ ឧបាទានំ អបយន្តំ ភវំ អបយាបេតិ ភវោ អបយន្តោ ជាតឹ អបយាបេតិ ជាតិ អបយន្តី ជរាមរណំ អបយាបេតីតិ ។ ឆដ្ឋំ ។

(២៧៨) ម្នាលភិក្ខុទាំងឡាយ កាលបើមហាសមុទ្រនាបទៅវិញ ទន្លេក៏នាប កាលទន្លេនាប ស្ទឹងក៏នាប កាលស្ទឹងនាប ព្រែកធំក៏នាប កាលព្រែកធំនាប ព្រែកតូចក៏នាប មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូច អវិជ្ជាកាលខ្សោយកម្លាំង ក៏ញុំាងសង្ខារទាំងឡាយឲ្យខ្សោយ កាលសង្ខារទាំងឡាយខ្សោយ ក៏ញុំាងវិញ្ញាណឲ្យខ្សោយ កាលវិញ្ញាណខ្សោយ ក៏ញុំាងនាមរូបឲ្យខ្សោយ កាលនាមរូបខ្សោយ ក៏ញុំាងអាយតនៈ ៦ ឲ្យខ្សោយ កាលអាយតនៈ ៦ ខ្សោយ ក៏ញុំាងផស្សៈឲ្យខ្សោយ កាលផស្សៈខ្សោយ ក៏ញុំាងវេទនាឲ្យខ្សោយ កាលវេទនាខ្សោយ ក៏ញុំាងតណ្ហាឲ្យខ្សោយ កាលតណ្ហាខ្សោយ ក៏ញុំាងឧបាទានឲ្យខ្សោយ កាលឧបាទានខ្សោយ ក៏ញុំាងភពឲ្យខ្សោយ កាលភពខ្សោយ ក៏ញុំាងជាតិឲ្យខ្សោយ កាលជាតិខ្សោយ ក៏ញុំាងជរាមរណៈឲ្យខ្សោយ ដូច្នោះឯង ។ ចប់សូត្រទី ៩ ។

[២៧៩] ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ភគវា សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ភិក្ខុសង្ឃោបិ សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ អញ្ញតិត្ថិយា បន បរិព្វាជកា អសក្កតា ហោន្តិ អគរុកតា អមានិតា អបូជិតា អនបចិតា អលាភិនោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។

[២៨០] តេន ខោ បន សមយេន សុសីមោ បរិព្វាជកោ រាជគហេ បដិវសតិ មហតិយា បរិព្វាជកបរិសាយ សទ្ធឹ ។ អថ ខោ សុសីមស្ស បរិព្វាជកស្ស បរិសា សុសីមំ បរិព្វាជកំ ឯតទវោចុំ

[ ២៧៩ ] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមានព្រះភាគ មានមនុស្សនិងទេវតាធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ព្រះអង្គបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានបច្ច័យភេសជ្ជបរិក្ខារទាំងឡាយ ទាំងភិក្ខុសង្ឃក៏មានមនុស្សនិងទេវតា ធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានបច្ច័យភេសជ្ជបរិក្ខារទាំងឡាយដែរ ។ ចំណែកខាងពួកបរិព្វាជក ជាអន្យតិរ្ថិយ គេមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែង ជាអ្នកមិនបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានបច្ច័យភេសជ្ជបរិក្ខារទាំងឡាយឡើយ ។

[ ២៨០ ] សម័យនោះឯង បរិព្វាជកឈ្មោះសុសិមៈនៅអាស្រ័យក្នុងក្រុងរាជគ្រឹះ ជាមួយនឹងបរិព្វាជកបរិស័ទជាច្រើន ។ គ្រានោះ ពួកបរិស័ទរបស់សុសិមបរិព្វាជក បាននិយាយពាក្យនេះនឹងសុសិមបរិព្វាជកថា

ឯហិ ត្វំ អាវុសោ សុសិម សមណេ គោតមេ ព្រហ្មចរិយំ ចរ ត្វំ ធម្មំ បរិយាបុណិត្វា អម្ហេ វាចេយ្យាសិ តំ មយំ ធម្មំ បរិយាបុណិត្វា គិហីនំ ភាសិស្សាម ឯវំ មយម្បិ សក្កតា ភវិស្សាម គរុកតា មានិតា បូជិតា អបចិតា លាភិនោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ ឯវមាវុសោតិ ខោ សុសិមោ បរិព្វាជកោ សកាយ បរិសាយ បដិស្សុត្វា យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សុសិមោ បរិព្វាជកោ អាយស្មន្តំ អានន្ទំ ឯតទវោច ឥច្ឆាមហំ អាវុសោ អានន្ទ ឥមស្មឹ ធម្មវិនយេ ព្រហ្មចរិយំ ចរិតុន្តិ ។

ម្នាលអាវុសោសុសិមៈ អ្នកចូរមកអាយ ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុង ( សំណាក់ ) ព្រះសមណគោតម ចូរអ្នករៀនធម៌ ហើយបង្ហាញយើងទាំងឡាយផង យើងទាំងឡាយនឹងរៀនធម៌នោះ ហើយសំដែងប្រាប់គ្រហស្ថទាំងឡាយ កាលបើយ៉ាងនេះ ពួកយើងមុខជានឹងមានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ មិនខាន ។ សុសិមបរិព្វាជក ទទួលពាក្យបរិស័ទរបស់ខ្លួនថា អើអាវុសោ ហើយក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យគួររីករាយ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសុសិមបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ទើបនិយាយស្មើរសេចក្តីនុ៎ះ នឹងព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទមានអាយុ ខ្ញុំប្រាថ្នា ដើម្បីប្រព្រឹត្តព្រហ្មចរិយៈ ក្នុងធម្មវិន័យនេះ ។

(២៨១) អថ ខោ អាយស្មា អានន្ទោ សុសិមំ បរិព្វាជកំ អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អយំ ភន្តេ សុសិមោ បរិព្វាជកោ ឯវមាហ ឥច្ឆាមហំ អាវុសោ អានន្ទ ឥមស្មឹ ធម្មវិនយេ ព្រហ្មចរិយំ ចរិតុន្តិ ។ តេនហានន្ទ សុសិមំ បព្វាជេថាតិ ។ អលត្ថ ខោ សុសិមោ បរិព្វាជកោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថុបសម្បទំ ។

(២៨២) តេន ខោ បន សមយេន សម្ពហុលេហិ កិរ ភិក្ខូហិ ភគវតោ សន្តិកេ អញ្ញា ព្យាកតា ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមាតិ ។ អស្សោសិ ខោ អាយស្មា សុសិមោ សម្ពហុលេហិ កិរ ភិក្ខូហិ ភគវតោ សន្តិកេ អញ្ញា ព្យាកតា ខីណា ជាតិ

[ ២៨១ ] គ្រានោះឯង ព្រះអានន្ទមានអាយុ នាំសុសិមបរិព្វាជក ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុអង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សុសិមបរិព្វាជកនេះ បាននិយាយយ៉ាងនេះថា បពិត្រអានន្ទមានអាយុ ខ្ញុំប្រាថ្នាដើម្បីប្រព្រឹត្តព្រហ្មចរិយៈ ក្នុងធម៌វិន័យនេះ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកនាំគ្នាបំបួសសុសិមៈចុះ ។ សុសិមបរិព្វាជកក៏បានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។

[ ២៨២ ] សម័យនោះឯង ឮថា ពួកភិក្ខុច្រើនរូប បាននាំគ្នាក្រាបទូលនូវអរហត្តផល ក្នុងសំណាក់ព្រះមានព្រះភាគថា ពួកខ្ញុំព្រះអង្គដឹងច្បាស់ថា ជាតិ ( របស់អាត្មាអញ ) អស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ សុសិមភិក្ខុមានអាយុ បានឮថា ពួកភិក្ខុច្រើនរូប នាំគ្នាក្រាបទូលអរហត្តផល ក្នុងសំណាក់ព្រះមានព្រះភាគថា ពួកខ្ញុំព្រះអង្គដឹងច្បាស់ថា ជាតិ ( របស់អាត្មាអញ ) អស់ហើយ

វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមាតិ ។ អថខោ អាយស្មា សុសិមោ យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេហិ ភិក្ខូហិ សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សុសិមោ តេ ភិក្ខូ ឯតទវោច សច្ចំ កិរ អាយស្មន្តេហិ ភគវតោ សន្តិកេ អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមាតិ ។ ឯវមាវុសោតិ ។

(២៨៣) អបិ នុ តុម្ហេ អាយស្មន្តោ ឯវំ ជានន្តា ឯវំ បស្សន្តា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោថ ឯកោបិ ហុត្វា ពហុធា ហោថ ពហុធាបិ ហុត្វា ឯកោ ហោថ

មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញ បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ គ្រានោះឯង សុសិមភិក្ខុមានអាយុ ក៏ចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ ជាមួយនឹងភិក្ខុទាំងនោះ លុះបញ្ចប់ពាក្យគួររីករាយនិងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសុសិមភិក្ខុមានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបពោលពាក្យនេះ នឹងភិក្ខុទាំងនោះថា បានឮថា លោកមានអាយុទាំងឡាយ នាំគ្នាក្រាបទូលអរហត្តផល ក្នុងសំណាក់ព្រះមានព្រះភាគថា ពួកខ្ញុំព្រះអង្គដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញ បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ (ដូច្នេះ) ពិតមែនឬ ។ ពួកភិក្ខុទាំងនោះតបថា ពិតមែន អាវុសោ ។

(២៨៣) សុសិមភិក្ខុសួរថា បពិត្រលោកមានអាយុទាំងឡាយ ចុះលោកទាំងឡាយ កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើបាននូវការគាត់តែង ឬសំដែងឫទ្ធិច្រើនប្រការ គឺកាយតែមួយ ធ្វើឲ្យទៅជាកាយច្រើនក៏បាន កាយច្រើន ធ្វើឲ្យទៅជាកាយតែមួយវិញក៏បាន

អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានា គច្ឆថ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោថ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆថ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន កមថ សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសថ បរិមជ្ជថ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេថាតិ ។ នោ ហេតំ អាវុសោ ។

(២៨៦) អបិ នុ តុម្ហេ អាយស្មន្តោ ឯវំ ជានន្តា ឯវំ បស្សន្តា ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាថ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ចាតិ ។ នោ ហេតំ អាវុសោ ។

ដើរទៅក្នុងទីណាក៏បាន ឥតមានទើសទាល់ គឺទៅក្នុងទីកំបាំង ដើរទៅក្នុងទីវាលក៏បាន ទៅខាងក្នុង ដើរចេញទៅខាងក្រៅក៏បាន ទៅខាងក្នុងជញ្ជាំង ដើរចេញទៅខាងក្រៅជញ្ជាំង (ដោយឥតទ្វារឥតផ្លូវ) ក៏បាន ទៅខាងក្នុងកំពែង ដើរចេញទៅខាងក្រៅកំពែងក៏បាន ទៅខាងក្នុងភ្នំ ដើរចេញទៅខាងក្រៅភ្នំវិញឥតមានទើសទាល់ ដូចជាគេដើរទៅក្នុងអាកាសក៏បាន មុជងើបក្នុងផែនដី ដូចជាគេមុជងើបក្នុងទឹកក៏បាន ដើរលើទឹកឥតមានបែកធ្លាយ ដូចជាគេដើរលើផែនដីក៏បាន អង្គុយពែនភ្នែនលើអាកាស ដូចជាសកុណជាតិទាំងឡាយ ដែលមានស្លាបហើរទៅក្នុងអាកាសក៏បាន យកដៃស្ទាបអង្អែល (មណ្ឌល) ព្រះចន្ទ្រព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិធំមានអានុភាពធំយ៉ាងនេះក៏បាន ឬញុំាងអំណាចកាយឲ្យប្រព្រឹត្តទៅ រហូតដល់ព្រហ្មលោកក៏បាន ដូច្នេះបានឬទេ ។ មិនដូច្នោះទេ អាវុសោ ។

[៤៨៦] បពិត្រលោកមានអាយុទាំងឡាយ ចុះកាលបើលោកទាំងឡាយ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើមានត្រចៀកដូចជាទិព្វដ៏បរិសុទ្ធ កន្លងហួសត្រចៀករបស់មនុស្សធម្មតា រមែងឮសំឡេងពីរប្រការ គឺសំឡេងទិព្វនិងសំឡេងមនុស្ស ដែលនៅក្នុងទីឆ្ងាយ ឬនៅក្នុងទីជិតដែរឬទេ ។ មិនដូច្នោះ អាវុសោ ។

(២៨៩) អបិ នុ តុម្ហេ អាយស្មន្តោ ឯវំ ជានន្តា ឯវំ បស្សន្តា បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច ជានាថ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាថ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាថ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាថ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាថ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាថ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាថ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាថ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាថ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាថ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាថ

(២៨៥) បពិត្រលោកមានអាយុទាំងឡាយ ចុះកាលបើលោកទាំងឡាយ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើអាចកំណត់ដឹងចិត្តរបស់សត្វដទៃ របស់បុគ្គលដទៃ ដោយចិត្តរបស់ខ្លួនបាន គឺចិត្តប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថាចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ដឹងច្បាស់ថាចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ដឹងច្បាស់ថាចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈក្តី ក៏ដឹងច្បាស់ថាចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ដឹងច្បាស់ថាចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈក្តី ក៏ដឹងច្បាស់ថាចិត្តប្រាសចាកមោហៈ ចិត្តដែលរួញថយក្តី ក៏ដឹងច្បាស់ថាចិត្តរួញថយ ចិត្តដែលរាយមាយក្តី ក៏ដឹងច្បាស់ថាចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ គឺរូបាវចរនិងអរូបាវចរក្តី ក៏ដឹងច្បាស់ថាចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈក្តី ក៏ដឹងច្បាស់ថាចិត្តមិនមែន

សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាថ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាថ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាថ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាថ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាថ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាថាតិ ។ នោ ហេតំ អាវុសោ ។

[៤៨៦] អបិ នុ តុម្ហេ អាយស្មន្តោ ឯវំ ជានន្តា ឯវំ បស្សន្តា អនេកវិហិតំ បុព្វេនិវាសំ អនុស្សរថ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ

ជាមហគ្គតៈ ចិត្តជាសទុត្តរៈ គឺការមានចិត្តក៏ដឹងច្បាស់ថា ចិត្តជាសទុត្តរៈ ចិត្តដែលជាអនុត្តរៈ គឺរូបាវចរនិងអរូបាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ចិត្តដែលតាំងនៅខ្ជាប់ខ្ជួនក្តី ក៏ដឹងច្បាស់ថាចិត្តតាំងនៅខ្ជាប់ខ្ជួន ចិត្តដែលមិនតាំងនៅខ្ជាប់ខ្ជួនក្តី ក៏ដឹងច្បាស់ថាចិត្តមិនតាំងនៅខ្ជាប់ខ្ជួន ចិត្តដែលរួចស្រឡះចាកកិលេសហើយក្តី ក៏ដឹងច្បាស់ថាចិត្តរួចស្រឡះហើយ ចិត្តដែលមិនទាន់រួចស្រឡះក្តី ក៏ដឹងច្បាស់ថាចិត្តមិនទាន់រួចស្រឡះ ដែលប្តូរ ។ មិនជួបប្រទះទេ អាវុសោ ។

[ ២៨៦ ] បពិត្រលោកមានអាយុទាំងឡាយ ចុះកាលបើលោកទាំងឡាយ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើពួកលោកឃើញនូវបុព្វេនិវាសគឺខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ជាច្រើនប្រការ គឺពួកឃើញបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន ពួកឃើញសំវដ្តកប្បជាច្រើនក៏បាន វិវដ្តកប្បជាច្រើនក៏បាន សំវដ្តវិវដ្តកប្បជាច្រើនក៏បាន ថាអាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ

សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតីតិ ។ សោ ហោតិ អាវុសោ ។

(៥៨៧) អបិ នុ តុម្ហេ អាយស្មន្តោ ឯវំ ជានន្តា ឯវំ បស្សន្តា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សថ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាថ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា

លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញនោះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ លោកទាំងឡាយរឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការៈ គឺរូបនិងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះនិងគោត្រត្រកូល ដោយប្រការដូច្នេះ បានដែរឬទេ ។ មិនដូច្នោះទេ អាវុសោ ។

(៤៨៧) បពិត្រលោកមានអាយុទាំងឡាយ ចុះកាលបើលោកទាំងឡាយ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា រមែងឃើញនូវពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់ នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោ-ទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គល មានសេចក្តីយល់ខុស ប្រកាន់នូវអំពើតាមសេចក្តីយល់ខុស សត្វទាំងអម្បាលនោះ លុះរំលាយកាយ

បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ សោ ហោតិ អាវុសោ ។

(៥៨៨) អបិ នុ ត្វេ អាយស្មន្តោ ឃរំ ឆា-នន្តា ឃរំ បស្សន្តោ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ កាយេន ផុសិត្វា វិហរតីតិ ។ សោ ហោតិ អាវុសោ ។

ស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក មួយទៀត អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀល ព្រះអរិយបុគ្គល មានសេចក្តីយល់ត្រូវ ប្រកាន់នូវអំពើតាមសេចក្តីយល់ត្រូវ សត្វទាំងអម្បាលនោះ លុះរំលាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ ទេវលោក ចុះលោកទាំងឡាយ មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា រមែងឃើញនូវពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ ដែរឬទេ ។ មិនដូច្នោះទេ អាវុសោ ។

[២៨៨] បពិត្រលោកមានអាយុទាំងឡាយ ចុះកាលបើលោកទាំងឡាយ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើកន្លងនូវរូបជ្ឈានហើយ បាននូវអារុប្បវិមោក្ខ ដែលជាធម៌ស្ងប់រម្ងាប់ ដោយនាមកាយ ហើយសម្រេចនៅ ដែរឬទេ ។ មិនដូច្នោះទេ អាវុសោ ។

(២៨៩) ឯត្តកានិ អាយស្មតោ ឥទញ្ច វេយ្យាករណំ ឥមេសញ្ច ធម្មានំ អសមាបត្តិ ឥទំ នោ អាវុសោ កថន្តិ ។ បញ្ញាវិមុត្តា ខោ មយំ អាវុសោ សុសីមាតិ ។ ន ខ្វាហំ ឥមស្ស អាយស្មន្តានំ សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាមិ សាធុ មេ អាយស្មន្តោ តថា ភាសន្តុ យថាហំ ឥមស្ស អាយស្មន្តានំ សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានេយ្យន្តិ ។ អាជានេយ្យាសិ វា ត្វំ អាវុសោ សុសីម ន វា ត្វំ អាជានេយ្យាសិ អថខោ បញ្ញាវិមុត្តា មយន្តិ ។

(២៩០) អថខោ អាយស្មា សុសីមោ ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សុសីមោ យាវតកោ តេហិ ភិក្ខូហិ សទ្ធឹ អហោសិ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ បុព្វេ ខោ សុសីម ធម្មដ្ឋិតិញាណំ

[ ២៨៩ ] សុសិមភិក្ខុសួរថា ម្នាលលោកមានអាយុទាំងឡាយ ឥឡូវនេះ ការដោះស្រាយនេះក្តី ការមិនបានលុះនូវធម៌ទាំងនេះក្តី ក្នុងដំណើរនុះ ម្នាលអាវុសោ ចុះហេតុនេះតើដូចម្តេច ។ ពួកភិក្ខុទាំងនោះតបថា ម្នាលអាវុសោសុសិមៈ យើងទាំងឡាយ ជាបញ្ញាវិមុត្តបុគ្គល គឺជាអ្នករួចស្រឡះចាកកិលេសដោយសារបញ្ញាទេតើ ។ សុសិមភិក្ខុឆ្លើយថា ខ្ញុំមិនទាន់យល់សេចក្តី នៃពាក្យដែលលោកមានអាយុទាំងឡាយសំដែងសង្ខេបហើយនេះ ដោយពិស្តារបានទេ ខ្ញុំសូមអង្វរ សូមលោកមានអាយុទាំងឡាយ សំដែងប្រាប់ខ្ញុំ យ៉ាងណាឲ្យខាងតែខ្ញុំយល់សេចក្តីនៃពាក្យដែលលោកមានអាយុទាំងឡាយសំដែងសង្ខេបហើយនេះ ដោយពិស្តារបាន ។ ពួកភិក្ខុទាំងនោះតបថា ម្នាលអាវុសោសុសិមៈ លោកយល់ក្តី មិនយល់ក្តី យើងទាំងឡាយជាក់ជាបញ្ញាវិមុត្តបុគ្គលដោយពិត ៗ

[ ២៩០ ] គ្រានោះឯង សុសិមភិក្ខុមានអាយុ ក្រោកអំពីអាសនៈចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសុសិមភិក្ខុមានអាយុអង្គុយ ក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូល នូវពាក្យទាំងអស់នោះ ដែលខ្លួនចរចាទាំងប៉ុន្មាន ជាមួយនឹងពួកភិក្ខុទាំងនោះ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសុសិមៈ ធម្មដ្ឋិតិញាណ

បច្ឆា និព្ពានេ ញាណន្តិ ។ ន ខ្វាហំ ភន្តេ ឥមស្ស ភគវតា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាមិ សាធុ មេ ភន្តេ ភគវា តថា ភាសតុ យថាហំ ឥមស្ស ភគវតា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានេយ្យន្តិ ។

(២៩១) អាជានេយ្យាសិ វា សុសិម ន វា ត្វំ អាជានេយ្យាសិ អថខោ ធម្មដ្ឋិតិញ្ញាណំ បុព្វេ បច្ឆា និព្ពានេ ញាណំ ។ តំ កឹ មញ្ញសិ សុសិម រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ

គឺវិបស្សនាញាណ តែងកើតឡើងមុន ការដឹងក្នុងព្រះនិព្វាន គឺមគ្គ-ញាណ តែងកើតឡើងក្រោយ ៗ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចយល់សេចក្តីនៃព្រះពុទ្ធដីកា ដែលព្រះអង្គសំដែងសង្ខេបនេះ ដោយពិស្តារបានទេ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគសំដែងប្រាប់ខ្ញុំព្រះអង្គ យ៉ាងណាឲ្យខាងតែខ្ញុំព្រះអង្គ យល់សេចក្តីនៃព្រះពុទ្ធ-ដីកា ដែលព្រះអង្គសំដែងសង្ខេបនេះ ដោយពិស្តារបានឲ្យបាន ៗ

[៦៩១] ម្នាលសុសិមៈ អ្នកយល់ក្តី អ្នកមិនយល់ក្តី ចំណែកធម្មដ្ឋិតិញាណ តែងកើតឡើងមុន ការដឹងក្នុងព្រះនិព្វាន តែងកើតឡើងក្រោយដោយពិត ម្នាលសុសិមៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ៗ មិនទៀងទេ ព្រះអង្គ ៗ ចុះរបស់ណា

បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ
បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុ-
បស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។
នោ ហេតំ ភន្តេ ។ វេទនា និច្ចា វា អនិច្ចា វាតិ ។
អនិច្ចា ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ
វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិ-
ណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម
ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ
ភន្តេ ។ សញ្ញា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា
ភន្តេ ។បេ។ សង្ខារា និច្ចា វា អនិច្ចា វាតិ ។
អនិច្ចា ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ
វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណា-
មធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោ-
ហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

ដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា ដែលមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះឬទេ ។ មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ព្រះអង្គ ។ វេទនាទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា ដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា ដែលមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញរបស់នោះថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះឬទេ ។ មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ព្រះអង្គ ។ សញ្ញាទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ សង្ខារទាំងឡាយទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា ដែលមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះឬទេ ។ មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ព្រះអង្គ ។

វិញ្ញាណំ ឋិតំ វា អឋិតំ វាតិ ។ អឋិតំ ភន្តេ ។ យំ បនាឋិតំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនាឋិតំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

(២៩២) តស្មាតិហ សុសិម យំ កិញ្ចិ រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ យា កាចិ វេទនា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្វា វេទនា នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ យា កាចិ សញ្ញា ។ បេ ។ យេ កេចិ សង្ខារា អតីតានាគត-

វិញ្ញាណទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា ដែលមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះឬទេ ។ មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ព្រះអង្គ ។

[៤៩២] ម្នាលសុសិមៈ ព្រោះហេតុនោះ រូបណាមួយ ដែលជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះ គ្រាន់តែជារូប (ប៉ុណ្ណោះឯង) បុគ្គលគួរឃើញរូបនុ៎ះដោយបញ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ វេទនាណាមួយដែលជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វេទនាណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វេទនាទាំងអស់នោះ គ្រាន់តែជាវេទនា (ប៉ុណ្ណោះឯង) បុគ្គលគួរឃើញវេទនានុ៎ះដោយបញ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ សញ្ញាណាមួយ ។ បេ ។ សង្ខារទាំងឡាយណាមួយ ដែលជាអតីត

បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា សព្វេ សង្ខារា នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។

(៥៩៣) ឯវំ បស្សំ សុសិម សុតវា អរិយសាវ-កោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញា-យបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ

អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សង្ខារទាំងឡាយណា ដែលមានក្នុងទីឆ្ងាយក្តី មានក្នុងទីជិតក្តី សង្ខារទាំងអស់នោះ គ្រាន់តែជាសង្ខារ ( ប៉ុណ្ណោះឯង ) បុគ្គលគួរឃើញសង្ខារនុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ឡើយ ។ វិញ្ញាណណាមួយ ដែលជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ គ្រាន់តែជាវិញ្ញាណ ( ប៉ុណ្ណោះឯង ) បុគ្គលគួរឃើញវិញ្ញាណនុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។

[២៩៣] ម្នាលសុសិម: អរិយសាវកជាអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ក៏នឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំងឡាយផង នឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយ ( យ៉ាងនេះហើយ ) ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ ( ចាកអាសវៈ ) ព្រោះប្រាសចាកតម្រេក ។ កាលចិត្តផុតស្រឡះ ( ចាកអាសវៈ )

វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។

(២៩៦) ជាតិប្បច្ចយា ជរាមរណន្តិ សុសិម បស្សសីតិ ។ ឯវំ ភន្តេ ។ ភវប្បច្ចយា ជាតីតិ សុសិម បស្សសីតិ ។ ឯវំ ភន្តេ ។ ឧបាទានប្បច្ចយា ភវោតិ សុសិម បស្សសីតិ ។ ឯវំ ភន្តេ ។ តណ្ហាបច្ចយា ឧបាទានន្តិ សុសិម បស្សសីតិ ។ ឯវំ ភន្តេ ។ វេទនាបច្ចយា តណ្ហាតិ... ផស្សប្បច្ចយា វេទនាតិ... សឡាយតនប្បច្ចយា ផស្សោតិ... នាមរូបប្បច្ចយា សឡាយតនន្តិ... វិញ្ញាណប្បច្ចយា នាមរូបន្តិ... សង្ខារប្បច្ចយា វិញ្ញាណន្តិ... អវិជ្ជាបច្ចយា សង្ខារាតិ សុសិម បស្សសីតិ ។ ឯវំ ភន្តេ ។

ហើយ ញាណ (របស់អរិយសាវ័កនោះ) កើតឡើងប្រាកដថា ចិត្តផុតស្រឡះហើយ ។ អរិយសាវ័កនោះ រមែងដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញ បាននៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៩៦] ម្នាលសុសិមៈ អ្នកយល់ឃើញថា ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលសុសិមៈ អ្នកយល់ឃើញថា ជាតិកើតមាន ព្រោះភពជាបច្ច័យដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលសុសិមៈ អ្នកយល់ឃើញថា ភពកើតមាន ព្រោះឧបាទានជាបច្ច័យដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលសុសិមៈ អ្នកយល់ឃើញថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យដែរឬ ។ ព្រះករុណា ព្រះអង្គ ។ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ... វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ... ផស្សៈកើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ... អាយតនៈ ៦ កើតមាន ព្រោះនាមរូបជាបច្ច័យ ... នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ... វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ... ម្នាលសុសិមៈ អ្នកយល់ឃើញថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យដែរឬ ។ ព្រះករុណា ព្រះអង្គ ។

(២៩៥) ជាតិនិរោធា ជរាមរណនិរោធោតិ សុសិម បស្សសីតិ ។ ឯវំ ភន្តេ ។ ភវនិរោធា ជាតិនិរោធោតិ សុសិម បស្សសីតិ ។ ឯវំ ភន្តេ ។ ឧបាទាននិរោធា ភវនិរោធោតិ ... តណ្ហានិរោធា ឧបាទាននិរោធោតិ ... វេទនានិរោធា តណ្ហានិរោធោតិ...ផស្សនិរោធា វេទនានិ-រោធោតិ...សឡាយតននិរោធា ផស្សនិរោធោតិ ... នា-មរូបនិរោធា សឡាយតននិរោធោតិ... វិញ្ញាណនិរោធា នាមរូបនិរោធោតិ...សង្ខារនិរោធា វិញ្ញាណនិរោធោតិ... អវិជ្ជានិរោធា សង្ខារនិរោធោតិ សុសិម បស្សសីតិ ។ ឯវំ ភន្តេ ។

(២៩៦) អបិ នុ ត្វំ សុសិម ឯវំ ជានន្តោ ឯវំ បស្សន្តោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោសិ ឯកោបិ ហុត្វា ពហុធា ហោសិ ពហុធាបិ ហុត្វា ឯកោ ហោសិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ

(២៩៥) ម្នាលសុសិមៈ អ្នកយល់ឃើញថា ការរលត់នៃជរាមរណៈ ព្រោះការរលត់នៃជាតិដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលសុសិមៈ អ្នកយល់ឃើញថា ការរលត់នៃជាតិ ព្រោះការរលត់នៃភពដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ការរលត់នៃភព ព្រោះការរលត់នៃឧបាទាន ... ការរលត់នៃឧបាទាន ព្រោះការរលត់នៃតណ្ហា ... ការរលត់នៃតណ្ហា ... ការរលត់នៃវេទនា ... ការរលត់នៃវេទនា ព្រោះការរលត់នៃផស្សៈ ... ការរលត់នៃផស្សៈ ព្រោះការរលត់នៃអាយតនៈ ៦ ... ការរលត់នៃអាយតនៈ ៦ ព្រោះការរលត់នៃនាមរូប ... ការរលត់នៃនាមរូប ព្រោះការរលត់នៃវិញ្ញាណ ... ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ... ម្នាលសុសិមៈ អ្នកយល់ឃើញថា ការរលត់នៃសង្ខារ ព្រោះការរលត់នៃអវិជ្ជាដែរឬ ។ ព្រះករុណា ព្រះអង្គ ។

(២៩៦) ម្នាលសុសិមៈ ចុះកាលបើអ្នក ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើបាននូវការតាក់តែង ឬសំដែងឫទ្ធិច្រើនប្រការ គឺកាយតែមួយ ធ្វើឲ្យទៅជាកាយច្រើនក៏បាន កាយច្រើន ធ្វើឲ្យទៅជាកាយតែមួយវិញក៏បាន ដើរទៅទីណា ឥតទើសទាល់ គឺនៅក្នុងទីកំបាំង ដើរទៅក្នុងទីវាលក៏បាន នៅខាងក្នុង ដើរចេញទៅខាងក្រៅក៏បាន នៅខាងក្នុងជញ្ជាំង ដើរចេញទៅខាងក្រៅជញ្ជាំង (ដោយឥតទ្វារ ឬផ្លូវ) ក៏បាន នៅខាងក្នុងកំពែង ដើរចេញទៅខាងក្រៅកំពែងក៏បាន

តិរោបព្វតំ អសជ្ជមានោ គច្ឆសិ សេយ្យថាបិ អាកា-
សេ បឋវិយាបិ ឧម្មុជ្ជនិមុជ្ជំ ករោសិ សេយ្យថាបិ
ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆសិ សេយ្យថាបិ
បឋវិយំ អាកាសេបិ បល្លង្កេន កមសិ សេយ្យថាបិ
បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ
ឯវំមហានុភាវេ បាណិនា បរិមសសិ បរិមជ្ជសិ យាវ
ព្រហ្មលោកាបិ កាយេន វសំ វត្តេសីតិ ។ នោ ហេតំ
ភន្តេ ។

(២៩៣) អបិ នុ ត្វំ សុសិម ឯវំ ជានន្តោ ឯវំ
បស្សន្តោ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្ត-
មានុសិកាយ ឧភោ សទ្ទេ សុណាសិ ទិព្វេ ច មានុ-
សេ ច យេ ទូរេ សន្តិកេ ចាតិ ។ នោ ហេតំ ភន្តេ ។

(២៩៤) អបិ នុ ត្វំ សុសិម ឯវំ ជានន្តោ ឯវំ
បស្សន្តោ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ
បរិច្ច បជានាសិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជា-

នៅខាងក្នុង ដើរចេញទៅខាងក្រៅក៏ឥតទើសទាល់ ដូចជាគេដើរទៅក្នុងអាកាសទទេក៏បាន មុជងើបក្នុងផែនដី ដូចជាគេមុជងើបក្នុងទឹកក៏បាន ដើរលើទឹកឥតបែកធ្លាយ ដូចជាគេដើរលើផែនដីក៏បាន ពែនភ្នែនទៅក្នុងអាកាស ដូចជាសកុណជាតិដែលមានស្លាបហើរទៅក្នុងអាកាសក៏បាន យកដៃទៅស្ទាបអង្អែល (មណ្ឌល) ព្រះចន្ទ្រព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើន មានអានុភាពច្រើនយ៉ាងនេះក៏បាន ញុំាងអំណាចកាយឲ្យប្រព្រឹត្តទៅ រហូតដល់ព្រហ្មលោកឆ្ងាយក៏បាន ដែរឬទេ ។ មិនដូច្នោះទេ ព្រះអង្គ ។

[៥៩៧] មាលសុសិមៈ ចុះកាលបើអ្នក ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើមានត្រចៀកដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងហួសត្រចៀកជារបស់មនុស្សធម្មតា រមែងឮសំឡេងពីរប្រការ គឺសំឡេងទិព្វនិងសំឡេងមនុស្ស ដែលនៅក្នុងទីឆ្ងាយឬនៅក្នុងទីជិត ដែរឬទេ ។ មិនដូច្នោះទេ ព្រះអង្គ ។

[៥៩៨] មាលសុសិមៈ ចុះកាលបើអ្នក ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើអាចកំណត់ដឹងចិត្តរបស់សត្វដទៃ របស់បុគ្គលដទៃ ដោយចិត្តរបស់ខ្លួនបាន គឺចិត្តប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកប

នាសិ ។ បេ ។ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជា-នាសីតិ ។ នោ ហេតំ ភន្តេ ។

(២៩៩) អបិ នុ ត្វំ សុសិម ឯវំ ជានន្តោ ឯវំ បស្សន្តោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរសិ សេយ្យថីទំ ឯកម្បិ ជាតឹ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរសីតិ ។ នោ ហេតំ ភន្តេ ។

(៣០០) អបិ នុ ត្វំ សុសិម ឯវំ ជានន្តោ ឯវំ បស្សន្តោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុស-កេន សត្តេ បស្សសិ ចវមានេ ។ បេ ។ យថាកម្មូ-បគេ សត្តេ បជានាសីតិ ។ នោ ហេតំ ភន្តេ ។

(៣០១) អបិ នុ ត្វំ សុសិម ឯវំ ជានន្តោ ឯវំ បស្សន្តោ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ កាយេន ផុសិត្វា វិហរសីតិ ។ នោ ហេតំ ភន្តេ ។

ដោយភាគៈ ។ បេ ។ ចិត្តមិនទាន់ផុតស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់ផុតស្រឡះ ដែរឬទេ ។ មិនដូច្នោះទេ ព្រះអង្គ ។

(២៩៩) ម្នាលសុសិមៈ ចុះកាលបើអ្នក ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើរឭកឃើញបុព្វេនិវាស បានជាច្រើនប្រការ គឺរឭកឃើញបាន ១ ជាតិ ។ បេ ។ អ្នករឭកឃើញបុព្វេនិវាស បានជាច្រើនប្រការ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ដែរឬទេ ។ មិនដូច្នោះទេ ព្រះអង្គ ។

(៣០០) ម្នាលសុសិមៈ ចុះកាលបើអ្នក ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញពួកសត្វកាលច្យុត ។ បេ ។ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដែរឬទេ ។ មិនដូច្នោះទេ ព្រះអង្គ ។

(៣០១) ម្នាលសុសិមៈ ចុះកាលបើអ្នក ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ តើកន្លងនូវរូបជ្ឈាន ហើយបាននូវអារុប្បវិមោក្ខ ដែលជាធម៌ស្ងប់រម្ងាប់ ដោយនាមកាយ ហើយសម្រេចនៅ ដែរឬទេ ។ មិនដូច្នោះទេ ព្រះអង្គ ។

(៣០២) ឯត្ថទានិ សុសិម ឥទញ្ច វេយ្យាករណំ ឥមេសញ្ច ធម្មានំ អសមាបត្តិ ឥទំ នោ សុសិម ក-ថន្តិ ។ អថខោ អាយស្មា សុសិមោ ភគវតោ បាទេ-សុ សិរសា និបតិត្វា ភគវន្តំ ឯតទវោច អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោហំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ ធម្មត្ថេនកោ បព្ពជិតោ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។

(៣០៣) តគ្ឃ ត្វំ សុសិម អច្ចយោ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោ ត្វំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ ធម្មត្ថេនកោ បព្ពជិតោ សេយ្យថាបិ សុសិម ចោរំ អាគុចារឹ គហេត្វា រញ្ញោ ទស្សេយ្យុំ អយំ តេ ទេវ ចោរោ អាគុចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ តមេនំ រាជា

(៣០២) ម្នាលសុសិមៈ ឥឡូវនេះ ការដោះស្រាយនេះក្ដី ការមិនបានលុះធម៌ទាំងនេះក្ដី ក្នុងដំណើរនោះ ម្នាលសុសិមៈ ចុះហេតុនេះ តើដូចម្ដេច ។ គ្រានោះឯង ព្រះសុសិមៈមានអាយុ ក្រាបចុះទៀបព្រះបាទា នៃព្រះមានព្រះភាគ ដោយសិរ្សៈ ពោលខមាទោសនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កំហុសគ្របសង្កត់ហើយនូវខ្ញុំព្រះអង្គ តាមដោយខ្ញុំព្រះអង្គជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ខ្ញុំព្រះអង្គណា ជាអ្នកលួចធម៌ បួសក្នុងធម្មវិន័យ ដែលព្រះអង្គសំដែងហើយដោយប្រពៃ យ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ អត់នូវកំហុសតាមទោស របស់ខ្ញុំព្រះអង្គនោះ ដើម្បីការសង្រួមតទៅ ។

(៣០៣) អើសុសិមៈ កំហុសគ្របសង្កត់អ្នក តាមដោយអ្នកជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាសមែន អ្នកឯងដែលជាអ្នកលួចធម៌ បួសក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយដោយប្រពៃ យ៉ាងនេះ ម្នាលសុសិមៈ ដូចពួករាជបុរសចាប់បានចោរដែលប្រព្រឹត្តអាក្រក់ នាំមកថ្វាយព្រះរាជាថា បពិត្រព្រះសម្មតិទេព នេះជាចោរ ប្រព្រឹត្តអាក្រក់នឹងព្រះអង្គ ព្រះអង្គទ្រង់សព្វព្រះហឫទ័យដាក់អាជ្ញាណា ដល់ចោរនេះ សូមព្រះអង្គដាក់អាជ្ញានោះចុះ ទើបព្រះរាជា

ឯវំ វទេយ្យុ គច្ឆថ ភោ ឥមំ បុរិសំ ទឡ្ហាយ រជ្ជុយា
បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា
ខរស្សរេន បណវេន រថិយា រថិយំ សិង្ឃាដកេន
សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខាមេត្វា
ទក្ខិណតោ នគរស្ស សីសំ ឆិន្ទថាតិ តមេនំ រញ្ញោ
បុរិសា ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ
ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយា
រថិយំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន
ទ្វារេន និក្ខាមេត្វា ទក្ខិណតោ នគរស្ស សីសំ
ឆិន្ទេយ្យុំ តំ កឹ មញ្ញសិ សុសិម អបិ នុ សោ
បុរិសោ តតោនិទានំ ទុក្ខទោមនស្សំ បដិសំវេទេយ-
ថាតិ ។ ឯវំ ភន្តេ ។

មានព្រះបន្ទូលនឹងរាជបុរសនោះយ៉ាងនេះថា នែប្រសន៍ទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរនាំគ្នាចងបុរសនេះ ឲ្យបានដើមដៃទៅខាងក្រោយ ( ចងស្លាបសេក ) ឲ្យខ្ជាប់ ដោយខ្សែដ៏មាំ កោរក្បាលឲ្យរលីងចេញហើយ ( ត្រខួង ) ស្គរដ៏យដែលមានសំឡេងឮខ្លាំង នាំបណ្តើរជុំវិញសព្វច្រក សព្វផ្លូវត្រឡែងកែង នាំចេញទៅតាមទ្វារខាងត្បូងហើយ ចូរកាត់ក្បាលត្រង់កន្លែងសម្រាប់ពិឃាត ជាខាងត្បូងនៃព្រះនគរចុះ ឯពួករាជបុរស នាំគ្នាចាប់ចងបុរសនោះ ឲ្យមានដើមដៃទៅខាងក្រោយឲ្យខ្ជាប់ ដោយខ្សែដ៏មាំ កោរក្បាលឲ្យរលីងចេញ ( ខួង ) ស្គរដ៏យដែលមាន សំឡេងឮខ្លាំង នាំបណ្តើរជុំវិញ សព្វច្រក សព្វផ្លូវត្រឡែងកែង រួចនាំ ចេញទៅតាមទ្វារខាងត្បូង កាត់ក្បាលនៅខាងត្បូងនៃព្រះនគរ ម្នាល សុសិមៈ អ្នកសំគាល់សេចក្តីនោះថាដូចម្តេច បុរសនោះ គប្បីទទួលទុក្ខ ទោមនស្ស ព្រោះដំណើរនោះជាហេតុដែរឬទេ ៗ ព្រះករុណា ព្រះអង្គ ៗ

(៣០៤) យំ ខោ សោ សុសិម បុរិសោ តតោនិទានំ ទុក្ខទោមនស្សំ បដិសំវេទេយ្យ យា ឯវំ ស្វាក្ខាតេ ធម្មវិនយេ ធម្មត្ថេនកស្ស បព្វជ្ជា អយំ តតោ ទុក្ខវិ-បាកតរា ច កដុកវិបាកតរា ច អបិច វិនិបាតាយ សំវត្តតិ យតោ ច ខោ ត្វំ សុសិម អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តន្តេ មយំ បដិគ្គណ្ហាម វុឌ្ឍិ ហេសា សុសិម អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតីតិ ។ ទសមំ ។

មហាវគ្គោ សត្តមោ ។

(៣០៤) ម្នាលសុសិមៈ បុរសនោះ ទទួលទុក្ខទោមនស្ស ព្រោះដំណើរនោះ ជាហេតុណា បព្វជ្ជាណា របស់បុគ្គលអ្នកលួចធម៌ ក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយដោយប្រពៃ យ៉ាងនេះ បព្វជ្ជានេះ មានទុក្ខវិបាកខ្លាំងផង មានវិបាកខ្លោចផ្សាខ្លាំងផង ជាងហេតុនោះទៅទៀត មិនតែប៉ុណ្ណោះ បព្វជ្ជានេះ រមែងប្រព្រឹត្តទៅក្នុងវិនិបាត-កំណើត ។ ម្នាលសុសិមៈ កាលណាបើអ្នកឃើញទោសតាមទោសហើយ សំដែងទោសឲ្យស្មមគួរតាមធម៌ តថាគតទទួលអត់ទោសដល់អ្នកនោះបាន ម្នាលសុសិមៈ នេះឯង ជាសេចក្ដីចម្រើន ក្នុងវិន័យរបស់អរិយៈ នៃបុគ្គលដែលឃើញទោសតាមទោស ហើយសំដែងទោសតាមធម៌ ដល់នូវសេចក្ដីសង្រួមតទៅដោយពិត ។ ចប់សូត្រ ទី ១០ ។

ចប់ មហាវគ្គ ទី ៣ ។

## តស្សុទ្ទានំ

ទ្វេ អស្សុតវតា វុត្តា

បុត្តមំសេន ចាបរំ

អត្ថិរាគោ ច នគរំ

សម្មសំ នឡកលាបិយំ(1)

កោសម្ពី ឧបយន្តិ ច

ទសមោ វុត្តោ សុសិមេន(2)តិ ។

---

១ ឱ. នឡកាលាបិយំ ។ ២ សុសមេន បាតិ ។

អភិសមយសំយុត្ត មហាវគ្គ អំពីឧទ្ទាន

# បញ្ជីរឿងនៃមហាវគ្គនោះគឺ

និយាយអំពីបុគ្គល ២ ពួក គឺបុគ្គលអ្នកមិនចេះដឹង និងបុគ្គលអ្នកចេះដឹង ដែលព្រះមានព្រះភាគត្រាស់ហើយ ១ អំពីបរិភោគដូចបរិភោគសាច់កូន ១ អំពីធម៌មានរាគៈជាដើមដែលមាន និងមិនមានក្នុងអាហារ ១ អំពីអដ្ឋង្គិកមគ្គដូចផ្លូវទៅកាន់បុរាណនគរ ១ អំពីការពិចារណានូវបដិច្ចសមុប្បាទ ១ អំពីនាមរូបដូចបាច់បបុះ ១ អំពីធម្មកថិកនៅក្នុងក្រុងកោសម្ពី ១ អំពីបដិច្ចសមុប្បាទចម្រើនឡើង និងថយកម្លាំងដូចមហាសមុទ្រជោរនាច ១ អំពីសុសិមបរិព្វាជក ១ ត្រូវជា ១០ ។

# សមណព្រាហ្មណវគ្គោ

(៣០៥) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

(៣០៦) តត្រ ខោ ភគវា ... យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ជរាមរណំ នប្បជា-នន្តិ ជរាមរណសមុទយំ នប្បជានន្តិ ជរាមរណនិរោធំ នប្បជានន្តិ ជរាមរណនិរោធគាមិនឹ បដិបទំ នប្ប-ជានន្តិ ន មេតេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បន តេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

(៣០៧) យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ជរាមរណំ បជានន្តិ ។បេ។ តេ ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា

# សមណព្រាហ្មណវគ្គ

(៣០៥) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

(៣០៦) ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់នូវជរានិងមរណៈ មិនដឹងច្បាស់នូវហេតុឲ្យកើតជរានិងមរណៈ មិនដឹងច្បាស់នូវសេចក្តីរលត់ជរានិងមរណៈ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់ជរានិងមរណៈ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនោះ មិនរាប់ថាជាសមណៈ ក្នុងពួកសមណៈផង មិនរាប់ថាជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍ផង មិនតែប៉ុណ្ណោះ សមណព្រាហ្មណ៍មានអាយុទាំងនោះ រមែងមិនធ្វើឲ្យជាក់ច្បាស់សម្រេច នូវសាមញ្ញផល ឬព្រហ្មញ្ញផល ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ក្នុងបច្ចុប្បន្នឡើយ ។

(៣០៧) ម្នាលភិក្ខុទាំងឡាយ លុះតែពួកសមណៈឬព្រាហ្មណ៍ណាមួយ ដឹងច្បាស់នូវជរានិងមរណៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ ទាំងអម្បាលនោះឯង ទើបរាប់ថាជាសមណៈ ក្នុងពួកសមណៈផង រាប់ថាជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍ផង

តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ សុត្តន្តោ ឯកោ ។

(៣០៨) ឯវម្មេ សុតំ ។ បេ ។ ជាតឹ នប្បជានន្តិ ។ បេ ។ ភវំ នប្បជានន្តិ ... ឧបាទានំ នប្បជានន្តិ ... តណ្ហំ នប្បជានន្តិ ... វេទនំ នប្បជានន្តិ ... ផស្សំ នប្បជានន្តិ សឡាយតនំ នប្បជានន្តិ ... នាមរូបំ នប្បជានន្តិ ... វិញ្ញាណំ នប្បជានន្តិ ... សង្ខារេ នប្បជានន្តិ សង្ខារសមុទយំ នប្បជានន្តិ សង្ខារនិរោធំ នប្បជានន្តិ សង្ខារនិរោធគាមិនឹ បដិបទំ នប្បជានន្តិ ។ បេ ។ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ ឯកាទសមំ ។

សមណព្រាហ្មណវគ្គោ អដ្ឋមោ ។

មិនតែប៉ុណ្ណោះ ពួកសមណព្រាហ្មណ៍មានអាយុទាំងនោះ រមែងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផលផង នូវព្រហ្មញ្ញផលផង ដោយប្រាជ្ញាដ៏ឧត្ដមរបស់ខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ចប់សូត្រ ទី ១០ ។

( ៣០៨ ) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ បេ ។ មិនដឹងច្បាស់នូវជាតិ ។ បេ ។ មិនដឹងច្បាស់នូវភព ... មិនដឹងច្បាស់នូវឧបាទាន ... មិនដឹងច្បាស់នូវតណ្ហា ... មិនដឹងច្បាស់នូវវេទនា ... មិនដឹងច្បាស់នូវផស្សៈ ... មិនដឹងច្បាស់នូវអាយតនៈ ៦ ... មិនដឹងច្បាស់នូវនាមរូប ... មិនដឹងច្បាស់នូវវិញ្ញាណ ... មិនដឹងច្បាស់នូវសង្ខារទាំងឡាយ មិនដឹងច្បាស់នូវហេតុឲ្យកើតសង្ខារ មិនដឹងច្បាស់នូវសេចក្ដីរលត់សង្ខារ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្ដីរលត់សង្ខារ ។ បេ ។ ធ្វើឲ្យជាក់ច្បាស់ សម្រេច ដោយប្រាជ្ញាដ៏ឧត្ដមរបស់ខ្លួនឯង ។ ចប់សូត្រ ទី ១១ ។

ចប់ សមណព្រាហ្មណវគ្គ ទី ៨ ។

## តស្សុទ្ទានំ

បច្ចយោ ចា ទស វុត្តា
ចតុស្សច្ចិកដ្ឋា
សមណព្រាហ្មណា វុត្តា
និទានំ ភវតិ អដ្ឋមំ ។

## វគ្គស្សុទ្ទានំ

ពុទ្ធោ អាហារទសពលោ
កឡារំ គហបតិបញ្ចមំ
ទុក្ខវគ្គោ មហាវគ្គោ
អដ្ឋមំ សមណព្រាហ្មណាន្តិ ។

## បញ្ជីរឿងនៃសមណព្រាហ្មណវគ្គនោះគឺ

ការចែកនូវសច្ចៈ ៤ មានបច្ច័យ ១១ ព្រះមានព្រះភាគត្រាស់ ហើយ សមណព្រាហ្មណវគ្គ មាននិទានជាគម្រប់ ៨ ។

## បញ្ជីនៃវគ្គគឺ

ពុទ្ធវគ្គ ១ អាហារវគ្គ ១ ទសពលវគ្គ ១ កឡារខត្តិយវគ្គ ១ គហបតិវគ្គ ១ ជាគម្រប់ ៥ ទុក្ខវគ្គ ១ មហាវគ្គ ១ សមណព្រាហ្មណវគ្គ ១ ត្រូវជាគម្រប់ ៨ ។

# អន្តរបេយ្យាលោ

(៣០៩) សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ជរាមរណំ ភិក្ខវេ អជានតា អបស្សតា យថាភូតំ ជរាមរណេ យថាភូតំ ញាណាយ សត្ថា បរិយេសិតព្វោ ជរាមរណសមុទយំ អជានតា អបស្សតា យថាភូតំ ជរាមរណសមុទយេ យថាភូតំ ញាណាយ សត្ថា បរិយេសិតព្វោ ជរាមរណនិរោធំ អជានតា អបស្សតា យថាភូតំ ជរាមរណនិរោធេ យថាភូតំ ញាណាយ សត្ថា បរិយេសិតព្វោ ជរាមរណនិរោធគាមិនឹ បដិបទំ អជានតា អបស្សតា យថាភូតំ ជរាមរណនិរោធគាមិនិយា បដិបទាយ យថាភូតំ ញាណាយ សត្ថា បរិយេសិតព្វោតិ[១] ។

( សត្ថុសំ ឃរិ បេយ្យាលោ ) ។

---

១ កត្ថចិ សុត្តន្តោ ឯកោ ឥតិ វា ឈហោ ទិស្សតិ ។

# អន្តរបេយ្យាលៈ

(៣០៩) ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវជរាមរណៈតាមពិតទេ គប្បីស្វែងរកសាស្តា ដើម្បីការដឹងក្នុងជរាមរណៈតាមពិត បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវហេតុ ដែលនាំឲ្យកើតជរាមរណៈតាមពិតទេ គប្បីស្វែងរកសាស្តា ដើម្បីការដឹងក្នុងហេតុដែលនាំឲ្យកើតជរាមរណៈតាមពិត បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវសេចក្តីរលត់ជរាមរណៈតាមពិតទេ គប្បីស្វែងរកសាស្តា ដើម្បីការដឹងក្នុងសេចក្តីរលត់ជរាមរណៈតាមពិត បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវបដិ-បទា ជាដំណើរទៅកាន់សេចក្តីរលត់ជរាមរណៈតាមពិតទេ គប្បីស្វែងរកសាស្តា ដើម្បីការដឹងក្នុងបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់ជរាមរណៈតាមពិត ។

(ការបំប្រួញនៃបទទាំងអស់យ៉ាងនេះឯង) ។

ជាតឹ ភិក្ខវេ អជានតា អបស្សតា យថាភូតំ ...ភវំ ភិក្ខវេ អជានតា អបស្សតា យថាភូតំ ... ឧបាទានំ ភិក្ខវេ អជានតា អបស្សតា យថាភូតំ...តណ្ហំ ភិក្ខវេ អជានតា អបស្សតា យថាភូតំ ... វេទនំ ភិក្ខវេ អជានតា អបស្សតា យថាភូតំ ... ផស្សំ ភិក្ខវេ អជានតា អបស្សតា យថាភូតំ ...សឡាយតនំ ភិក្ខវេ អជានតា អបស្សតា យថាភូតំ ... នាមរូបំ ភិក្ខវេ អជានតា អបស្សតា យថាភូតំ... វិញ្ញាណំ ភិក្ខវេ អជានតា អបស្សតា យថាភូតំ ... សង្ខារេ ភិក្ខវេ អជានតា អបស្សតា យថាភូតំ សង្ខារេសុ យថាភូតំ ញាណាយ សត្ថា បរិយេសិតព្វោ សង្ខារសមុទយំ អជានតា អបស្សតា យថាភូតំ សង្ខារសមុទយេ យថាភូតំ ញាណាយ សត្ថា បរិយេសិតព្វោ សង្ខារនិរោធំ អជានតា អបស្សតា យថាភូតំ

ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវជាតិតាមពិតទេ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវភពតាមពិតទេ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវឧបាទានតាមពិតទេ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវតណ្ហាតាមពិតទេ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវវេទនាតាមពិតទេ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវផស្សៈតាមពិតទេ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវអាយតនៈ ៦ តាមពិតទេ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវនាមរូបតាមពិតទេ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវវិញ្ញាណតាមពិតទេ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវសង្ខារទាំងឡាយតាមពិតទេ គប្បីស្វែងរកសាស្តា ដើម្បីការដឹងក្នុងសង្ខារទាំងឡាយតាមពិត បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវហេតុ ដែលនាំឲ្យកើតសង្ខារតាមពិតទេ គប្បីស្វែងរកសាស្តា ដើម្បីការដឹងក្នុងហេតុ ដែលនាំឲ្យកើតសង្ខារតាមពិត បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញនូវសេចក្តីរលត់សង្ខារតាមពិតទេ

សង្ខារនិរោធេ យថាភូតំ ញាណាយ សត្ថា បរិយេសិតព្វោ សង្ខារនិរោធគាមិនី បដិបទំ អជានតា អបស្សតា យថាភូតំ សង្ខារនិរោធគាមិនិយា បដិបទាយ យថាភូតំ ញាណាយ សត្ថា បរិយេសិតព្វោតិ ។

(សព្វេសំ ចតុសច្ចិកំ កាតព្វំ សុត្តន្តា ឯកោ)។

[៣១០] ជរាមរណំ ភិក្ខវេ អជានតា អបស្សតា យថាភូតំ ជរាមរណេ យថាភូតំ ញាណាយ សិក្ខា ករណីយា ។

(ឯវំ បេយ្យាលោ ចតុសច្ចិកំ កាតព្វំ) ។

យោគោ ករណីយោ...ឆន្ទោ ករណីយោ...ឧស្សោឡ្ហី ករណីយា...អប្បដិវានី ករណីយា...អាតប្បំ ករណីយំ...វីរិយំ ករណីយំ...សាតច្ចំ ករណីយំ...សតិ ករណីយា...សម្បជញ្ញំ ករណីយំ...អប្បមាទោ ករណីយោតិ ។

អន្តរបេយ្យាលោ នវមោ ។

គប្បីស្វែងរកសាស្តា ដើម្បីការដឹងក្នុងសេចក្តីរលត់សង្ខារតាមពិត បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញ នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់សង្ខារតាមពិតទេ គប្បីស្វែងរកសាស្តា ដើម្បីការដឹងក្នុងបដិបទាជាដំណើរទៅកាន់សេចក្តីរលត់សង្ខារតាមពិត ។

(គប្បីធ្វើបច្ច័យនៃបទទាំងអស់ឲ្យប្រកបដោយសច្ចៈ ៤ សូត្រ ទី ១) ។

(៣១០) ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនទាន់ដឹង មិនទាន់ឃើញ នូវជរាមរណៈតាមពិតទេ គប្បីធ្វើការសិក្សា ដើម្បីការដឹងក្នុងជរាមរណៈតាមពិត ។

(ត្រូវធ្វើនូវការបំប្រួញបច្ច័យឲ្យប្រកបដោយសច្ចៈ ៤ យ៉ាងនេះ)

គប្បីធ្វើការប្រកបព្យាយាម ... គប្បីធ្វើសេចក្តីពេញចិត្តក្នុងកុសល ... គប្បីធ្វើសេចក្តីប្រឹងប្រែងដ៏មាំ ... គប្បីធ្វើសេចក្តីព្យាយាមមិនរួញរា ... គប្បីធ្វើសេចក្តីព្យាយាមដុតកំដៅកិលេស ... គប្បីធ្វើសេចក្តីព្យាយាមខ្នះខ្នែង ... គប្បីធ្វើសេចក្តីព្យាយាមរឿយ ៗ ... គប្បីធ្វើសេចក្តីរឭក ... គប្បីធ្វើសេចក្តីដឹងខ្លួន ... គប្បីធ្វើសេចក្តីមិនប្រមាទ ។

ចប់ អន្តរបេយ្យាល ទី ៩ ។

# តស្សុទ្ទានំ

សត្ថា សិក្ខា ច យោគោ ច
ឆន្ទោ ឧស្សោឡ្ហិ បញ្ចមី
អប្បដិវានិយាតប្បំ
វីរិយំ សាតច្ច វុច្ចតិ
សតិ ច សម្បជញ្ញញ្ច
អប្បមាទេន ទ្វាទសាតិ ។

សុត្តា អន្តរបេយ្យាលា និដ្ឋិតា ។

បរេ តេ ទ្វាទស ហោន្តិ
សុត្តា ទ្វត្តឹស សតានិ ច
ចតុស្សច្ចេន តេ វុត្តា
បេយ្យាលា អន្តរម្ហិ យេតិ ។

អន្តរបេយ្យាលេសុ ឧទ្ទានំ សមត្តំ ។

សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ

## បញ្ជីរឿងនៃអន្តរបេយ្យាលៈនោះគឺ

ការស្វែងរកសាស្តា ១ ការសិក្សា ១ ការប្រកបព្យាយាម ១ សេចក្តីពេញចិត្តក្នុងកុសល ១ សេចក្តីប្រឹងប្រែងដ៏មាំ ១ ជាទី ៥ សេចក្តីព្យាយាមមិនរួញរា ១ សេចក្តីព្យាយាមដុតកំដៅកិលេស ១ សេចក្តីខ្នះខ្នែង ១ សេចក្តីព្យាយាមរឿយ ៗ ១ សេចក្តីរឭក ១ សេចក្តីដឹងខ្លួន ១ សេចក្តីមិនប្រមាទ ១ ត្រូវ ១២ ។

ចប់ សូត្រជាអន្តរបេយ្យាលៈ ។

សូត្រក្រៅពីនេះ មាន ១២ ផង មាន ១៣២ ផង បេយ្យាលៈណា មានក្នុងបន្ទោះ បេយ្យាលៈនោះ ព្រះអង្គសំដែងហើយដោយសច្ចៈ ៤ ។

ចប់ បញ្ជីរឿងក្នុងអន្តរបេយ្យាលៈ ។

# អភិសមយវគ្គោ

(៣១១) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ភគវា បរិត្តំ នខសិខាយ បំសុំ អារោបេត្វា ភិក្ខូ អាមន្តេសិ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុខោ ពហុតរំ យោ វាយំ មយា បរិត្តោ នខសិខាយ បំសុ អារោបិតោ អយំ ច មហាបថវីតិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ មហាបថវី អប្បមត្តកោ ភគវតា បរិត្តោ នខសិខាយ បំសុ អារោបិតោ នេវ សតិមំ កលំ ឧបេតិ ន សហស្សិមំ កលំ ឧបេតិ ន សតសហស្សិមំ កលំ ឧបេតិ មហាបថវឹ ឧបនិធាយ ភគវតា បរិត្តោ នខសិខាយ បំសុ អារោបិតោតិ ។

# អភិសមយវគ្គ

(៣១១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចាប់លើកអាចម៍ដីបន្តិច ដោយចុងព្រះនខៈ រួចទ្រង់ត្រាស់សួរពួកភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ហេតុនោះដូចម្តេច អាចម៍ដីបន្តិច ដែលតថាគតចាប់លើកដោយចុងក្រចកនេះ និងមហាប្រឹថពីនេះ តើណាច្រើនជាង ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មហាប្រឹថពីច្រើនជាង អាចម៍ដីបន្តិច ដែលព្រះអង្គចាប់លើកដោយចុងព្រះនខៈនុ៎ះ មានប្រមាណតិចណាស់ អាចម៍ដីបន្តិច ដែលព្រះអង្គចាប់លើកដោយចុងព្រះនខៈ យកទៅប្រៀបធៀបនឹងមហាប្រឹថពី មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

(៣១២) ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស អភិសមេតាវិនោ ឯតទេវ ពហុតរំ ទុក្ខំ យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្ប-មត្តកំ អវសិដ្ឋំ នេវ សតិមំ កលំ ឧបេតិ ន ស-ហស្សិមំ កលំ ឧបេតិ ន សតសហស្សិមំ កលំ ឧបេតិ បុរិមំ ទុក្ខក្ខន្ធំ បរិក្ខីណំ បរិយាទិន្នំ ឧប-និធាយ យទិទំ សត្តក្ខត្តុបរមតា ។ ឯវំ មហត្ថិយោ ខោ ភិក្ខវេ ធម្មាភិសមយោ ឯវំ មហត្ថិយោ ធម្ម-ចក្ខុប្បដិលាភោតិ ។ បឋមំ ។

( ៣១៥ ) ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូចបុគ្គលជាអរិយសាវ័ក ជាអ្នកបរិបូណ៌ដោយទិដ្ឋិ ត្រាស់ដឹងនូវអរិយសច្ច រមែងមានសេចក្តីទុក្ខដែលអស់ទៅ រីងស្ងួតទៅ ច្រើនជាង ឯសេចក្តីទុក្ខដែលសល់នៅ សំដៅយកត្រឹម ៧ អត្តភាព មានប្រមាណតិចណាស់ មិនដល់នូវចំណែកមួយ គុណនឹងមួយរយចំណែក មិនដល់នូវចំណែកមួយ គុណនឹងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ គុណនឹងមួយសែនចំណែក ដោយការប្រៀបធៀបនឹងគំនរទុក្ខអំពីមុន ដែលអស់ទៅ សាបសូន្យទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ ការត្រាស់ដឹងធម៌ មានប្រយោជន៍ច្រើនយ៉ាងនេះ ការបានធម្មចក្ខុ មានប្រយោជន៍ច្រើនយ៉ាងនេះ ។ ចប់សូត្រ ទី ១ ។

(៣១៣) សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ...

សេយ្យថាបិ ភិក្ខវេ បោក្ខរណី បញ្ញាសយោជនា អាយាមេន បញ្ញាសយោជនា វិត្ថារេន បញ្ញាសយោជនា ឧព្វេធេន បុណ្ណា ឧទកស្ស សមតិត្តិកា កាកបេយ្យា តតោ បុរិសោ កុសគ្គេន ឧទកំ ឧទ្ធរេយ្យ ។ តំ កិំ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា កុសគ្គេន ឧទកំ ឧព្ភតំ យំ វា បោក្ខរណិយា ឧទកន្តិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ បោក្ខរណិយា ឧទកំ អប្បមត្តកំ កុសគ្គេន ឧទកំ ឧព្ភតំ នេវ សតិមំ កលំ ឧបេតិ ន សហស្សិមំ កលំ ឧបេតិ ន សតសហស្សិមំ កលំ ឧបេតិ បោក្ខរណិយា ឧទកំ ឧបនិធាយ កុសគ្គេន ឧទកំ ឧព្ភតន្តិ ។

[ ៣១៣ ] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចជាស្រះបោក្ខរណី មានបណ្ដោយ ៥០ យោជន៍ ទទឹង ៥០ យោជន៍ ជម្រៅ ៥០ យោជន៍ ពេញដោយទឹកស្មើមាត់ច្រាំង ល្មមក្អែកទុំទឹកបាន មានបុរសម្នាក់ទៅដួសទឹកអំពីស្រះនោះ ដោយចុងស្បូវ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ សំគាល់ហេតុនោះដូចម្ដេច ទឹកដែលបុរសដួសដោយចុងស្បូវ និងទឹកក្នុងស្រះបោក្ខរណី តើណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ទឹកក្នុងស្រះបោក្ខរណីនេះច្រើនជាង ទឹកដែលបុរសដួសឡើងដោយចុងស្បូវ មានប្រមាណតិចណាស់ ទឹកដែលបុរសដួសឡើងដោយចុងស្បូវ យកទៅប្រៀបធៀបនឹងទឹកក្នុងស្រះបោក្ខរណី មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

(៣១៦) ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស អភិសមេតាវិនោ ឯតទេវ ពហុតរំ ទុក្ខំ យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តកំ អវសិដ្ឋំ នេវ សតិមំ កលំ ឧបេតិ ន សហស្សិមំ កលំ ឧបេតិ ន សតសហស្សិមំ កលំ ឧបេតិ បុរិមំ ទុក្ខក្ខន្ធំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ យទិទំ សត្តក្ខត្តុបរមតា ។ ឯវំ មហត្ថិយោ ខោ ភិក្ខវេ ធម្មាភិសមយោ ឯវំ មហត្ថិយោ ធម្មចក្ខុប្បដិលាភោតិ ។ ទុតិយំ ។

(៣១៧) សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... សេយ្យថាបិ ភិក្ខវេ យត្ថិមា មហានទិយោ សំសន្ទន្តិ សមេន្តិ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី តតោ បុរិសោ ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧទ្ធរេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យានិ វា ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧព្ភតានិ យំ វា សម្ភេជ្ជឧទកន្តិ ។ ឯតទេវ ភន្តេ

( ៣១៤ ) ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូចបុគ្គល ជាអរិយសាវ័ក ជាអ្នកបរិបូណ៌ដោយទិដ្ឋិ ត្រាស់ដឹងនូវអរិយសច្ចរមែងមានទុក្ខដែលអស់ទៅ សាបសូន្យទៅ ច្រើនជាង ឯទុក្ខដែលសល់នៅ សំដៅយកត្រឹម ៧ អត្តភាព មានប្រមាណតិចណាស់ មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែក ដោយការប្រៀបធៀបនឹងកងទុក្ខដែលអស់ទៅ សាបសូន្យទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ ការត្រាស់ដឹងធម៌ មានប្រយោជន៍ច្រើនយ៉ាងនេះ ការបានធម្មចក្ខុ មានប្រយោជន៍ច្រើនយ៉ាងនេះ ។ ចប់សូត្រ ទី ៤ ។

( ៣១៥ ) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯងព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចទន្លេទាំងនេះ គឺទន្លេគង្គា យមុនា អចិរវតី សរភូ មហី តែងហូរមកប្រសព្វលោយចូលគ្នា ក្នុងទីណា បុរសម្នាក់ទៅដួសយកតំណក់ទឹកពីរបីតំណក់ អំពីទីនោះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ហេតុនោះ ដូចម្តេច តំណក់ទឹកពីរបីតំណក់ដែលបុរសនោះដួស និងទឹកដែលហូរមកប្រសព្វលោយចូលគ្នា តើណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន

ពហុតរំ យទិទំ សមេ្ភជ្ជឧទកំ អប្បមត្តកានិ ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧព្ភតានិ នេវ សតិមំ កលំ ឧបេន្តិ ន សហស្សិមំ កលំ ឧបេន្តិ ន សតសហស្សិមំ កលំ ឧបេន្តិ សមេ្ភជ្ជឧទកំ ឧបនិធាយ ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧព្ភតានីតិ ។

(៣១៦) ឯវមេវ ខោ ភិក្ខវេ ។បេ។ ឯវំ មហត្ថិយោ ធម្មចក្ខុប្បដិលាភោតិ ។ នវមំ ។

(៣១៧) សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... សេយ្យថាបិ ភិក្ខវេ យត្ថិមា មហានទិយោ សំសន្ទន្តិ សមេន្តិ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី តំ ឧទកំ បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ឋបេត្វា

ទឹកដែលហូរមកប្រសព្វលាយចូលគ្នានុ៎ះឯង ច្រើនជាង តំណក់ទឹកពីរបីតំណក់ដែលបុរសដួសនុ៎ះ មានប្រមាណតិចណាស់ តំណក់ទឹកពីរបីតំណក់ដែលបុរសដួសនោះ យកទៅប្រៀបធៀបនឹងទឹក ដែលហូរមកប្រសព្វលាយចូលគ្នា មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

(៣១៦) ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះ មានឧបមេយ្យដូច ។ បេ ។ ការបាននូវធម្មចក្ខុ មានប្រយោជន៍ច្រើនយ៉ាងនេះ ។ ចប់ សូត្រ ទី ៣ ។

(៣១៧) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចទន្លេទាំងនេះ គឺទន្លេគង្គា យមុនា អចិរវតី សរភូ មហី តែងហូរមកប្រសព្វលាយចូលស្មើគ្នា ក្នុងទីណា ទឹកនោះគប្បីអស់ទៅ រីងស្ងួតទៅ ក្នុងទីនោះ វៀរលែង

ទ្វេ វា តីណិ វា ឧទកផុសិតានិ ។ តំ កិំ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា សមុទ្ទឧទកំ បរិក្ខីណំ បរិយាទិន្នំ យានិ វា ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានីតិ ។ ឯតទេវ ភន្តេ ពហុតរំ សមុទ្ទឧទកំ យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តកានិ ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានិ នេវ សតិមំ កលំ ឧបេន្តិ ន សហស្សិមំ កលំ ឧបេន្តិ ន សតសហស្សិមំ កលំ ឧបេន្តិ សមុទ្ទឧទកំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានីតិ ។

(៣១៨) ឯវមេវ ខោ ភិក្ខវេ ។បេ។ ឯវំ មហត្ថិយោ ធម្មចក្ខុប្បដិលាភោតិ ។ ចតុត្ថំ ។

តែតំណក់ទឹកពីរបីតំណក់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះដូចម្តេច ទឹកដែលហូរមកប្រសព្វលាយចូលគ្នា ដែលអស់ទៅ រីងស្ងួតទៅ និងតំណក់ទឹកពីរបីតំណក់ ដែលសល់នៅ តើណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ទឹកហូរមកប្រសព្វលាយចូលគ្នា ដែលអស់ទៅ រីងស្ងួតទៅ ច្រើនជាង តំណក់ទឹកពីរបីតំណក់ដែលសល់នៅ មានប្រមាណតិចណាស់ តំណក់ទឹកពីរបីតំណក់ដែលសល់នៅ យកទៅប្រៀបធៀបនឹងទឹក ដែលហូរមកប្រសព្វលាយចូលគ្នា ដែលអស់ទៅ រីងស្ងួតទៅ មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

(៣១៨) ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូច្នេះ ។ បេ ។ ការបានធម្មចក្ខុ មានប្រយោជន៍ច្រើន យ៉ាងនេះ ។ ចប់សូត្រ ទី ៤ ។

[៣១៩] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា ... សេយ្យថាបិ ភិក្ខវេ បុរិសោ មហាបថវិយា សត្ត កោលដ្ឋិមត្តិយោ គុឡិកា ឧបនិក្ខិបេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យា វា សត្ត កោលដ្ឋិមត្តិយោ គុឡិកា ឧបនិក្ខិត្តា យា វា មហាបថវីតិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ មហាបថវី អប្បមត្តិកា សត្ត កោលដ្ឋិមត្តិយោ គុឡិកា ឧបនិក្ខិត្តា នេវ សតិមំ កលំ ឧបេន្តិ ន សហស្សិមំ កលំ ឧបេន្តិ ន សតសហស្សិមំ កលំ ឧបេន្តិ មហាបថវឹ ឧបនិធាយ សត្ត កោលដ្ឋិមត្តិយោ គុឡិកា ឧបនិក្ខិត្តាតិ ។

[៣២០] ឯវមេវ ខោ ភិក្ខវេ ។ បេ ។ ឯវំ មហត្ថិយោ ធម្មចក្ខុប្បដិលាភោតិ ។ បញ្ចមំ ។

[ ៣១៩ ] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចបុរសលើកយកដុំដី ៧ ដុំ ប៉ុនផ្លែពុទ្រា អំពីមហាប្រឹថពី ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយសំគាល់ហេតុនោះដូចម្តេច ដុំដី ៧ ដុំ ប៉ុនផ្លែពុទ្រា ដែលគេលើកយកមក និងមហាប្រឹថពី តើណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន មហាប្រឹថពី ច្រើនជាង ឯដុំដី ៧ ដុំ ប៉ុនផ្លែពុទ្រាដែលគេលើកយកមកនោះ មានប្រមាណតិចណាស់ ដុំដី ៧ ដុំ ប៉ុនផ្លែពុទ្រា ដែលគេចាប់លើកឡើង យកមកប្រៀបធៀបនឹងមហាប្រឹថពី មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

[ ៣២០ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូច ។ បេ ។ ការបាននូវធម្មចក្ខុ មានប្រយោជន៍ច្រើនយ៉ាងនេះ ។ ចប់ សូត្រ ទី ៥ ។

(៣៦១) សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា ... សេយ្យថាបិ ភិក្ខវេ មហាបថវី បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ឋបេត្វា សត្ត កោលដ្ឋិមត្តិយោ គុឡិកា ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា មហាបថវិយា បរិក្ខីណំ បរិយាទិន្នំ យា វា សត្ត កោលដ្ឋិមត្តិយោ គុឡិកា អវសិដ្ឋាតិ ។ ឯតទេវ ភន្តេ ពហុតរំ មហាបថវិយា យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តិកា សត្ត កោលដ្ឋិមត្តិយោ គុឡិកា អវសិដ្ឋា នេវ សតិមំ កលំ ឧបេន្តិ ន សហស្សិមំ កលំ ឧបេន្តិ ន សតសហស្សិមំ កលំ ឧបេន្តិ មហាបថវិយា បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ សត្ត កោលដ្ឋិមត្តិយោ គុឡិកា អវសិដ្ឋាតិ ។

(៣៦២) ឯវមេវ ខោ ភិក្ខវេ ។ បេ ។ ឯវំ មហត្ថិយោ ធម្មចក្ខុប្បដិលាភោតិ ។ ឆដ្ឋំ ។

[៣៦១] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចមហាប្រឹថពី គប្បីអស់ទៅ វិនាសទៅ វៀរលែងតែដុំដី ៧ ដុំ ប៉ុនផ្លែពុទ្រា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះដូចម្ដេច មហាប្រឹថពី ដែលអស់ទៅ វិនាសទៅ និងដុំដី ៧ ដុំ ប៉ុនផ្លែពុទ្រា ដែលសល់នៅ តើណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន មហាប្រឹថពីដែលអស់ទៅ វិនាសទៅ ច្រើនជាង ឯដុំដី ៧ ដុំ ប៉ុនផ្លែពុទ្រា ដែលសល់នៅ មានប្រមាណតិចណាស់ ដុំដី ៧ ដុំ ប៉ុនផ្លែពុទ្រា ដែលសល់នៅ យកទៅប្រៀបធៀបនឹងមហាប្រឹថពី ដែលអស់ទៅ វិនាសទៅ មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

[៣៦២] ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះ មានឧបមេយ្យដូច ។បេ។ ការបានធម្មចក្ខុ មានប្រយោជន៍ច្រើនយ៉ាងនេះ ។ ចប់ សូត្រ ទី ៦ ។

(៣២៣) សាវត្ថិយំ វិហរតិ .. តត្រ ខោ ភគវា ...
សេយ្យថាបិ ភិក្ខវេ បុរិសោ មហាសមុទ្ទា(១) ទ្វេ វា
តីណិ វា ឧទកផុសិតានិ ឧទ្ធរេយ្យ ។ តំ កឹ មញ្ញថ
ភិក្ខវេ កតមំ នុ ខោ ពហុតរំ យានិ វា ទ្វេ វា
តីណិ វា ឧទកផុសិតានិ ឧព្ភតានិ យំ វា មហាស-
មុទ្ទេ ឧទកន្តិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ
មហាសមុទ្ទេ ឧទកំ អប្បមត្តកានិ ទ្វេ វា តីណិ វា
ឧទកផុសិតានិ ឧព្ភតានិ នេវ សតិមំ កលំ ឧ-
បេន្តិ ន សហស្សិមំ កលំ ឧបេន្តិ ន សតសហស្សិមំ
កលំ ឧបេន្តិ មហាសមុទ្ទេ ឧទកំ ឧបនិធាយ ទ្វេ វា
តីណិ វា ឧទកផុសិតានិ ឧព្ភតានីតិ ។

(៣២៤) ឯវមេវ ខោ ភិក្ខវេ ។ បេ ។ ឯវំ
មហត្ថិយោ ធម្មចក្ខុបដិលាភោតិ ។ សត្តមំ ។

---

១ ម មហាសមុទ្ទេ ។

[៣២៣] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... គង់នៅទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចបុរសដួសយកតំណក់ទឹក ពីរបីតំណក់ពីមហាសមុទ្រ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះថាដូចម្តេច តំណក់ទឹកពីរបីតំណក់ ដែលបុរសដួសឡើង និងទឹកក្នុងមហាសមុទ្រ តើណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន ទឹកក្នុងមហាសមុទ្រ ច្រើនជាង ឯតំណក់ទឹកពីរបីតំណក់ ដែលបុរសដួសឡើង មានប្រមាណតិចណាស់ តំណក់ទឹកពីរបីតំណក់ ដែលបុរសដួសឡើង យកទៅប្រៀបធៀបនឹងទឹកក្នុងមហាសមុទ្រ មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

[៣២៤] ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូច ។ បេ ។ ការបានធម្មចក្ខុ មានប្រយោជន៍ច្រើន យ៉ាងនេះ ។ ចប់ សូត្រ ទី៧ ។

(៣២៨) សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ឋបេត្វា ទ្វេ វា តីណិ វា ឧទកផុសិតានិ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា មហាសមុទ្ទា ឧទកំ បរិក្ខីណំ បរិយាទិន្នំ យានិ វា ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានីតិ ។ ឯតទេវ ភន្តេ ពហុតរំ មហាសមុទ្ទេ ឧទកំ យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តកានិ ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានិ នេវ សតិមំ កលំ ឧបេន្តិ ន សហស្សិមំ កលំ ឧបេន្តិ ន សតសហស្សិមំ កលំ ឧបេន្តិ មហាសមុទ្ទេ ឧទកំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានីតិ ។

(៣២៩) ឯវមេវ ខោ ភិក្ខវេ ។ បេ ។ ឯវំ មហត្ថិយោ ធម្មចក្ខុប្បដិលាភោតិ ។ អដ្ឋមំ ។

[ ៣២៥ ] ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចមហាសមុទ្រ គប្បីអស់ទៅ រីងស្ងួតទៅ លើកលែងតែតំណក់ទឹកពីរបីតំណក់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះថាដូចម្តេច ទឹកដែលអស់ទៅ រីងស្ងួតទៅអំពីមហាសមុទ្រ និងតំណក់ទឹកពីរបីតំណក់ដែលសល់នៅ តើណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ទឹកក្នុងមហាសមុទ្រដែលអស់ទៅ រីងស្ងួតទៅ ច្រើនជាង ឯតំណក់ទឹកពីរបីតំណក់ដែលសល់នៅ មានប្រមាណតិចណាស់ តំណក់ទឹកពីរបីតំណក់ដែលសល់នៅ យកទៅប្រៀបធៀបនឹងទឹកក្នុងមហាសមុទ្រ ដែលអស់ទៅ រីងស្ងួតទៅ មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

[ ៣២៦ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូច ។ បេ ។ ការបាននូវធម្មចក្ខុ មានប្រយោជន៍ច្រើន យ៉ាងនេះ ។ ចប់សូត្រ ទី ៨ ។

(៣២៧) សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា ... សេយ្យថាបិ ភិក្ខវេ បុរិសោ ហិមវតោ បព្វតរាជស្ស សត្ត សាសបមត្តិយោ បាសាណសក្ខរា ឧបនិក្ខិបេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យា វា សត្ត សាសបមត្តិយា បាសាណសក្ខរា ឧបនិក្ខិត្តា យោ វា ហិមវា បព្វតរាជាតិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ ហិមវា បព្វតរាជា អប្បមត្តិកា សត្ត សាសបមត្តិយោ បាសាណសក្ខរា ឧបនិក្ខិត្តា នេវ សតិមំ កលំ ឧបេន្តិ ន សហស្សិមំ កលំ ឧបេន្តិ ន សតសហស្សិមំ កលំ ឧបេន្តិ ហិមវន្តំ បព្វតរាជានំ ឧបនិធាយ សត្ត សាសបមត្តិយោ បាសាណសក្ខរា ឧបនិក្ខិត្តាតិ ។

(៣២៨) ឯវមេវ ខោ ភិក្ខវេ ។បេ។ ឯវំ មហត្ថិយោ ធម្មចក្ខុប្បដិលាភោតិ ។ ឆដ្ឋំ ។

( ៣២៧ ) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចបុរសរើសយកថ្មនិងក្រួស ៧ ដុំ ប៉ុនគ្រាប់ស្ពៃ អំពីស្តេចភ្នំហិមពាន្ត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះថាដូចម្តេច ថ្មនិងក្រួស ៧ ដុំ ប៉ុនគ្រាប់ស្ពៃ ដែលបុរសរើសយកមក និងស្តេចភ្នំហិមពាន្ត តើណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ស្តេចភ្នំហិមពាន្តច្រើនជាង ឯថ្មនិងក្រួស ៧ ដុំ ប៉ុនគ្រាប់ស្ពៃ ដែលបុរសរើសយកមក មានប្រមាណតិចណាស់ ថ្មនិងក្រួស ៧ ដុំ ប៉ុនគ្រាប់ស្ពៃ ដែលបុរសរើសយកមក ទៅប្រៀបធៀបនឹងស្តេចភ្នំហិមពាន្ត មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

( ៣២៨ ) ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូច ។បេ។ ការបានធម្មចក្ខុ មានប្រយោជន៍ច្រើន យ៉ាងនេះ ។ ចប់ សូត្រ ទី ៩ ។

[៣៤៩] សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... សេយ្យថាបិ ភិក្ខវេ ហិមវា បព្វតរាជា បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ឋបេត្វា សត្ត សាសបមត្តិយោ បាសាណសក្ខរា ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា ហិមវតោ បព្វតរាជស្ស បរិក្ខីណំ បរិយាទិន្នំ យា វា សត្ត សាសបមត្តិយោ បាសាណសក្ខរា អវសិដ្ឋាតិ ។ ឯតទេវ ភន្តេ ពហុតរំ ហិមវតោ បព្វតរាជស្ស យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តិកា សត្ត សាសបមត្តិយោ បាសាណសក្ខរា អវសិដ្ឋា នេវ សតិមំ កលំ ឧបេន្តិ ន សហស្សិមំ កលំ ន ឧបេន្តិ ន សតសហស្សិមំ កលំ ឧបេន្តិ ហិមវតោ បព្វតរាជស្ស បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ សត្ត សាសបមត្តិយោ បាសាណសក្ខរា អវសិដ្ឋាតិ ។

( ៣៦៩ ) ច្រើនគង់នៅទៀបក្រុងសាវត្ថី ... កុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចស្ដេចកំហិមពាន្ត ដល់នូវការអស់ទៅ វិនាសទៅ លើកលែងតែថ្មបូក្រុស ៧ ដុំ ប៉ុនគ្រាប់ស្ពៃ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះ ថាដូចម្ដេច ស្ដេចកំហិមពាន្ត ដែលអស់ទៅ វិនាសទៅ និងថ្មបូក្រុស ៧ ដុំ ប៉ុនគ្រាប់ស្ពៃដែលសល់នៅ តើណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ស្ដេចកំហិមពាន្ត ដែលអស់ទៅ វិនាសទៅ ច្រើនជាង ឯថ្មបូក្រុស ៧ ដុំ ប៉ុនគ្រាប់ស្ពៃដែលសល់នៅ មានប្រមាណតិចណាស់ ថ្មបូក្រុស ៧ ដុំ ប៉ុនគ្រាប់ស្ពៃដែលសល់នៅ យកទៅប្រៀបធៀបនឹងស្ដេចកំហិមពាន្ត ដែលអស់ទៅ វិនាសទៅ មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

(៣៣០) ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស អភិសមេតាវិនោ ឯតទេវ ពហុតរំ ទុក្ខំ យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តកំ អវសិដ្ឋំ នេវ សតិមំ កលំ ឧបេតិ ន សហស្សិមំ កលំ ឧបេតិ ន សតសហស្សិមំ កលំ ឧបេតិ បុរិមំ ទុក្ខក្ខន្ធំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ យ-ទិទំ សត្តក្ខត្តុបរមតា ។ ឯវំ មហត្ថិយោ ខោ ភិក្ខវេ ធម្មាភិសមយោ ឯវំ មហត្ថិយោ ធម្មចក្ខុប្បដិលា-ភោតិ ។ ទសមំ ។

(៣៣១) សាវត្ថិយំ វិហរតិ ... តត្រ ខោ ភគវា ... សេយ្យថាបិ ភិក្ខវេ បុរិសោ សិនេរុស្ស បព្វតរាជស្ស សត្ត មុគ្គមត្តិយោ បាសាណសក្ខរា ឧបនិក្ខិបេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យា វា សត្ត មុគ្គមត្តិយោ បាសាណសក្ខរា ឧបនិក្ខិត្តា យោ វា សិនេរុ បព្វតរាជាតិ ។ ឯត-ទេវ ភន្តេ ពហុតរំ យទិទំ សិនេរុ បព្វតរាជា

(៣៣០) ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះ មានឧបមេយ្យដូចបុគ្គលជាអរិយសាវ័ក ជាអ្នកបរិបូណ៌ដោយទិដ្ឋិ ត្រាស់ដឹងនូវអរិយសច្ច រមែងមានទុក្ខ ដែលអស់ទៅ រីងស្ងួតទៅច្រើនជាង ឯទុក្ខដែលសល់នៅ សំដៅយកត្រឹម ៧ អត្តភាព មានប្រមាណតិចណាស់ មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការត្រាស់ដឹងធម៌ មានប្រយោជន៍ច្រើន យ៉ាងនេះ ការបានធម្មចក្ខុ មានប្រយោជន៍ច្រើន យ៉ាងនេះ ។ ចប់សូត្រ ទី ១០ ។

(៣៣១) ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ ... ម្នាលភិក្ខុទាំងឡាយ ដូចបុរសរើសយកថ្មឬក្រួស ៧ ដុំ ប៉ុនគ្រាប់សណ្ដែកបាយ អំពីស្ដេចភ្នំសិនេរុ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះថាដូចម្ដេច ថ្មឬក្រួសប៉ុនគ្រាប់សណ្ដែកបាយ ដែលបុរសរើសមក និងស្ដេចភ្នំសិនេរុ តើណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ស្ដេចភ្នំសិនេរុច្រើនជាង ឯថ្ម

អប្បមត្តិកា សត្ត មុគ្គមត្តិយោ បាសាណសក្ខរា ឧបនិក្ខិត្តា នេវ សតិមំ កលំ ឧបេតិ ន សហស្សិមំ កលំ ឧបេតិ ន សតសហស្សិមំ កលំ ឧបេតិ សិនេរុំ បព្វតរាជានំ ឧបនិធាយ សត្ត មុគ្គមត្តិយោ បាសាណសក្ខរា ឧបនិក្ខិត្តាតិ ។

(៣៣៤) ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស អធិគមំ ឧបនិធាយ អញ្ញតិត្ថិយសមណព្រាហ្មណបរិព្វាជកានំ អធិគមោ នេវ សតិមំ កលំ ឧបេតិ ន សហស្សិមំ កលំ ឧបេតិ ន សតសហស្សិមំ កលំ ឧបេតិ ។ ឯវំ មហាធិគមោ ខោ ភិក្ខវេ ទិដ្ឋិសម្បន្នោ បុគ្គលោ ឯវំ មហាភិញ្ញោតិ ។ ឯកាទសមំ ។

អភិសមយវគ្គោ ទសមោ ។

ឬក្រួស ៧ ដុំ ប៉ុនគ្រាប់សណ្តែកបាយដែលបុរសលើកមក មានប្រមាណតិចណាស់ ថ្មក្រួស ៧ ដុំ ប៉ុនគ្រាប់សណ្តែកបាយ ដែលបុរសលើកមក យកទៅប្រៀបធៀបនឹងស្តេចភ្នំសិនេរុ មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។

(៣៣៦) ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូចការត្រាស់ដឹង របស់សមណព្រាហ្មណ៍បរិព្វាជក ជាអន្យតិរ្ថិយ ប្រៀបធៀបនឹងការត្រាស់ដឹង របស់បុគ្គលជាអរិយសាវ័ក ជាអ្នកបរិបូណ៌ដោយទិដ្ឋិ មិនដល់នូវចំណែកមួយ ក្នុងមួយរយចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយពាន់ចំណែក មិនដល់នូវចំណែកមួយ ក្នុងមួយសែនចំណែកឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មានការត្រាស់ដឹងច្រើន យ៉ាងនេះ មានអភិញ្ញាច្រើន យ៉ាងនេះ ។ ចប់សូត្រ ទី ១១ ។

ចប់ អភិសមយវគ្គ ទី ១០ ។

## តស្សុទ្ទានំ

នខសិខា បោក្ខរណី
សម្ភេជ្ជឧទកា (១) ទ្វេ
ទ្វេ បថវី ទ្វេ សមុទ្ទា
ឯសោ ច បព្វតូបមាតិ ។

អភិសមយសំយុត្តំ បឋមំ និដ្ឋិតំ ។

---

១ ឱ. ម. សម្ភេជ្ជឧទកេ ប ទ្វេ ។

អភិសមយសំយុត្ត អភិសមយវគ្គ ឧទ្ទាន

## បញ្ជីរឿងនៃអភិសមយវគ្គនោះគឺ

សំដែងអំពីការប្រៀបធៀបដូចលើកអាចម៍ដីឡើងដោយចុងក្រចក ដូចទឹកក្នុងស្រះបោក្ខរណី ដូចទឹកដែលហូរប្រសព្វរលាយចូលគ្នា ២ លើក ឧបមាដូចផែនដី ២ លើក ដូចសមុទ្រ ២ លើក ដូចភ្នំ ៣ លើក ។

ចប់ អភិសមយសំយុត្ត ទី ១ ។

---

# សុត្តន្តបិដកេ សំយុត្តនិកាយស្ស និទានវគ្គោ

## តតិយោ ភាគោ

---

## អភិសមយសំយុត្តំ

### ពុទ្ធវគ្គោ

មាតិកា អង្កេ


អភិសមយសំយុត្តស្ស ពុទ្ធវគ្គេ បដិច្ចសមុប្បាទោ . . . . . . . ៣

ជាតិ . . . . . . . . . . . ៥

វិញ្ញាណំ . . . . . . . . . . ៧

សម្មាបដិបទា . . . . . . . . ៩

ទុក្ខក្ខន្ធសមុទយោ . . . . . . . ១១

ទុក្ខក្ខន្ធនិរោធោ . . . . . . . . ១៥


### អាហារវគ្គោ


អភិសមយសំយុត្តស្ស អាហារវគ្គេ ទុក្ខក្ខន្ធនិរោធោ . . . . . . ២៥

អាហារប្បញ្ហា . . . . . . . ២៧

ជកមរណាទុប្បជាននំ . . . . ៣១

# សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ

## តតិយភាគ

---

## អភិសមយសំយុត្ត

### ពុទ្ធវគ្គ

## មាតិកា

លេខទំព័រ


អភិសមយសំយុត្ត ពុទ្ធវគ្គ បដិច្ចសមុប្បាទ . . . . . . . ៣
ជាតិ . . . . . . . . ៥
វិញ្ញាណ . . . . . . . ៧
សម្មាបដិបទា . . . . . . ៩
ហេតុឲ្យកើតកងទុក្ខ . . . . . . . ១១
កិរិយារលត់កងទុក្ខ . . . . . . ១៥

*អាហារវគ្គ*

អភិសមយសំយុត្ត អាហារវគ្គ កិរិយារលត់កងទុក្ខ . . . . . ២៥
ការសាកសួររកអាហារ . . . . ២៧
កិរិយាមិនដឹងច្បាស់នូវជរានិងមរណៈជាដើម . ៣១

# មាតិកា

អង្ក

អភិសមយសំយុត្តស្ស អាហារវគ្គេ សម្មាទិដ្ឋិបញ្ហា . . . ៣៥
ធម្មកថិកបញ្ហា . . . ៣៧
ភគវន្តុបសង្កមនំ . . . ៣៩
ទុក្ខបញ្ហា . . . . ៤១
ទុក្ខព្យាករណំ . . . . ៤៣
ឧបសម្ពាលកនំ . . . ៤៥
ទុក្ខបញ្ហា . . . . . ៤៧
ទុក្ខព្យាករណំ . . . . ៤៩
ពាលបណ្ឌិតនានត្តំ . . . ៥១
បដិច្ចសមុប្បាទោ . . . ៥៣
សុទិដ្ឋការោ . . . . ៥៧

ទសពលវគ្គោ

អភិសមយសំយុត្តស្ស ទសពលវគ្គេ សុខទុក្ខការោ . . . . ៦១
វីរិយការោ . . . . . ៦៣
ខយេញាណំ . . . . ៦៥

# មាតិកា

លេខទំព័រ


អភិសមយសំយុត្ត អាហារវគ្គ ការសាកសួររកសម្មាទិដ្ឋិ . . . . . . ៣៥

ការសាកសួររកធម្មកថិក . . . . . . ៣៧

អចេលកស្សបចូលទៅរកព្រះមានព្រះភាគ . . ៣៩

ការសាកសួររកសេចក្តីទុក្ខ . . . . . ៤១

ការព្យាករណ៍នូវសេចក្តីទុក្ខ . . . . . ៤៣

ការបាននូវឧបសម្បទា . . . . . ៤៥

ការសាកសួររកសេចក្តីទុក្ខ . . . . . ៤៧

ការព្យាករណ៍នូវសេចក្តីទុក្ខ . . . . . ៤៩

សេចក្តីផ្សេងគ្នានៃពាលនិងបណ្ឌិត . . . . ៥១

បដិច្ចសមុប្បាទ . . . . . . . ៥៣

ភាពនៃធម៌ដែលព្រះអរិយៈបានឃើញច្បាស់ . . ៥៧


## ទសពលវគ្គ


អភិសមយសំយុត្ត ទសពលវគ្គ ភាពនៃសេចក្តីសុខនិងទុក្ខ . . . . . ៦១

ភាពនៃសេចក្តីព្យាយាម . . . . . ៦៣

ខយញ្ញាណ . . . . . . . ៦៥

# មាតិកា

អង្កេ

អភិសមយសំយុត្តស្ស ទសពលវគ្គ យថាទិន្នបវត្តទុក្ខូបមា . . . ៦៩
បរិញ្ញាផលវចនំ . . . . . . ៧១
ភគវន្តុបសង្កមនំ . . . . . ៧៣
ភគវតោ វចនំ . . . . . ៧៥
អានន្ទវចនំ . . . . . . . . ៧៩
បដិច្ចសមុប្បន្នភាសិតំ . . . ៨១
កាយវចីមនោភិសង្ខរណំ . . . ៨៧
ភគវន្តុបសង្កមនំ . . . . . ៨៩
បដិច្ចសមុប្បន្នភាសិតំ . . . ៩១
ជរាមរណាទិបជាននំ . . . ៩៣
ជរាមរណាទ្យាបរិជាននំ . . . ៩៧
ជរាមរណាទ្យាបជាននំ . . . ៩៩

## កឡារខត្តិយវគ្គោ

អភិសមយសំយុត្តស្ស កឡារខត្តិយវគ្គ សង្ខាតធម្មកថា . . . ១០៣
ភគវន្តុបសង្កមនំ . . . ១០៩

# មាតិកា

លេខទំព័រ

អភិសមយសំយុត្ត ទសពលវគ្គ ឧបមាដោយទឹកប្រព្រឹត្តទៅក្នុងទីទាប . . . ៦៩

ពាក្យនៃបរិញ្ញាជក . . . . . . . ៧១

ព្រះអានន្ទចូលទៅគាល់ព្រះមានព្រះភាគ . . ៧៣

ព្រះពុទ្ធដីកានៃព្រះមានព្រះភាគ . . . . ៧៥

ពាក្យនៃព្រះអានន្ទ . . . . . . ៧៩

ទ្រង់ពោលនូវបដិច្ចសមុប្បន្នធម៌ . . . ៨១

កិរិយាធ្វើនូវកាយ វចី មនោ សង្ខារ . . . ៨៧

ព្រះឧបវាណចូលទៅគាល់ព្រះមានព្រះភាគ . . ៨៩

ទ្រង់ពោលនូវបដិច្ចសមុប្បន្នធម៌ . . . . ៩១

កិរិយាដឹងច្បាស់នូវជរានិងមរណៈជាដើម . . ៩៣

កិរិយាមិនកំណត់ដឹងនូវជរានិងមរណៈជាដើម . . ៩៧

កិរិយាមិនដឹងច្បាស់នូវជរានិងមរណៈជាដើម . . ៩៩

## កឡារខត្តិយវគ្គ

អភិសមយសំយុត្ត កឡារខត្តិយវគ្គ ពោលអំពីបុគ្គលមានធម៌ពិចារណាហើយ . . ១០៣

កឡារខត្តិយភិក្ខុចូលទៅគាល់ព្រះមានព្រះភាគ . ១០៩

# មាតិកា

អង្ក

អភិសមយសំយុត្តស្ស ខន្ធវគ្គិយវគ្គេ សារីបុត្តប្បដិបុច្ឆា . . . ១១១
មុញ្ចទាននិទានាទិកថា . ១១៣
ផស្សនិទានាទិវេទនា . . ១១៥
សាធុការទានំ . . . . ១១៧
ភិក្ខាមន្តំ . . . . . ១១៩
ភគវន្តាភេបនំ . . . . ១២១
ញាណវត្ថុកថា . . . . . ១២៣
ជរាមរណកថា . . . . ១២៥
អរិយសាវកសាមញ្ញា . . ១២៧
អតីតាទិញាណំ . . . . ១២៩
ញាណវត្ថុកថា . . . . ១៣១
ជរាមរណបុច្ឆា . . . . ១៣៣
ភវាទិបុច្ឆា . . . . . . ១៣៥
សង្ខារបុច្ឆា . . . . . ១៣៩
អវិជ្ជាយ និរោធោ . . . ១៤១

# មាតិកា

លេខទំព័រ


អភិសមយសំយុត្ត កឡារខត្តិយវគ្គ ទ្រង់សួរបញ្ជាក់ព្រះសារីបុត្ត . . . ១១១

ភពមានឧបាទានជាហេតុជាដើម . . ១១៣

វេទនាមានផស្សៈជាហេតុជាដើម . . ១១៥

ទ្រង់ប្រទានសាធុការៈ . . . . ១១៧

ព្រះសារីបុត្តហៅភិក្ខុទាំងឡាយ . . ១១៩

កឡារខត្តិយភិក្ខុក្រាបទូលព្រះមានព្រះភាគ . ១២១

ពោលអំពីញាណវត្ថុ . . . . ១២៣

ពោលអំពីជរានិងមរណៈ . . . ១២៥

ឈ្មោះអរិយសាវ័ក . . . . ១២៧

សេចក្ដីដឹងក្នុងអតីតកាលជាដើម . . ១២៩

ពោលអំពីញាណវត្ថុ . . . . ១៣១

ការសាកសួររកជរានិងមរណៈ . . . ១៣៣

ការសាកសួររកភពជាដើម . . . ១៣៥

ការសាកសួររកសង្ខារ . . . . ១៣៩

ការរលត់នៃអវិជ្ជា . . . . ១៤១

# មាតិកា


អង្ក

អភិសមយសំយុត្តស្ស កឡារខត្តិយវគ្គេ ទុក្ខក្ខន្ធសមុទយោ . . ១៤៣

ទុញ្ញានំ . . . . . ១៤៩

គហបតិវគ្គោ

អភិសមយសំយុត្តស្ស គហបតិវគ្គេ បញ្ចភយានិ . . . . ១៥១

សោតាបត្តិយង្គានិ . . . ១៥៣

អត្តញ្ញាករណំ . . . . ១៥៥

ទុក្ខត្ថង្គមោ . . . . ១៥៩

លោកសមុទយោ . . . ១៦១

ទុក្ខក្ខន្ធសមុទយោ . . . ១៦៣

អាទិព្រហ្មចរិយកោ . . . ១៦៥

ភគវន្តុបសង្កមនំ . . . . ១៦៧

ទុក្ខក្ខន្ធសមុទយោ . . . ១៦៩

លោកសមុទយោ . . . ១៧១

ទិដ្ឋិសម្បន្នភាវោ . . . . ១៧៥

# មាតិកា

លេខទំព័រ

អភិសមយសំយុត្ត កឡាបវត្តិយវគ្គ ការកើតឡើងនៃកងទុក្ខ . . . . . ១៤៣
ឧទ្ទាន . . . . . . . ១៤៩

*គហបតិវគ្គ*

អភិសមយសំយុត្ត គហបតិវគ្គ ភ័យប្រាំប្រការ . . . . . . . ១៥១
អង្គនៃសោតាបត្តិ . . . . . . ១៥៣
ការព្យាករណ៍ខ្លួន . . . . . . ១៥៥
ការរលត់ទៅនៃទុក្ខ . . . . . . ១៥៩
ហេតុនាំឱ្យកើតសង្ខារលោក . . . . ១៦១
ហេតុនាំឱ្យកើតកងទុក្ខ . . . . . ១៦៣
ធម្មបរិយាយជាខាងដើមនៃព្រហ្មចរិយៈ . . ១៦៥
ជាណុស្សោណិព្រាហ្មណ៍ចូលទៅគាល់ព្រះ
មានព្រះភាគ . . . . . . . ១៦៧
ហេតុនាំឱ្យកើតកងទុក្ខ . . . . . ១៦៩
ហេតុនាំឱ្យកើតសង្ខារលោក . . . . . ១៧១
ភាពនៃព្រះអរិយសាវ័កបរិបូណ៌ដោយទិដ្ឋិ . . ១៧៥

## ទុក្ខវគ្គោ

# មាតិកា

| | | |
|---|---|---|
| អភិសមយសំយុត្តស្ស ទុក្ខវគ្គេ | ទុក្ខក្ខយបរិវីមំសនា . . . | ១៧៩ |
| | អវិជ្ជាបហានំ . . . . . | ១៨១ |
| | បុញ្ញាភិសង្ខារាទិអភិសង្ខរណបុច្ឆា | ១៨៣ |
| | ទុក្ខក្ខន្ធសមុទយោ . . . | ១៨៥ |
| | អគ្គិក្ខន្ធូបមា . . . . . | ១៨៧ |
| | ទុក្ខក្ខន្ធនិរោធោ . . . . | ១៨៩ |
| | តេលប្បទីបូបមា . . . . | ១៩១ |
| | មហារុក្ខូបមា . . . . | ១៩៣ |
| | តរុណរុក្ខូបមា . . . . | ១៩៧ |
| | ទុក្ខក្ខន្ធសមុទយោ . . . | ១៩៩ |
| | បដិច្ចសមុប្បាទគម្ភីរោ . . | ២០១ |
| | មហារុក្ខូបមា . . . . | ២០៣ |
| | ឧទ្ទានំ . . . . . . | ២០៥ |

អង្កេ

# មាតិកា

លេខទំព័រ

អភិសមយសំយុត្ត ទុក្ខវគ្គ ការពិចារណារកកិរិយាអស់ទៅនៃសេចក្ដីទុក្ខ . . . ១៧៩

ការលះបង់អវិជ្ជា . . . . . . . ១៨១

ទ្រង់សាកសួររកការតាក់តែងបុញ្ញាភិសង្ខារជាដើម . ១៨៣

ការកើតឡើងនៃកងទុក្ខ . . . . . . ១៨៥

ឧបមាដោយគំនរភ្លើង . . . . . . ១៨៧

ការរលត់ទៅនៃកងទុក្ខ . . . . . . ១៨៩

ឧបមាដោយប្រទីបប្រេង . . . . . . ១៩១

ឧបមាដោយឈើធំ . . . . . . . ១៩៣

ឧបមាដោយឈើខ្ចី . . . . . . . ១៩៧

ហេតុនាំឲ្យកើតកងទុក្ខ . . . . . . ១៩៩

ដំម្រារបស់បដិច្ចសមុប្បាទ . . . . . ២០១

ឧបមាដោយឈើធំ . . . . . . . ២០៣

ឧទ្ទាន . . . . . . . . . . ២០៥

## មហាវគ្គ

# មាតិកា

អង្គ

អភិសមយសំយុត្តស្ស មហាវគ្គ ចាតុម្មហាភូតិកកាយោ . . . . ២០៧
កាយនិព្វិទា . . . . . . ២០៩
បដិច្ចសមុប្បាទមនសិការកថា . ២១១
សុខវេទនាទិទុប្បដ្ឋនំ . . . ២១៣
កវឡីការាហារកថា . . . . ២១៥
ផស្សាហារកថា . . . . . ២១៧
វិញ្ញាណាហារកថា . . . . ២១៩
បត្តារោ អាហារ . . . . ២២១
រជកចិត្តការកូបមា . . . . ២២៣
កវឡីការាហារោ . . . . ២២៥
កូដាគារសាលូបមា . . . . ២២៧
ភគវន្តបរិវិតក្កំ . . . . . ២២៩
ទុក្ខក្ខន្ធនិរោធោ . . . . ២៣១
បុណ្ណញ្ញសូបមា . . . . ២៣៣
អន្តរសម្មសកថា . . . . ២៣៥

## មហាវគ្គ

# មាតិកា

លេខទំព័រ


អភិសមយសំយុត្ត មហាវគ្គ ភាពនៃមហាភូតទាំងបួន . . . . . ២០៧

សេចក្ដីនឿយណាយក្នុងកាយ . . . . ២០៩

ពោលអំពីការកំណត់ទុកក្នុងចិត្តនូវបដិច្ចសមុប្បាទធម៌ ២១១

ការកើតឡើងនៃសុខវេទនាជាដើម . . . ២១៣

ពោលអំពីកវឡីការាហារ . . . . . ២១៥

ពោលអំពីផស្សាហារ . . . . . . ២១៧

ពោលអំពីវិញ្ញាណាហារ . . . . . . ២១៩

អាហារបួនយ៉ាង . . . . . . . ២២១

ឧបមាដោយផាងត្រឡាក់ឬផាងគំនូរ . . . . ២២៣

កវឡីការាហារ . . . . . . . ២២៥

ឧបមាដោយផ្ទះមានកំពូលឬសាលា . . . . ២២៧

សេចក្ដីត្រិះរិះរបស់ព្រះមានព្រះភាគ . . . . ២២៩

ការរលត់នៃកងទុក្ខ . . . . . . . ២៣១

ឧបមាដោយផ្លូវផ្លាចាស់ . . . . . . ២៣៣

និយាយអំពីការពិចារណាបច្ច័យខាងក្នុង . . . ២៣៥

# មាតិកា

អង្កេ

អភិសមយសំយុត្តស្ស មហាវគ្គេ តណ្ហាទិវឌ្ឍនំ . . . . . ២៤១

អាបានីយកំសូបមា . . . . ២៤៣

តណ្ហាទិបជហនំ . . . . ២៤៥

អាបានីយកំសូបមា . . . ២៤៧

សារីបុត្តុបសង្កមនំ . . . ២៤៩

ជាតាទិបុច្ឆា . . . . . ២៥១

នឡកលាបូបមា . . . . ២៥៣

មុសិលាទិត្ថេរេ . . . . ២៥៥

ជរាមរណាទិបុច្ឆា. . . . ២៥៧

ជាតាទិបុច្ឆា . . . . . ២៦១

ឃម្មាភិតត្តូបមា . . . . ២៦៣

មហាសមុទ្ទោបមា . . . . ២៦៥

អានន្ទុបសង្កមនំ . . . . ២៦៧

សុសិមបុច្ឆា . . . . . ២៦៩

# មាតិកា

លេខទំព័រ

អភិសមយសំយុត្ត មហាវគ្គ ការញុំាងតណ្ហាជាដើមឲ្យចម្រើន . . . . ២៤១
ឧបមាដោយថ្លុលពេញដោយស្រា . . . . ២៤៣
ការលះតណ្ហាជាដើម . . . . . . ២៤៥
ឧបមាដោយថ្លុលពេញដោយស្រា . . . . ២៤៧
ព្រះមហាកោដ្ឋិតៈទូលទៅរកព្រះសារីបុត្ត . . . ២៤៩
ការសួររកជាតិជាដើម . . . . . . ២៥០
ឧបមាដោយបាច់បបុះ . . . . . . ២៥៣
ព្រះមុសិលត្ថេរជាដើម . . . . . . . ២៥៥
ការសួររកជរានិងមរណៈជាដើម . . . . . ២៥៧
ការសួររកជាតិជាដើម . . . . . . ២៦០
ឧបមាដោយបុរសដែលក្តៅក្រហាយ . . . . ២៦៣
ឧបមាដោយមហាសមុទ្រ . . . . . . ២៦៥
សុសិមបរិព្វាជកចូលទៅរកព្រះអានន្ទ . . . . ២៦៧
ពាក្យសួររបស់សុសិមភិក្ខុ . . . . . . ២៦៩

# មាតិកា


អង្ក

អភិសមយសំយុត្តស្ស មហាវគ្គេ ចេតោបរិយញ្ញាណបញ្ហា . . ២៧១

ទិព្វចក្ខុញ្ញាណបញ្ហា . . . . . ២៧៣

ភគវន្តូបសង្កមនំ . . . . . . ២៧៥

វុប្បាទិច្ឆាទិបញ្ហា . . . . . ២៧៧

វុប្បាទិនិព្វុនំ . . . . . ២៧៩

ឥទ្ធិវិធបញ្ហា . . . . . . . ២៨១

ទិព្វចក្ខុបញ្ហា . . . . . . ២៨៣

បោក្ខរណូបមា . . . . . ២៨៥

ទុក្ខំ . . . . . . . . ២៨៧

សមណព្រាហ្មណវគ្គោ

អភិសមយសំយុត្តស្ស សមណព្រាហ្មណវគ្គេ ជរាមរណាទិអជាននំ ២៨៩

អន្តរបេយ្យាលោ

អភិសមយសំយុត្តស្ស អន្តរបេយ្យាលេ សិក្ខាទិករណីយតា . . ២៩៣

# មាតិកា

លេខទំព័រ

អភិសមយសំយុត្ត មហាវគ្គ ការសួររកចេតោបរិយញ្ញាណ . . . ២៧១

ការសួររកទិព្វចក្ខុញ្ញាណ . . . . ២៧៣

សុសិមភិក្ខុចូលទៅគាល់ព្រះមានព្រះភាគ . . ២៧៥

ការសួររករូបមិនទៀងជាដើម . . . . ២៧៧

ការនឿយណាយក្នុងរូបជាដើម . . . ២៧៩

ការសួររកឥទ្ធិវិធី . . . . . . ២៨១

ការសួររកទិព្វចក្ខុ . . . . . . ២៨៣

សេចក្ដីឧបមាដោយការចាប់ចោរ . . . ២៨៥

ឧទ្ទាន . . . . . . . ២៨៧

## សមណព្រាហ្មណវគ្គ

អភិសមយសំយុត្ត សមណព្រាហ្មណវគ្គ សេចក្ដីមិនដឹងនូវជរានិងមរណៈជាដើម ២៨៩

## អន្តរបេយ្យាលៈ

អភិសមយសំយុត្ត អន្តរបេយ្យាលៈ កិរិយាធ្វើនូវការសិក្សាជាដើម . . . ២៩៣

# អភិសមយវគ្គោ

## មាតិកា

អង្ក

អភិសមយសំយុត្តស្ស អភិសមយវគ្គ បោក្ខរណូបមា . . . ២៩៧

មហានទូបមា . . . ២៩៩

មហត្តិកកាទេ . . . ៣០១

សិនេរុបព្វតកដូបមា . . ៣០៧

ឧទ្ទានំ . . . . . . ៣០៩

អភិសមយវគ្គ

## មាតិកា

លេខទំព័រ


អភិសមយសំយុត្ត អភិសមយវគ្គ ឧបមាដោយស្រះបោក្ខរណី . . . ២៩៧

ឧបមាដោយស្ទឹងធំ . . . . ២៩៩

ភាពនៃការបានធម្មចក្ខុមានប្រយោជន៍ច្រើន . ៣០១

ឧបមាដោយស្តេចភ្នំសិនេរុ . . . ៣០៧

ឧទ្ទាន . . . . . . ៣០៩

# វិរុទ្ធាវិរុទ្ធបត្តិ

| វិរុទ្ធបាឋ | អវិរុទ្ធបាឋ | អង្ក | វគ្គលេខាយំ |
|---|---|---|---|
| អបលោ | អបេលោ | ៤៤ | ២ |
| គតវំបដិសរណា | គតវំបដិស្សរណា | ៥១ | ១០ |
| ផស្សម្បច្ចយា | ផស្សប្បច្ចយា | ៧៨ | ៣ |
| គន្ធំ | គន្ធិ | ៨៧ | ១៧ |
| ទិស្ស | ទិស្សតិ | ,, | ១៨ |
| អកាលគេន | អកាលិគេន | ១២៩ | ៦ |
| គព្ទុបព្វា | គព្ទិបព្វា | ១៣៥ | ១ |
| បរិមេសនា | បរិមេសនា | ១៧៩ | ,, |
| អាហារ | អាហារេ | ២១៨ | ១៤ |
| គវេទិកោធា | គវេទិកោធោ | ២៥៨ | ៦ |
| គីសម៉ិ | គីសម្បិ | ២៧២ | ១២ |
| ជាតស្សិយោ | ជាតិយោ | ,, | ,, |
| បជកេ | បិជកេ | ២៨២ | ១ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ព្រះពុទ្ធ | ព្រះពុទ្ធ- | ៤ | ៥ |
| នរណាហ្ន៊ | នរណាហ្ន៊ | ២៨ | ១៧ |
| ទីលេក | ទីលេក់ | ៣៣ | ១០ |
| ដូចជាកំណាត់សំពត់ | ដូចជាបុរសគ្មាន | ៦១ | ,, |
| ដែលគេកាត់ហើយ | កំណាត់សំពត់បិទបាំងកាយ | ,, | ១១ |
| ដូចជាកំណាត់សំពត់ | ដូចជាបុរសគ្មាន | | |
| ដែលគេកាត់ហើយ | កំណាត់សំពត់បិទបាំងកាយ | ,, | ១៣ |
| គប្ប | គប្បី | ៦៥ | ៤ |
| ពលរិប- | ពលវិប- | ,, | ៧ |
| ០៤៩ | ១៤៩ | លេខទំព័រ | |
| លូតលាស់ | មិនលូតលាស់ | ១៤៩ | ២ |
| ក៏រលត់តទៅ | ក៏រលត់ទៅ | ,, | ៦ |
| ប្រហារនោះ | ប្រហារនោះដែរឬ | ២២០ | ១០ |
| ផ្តល | ផ្តិល | ២៤៧ | ១ |
| ពាកពាស- | ពាកពោស: | ២៧១ | ៨ |
| ...ការរលត់នៃតណ្ហា... | ...ការរលត់នៃតណ្ហា ព្រោះ | ២៨១ | ៦ |
| មួយសែន | សែន | ២៩៦ | ៨ |

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE